CIMB BANK

របាយការណ៍ប្រចាំឆ្នាំ ២០២៤

# រីកចម្រើន ទៅមុខ ជាមួយអ្នក

**ពង្រឹងភាពខ្លាំង ផ្នែកបច្ចេកវិទ្យា**

ដាក់ឱ្យប្រើប្រាស់ នូវកម្មវិធីធនាគារចល័ត
ជំនាន់ទី២ ដើម្បីទាក់ទាញអតិថិជនបន្ថែមទៀត
និងកែលម្អបទពិសោធន៍សេវាកម្មអតិថិជន
**ទំព័រទី១០**

**លើកកម្ពស់ហិរញ្ញប្បទាន ប្រកបដោយចីរភាព**

នាំយកផលិតផលឥណទានរថយន្តអគ្គិសនី
និងឥណទានដំបូលសូឡា សម្រាប់
អតិថិជនឥណទានគេហដ្ឋាន
**ទំព័រទី១៣**

**ជួយត្រឡប់ ដល់សហគមន៍**

រៀបចំគម្រោងទំនួលខុសត្រូវសង្គមជាច្រើន
លើវិស័យអប់រំ សុខាភិបាល បរិស្ថាន
និងសង្គមកិច្ចជាដើម
**ទំព័រទី៦០**

អតិថិជន ជាបុគ្គល និងក្រុមហ៊ុនរបស់យើងខ្ញុំ៖

ជាង
**២៨លាន**

ទីតាំងម៉ាស៊ីនស្វ័យប្រវត្តិរបស់យើងខ្ញុំ៖

**៦.១៤៨**
**កន្លែង**



**ប្រទេសថៃ**

សាខា៖ **៥១កន្លែង**
បើកដំណើរការ៖ **ឆ្នាំ២០០៩**

**ប្រទេសកម្ពុជា**

សាខា៖ **១៤កន្លែង**
បើកដំណើរការ៖ **ឆ្នាំ២០១០**

**ប្រទេសម៉ាឡេស៊ី**

សាខា៖ **២១៧កន្លែង**
បើកដំណើរការ៖ **ឆ្នាំ២០០៦** (**ស៊ីអាយអិមប៊ី គ្រុប**)

**ប្រទេសសិង្ហបុរី**

សាខា៖ **១កន្លែង**
បើកដំណើរការ៖ **ឆ្នាំ២០០៩**

សាខារបស់យើងខ្ញុំ៖

**៥៩២**
**កន្លែង**

បុគ្គលិកបម្រើការរបស់យើងខ្ញុំ៖

ជាង
**៣៣.០០០នាក់**



### ប្រទេសវៀតណាម

សាខា៖ **២កន្លែង**
បើកដំណើរការ៖ **ឆ្នាំ២០១៦**

### ប្រទេសហ្វីលីពីន

ការិយាល័យ៖ **១កន្លែង**
បើកដំណើរការ៖ **ឆ្នាំ២០១៨**

### ប្រទេសឥណ្ឌូនេស៊ី

សាខា៖ **៣០៣កន្លែង**
មជ្ឈមណ្ឌលរក្សាប្រាក់ និងទូទាត់ប្រាក់
បន្ទប់សេវាកម្មឌីជីថល និងរថយន្តដឹកប្រាក់៖ **៩៤កន្លែង**
បើកដំណើរការ៖ **ឆ្នាំ១៩៥៥**

### ទីផ្សារផ្សេងទៀត

ទីក្រុងសៀងហៃ
សាខា៖ **១កន្លែង**

ទីក្រុងហុងកុង
សាខា៖ **១កន្លែង**

ចក្រភពអង់គ្លេស
សាខា៖ **១កន្លែង**

# ផ្នែកខាងក្នុង

## ០១

### ទិដ្ឋភាពទូទៅ


០៨ ..... សាវតារធនាគារ
០៩ ..... ការប្តេជ្ញាចិត្ត លើគុណភាពសេវាកម្ម និងឧត្តមភាព
០៩ ..... តម្លៃស្នូលរបស់ស្ថាប័ន
១០ ..... សារពីប្រធានក្រុមប្រឹក្សាភិបាល
១២ ..... សារពីប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ
១៤ ..... ការពិនិត្យមើលលទ្ធផលប្រតិបត្តិការរបស់ប្រធាននាយកប្រតិបត្តិ


## ០២

### ការពិនិត្យមើលធុរកិច្ច


១៨ ..... សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
១៩ ..... សេវាកម្មហិរញ្ញវត្ថុបុគ្គល
២០ ..... សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ
២១ ..... រតនាគិបាល និងទីផ្សារ
២២ ..... ហិរញ្ញវត្ថុ
២៣ ..... ធនធានសាជីវកម្ម
២៤ ..... បច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ
២៥ ..... ប្រតិបត្តិការ
២៦ ..... ទីផ្សារ និងទំនាក់ទំនង
២៧ ..... គ្រប់គ្រងផលិតផល
២៨ ..... គ្រប់គ្រងហានិភ័យ
៣១ ..... ប្រតិបត្តិតាម
៣២ ..... យុទ្ធសាស្ត្រ | ចីរភាព
៣៣ ..... សវនកម្មផ្ទៃក្នុង | នីតិកម្ម និងលេខាធិការក្រុមហ៊ុន


## ០៥

### ប្រវត្តិសង្ខេបរបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការគ្រប់គ្រង


៦៨ ..... ក្រុមប្រឹក្សាភិបាល
៧៦ ..... លេខាធិការក្រុមហ៊ុនរួម
៨០ ..... គណៈកម្មាធិការគ្រប់គ្រង

# នៃរបាយការណ៍

## ០៣

### អភិបាលកិច្ចធនាគារ


៣៦ ..... សេចក្តីថ្លែងការណ៍ ស្តីពីអភិបាលកិច្ចធនាគារ
៤៨ ..... របាយការណ៍គណៈកម្មាធិការសវនកម្ម
៥១ ..... សេចក្តីថ្លែងការណ៍ ស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
៥៤ ..... រចនាសម្ព័ន្ធក្រុមហ៊ុនមេ
៥៥ ..... រចនាសម្ព័ន្ធក្រុមហ៊ុន
៥៦ ..... របាយការណ៍ព័ត៌មានរបស់ធនាគារ


## ០៤

### ព្រឹត្តិការណ៍សំខាន់ៗ និងការចុះផ្សាយ ក្នុងសារព័ត៌មាន នៅឆ្នាំ២០២៤


៦០ ..... ព្រឹត្តិការណ៍សំខាន់ៗ
៦៤ ..... ការចុះផ្សាយ ក្នុងសារព័ត៌មាន


## ០៦

### របាយការណ៍ហិរញ្ញវត្ថុ


៩០ ..... របាយការណ៍ក្រុមប្រឹក្សាភិបាល
៩២ ..... របាយការណ៍សនវកម្មឯករាជ្យ
៩៤ ..... របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
៩៥ ..... របាយការណ៍ចំណូលលម្អិត
៩៦ ..... របាយការណ៍បម្រែបម្រួលមូលធន
៩៧ ..... របាយការណ៍លំហូរសាច់ប្រាក់
៩៨ ..... កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
១៤២ ..... ព័ត៌មានហិរញ្ញវត្ថុបន្ថែម ទៅតាមតម្រូវការ របស់ធនាគារជាតិ នៃកម្ពុជា


## ០៧

### បណ្តាញរបស់ធនាគារ


១៥៨ ..... បណ្តាញធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី
១៦០ ..... បណ្តាញសាខារបស់ក្រុមហ៊ុនមេ



# ០១

## ទិដ្ឋភាពទូទៅ


០៨ ..... សារតារធនាគារ

០៩ ..... ការប្តេជ្ញាចិត្ត លើគុណភាពសេវាកម្ម និងឧត្តមភាព

០៩ ..... តម្លៃស្នូលរបស់ស្ថាប័ន

១០ ..... សារពីប្រធានក្រុមប្រឹក្សាភិបាល

១២ ..... សារពីប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ

១៤ ..... ការពិនិត្យមើលលទ្ធផលប្រតិបត្តិការរបស់ប្រធាននាយកប្រតិបត្តិ

# សាវតារធនាគារ

**១៤**
**សាខា**

**៥00+**
**បុគ្គលិក**




## អំពីធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចាប់ផ្តើមប្រតិបត្តិការ នៅក្នុងទីផ្សារប្រទេសកម្ពុជា នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយបានបើកដំណើរការសាខាធនាគារពាណិជ្ជទី១ នៅចំកណ្តាលរាជធានីភ្នំពេញ។ រហូតមកដល់បច្ចុប្បន្ននេះ ធនាគារមានសាខាចំនួន ១៤កន្លែង ជាមួយនឹងម៉ាស៊ីនដាក់ប្រាក់ ១១កន្លែង ម៉ាស៊ីនដាក់មូលប្បទានបត្រ ១០កន្លែង និងម៉ាស៊ីនអេធីអិម ៣០កន្លែង នៅក្នុងខេត្ត និងរាជធានីសំខាន់ៗ ចំនួនប្រាំ នៃព្រះរាជាណាចក្រកម្ពុជា រួមមានរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តបាត់ដំបង និងខេត្តកំពង់ចាម។

បច្ចុប្បន្ននេះ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី កំពុងបម្រើសេវាកម្ម និងផ្តល់ផលិតផលធនាគារជូនដល់អតិថិជន ប្រមាណ ៣៥.000នាក់ ដែលរួមមានទាំងអតិថិជនជាបុគ្គល និងក្រុមហ៊ុន។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការកើនឡើងរបស់ចំនួនអតិថិជន នៅក្នុងប្រទេសកម្ពុជា ធនាគារមានផ្តល់ជូនសេវាកម្ម និងផលិតផលធនាគារដ៏ទូលំទូលាយ រួមមានសេវាកម្មហិរញ្ញវត្ថុបុគ្គល សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ព្រមទាំងសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុផងដែរ។

គិតត្រឹមខែធ្នូ ឆ្នាំ២០២៤ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មាននិយោជិតជាង ៥00នាក់ ដែលមានបទពិសោធន៍ និងជំនាញផ្សេងៗគ្នា ទាំងក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ក៏ដូចជាវិស័យផ្សេងៗទៀតផងដែរ។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី នៅក្នុងប្រទេសកម្ពុជា បានប្តេជ្ញាចិត្ត ក្នុងការកសាងវិស័យហិរញ្ញវត្ថុឱ្យរឹងមាំ និងយូរអង្វែងមួយ សម្រាប់អតិថិជនរបស់ខ្លួន ហើយនឹងបន្តព្យាយាមបង្កើតឱកាស និងគុណតម្លៃ តាមរយៈផលិតផល និងសេវាកម្មថ្មីៗ ដែលមានអត្ថប្រយោជន៍ខ្ពស់។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មានមោទកភាពក្រៃលែង ដោយសារតែយើងមិនត្រឹមតែជាអ្នកបម្រើសេវាកម្មហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាដៃគូអាជីវកម្មដ៏ល្អមួយរបស់អតិថិជនផងដែរ ក្នុងការគាំទ្រពួកគេឱ្យធ្វើការសម្រេចចិត្តត្រឹមត្រូវ លើផ្នែកហិរញ្ញវត្ថុ និងការវិនិយោគ។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺជាសាខារបស់ស៊ីអាយអិមប៊ី គ្រុប។

## អំពី ស៊ីអាយអិមប៊ី គ្រុប

ស៊ីអាយអិមប៊ី គ្រុប គឺជាធនាគារឈានមុខគេមួយ ដែលផ្តោតលើតំបន់អាស៊ាន និងជាដៃគូប្រឹក្សាសាជីវកម្មធំបំផុតមួយ ក្នុងតំបន់។ ស៊ីអាយអិមប៊ី គ្រុប ក៏នាំមុខគេ ក្នុងពិភពលោក លើផ្នែកហិរញ្ញវត្ថុឥស្លាមផងដែរ។

ស៊ីអាយអិមប៊ី គ្រុប មានទីស្នាក់ការកណ្តាល នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ហើយមានផ្តល់សេវាកម្មធនាគារពាណិជ្ជ ធនាគារវិនិយោគ ធនាគារឥស្លាម សេវាកម្មគ្រប់គ្រងទ្រព្យធន និងផលិតផល ព្រមទាំងសេវាកម្មទូទាត់ឌីជីថលផងដែរ។ ស៊ីអាយអិមប៊ី គ្រុប គឺស្ថិតក្នុងលំដាប់លេខ៥ នៅអាស៊ីអាគ្នេយ៍ បើគិតលើទ្រព្យសកម្ម ហើយបើគិតត្រឹមចុងខែធ្នូ ឆ្នាំ២០២៤ មានបុគ្គលិកជាង ៣៣.000នាក់ និងអតិថិជនប្រហែល ២៨លាននាក់។

ស៊ីអាយអិមប៊ី គ្រុប ហូលឌីង បើហាដ ត្រូវបានចុះបញ្ជី នៅលើទីផ្សារភាគហ៊ុន ប៊ួរសា ម៉ាឡេស៊ី (Bursa Malaysia) តាំងពីឆ្នាំ១៩៨៧ ជាមួយតម្លៃលើទីផ្សារភាគហ៊ុន ៨៨,0ពាន់លានរឹងហ្គីត ម៉ាឡេស៊ី បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ទ្រព្យសរុបមានចំនួន ៧៥៥,១ពាន់លានរឹងហ្គីតម៉ាឡេស៊ី ជាមួយនឹងប្រាក់បម្រុងរបស់ភាគហ៊ុនិកសរុបចំនួន ៦៩,២ពាន់លានរឹងហ្គីតម៉ាឡេស៊ី ហើយទ្រព្យសរុបរបស់ធនាគារឥស្លាម មានចំនួន ២២៣,៧ពាន់លានរឹងហ្គីតម៉ាឡេស៊ី។ គិតត្រឹមចុងខែធ្នូ ឆ្នាំ២០២៤ ភាគហ៊ុនិក ដែលមានភាគហ៊ុនច្រើនបំផុត គឺ Khazanah Nasional Berhad ដែលមាន ២១,៥% នៃភាគហ៊ុនសរុប។ ប្រាក់បម្រុង សម្រាប់បុគ្គលិក (EPF) មានចំនួន ១៦,៥% និង Kumpulan Wang Persaraan (Diperbadankan) មានចំនួន ៥,៧%។

# ការប្តេជ្ញាចិត្ត លើគុណភាពសេវាកម្ម និងឧត្តមភាព

**ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺជាក្រុមហ៊ុន ដែលផ្តោតលើការដឹកនាំរបស់មនុស្ស។ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី អ្វីដែលយើងផ្តោតជាសំខាន់នោះ គឺការផ្តល់សេវាកម្ម ដល់អតិថិជន ឬក៏គាំទ្រដល់អ្នក ដែលផ្តល់សេវាកម្ម ដល់អតិថិជន។**

តាំងពីដើមរៀងមក អតិថិជន គឺជាចំណុចស្នូល នៃគ្រប់ការងារទាំងអស់ ដែលយើងបានធ្វើ។ គុណតម្លៃស្នូលទី១ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺយើងផ្តោតការយកចិត្តទុកដាក់ លើអតិថិជន។ វត្តមានរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺដើម្បីអតិថិជន ហើយយើងផ្តល់ផលិតផល និងសេវាកម្ម ដែលអតិថិជនយល់ និងផ្តល់តម្លៃឱ្យ។

យើងក៏ផ្តោតសំខាន់ដូចគ្នាផងដែរ ទៅលើគុណតម្លៃស្នូលចំនួនបួនផ្សេងទៀត រួមមានសមិទ្ធផលខ្ពស់ ការផ្តល់លទ្ធភាព ដល់បុគ្គលិក កម្លាំងចម្រុះ និងសុចរិតភាព។ យើងជឿជាក់ថា ការរួមបញ្ចូលគ្នា នៃគុណតម្លៃស្នូលទាំងអស់នេះ ទៅលើអ្វីគ្រប់យ៉ាង ដែលយើងធ្វើ នឹងបង្កើតនូវគុណតម្លៃយូរអង្វែង មិនត្រឹមតែសម្រាប់អតិថិជនប៉ុណ្ណោះទេ តែថែមទាំងសម្រាប់បុគ្គលិក និងភាគីពាក់ព័ន្ធរបស់យើងផងដែរ។

ដើម្បីសម្រេចបានគោលដៅសេវាកម្មអតិថិជនដ៏ល្អឥតខ្ចោះ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានកំណត់គោលការណ៍ នៃសេវាកម្មអតិថិជនរបស់ខ្លួន ដើម្បីផ្តល់សេវាកម្មល្អប្រសើរ ជូនដល់អតិថិជន។ គ្រប់ពេលវេលាទាំងអស់ យើងនឹង៖

ធ្វើការវកិច្ចអតិថិជន
ដោយ**ការសំពះ**

ផ្តល់សេវាកម្ម ភ្ជាប់
ជាមួយនឹង**ស្នាមញញឹម**

**បម្រើសេវាកម្ម**អតិថិជន ដោយ
កាត់បន្ថយរយៈពេលរង់ចាំ
មិនលើសពី ៥នាទី

ផ្តោតទៅលើ**ដំណោះស្រាយ**
សម្រាប់អតិថិជន

**នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី អតិថិជន គឺជាអ្វី ដែលយើងផ្តោតការយកចិត្តទុកដាក់ខ្លាំងបំផុត។**

# តម្លៃស្នូលរបស់ស្ថាប័ន

**E**

**ការបណ្តុះបណ្តាលធនធានមនុស្ស**

យើងខ្ញុំបណ្តុះបណ្តាល និង
អភិវឌ្ឍធនធានមនុស្សរបស់
យើងខ្ញុំ។ យើងខ្ញុំចង់កសាង
កន្លែងការងារល្អបំផុត សម្រាប់
ធនធានមនុស្សល្អបំផុត
របស់យើងខ្ញុំ។

**P**

**ការមានឆន្ទៈខ្ពស់**

យើងខ្ញុំប្រកាន់ខ្ជាប់
នូវភាពល្អឥតខ្ចោះ ចំពោះ
គ្រប់សកម្មភាព ដែល
យើងខ្ញុំប្រព្រឹត្ត ហើយខិតខំ
បំពេញការងារ លើសពី
ការរំពឹងទុក។

**I**

**សុចរិតភាព និងការទទួលខុសត្រូវ**

យើងខ្ញុំបំពេញការងារ ជាមួយនឹង
អកប្បកិរិយា ប្រកបដោយ
ក្រមសីលធម៌វិជ្ជាជីវៈ និងភាព
ជឿទុកចិត្តបាន។ យើងខ្ញុំមាន
ភាពម្ចាស់ការ ចំពោះគ្រប់
សកម្មភាព ដែលបានប្រព្រឹត្ត។

**C**

**កិច្ចសហប្រតិបត្តិការ**

យើងខ្ញុំប្តេជ្ញាចិត្ត
លើភាពជោគជ័យរួម
ជាលក្ខណៈក្រុមការងារ
ជាជាងបុគ្គល។ ភាពជោគជ័យ
របស់ស៊ីអាយអិមប៊ី គឺជាភាព
ជោគជ័យរបស់យើងខ្ញុំ។

**C**

**ការផ្តោតសំខាន់ លើអតិថិជន**

យើងខ្ញុំប្រកាន់ខ្ជាប់ថា
អតិថិជន គឺជាអ្វី ដែលយើងខ្ញុំ
ផ្តោតការយកចិត្តទុកដាក់
ខ្លាំងបំផុត។ យើងខ្ញុំតែងតែ
ប្រព្រឹត្តទង្វើត្រឹមត្រូវ
ចំពោះអតិថិជន។

# សារពីប្រធានក្រុមប្រឹក្សាភិបាល



**ជូនចំពោះ ភាគីពាក់ព័ន្ធទាំងអស់**

ឆ្នាំ២០២៤ បាននាំមកនូវសមិទ្ធផលសំខាន់ៗ សម្រាប់ស៊ីអាយអិមប៊ី គ្រុប ស្របពេលដែលអបអរសាទរខួបគម្រប់ ១០០ឆ្នាំរបស់យើង។ រយៈពេល ១០០ឆ្នាំនេះ មិនត្រឹមតែរំលឹកនូវកេរដំណែលរបស់យើងប៉ុណ្ណោះទេ តែថែមទាំងបញ្ជាក់ឡើងវិញ នូវគោលបំណងឥតងាករេរបស់យើងផងដែរ ក្នុងការលើកកម្ពស់ជីវភាពរបស់អតិថិជន និងសង្គម។ សម្រាប់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងប្រទេសកម្ពុជា ឆ្នាំមួយនេះ គឺជាការឆ្លុះបញ្ចាំងមួយ ដែលយើងសម្រេចបាន តាមគោលបំណងរបស់យើង ដោយកើតចេញពីការប្តេជ្ញាចិត្តរបស់យើង ចំពោះភាពច្នៃប្រឌិត ការរួមបញ្ចូលគ្នា និងឧត្តមភាពក្នុងការបម្រើសេវាកម្ម។

## ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា៖ ស្ថិរភាព ជាមួយនឹងសន្ទុះរីកចម្រើនទៅមុខ

សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ២០២៤ បានបង្ហាញនូវភាពធន់ល្អ ទោះបីជាមានបញ្ហាប្រឈម ពីខាងក្រៅក៏ដោយ។ គោលនយោបាយជំរុញកំណើនរបស់រាជរដ្ឋាភិបាល ដែលគាំទ្រដោយកំណែទម្រង់រចនាសម្ព័ន្ធ និងទំនាក់ទំនងពាណិជ្ជកម្ម ក្នុងតំបន់អាស៊ាន និងសាកលលោក បានបង្កើតនូវមូលដ្ឋានគ្រឹះសម្រាប់ការងើបឡើងវិញ ប្រកបដោយស្ថិរភាព និងការផ្លាស់ប្តូរយៈពេលវែង។ វិស័យសំខាន់ៗ រួមមានវិស័យទេសចរណ៍ ផលិតកម្មមិនមែនកាត់ដេរ និងកសិកម្ម បានស្ទុះងើបឡើងវិញ តាមការរំពឹងទុក ដែលរួមចំណែកជាវិជ្ជមាន ដល់កំណើនផលិតផលក្នុងស្រុកសរុប។

ជាពិសេស វិស័យទេសចរណ៍ បានងើបឡើងវិញ ក្រោយពីជំងឺរាតត្បាតកន្លងមក ជាមួយនឹងកំណើនជាលំដាប់ នៃភ្ញៀវទេសចរ តាមរយៈយុទ្ធនាការផ្សព្វផ្សាយ ដើម្បីទាក់ទាញភ្ញៀវទេសចរអន្តរជាតិ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ក្នុងខេត្តសៀមរាប និងខេត្តតាមតំបន់ឆ្នេរសមុទ្រ។ វិស័យផលិតកម្ម បានធ្វើពិពិធកម្មកាន់តែខ្លាំង ដោយពង្រីកខ្លួន ទៅក្នុងផ្នែកអេឡិកត្រូនិក គ្រឿងបន្លាស់ និងសេវាកម្មដំឡើងគ្រឿងបង្គុំ ដែលអំណោយផល ពីបណ្តាញខ្សែចង្វាក់ផ្គត់ផ្គង់ ក្នុងតំបន់។ ជាមួយគ្នានេះ វិស័យកសិកម្ម បានបន្តរក្សានូវកំណើន ដោយមានការគាំទ្រដោយកម្មវិធីកសិកម្មអាកាសធាតុវៃឆ្លាត និងយុទ្ធសាស្ត្រជំរុញការនាំចេញ សម្រាប់អង្ករ កៅស៊ូ និងជលផល។

វិស័យហិរញ្ញវត្ថុ រក្សាបានភាពល្អប្រសើរ និងដំណើរការជាប្រក្រតី ជាមួយនឹងកំណើនប្រាក់បញ្ញើ និងលំហូរឥណទានល្អ សម្រាប់អតិថិជនជាគ្រួសារ និងសហគ្រាសធុនតូច និងមធ្យម។ គោលនយោបាយរូបិយវត្ថុ ពីធនាគារជាតិ នៃកម្ពុជា មានភាពបត់បែន និងប្រុងប្រយ័ត្នខ្ពស់ ដើម្បីរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច គ្រប់គ្រងសម្ពាធអតិផរណា និងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ។

ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមជាក់លាក់មួយចំនួន នៅតែបន្តមាន។ ការធ្វើពាណិជ្ជកម្មខាងក្រៅ បានរងសម្ពាធ ពីតម្រូវការថមថយជាសាកល ខណៈដែលផលប៉ះពាល់ ពីអតិផរណាទោះស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក៏ដោយ នៅតែបានជះឥទ្ធិពល ដល់ការចំណាយ ក្នុងគ្រួសារ និងក្នុងអាជីវកម្មផងដែរ។ ការលើកកម្ពស់ លើបទប្បញ្ញត្តិ រួមទាំងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម បន្តរឹតបណ្តឹង លើស្តង់ដារប្រតិបត្តិការ និងប្រតិបត្តិតាម ដោយជំរុញឱ្យធនាគារ រក្សានូវការប្រុងប្រយ័ត្នខ្ពស់ និងការសម្លឹងមើលវែងឆ្ងាយ។

ក្នុងបរិបទនេះ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានប្រកាន់ខ្ជាប់ តាមផែនការថ្នាក់ជាតិ និងភាពបត់បែន ស្របតាមតម្រូវការរបស់អតិថិជន និយ័តករ និងសហគមន៍។

## សមិទ្ធផល និងយុទ្ធសាស្ត្រសំខាន់ៗ ក្នុងឆ្នាំ២០២៤

ទោះបីជាបន្តជួបប្រទៈ នូវបញ្ហាប្រឈម ផ្នែកសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយក៏ដោយ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី នៅតែសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់។ យើងបានកត់ត្រាប្រាក់ចំណេញមុនបង់ពន្ធចំនួន ២២,៣៤លានដុល្លារអាមេរិក ដែលជំរុញដោយកំណើនឥណទាន រឹងមាំ គុណភាពទ្រព្យសកម្មល្អ និងការគ្រប់គ្រងចំណាយ ប្រកបដោយប្រសិទ្ធភាព។ អនុបាតឥណទានមិនដំណើរការរបស់យើង គឺស្ថិតក្នុងអត្រា ២,៣៩% ដែលឆ្លុះបញ្ចាំង នូវការបន្តយកចិត្តទុកដាក់របស់ធនាគារ លើគោលការណ៍បញ្ចេញឥណទាន ដោយប្រុងប្រយ័ត្ន និងការគ្រប់គ្រងហានិភ័យដោយប្រសិទ្ធភាព។

ប្រាក់បញ្ញើរបស់អតិថិជនសរុប មានកំណើនប្រចាំឆ្នាំ ក្នុងអត្រា ១៥% ដែលជួយពង្រឹង ដល់កម្រិតសន្ទនីយភាព និងអនុញ្ញាតឱ្យយើង គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈការពង្រីកទំហំឥណទាន ប្រកបដោយទំនួលខុសត្រូវ និងសេវាកម្មហិរញ្ញវត្ថុ ប្រកបដោយភាពច្នៃប្រឌិតខ្ពស់។

ការវិវឌ្ឍ ផ្នែកឌីជីថល នៅតែជាចំណុចស្នូល នៃយុទ្ធសាស្ត្រប្រតិបត្តិការរបស់យើង។ ក្នុងឆ្នាំ២០២៤ យើងបានដាក់ឱ្យប្រើប្រាស់ នូវកម្មវិធីធនាគារចល័ត CIMB Mobile ជំនាន់ទី២ ដើម្បីទាក់ទាញអតិថិជនបន្ថែមទៀត និងកែលម្អបទពិសោធន៍សេវាកម្មអតិថិជន។ កម្មវិធីជំនាន់ថ្មីនេះ បាននាំយកមុខងារបន្ថែម ដំណើរការល្បឿនប្រសើរ និងផ្ទៃរចនាថ្មី ដើម្បីបំពេញតម្រូវការ ដែលកំពុងកើនឡើងរបស់អតិថិជន ជាបុគ្គល និងសហគ្រាសធុនតូច និងមធ្យម។ មិនតែប៉ុណ្ណោះ យើងបានពង្រីកការប្រើប្រាស់ការទូទាត់ប្រាក់ តាមកូដ QR និងសេវាធនាគារ ដោយខ្លួនឯងផងដែរ។

## ការកសាងសមត្ថភាព និងការពង្រឹងធនធានមនុស្ស

ធនធានមនុស្ស គឺជាមូលដ្ឋានគ្រឹះ នៃភាពរីកចម្រើនរបស់យើង។ ក្នុងឆ្នាំ២០២៤ យើងបានវិនិយោគជាង ១៨.៥០០ម៉ោង នៃវគ្គបណ្តុះបណ្តាល និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ទាំងនៅក្នុងស្រុក និងក្រៅប្រទេស ដោយបង្កើតឡើង ដើម្បីលើកកម្ពស់ធនធានមនុស្ស និងសមត្ថភាព នៃភាពជាអ្នកដឹកនាំ។ តាមរយៈគម្រោងឆ្លងមុខងារ និងការគាំទ្រ ពីថ្នាក់តំបន់ បុគ្គលិកខ្មែររបស់យើង បានរួមចំណែកគួរឱ្យកត់សម្គាល់ ដល់ការសម្រេចផែនការរបស់ស៊ីអាយអិមប៊ី គ្រុប ក្នុងតំបន់អាស៊ាន។

ជាផ្នែកមួយ នៃវប្បធម៌ការងារ EPICC រួមមាន -ការបណ្តុះបណ្តាលធនធានមនុស្ស -ការមានឆន្ទៈខ្ពស់ -សុចរិតភាព និងការទទួលខុសត្រូវ -កិច្ចសហប្រតិបត្តិការ និង -ការផ្តោតសំខាន់ លើអតិថិជន យើងទទួលស្គាល់បុគ្គលិកឆ្នើម តាមរយៈការផ្តល់ពានរង្វាន់ ហើយបញ្ចូលវប្បធម៌ការងារដែលជំរុញដល់ការសម្រេចចិត្ត នៅគ្រប់កម្រិត នៃស្ថាប័ន។

ពិធីសម្ពោធជាផ្លូវការ នៃឧទ្យានអង្គរ-ស៊ីអាយអិមប៊ី នាថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៤ ខេត្តសៀមរាប

## ផលប៉ះពាល់ លើចីរភាព និងសហគមន៍

ចីរភាព គឺជាចំណុចផ្តោតសំខាន់ នៃយុទ្ធសាស្ត្រ Forward23+។ ក្នុងឆ្នាំ២០២៤ យើងបានពង្រីកការផ្តល់ជូនផលិតផលហិរញ្ញវត្ថុ ទាក់ទងនឹងចីរភាព ដោយនាំយកផលិតផលថ្មី។ ដូចជាការផ្តល់តណាទានបៃតង សម្រាប់សហគ្រាសធុនតូច និងមធ្យម និងកញ្ចប់តណាទានសូឡា សម្រាប់អតិថិជន ដែលជាម្ចាស់គេហដ្ឋាន និងម្ចាស់អាជីវកម្មផងដែរ។ កិច្ចខិតខំប្រឹងប្រែងនេះ ជួយគាំទ្រដល់ផែនការជាតិរបស់ប្រទេសកម្ពុជា ចំពោះថាមពលកកើតឡើងវិញ និងការអភិវឌ្ឍ ប្រកបដោយចីរភាព។

តាមរយៈកិច្ចសហការ ជាមួយនឹងអាជ្ញាធរជាតិអប្សរា កម្មវិធីបរិស្ថានដ៏សំខាន់របស់យើង បានដាំកូនឈើជាង ២.០០០ពាន់ដើម នៅឧទ្យានអង្គរ-ស៊ីអាយអិមប៊ី ក្នុងខេត្តសៀមរាប។ យើងបន្តប្រកាន់ខ្ជាប់ នូវការប្តេជ្ញាចិត្ត ក្នុងការជះឥទ្ធិពលរយៈពេលវែង ដល់សហគមន៍ តាមរយៈគម្រោងដែលជួយគាំទ្រ ដល់ការគ្រប់គ្រងបរិស្ថាន និងភាពរីកចម្រើនរួមគ្នា។

## ការពង្រឹងប្រតិបត្តិតាម និងអភិបាលកិច្ច

ក្នុងឆ្នាំ២០២៤ នាយកដ្ឋានប្រតិបត្តិតាម បានពង្រឹងមូលដ្ឋានគ្រឹះ នៃអភិបាលកិច្ច តាមរយៈគម្រោងសំខាន់ៗមួយចំនួន។ ការត្រួតពិនិត្យ ដល់ទីកន្លែង ផ្នែកប្រតិបត្តិតាម ត្រូវបានធ្វើឡើង នៅផ្នែកអាជីវកម្ម និងសាខាចំនួន ៩ ដោយផ្នែកលើការវិភាគទិន្នន័យ ដែលអាចគ្របដណ្តប់ចំនួនប្រតិបត្តិការនៅតាមសាខាបានចំនួនច្រើន។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បានកែលម្អសមត្ថភាពរបស់យើងគួរឱ្យកត់សម្គាល់ ក្នុងការកំណត់ និងដោះស្រាយហានិភ័យប្រតិបត្តិតាម ឱ្យកាន់តែសកម្មជាងមុន។

នីតិវិធីប្រតិបត្តិការស្តង់ដាររបស់នាយកដ្ឋានប្រតិបត្តិតាម ត្រូវបានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាព ដើម្បីពង្រឹងការរាយការណ៍ តាមបទប្បញ្ញត្តិច្បាប់ ការរាយការណ៍ ទៅធនាគារមេ ការត្រួតពិនិត្យការប្រតិបត្តិតាមបទប្បញ្ញត្តិ និងការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ការផ្តោតចម្បងមួយទៀត គឺជាការបណ្តុះបណ្តាល និងចំណេះដឹង ដោយបានរៀបចំវគ្គសិក្សាសរុបចំនួន ២៨លើក ក្នុងអំឡុងឆ្នាំកន្លងទៅនេះ ដែលគ្របដណ្តប់ លើការតម្រូវតាមបទប្បញ្ញត្តិ និងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ និយោជិតថ្មីទាំងអស់ ត្រូវបានតម្រូវឱ្យចូលរួមវគ្គបណ្តុះបណ្តាល ក្នុងអំឡុងរយៈពេលបីខែ គិតចាប់ពីថ្ងៃចូលបម្រើការងារ ក្នុងធនាគារ ហើយនិយោជិត ដែលកំពុងបម្រើការងារស្រាប់ តម្រូវឱ្យចូលរៀនវគ្គសិក្សាប្រចាំឆ្នាំ អំពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមប្រព័ន្ធអេឡិកត្រូនិក ដែលបញ្ជាក់ អំពីវប្បធម៌ការងារ នៃសុចរិតភាព និងគណនេយ្យភាពរបស់យើង។

## ការឆ្ពោះទៅអនាគត

ស្របពេលដែលយើងឈានចូលដំណាក់កាលថ្មីមួយទៀត នៃយុទ្ធសាស្ត្រ Forward23+ ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា បន្តការប្តេជ្ញាចិត្ត ចំពោះការអនុវត្តវប្បធម៌ការងារ ប្រកបដោយចីរភាព ដែលគាំទ្រ ដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងក្លាយជាធនាគារឈានមុខគេ ដែលផ្តោតលើតំបន់អាស៊ាន។ យើងមានជំនឿយ៉ាងមុតមាំថា ជាមួយនឹងមូលដ្ឋានគ្រឹះដ៏រឹងមាំ ក្រុមការងារដែលពោរពេញដោយសមត្ថភាព និងការយកចិត្តទុកដាក់ លើអតិថិជនជាចម្បង យើងកំពុងស្ថិតក្នុងជំហរដ៏ត្រឹមត្រូវមួយ សម្រាប់ភាពរីកចម្រើនរយៈពេលវែង។

តាងនាមឱ្យក្រុមប្រឹក្សាភិបាលរបស់ធនាគារ ស៊ីអាយអិមប៊ី ខ្ញុំសូមសម្តែងការកោតសរសើរយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិ នៃកម្ពុជា អតិថិជន ដៃគូសហការ និងក្រុមការងារ #teamCIMB ទាំងអស់ ដែលបានបន្តជឿទុកចិត្ត និងជួយជ្រោមជ្រែងរៀងរហូតមក។ សូមថ្លែងអំណរគុណ ដល់អ្នកទាំងអស់គ្នា ដែលរួមចំណែក ក្នុងភាពរីកចម្រើនរបស់យើង។ យើងនឹងឈានឆ្ពោះទៅមុខ ជាមួយនឹងអនាគត ប្រកបដោយឱកាស គោលដៅ និងភាពរីកចម្រើនទាំងអស់គ្នា។

**Tan Sri Mohd Nasir Ahmad**
ប្រធានក្រុមប្រឹក្សាភិបាល

# សារពីប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ

**ជូនចំពោះ ភាគីពាក់ព័ន្ធទាំងអស់**

## ការបន្តការប្តេជ្ញាចិត្តរបស់ស៊ីអាយអិមប៊ី គ្រុប ចំពោះប្រទេសកម្ពុជា

ប្រទេសកម្ពុជា បន្តដើរតួនាទីគន្លឹះ ក្នុងយុទ្ធសាស្ត្រកំណើនយូរអង្វែងរបស់ស៊ីអាយអិមប៊ី ដោយពង្រឹងភាពចំបាច់របស់ខ្លួន ជាផ្នែកសំខាន់មួយ នៃបណ្តាញដ៏ទូលំទូលាយ ក្នុងតំបន់អាស៊ានរបស់យើង។ ចាប់តាំងពីបើកដំណើរការអាជីវកម្មរបស់ខ្លួន ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា សម្រេចបាននូវភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយបម្រើសេវាកម្ម ដល់អតិថិជនជាបុគ្គល និងក្រុមហ៊ុនជាង ៣៥.០០០នាក់ ជាមួយនឹងបណ្តាញសាខាចំនួន ១៨កន្លែង។

ក្នុងនាមជាប្រទេស ដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតមួយ ក្នុងតំបន់អាស៊ាន ប្រទេសកម្ពុជា មានសក្តានុពលខ្ពស់ ហើយស៊ីអាយអិមប៊ី គ្រុប បានប្តេជ្ញាចិត្ត ក្នុងការគាំទ្រ ដល់ដំណើររីកចម្រើនរបស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា។ ក្រុមការងារជំនាញថ្នាក់តំបន់ រួមទាំងការផ្តោតសំខាន់របស់យើង លើភាពរីកចម្រើន ប្រកបដោយចីរភាព នាំឱ្យយើងក្លាយជាដៃគូដ៏ជឿទុកចិត្ត លើការអភិវឌ្ឍ ក្នុងវិស័យហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា។ តាមរយៈធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា យើងមានគោលបំណង ក្នុងការរួមចំណែក ដល់ភាពរីកចម្រើនរបស់ប្រទេស ដោយផ្តល់ជូនសេវាកម្ម និងផលិតផលធនាគារ ដែលលើកស្ទួយអាជីវកម្ម ជំរុញសហគ្រិនភាព និងជួយបង្កើតឱកាសថ្មីៗ។

## ការស្វែងរកឱកាសសេដ្ឋកិច្ច ក្នុងប្រទេសកម្ពុជា និងសាកលលោក

ឆ្នាំ២០២៤ បានបង្ហាញនូវបរិយាកាស មិនអាចគ្រោងទុកមុនបាន សម្រាប់អាជីវកម្មជាសាកល ដែលនាំមកនូវការបញ្ហាវំខានចម្បងចំនួន៣ រួមមានភាពតានតឹង ផ្នែកភូមិសាស្ត្រនយោបាយ គោលនយោបាយសេដ្ឋកិច្ចមិនប្រាកដប្រជា និងការរើបឡើង នៃបញ្ញាសិប្បនិមិត្ត (AI) ។ សម្រាប់ប្រទេសកម្ពុជា បញ្ហាប្រឈមជាសាកលទាំងនេះ បានបង្កើតនូវទាំងហានិភ័យ និងឱកាស។

ដោយមានសេដ្ឋកិច្ចពឹងផ្អែកខ្លាំង លើប្រាក់ដុល្លារអាមេរិក ដែលបានចាក់គ្រឹះយ៉ាងជ្រៅ ក្នុងពាណិជ្ជកម្មអន្តរជាតិ ជាពិសេសលើវិស័យមួយចំនួន ដូចជាវិស័យកាត់ដេរ កសិកម្ម និងទេសចរណ៍ ប្រទេសកម្ពុជា ហាក់ងាយរងឥទ្ធិពល ទៅនឹងការប៉ះទង្គិច ពីខាងក្រៅ។ របាំងពាណិជ្ជកម្មអាចរំខានដល់ខ្សែចង្វាក់ផ្គត់ផ្គង់ និងកំណត់ទីផ្សារនាំចេញ ខណៈដែលអស្ថិរភាពភូមិសាស្ត្រនយោបាយ អាចប៉ះពាល់ ដល់ការវិនិយោគបរទេស និងវិស័យទេសចរណ៍។ មិនតែប៉ុណ្ណោះ ការវិវឌ្ឍយ៉ាងឆាប់រហ័សនៃផ្នែកបញ្ញាសិប្បនិមិត្ត បានគូសបញ្ជាក់នូវភាពចាំបាច់ សម្រាប់ផែនការផ្តោតសំខាន់ជាយុទ្ធសាស្ត្រ លើការអភិវឌ្ឍកម្លាំងពលកម្ម និងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីធានាថា ប្រទេសកម្ពុជា អាចរក្សាបាននូវភាពប្រកួតប្រជែង ក្នុងសម័យកាល នៃសេដ្ឋកិច្ចឌីជីថល ដែលមានភាពរីកចម្រើនខ្លាំង។

ទោះបីជាមានបញ្ហាប្រឈមទាំងអស់នេះក៏ដោយ ប្រទេសកម្ពុជា អាចរក្សាបាននូវគោលជំហរយ៉ាងរឹងមាំ ដើម្បីទទួលបានផលប្រយោជន៍ ពីទីតាំងយុទ្ធសាស្ត្ររបស់ខ្លួន ក្នុងតំបន់អាស៊ាន ជាមួយនឹងកំណើនប្រជាសាស្ត្រថ្នាក់កណ្តាល និងវ័យក្មេង ហើយនឹងបន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ខ្លួន។ ក្នុងឆ្នាំ២០២៤ ប្រទេសកម្ពុជា បានបង្ហាញនូវភាពធន់ ជាមួយនឹងកំណើនលើសពីអត្រា ៥% ដោយមានការជំរុញ ពីការនាំចេញផលិតផលកាត់ដេរ និងវិស័យកសិកម្ម ព្រមទាំងការងើបឡើងវិញ នៃវិស័យទេសចរណ៍។ ទោះជាយ៉ាងណាក៏ដោយ វិស័យសំណង់ និងអចលនទ្រព្យ បន្តជួបប្រទះនឹងបញ្ហាប្រឈម ជាមួយនឹងការកើនឡើងចំនួនឥណទានមិនដំណើរការ និងបញ្ហាបំណុល ក្នុងវិស័យឯកជន។ កត្តាប្រឈមទាំងអស់នេះ បានគូសបញ្ជាក់ ពីតម្រូវការបន្ទាន់ សម្រាប់ក្រុមហ៊ុននានា ក្នុងការសម្របយុទ្ធសាស្ត្ររបស់ខ្លួន ដោយធ្វើឱ្យមានតុល្យភាពកំណើន ជាមួយនឹងស្ថិរភាពហិរញ្ញវត្ថុ ស្របពេលដែលផ្តោតសំខាន់ លើចីរភាព ក្នុងរយៈពេលវែង។

ក្នុងនាមជាធនាគារ ដែលដឹកនាំតាមចក្ខុវិស័យ យើងប្តេជ្ញាចិត្ត ក្នុងការគាំទ្រ ដល់ការផ្លាស់ប្តូរនេះ ដោយសម្របយុទ្ធសាស្ត្ររបស់យើង ទៅតាមផែនការអាទិភាពរបស់ជាតិ និងពង្រឹងភាពច្នៃប្រឌិតរបស់យើង ហើយផ្តល់នូវសេវាកម្មធនាគារកាន់តែងាយស្រួល ល្អប្រសើរ និងលឿនជាងមុន ដែលអនុញ្ញាតឱ្យអតិថិជនរបស់យើង អាចផ្តោតសំខាន់ លើតម្រូវការណា ដែលចាំបាច់បំផុត សម្រាប់ពួកគេ ខណៈដែលកិច្ចការបន្ទាប់បន្សំផ្សេងទៀតរបស់ពួកគេ ទុកឱ្យយើងជាអ្នកជួយដោះស្រាយ។

ដោយជម្នះនឹងបរិបទសេដ្ឋកិច្ចតានតឹង ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា សម្រេចបានសមិទ្ធផលហិរញ្ញវត្ថុដ៏រឹងមាំ ក្នុងឆ្នាំ២០២៤។ ប្រាក់ចំណូលប្រតិបត្តិការ បានកើនឡើង ក្នុងអត្រា ១១% រហូតដល់ ៥០,៦លានដុល្លារអាមេរិក ជាមួយនឹងផលចំណេញសុទ្ធ ក្នុងអត្រា ៨,៣%។ កំណើន និងភាពធន់នេះ បានគូសបញ្ជាក់នូវភាពខ្លាំង នៃគម្រូអាជីវកម្ម និងប្រសិទ្ធភាព នៃផែនការយុទ្ធសាស្ត្ររបស់យើង ដែលគាំទ្រដោយការគ្រប់គ្រងហានិភ័យច្បាស់លាស់ និងការវាយតម្លៃឥណទានរឹងមាំ ដែលឆ្លុះបញ្ចាំង ក្នុងគុណភាពទ្រព្យសកម្មរឹងមាំ និងអនុបាតឥណទានមិនដំណើរការដ៏មានស្ថិរភាព។

## ធនធានមនុស្ស និងវប្បធម៌ការងារ

ក្នុងនាមជាធនាគារអាស៊ាន ទ្រព្យសម្បត្តិសំខាន់បំផុតរបស់យើង គឺជាធនធានមនុស្ស។ ធនាគារ ស៊ីអាយអិមប៊ី ឈ្លោះទៅមុខ តាមរយៈវប្បធម៌ និងចក្ខុវិស័យ ប្រកបដោយថាមវន្ត និងភាពច្រេះបែប ជាមួយនឹងនិយោជិត ប្រកបដោយទេពកោសល្យ មកពី ១០ប្រទេស។ តាមរយៈវប្បធម៌ការងារ EPICC យើងចែករំលែកគោលបំណងរួម នៃការលើកកម្ពស់ជីវភាពរបស់អតិថិជន និងសង្គមជាតិ។

ក្នុងឆ្នាំ២០២៤ ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា បាននិយោគគួរឱ្យកត់សម្គាល់ ចំពោះនិយោជិតរបស់ខ្លួន តាមរយៈកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដ៏សម្បូរបែប ដូចជាកម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំថ្នាក់តំបន់ វគ្គសិក្សា Chartered Banker Certification និងវគ្គសិក្សា OMEGA Certification។ ជាលទ្ធផល ១២% នៃបុគ្គលិករបស់យើង ត្រូវបានដំឡើងតំណែង។ ដោយទទួលស្គាល់នូវសារៈសំខាន់ នៃសន្តិសុខ ផ្នែកហិរញ្ញវត្ថុ និងការលើកកម្ពស់សុខុមាលភាពនិយោជិត យើងបាននាំយកឥណទានគេហដ្ឋានបុគ្គលិកដ៏ល្អប្រសើរ ដែលជួយឱ្យ ៤០% នៃបុគ្គលិកទាំងអស់របស់យើង ក្លាយជាម្ចាស់គេហដ្ឋានផ្ទាល់ខ្លួន។

ផែនការផ្តួចផ្តើមទាំងនេះ មិនត្រឹមតែបង្កើនកម្រិតពេញចិត្តរបស់និយោជិតប៉ុណ្ណោះទេ តែថែមទាំងពង្រឹងកេរ្តិ៍ឈ្មោះរបស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ក្នុងនាមជាទីកន្លែងការងារល្អបំផុតមួយផងដែរ។ យើងមានកិត្តិយស ដែលត្រូវបានទទួលស្គាល់ជា ទីកន្លែងការងារល្អបំផុត ក្នុងឆ្នាំ២០២៤ ដោយទស្សនាវដ្តី HR Asia។ ខ្ញុំមានមោទកភាពក្រៃលែង ដែលធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា គឺពិតជាទីកន្លែងការងារមួយ ដែលបុគ្គលិករបស់យើងអាចបញ្ចេញសមត្ថភាព បង្កើតភាពច្នៃប្រឌិត និងជំរុញភាពរីកចម្រើន ប្រកបដោយចីរភាព សម្រាប់អតិថិជន និងសហគមន៍។

## សមិទ្ធផលសំខាន់ៗ របស់ស៊ីអាយអិមប៊ី គ្រុប ផ្នែកចីរភាព

### ចំណាត់ថ្នាក់ លេខមួយ

ក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុទាំងអស់ ក្នុងពិភពលោក សម្រាប់កម្មវិធីសម្ព័ន្ធភាពវាយតម្លៃពិភពលោក នៃប្រព័ន្ធហិរញ្ញវត្ថុ ឆ្នាំ២០២៥

### សម្រេចលើស ផែនការ

នៃសមិទ្ធផលហិរញ្ញវត្ថុ ដោយចីរភាព រហូតដល់ ១០០៣ន់លានរីងហ្គីត ដោយច្រើនជាងបីដង ពីផែនការដើមរបស់យើង ដែលធ្លាប់បានប្រកាស កាលពីឆ្នាំ២០២១

## ការប្តេជ្ញាចិត្ត ចំពោះចីរភាព

ចីរភាព គឺជាសសរស្តម្ភដ៏សំខាន់ សម្រាប់ភាពជោគជ័យអាជីវកម្ម។ នៅធនាគារ ស៊ីអាយអិមប៊ី ចីរភាពមិនត្រឹមតែជាការប្តេជ្ញាចិត្តប៉ុណ្ណោះទេ តែវាថែមទាំងជាកម្លាំងចលករ ដែលជំរុញសកម្មភាពដើម្បីការពារអនាគត នៃស្ថាប័នរបស់យើង និងជួយនាំឱ្យមានការផ្លាស់ប្តូរ ដល់អតិថិជនរបស់យើង ដោយកាត់បន្ថយហានិភ័យរបស់ពួកគេ ពីការត្រូវបានកាត់ចេញ ពីខ្សែចង្វាក់ផ្គត់ផ្គង់សាកល នាពេលអនាគត។

ចំពោះស៊ីអាយអិមប៊ី គ្រុប យើងមានកិត្តិយស ដែលទទួលបានចំណាត់ថ្នាក់លេខមួយ ក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុទាំងអស់ ក្នុងពិភពលោក សម្រាប់កម្មវិធីសម្ព័ន្ធភាពវាយតម្លៃពិភពលោក នៃប្រព័ន្ធហិរញ្ញវត្ថុ ឆ្នាំ២០២៥ (World Benchmarking Alliance's Financial System Benchmark 2025)។ យើងបន្តការប្តេជ្ញាចិត្ត ចំពោះការនាំយកកញ្ចប់ផលិតផល និងសេវាកម្ម ដែលជះឥទ្ធិពលល្អដល់ចីរភាព សង្គម និងភាពបៃតង ដែលកំណត់ដោយស៊ីអាយអិមប៊ី គ្រុប ដើម្បីសម្រេចបានសមិទ្ធផលហិរញ្ញវត្ថុ ដោយចីរភាព។ ក្នុងឆ្នាំ២០២៤ យើងបានកំណត់គោលដៅ នៃសមិទ្ធផលហិរញ្ញវត្ថុ ដោយចីរភាព រហូតដល់ ១០០៣ន់លានរីងហ្គីត ដោយច្រើនជាងបីដង ពីផែនការដើមរបស់យើង ដែលធ្លាប់បានប្រកាស កាលពីឆ្នាំ២០២១ ហើយយើងមានក្តីសោមនស្សរីករាយ ដោយប្រកាសថា យើងសម្រេចបានលើសផែនការនេះទៀតផង។

ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា បានប្តេជ្ញាចិត្ត ចំពោះការរួមបញ្ចូលចីរភាព ទៅក្នុងប្រតិបត្តិការស្នូលរបស់យើង។ យើងបានអនុវត្តយុទ្ធសាស្ត្រយ៉ាងសកម្ម ក្នុងការកាត់បន្ថយផលប៉ះពាល់ ដល់បរិស្ថាន រួមមានសវនកម្ម លើការប្រើប្រាស់ថាមពល ការគ្រប់គ្រងការចោលកាកសំណល់ និងការផ្លាស់ប្តូរ ពីការប្រើប្រាស់យានយន្តរបស់យើង ទៅកាន់យានយន្តអគ្គិសនីវិញផងដែរ។ ជាងនេះទៅទៀត យើងបាននាំយកផលិតផលឥណទានរថយន្តអគ្គិសនី និងឥណទានដំបូលសូឡា សម្រាប់អតិថិជនឥណទានគេហដ្ឋាន ក្នុងឆ្នាំ២០២៤ ដែលជំរុញអតិថិជនរបស់យើង ក្នុងការប្រើប្រាស់ថាមពលកកើតឡើងវិញ និងរួមចំណែក ដល់ការបង្កើតអនាគតកាន់តែបៃតង។

ចំពោះផ្នែកសង្គមកិច្ច យើងបានរួមចំណែកជាង ៦០០.០០០ដុល្លារអាមេរិក និងលើសពី ១៦.០០០ម៉ោងស្ម័គ្រចិត្ត តាមរយៈគម្រោងកម្មវិធីទំនួលខុសត្រូវសង្គមនានារបស់យើង ពីឆ្នាំ២០២០ ដល់បច្ចុប្បន្ន។ កិច្ចខិតខំប្រឹងប្រែងរបស់យើង នៅក្នុងវិស័យជាច្រើន បានបង្កើតនូវផលវិជ្ជមាន ដែលលើសពីការបម្រើសេវាកម្មធនាគារផងដែរ។

## ការឆ្ពោះទៅអនាគត

ស្របពេលដែលយើងឈានដល់ដំណាក់កាលថ្មីមួយទៀត នៃដំណើរអាជីវកម្មរបស់យើង ខ្ញុំសូមសង្កត់ធ្ងន់ថា ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា បានរក្សានូវតួនាទីយ៉ាងសំខាន់ នៃយុទ្ធសាស្ត្ររបស់ស៊ីអាយអិមប៊ី គ្រុប ក្នុងការក្លាយជា ធនាគារឈានមុខគេមួយ ដែលផ្តោតលើតំបន់អាស៊ាន។ ចក្ខុវិស័យជាយុទ្ធសាស្ត្ររបស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា គឺច្បាស់លាស់រួមមានការប្រែក្លាយទៅជា ធនាគារ ដែលផ្តោតលើចំណុចពិសេសរបស់ខ្លួន និងជាធនាគារ ដែលសម្រេចបានប្រាក់ចំណេញច្រើនបំផុត ដោយពង្រឹងបន្ថែម លើវត្តមានថ្នាក់តំបន់របស់យើង។ ស្របពេលដែលបញ្ហាប្រឈមនៅតែបន្ត យើងមានទំនុកចិត្តខ្ពស់ថា សេដ្ឋកិច្ចកម្ពុជា នឹងរក្សានូវកំណើនផងដែរ។

ធនាគារ ស៊ីអាយអិមប៊ី បានប្តេជ្ញាចិត្ត ចំពោះការលើកកម្ពស់ជីវភាពរបស់អតិថិជន និងសង្គមព្រមទាំងជួយធ្វើឱ្យជីវិតកាន់តែងាយស្រួល ល្អប្រសើរ និងលឿនជាងមុន សម្រាប់បុគ្គលិក និងអតិថិជនរបស់យើង។ ដោយការរួមបញ្ចូលនូវក្រុមការងារជំនាញក្នុងស្រុក ជាមួយនឹងបណ្តាញដ៏ទូលំទូលាយ និងសក្តានុពលរបស់ស៊ីអាយអិមប៊ី គ្រុប ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា នឹងជួយសម្រេចចក្ខុវិស័យរបស់យើង ក្នុងការក្លាយជា ធនាគារ ដែលផ្តោតលើតំបន់អាស៊ាន ដោយមានការប្តេជ្ញាចិត្ត ចំពោះការគាំទ្រ ដល់ការអភិវឌ្ឍ និងកិច្ចសហការថ្នាក់តំបន់ ក្នុងការជំរុញគុណតម្លៃ ដល់អតិថិជនរបស់យើង ក្នុងតំបន់អាស៊ានទាំងមូល។

**Novan Amirudin**
ប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ
ស៊ីអាយអិមប៊ី គ្រុប ហូលឌីង ប៊ើហាដ

# ការពិនិត្យមើលលទ្ធផលប្រតិបត្តិការរបស់ប្រធាននាយកប្រតិបត្តិ

## បរិយាកាសប្រតិបត្តិការ ឆ្នាំ២០២៤

នៅក្នុងឆ្នាំ២០២៤ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានធ្វើឱ្យស្ថានភាពប្រតិបត្តិការរបស់ខ្លួនមានភាពល្អប្រសើរឡើងវិញ បើប្រៀបធៀបទៅនឹងឆ្នាំមុន។ ធនាគារកណ្តាលធំៗ នៅអឺរ៉ុប អាស៊ី និងសហរដ្ឋអាមេរិក បានបន្ធូរបន្ថយអត្រាការប្រាក់របស់ខ្លួន ដែលបានធ្វើឱ្យបរិយាកាស នៃការផ្តល់តណទានមានភាពល្អប្រសើរឡើង។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមជាសាកល រួមទាំងការប្រែប្រួលតម្លៃ នៃវត្ថុធាតុដើម និងទំនិញ និងភាពមិនច្បាស់លាស់ នៃនយោបាយភូមិសាស្ត្រ នៅមជ្ឈិមបូព៌ា អ៊ុយក្រែន និងរុស្ស៊ី បានបន្តជំរុញឱ្យមានអតិផរណា នៅទូទាំងពិភពលោក។ ចំណែកឯនៅតំបន់អាស៊ីអាគ្នេយ៍ ឱកាសក្នុងការធ្វើពាណិជ្ជកម្មនាំចេញនាំចូលផ្សេងៗ បាននឹងកំពុងតែមានសន្ទុះកើនឡើង ស្របពេលដែលសហរដ្ឋអាមេរិក និងអឺរ៉ុប កំពុងតែព្យាយាមកាត់បន្ថយការពឹងផ្អែកលើទំនាក់ទំនង ជាមួយប្រទេសចិន។

ក្នុងប្រទេសកម្ពុជា ផលិតផលក្នុងស្រុកសរុប បានបន្តកើនឡើងប្រចាំឆ្នាំ ក្នុងអត្រា ៥.៨% ដែលកំណើននេះ បណ្តាលមកពីសន្ទុះងើបឡើងវិញ នៃវិស័យទេសចរណ៍ គួបផ្សំនឹងការពង្រឹងកំណើននៃវិស័យឧស្សាហកម្ម និងសេវាកម្ម។ល។ បន្ថែមពីលើនេះ យើងក៏សូមកោតសរសើរ ដល់កិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិ នៃកម្ពុជា ក្នុងការគ្រប់គ្រងស្ថិរភាពអតិផរណា នៅត្រឹមកម្រិត ១%-២% ដែលជាកត្តាធ្វើឱ្យបរិយាកាស សម្រាប់ការធ្វើអាជីវកម្មមានស្ថិរភាព។ ទន្ទឹមនឹងនេះ ក្នុងឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យប្រើប្រាស់ច្បាប់វិនិយោគថ្មីរបស់កម្ពុជា រួមជាមួយនឹងកិច្ចព្រមព្រៀងគ្រោងទុកជាច្រើន ក្រោមក្របខណ្ឌភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) ដែលការអនុវត្តនេះ បានជំរុញឱ្យលទ្ធខណ្ឌវិនិយោគ មានភាពកាន់តែប្រសើរឡើង ព្រមទាំងជួយបង្កើនលំហូរនៃមូលនិធិចូលក្នុងស្រុក បន្ធូរបន្ថយការរាំងស្ទះ នៃសន្ទនីយភាព ដែលបានកើតឡើង កាលពីឆ្នាំមុនៗ។ ដោយឡែក បើទោះជាមានការបន្ធូរបន្ថយ នូវភាពរាំងស្ទះ នៃសន្ទនីយភាពក្តី សកម្មភាពអចលនទ្រព្យ នៅតែមានសន្ទុះពុំទាន់ល្អ រួមជាមួយនឹងការធ្លាក់ចុះ នៃលំហូរការវិនិយោគ ពីបរទេស ខណៈដែលទីផ្សារក្នុងស្រុក ត្រូវការរក្សាលំនឹង នៃទ្រព្យសកម្មសន្ទនីយ ដែលជាកត្តាបង្កឱ្យស្ថានភាពទីផ្សារមានភាពមិនច្បាស់លាស់។

វិស័យធនាគារ នៅកម្ពុជា នៅតែមានការប្រកួតប្រជែងខ្លាំង នៅក្នុងតំបន់។ ជាងនេះទៅទៀត ត្រឹះស្ថានហិរញ្ញវត្ថុ បានបន្តប្រឈមនឹងកំណើនឡើង នៃការប្រាក់ សម្រាប់ប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែង ដែលនាំឱ្យការចំណាយមូលនិធិកាន់តែខ្ពស់។ បញ្ហាប្រឈមនេះកាន់តែធ្ងន់ធ្ងរបន្ថែមទៀត ដោយសារការកំណត់អត្រាការប្រាក់តណទាន ពុំមានលក្ខណៈបត់បែន រួមជាមួយនឹងការកើនឡើង នៃសំវិធានធន ដែលបណ្តាលឱ្យមានការធ្លាក់ចុះ នៃប្រាក់ចំណេញ សម្រាប់ធនាគារជាច្រើន និងប៉ះពាល់គួរឱ្យកត់សម្គាល់ ដល់គម្លាតនៃចំណូលការប្រាក់ និងចំណាយការប្រាក់សុទ្ធ (NIM) ក្នុងឆ្នាំ២០២៤។ អ្វីដែលគួរឱ្យកត់សម្គាល់ លើហានិភ័យនៃការធ្លាក់ចុះ លើប្រាក់ចំណេញនេះ គឺបណ្តាលមកពីការកើនឡើង នៃតណទានមិនដំណើរការ នៅទូទាំងវិស័យធនាគារ ដែលពុំទាន់មានសញ្ញាណាមួយបង្ហាញថា នឹងមានការថយចុះ ។

ថ្វីបើស្ថានភាពសេដ្ឋកិច្ច មានការលំបាកក៏ដោយ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ក្នុងការជម្រាបជូនថា ធនាគារ ស៊ីអាយអិមប៊ី អាចរក្សាបាននូវកំណត់ត្រាប្រាក់ចំណេញដ៏រឹងមាំ លើសពីគម្រោងហិរញ្ញវត្ថុ ដែលបានរៀបចំទុក។ សំខាន់ជាងនេះទៅទៀត បើធៀបនឹងនិន្នាការ ក្នុងវិស័យធនាគារ បានសម្រេច និងអាចរក្សាបាន យ៉ាងយូរអង្វែង នូវគុណភាពទ្រព្យសកម្ម ដែលល្អបំផុតជាមួយនឹងអនុបាតតណទានមិនដំណើរការត្រឹម ២.៣៩% ដែលអត្រានេះមានកម្រិតទាបជាងស្ទើរតែ ៤ដង ក្រោមអនុបាត នៅក្នុងវិស័យធនាគារ។ នេះគឺជាសក្ខីភាពមួយ ដែលបង្ហាញពីយុទ្ធសាស្ត្ររបស់យើង ក្នុងការត្រៀមខ្លួន ប្រឈមនឹងលក្ខខណ្ឌទីផ្សារមិនច្បាស់លាស់ ហើយថែមទាំងអាចបង្កើនភាពរឹកចម្រើន សម្រាប់ធនាគារ ជាមួយនឹងតុល្យភាពអនុបាតតណទាន ធៀបនឹងប្រាក់បញ្ញើ និងសមតុល្យផ្សេងៗ ដែលពោរពេញទៅដោយភាពរឹងមាំ។

ឆ្នាំ២០២៤នេះ គឺជាឆ្នាំ ដែលស្ថានភាពធនាគារ ស៊ីអាយអិមប៊ី ត្រូវបានស្តារឱ្យរីកចម្រើនឡើងវិញគួរឱ្យកត់សម្គាល់។ សម្រាប់ពេលអនាគត យើងនឹងបន្តប្តេជ្ញាចិត្ត ក្នុងការបង្កើនផលចំណូល ជូនភាគទុនិក តាមរយៈការពង្រឹងមូលដ្ឋានប្រាក់បញ្ញើ ឱ្យមានភាពរឹងមាំ ការអនុវត្តការផ្តល់តណទានប្រកបដោយភាពប្រុងប្រយ័ត្ន ការជំរុញការអភិវឌ្ឍឌីជីថល និងការបន្តផ្តល់អាទិភាព លើការពង្រឹងធនធានមនុស្ស ដែលប្រកបទៅដោយទេពកោសល្យ។

ជាមួយវិធីសាស្ត្រដ៏ហ្មត់ចត់ និងប្រកបដោយតុល្យភាពនេះ ខ្ញុំពិតជាមានទំនុកចិត្តថា ធនាគារ ស៊ីអាយអិមប៊ី នឹងបន្តទទួលបានការរីកចម្រើន ប្រកបទៅដោយស្ថិរភាព នាពេលអនាគត។

## ទិដ្ឋភាពទូទៅ នៃសមិទ្ធផលហិរញ្ញវត្ថុ

ប្រាក់ចំណេញមុនបង់ពន្ធ របស់ធនាគារ ស៊ីអាយអិមប៊ី បានកើនឡើងដល់ ២២,៣៤លាន ដុល្លារអាមេរិក ដែលបង្ហាញពីការកើនឡើងប្រចាំឆ្នាំ ក្នុងអត្រា ៦% និងលើសពីផែនការចំនួន ១០%។ កំណើននេះ បានរួមចំណែកយ៉ាងធំ ពីការកើនឡើងប្រចាំឆ្នាំ ក្នុងអត្រា ១១% នៃប្រាក់ចំណូល ពីការប្រាក់ រួមជាមួយនឹងការកើនឡើង នៃចំណូលផ្សេងៗ ក្រៅពីចំណូលការប្រាក់ ក្នុងអត្រា៨%។ តាមរយៈវិធីសាស្ត្រដ៏ហ្មត់ចត់ និងប្រកបដោយតុល្យភាពនេះ តណទានបានកើនឡើងតិចតួច ក្នុងអត្រា ០,១% ដែលធ្វើឱ្យទំហំតណទានកើនដល់ ៩៥០លានដុល្លារអាមេរិក ខណៈដែលប្រាក់បញ្ញើពីអតិថិជន មានការកើនឡើងយ៉ាងគួរឱ្យកត់សម្គាល់ ក្នុងអត្រា ១៥% សរុបចំនួន ១.១៤៤លានដុល្លារអាមេរិក។ សមិទ្ធផលនេះ បានធ្វើឱ្យអនុបាតតណទាន ធៀបនឹងប្រាក់បញ្ញើ មានអត្រាប្រហែល ៨៣% ដែលនេះជាលទ្ធផលល្អគួរឱ្យកត់សម្គាល់។

យុទ្ធសាស្ត្ររបស់យើង ក្នុងការអនុវត្តវិធីសាស្ត្រតម្រង់ទិសទីផ្សារ ដើម្បីបង្កើនប្រសិទ្ធភាពទាំងប្រាក់បញ្ញើ និងតណទាន បានសម្រួល ដល់ការគ្រប់គ្រងយ៉ាងសកម្ម នៃហានិភ័យមូលនិធិ និងសន្ទនីយភាព របស់ធនាគារ ស៊ីអាយអិមប៊ី។ កត្តានេះបានធ្វើឱ្យការអនុវត្តការគ្រប់គ្រង លើការចំណាយ លើប្រភពទុន និងផលចំណេញ ពីតណទានកាន់តែប្រសើរឡើង ជាពិសេសលើគម្លាត នៃចំណូលការប្រាក់ និងចំណាយការប្រាក់ មានភាពប្រសើរឡើង។ ចំពោះគុណភាពទ្រព្យសកម្ម យើងពិនិត្យឃើញថា អនុបាតតណទានមិនដំណើរការ ក្នុងឆ្នាំ២០២៤ ត្រូវបានកត់ត្រា នៅត្រឹម ២.៣៩% ដែលមានកម្រិតទាបជាងការព្យាករ សម្រាប់វិស័យហិរញ្ញវត្ថុកម្ពុជា ដែលមានអត្រា ៨% ដល់ ១០% ហើយនេះជាការសបញ្ជាក់ ពីការប្តេជ្ញាចិត្តជាយុទ្ធសាស្ត្រ ចំពោះកំណើនដ៏ប្រុងប្រយ័ត្ន។

## សមិទ្ធផលសំខាន់ៗ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០២៤

**២២,៣៤លានដុល្លារអាមេរិក**
ប្រាក់ចំណូលមុនបង់ពន្ធ

**២,៣៩%**
អនុបាតឥណទានមិនដំណើរការ

**១៥%**
កំណើនប្រចាំឆ្នាំ
នៃប្រាក់បញ្ញើ

**១១%**
កំណើនប្រចាំឆ្នាំ
នៃប្រាក់ចំណូល ពីការប្រាក់

គ្រប់ផ្នែក នៃអាជីវកម្មទាំងអស់របស់យើង បានបន្តរីកចម្រើនយ៉ាងល្អប្រសើរ។ ផ្នែកសេវាកម្មហិរញ្ញវត្ថុបន្ថែម មានសន្ទុះកើនឡើង គួរឱ្យកត់សម្គាល់ ទៅលើប្រាក់បញ្ញើ ដែលការកើនឡើងនេះ បណ្តាលមកពីភាពល្អប្រសើរជាងមុន នៃសន្ទនីយភាពទីផ្សារ និងការផ្តល់ជូននូវផលិតផល ដែលមានការប្រកួតប្រជែង ក្នុងទីផ្សារ។ ចំពោះផ្នែកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មវិញ យើងសម្រេចបានកំណើនប្រាក់បញ្ញើប្រចាំឆ្នាំ គួរឱ្យកត់សម្គាល់ ក្នុងអត្រា ២៦% និងកំណើនឥណទានប្រចាំឆ្នាំ ក្នុងអត្រា ៧% ក្នុងខណៈពេលដែលធនាគារបន្តរក្សា នូវគោលការណ៍ឥណទានយ៉ាងខ្ជាប់ខ្ជួនផងដែរ។ ដូចគ្នានេះដែរ យើងក៏រំពឹងផងដែរថា នឹងពង្រីកផ្នែកសេវាកម្មហិរញ្ញវត្ថុសហគ្រាសរបស់យើង ខណៈពេលដែលផ្តោតសំខាន់ លើអាជីវកម្មសហគ្រាសធុនតូច និងមធ្យម ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រ ដល់វិស័យអាជីវកម្ម ដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស។ សម្រាប់ផ្នែកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុវិញ យើងមានសេចក្តីសោមនស្សរីករាយ ក្នុងការជម្រាបជូនថា ជាផ្នែកមួយ ដែលគ្មានអនុបាតឥណទានមិនដំណើរការទាល់តែសោះ និងរក្សាបាននូវអនុបាតឥណទាន ធៀបនឹងប្រាក់បញ្ញើដ៏រឹងមាំ បើទោះបីជាអតិថិជនរបស់យើងភាគច្រើន នៅក្នុងផ្នែកនេះ ជាអតិថិជន ដែលងាយរងផលប៉ះពាល់ ពីកត្តាបម្រែបម្រួលសេដ្ឋកិច្ចខាងក្រៅក៏ដោយ។ ជាចុងក្រោយ ក្រុមការងាររតនាគិបាល និងទីផ្សាររបស់យើង បានបំពេញតួនាទីយ៉ាងល្អពិសេស ក្នុងការគ្រប់គ្រងបម្រែបម្រួល ក្នុងតារាងតុល្យការ ព្រមទាំងបានជួយជំរុញចំណូលផ្សេងៗ ក្រៅពីចំណូលការប្រាក់ ជាមួយនឹងកំណើនប្រាក់ចំណូលសរុបគួរឱ្យកត់សម្គាល់ ក្នុងអត្រាកំណើន ៣៣%។

យើងបានបន្តធ្វើការវិនិយោគយ៉ាងច្រើន ទៅលើហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ការធ្វើប្រតិបត្តិការរបស់យើង ដោយផ្តោតសំខាន់ លើការពង្រឹងសមត្ថភាពបច្ចេកវិទ្យា និងឌីជីថល។ ការប្តេជ្ញាចិត្តរបស់យើង ក្នុងការធ្វើឱ្យប្រសើរឡើង នូវបទពិសោធន៍សេវាកម្មអតិថិជន តាមរយៈការបន្តអភិវឌ្ឍនូវបច្ចេកវិទ្យា ជាពិសេសជាមួយនឹងការពង្រឹងមុខងារជាច្រើន លើកម្មវិធីធនាគារ តាមទូរសព្ទដៃជាបន្តបន្ទាប់ បានជំរុញធ្វើឱ្យមានការកើនឡើង គួរឱ្យកត់សម្គាល់ លើបរិមាណប្រតិបត្តិការ សម្រាប់សេវាកម្មធនាគារឌីជីថលរបស់យើង ជាមួយនឹងការរំពឹងទុក សម្រាប់កំណើនដ៏ច្រើនលើសលប់ ជានិរន្តរ៍។ លើសពីនេះ យើងកំពុងអភិវឌ្ឍយ៉ាងសកម្ម នូវផលិតផល និងសេវាកម្មថ្មីៗ ដើម្បីសម្របតាមតម្រូវការរបស់អតិថិជន រួមទាំងកម្មវិធីធនាគារ តាមទូរសព្ទដៃ សម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលនឹងត្រូវបានដាក់ដំណើរការ នាពេលខាងមុខនេះផងដែរ។

តាមរយៈការឆ្លុះបញ្ចាំង ពីឆ្នាំ២០២៤នេះ ខ្ញុំពិតជាមានមោទកភាពក្រៃលែង ចំពោះការបំពេញកិច្ចការ ប្រកបដោយភាពអត់ធ្មត់ និងការលះបង់របស់ក្រុមការងារយើងទាំងអស់ ដែលអាចឱ្យយើងជម្នះបាននូវបញ្ហាប្រឈម និងឧបសគ្គជាច្រើន ហើយថែមទាំងអាចធ្វើឱ្យលទ្ធផលមានភាពល្អប្រសើរឡើងវិញគួរឱ្យកត់សម្គាល់។ ឈានចូលក្នុងឆ្នាំ២០២៥ យើងនៅតែបន្តប្តេជ្ញាចិត្តអនុវត្តនូវគុណតម្លៃស្នូលរបស់យើង ដែលរួមមានសុចរិតភាព ការផ្តោតសំខាន់ លើការបម្រើសេវាកម្មអតិថិជនដ៏ល្អឥតខ្ចោះ ព្រមទាំងឧត្តមភាព ក្នុងគ្រប់ប្រតិបត្តិការ។ យើងក៏ទន្ទឹងរង់ចាំឱកាសរីកចម្រើនថ្មីៗ ដែលផ្តោតសំខាន់លើការច្នៃប្រឌិតថ្មី ការបង្កើនបទពិសោធន៍សេវាកម្មអតិថិជនល្អ និងការពង្រីកបន្ថែម នូវផលិតផលនានា សម្រាប់ផ្តល់ជូនអតិជន ទន្ទឹមនឹងការពង្រឹងភាពជាដៃគូរបស់យើង ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារជាតិ នៃកម្ពុជា។

តាងនាមឱ្យគណៈគ្រប់គ្រង ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអតិថិជនដ៏ស្មោះស្ម័គ្ររបស់យើង សហការី ដែលបានខិតខំប្រឹងប្រែងបំពេញការងារ ប្រកបដោយភាពអត់ធ្មត់ និងការលះបង់ និងក្រុមប្រឹក្សាភិបាល សម្រាប់ការគាំទ្រ ដោយគ្មានដែនកំណត់ និងឥតឈប់ឈរ។ ការជឿទុកចិត្តរបស់អ្នកទាំងអស់គ្នា ដើរតួនាទីយ៉ាងសំខាន់ខ្លាំងណាស់ ចំពោះភាពជោគជ័យរបស់យើង។ តាមរយៈការចូលរួមរបស់អ្នកទាំងអស់គ្នា យើងអាចឆ្ពោះទៅរកភាពរីកចម្រើន នៅឆ្នាំ២០២៥ ជាមួយនឹងទំនុកចិត្តខ្ពស់ថា នឹងអាចដោះស្រាយបញ្ហាប្រឈមនានា និងខិតខំសម្រេចឱ្យបាន នូវគោលដៅខ្ពស់ជាងនេះបន្ថែមទៀត។ ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណ ដល់អ្នកទាំងអស់គ្នា ដែលបានចូលរួមជាផ្នែកដ៏សំខាន់មួយ នៃដំណើររបស់ធនាគារ ស៊ីអាយអិមប៊ី ។

**ប៊ុន យ៉ីន**
ប្រធាននាយកប្រតិបត្តិ



# ០២

## ការពិនិត្យមើលធុរកិច្ច


១៨ ..... សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

១៩ ..... សេវាកម្មហិរញ្ញវត្ថុបុគ្គល

២០ ..... សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ

២១ ..... រតនាភិបាល និងទីផ្សារ

២២ ..... ហិរញ្ញវត្ថុ

២៣ ..... ធនធានសាជីវកម្ម

២៤ ..... បច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ

២៥ ..... ប្រតិបត្តិការ

២៦ ..... ទីផ្សារ និងទំនាក់ទំនង

២៧ ..... គ្រប់គ្រងផលិតផល

២៨ ..... គ្រប់គ្រងហានិភ័យ

៣១ ..... ប្រតិបត្តិតាម

៣២ ..... យុទ្ធសាស្ត្រ | ចីរភាព

៣៣ ..... សវនកម្មផ្ទៃក្នុង | នីតិកម្ម និងលេខាធិការក្រុមហ៊ុន

# សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

**នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បម្រើសេវាកម្ម និងបំពេញតម្រូវការ ដល់អតិថិជន ដែលជាអាជីវករ ដោយផ្តល់ជូននូវផលិតផលឥណទាន និងប្រាក់បញ្ញើ ព្រមទាំងសេវាកម្មផ្សេងៗទៀត ទៅដល់អតិថិជន ដែលជាសហគ្រាសធុនតូច និងមធ្យម ក៏ដូចជាសហគ្រាសធំៗផងដែរ។**

## លទ្ធផលហិរញ្ញវត្ថុ និងសមិទ្ធផលសំខាន់ៗ ក្នុងឆ្នាំ២០២៤

នៅក្នុងឆ្នាំ២០២៤ នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម សម្រេចបានកំណើនប្រចាំឆ្នាំគួរឱ្យកត់សម្គាល់ លើប្រាក់បញ្ញើ ក្នុងកម្រិត ២៦% និងឥណទាន ក្នុងកម្រិត ៧%។ ជាមួយនឹងកំណើននៃតារាងតុល្យការដ៏រឹងមាំ នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ទទួលបានកំណើនចំនួនពីរខ្ទង់ លើប្រាក់ចំណូល ពីការប្រាក់ ក្នុងកម្រិត ២៤% និងប្រាក់ចំណូល មិនមែនពីការប្រាក់ ក្នុងកម្រិត ១៤% ដែលជំរុញឱ្យកំណើនប្រាក់ចំណូលប្រតិបត្តិការ បានកើនឡើង ក្នុងកម្រិត ២១%។ អនុបាតគណនីចរន្ត/គណនីសន្សំ ក្នុងកម្រិត ៥៧% គឺជាសញ្ញាបញ្ជាក់ពីការគ្រប់គ្រងតារាងតុល្យការដ៏មានប្រសិទ្ធភាព ដែលនាំឱ្យមានការចំណាយថវិកាជារួម ក្នុងកម្រិតទាប។ គុណភាពឥណទាន របស់នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម បន្តរក្សាបាននូវភាពរឹងមាំ ជាមួយនឹងកម្រិតឥណទានមិនដំណើរការ ក្នុងកម្រិតត្រឹមតែ ២.៣៧% តែប៉ុណ្ណោះ។

គិតត្រឹមចុងឆ្នាំ២០២៤ នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម មានបុគ្គលិកប្រកបដោយសក្តានុពលសរុបចំនួន ៦៥នាក់ រួមមានមជ្ឈមណ្ឌលសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មចំនួនពីរ ផ្នែកសហគ្រាសធុនតូច និងមធ្យម ផ្នែកគាំទ្រអាជីវកម្ម ព្រមទាំងផ្នែកគ្រប់គ្រង និងថែរក្សាគុណភាពទ្រព្យសកម្ម។ ជាមួយនឹងការផ្តោតសំខាន់ លើការលើកកម្ពស់ការផ្ទេរចំណេះដឹង និងបទពិសោធន៍ ព្រមទាំងដំណើរអភិវឌ្ឍន៍អាជីពយ៉ាងច្បាស់លាស់ យើងបានផ្តល់ជូនកម្មវិធីបណ្តុះបណ្តាលផ្សេងៗគ្នា ដើម្បីអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិក នៅគ្រប់កម្រិត។ ជាលទ្ធផល សមត្ថភាពរបស់បុគ្គលិកមានការរីកចម្រើន គួរឱ្យកត់សម្គាល់ ទៅលើប្រសិទ្ធភាព និងផលិតភាពការងារ ហើយបុគ្គលិក ដែលមានស្នាដៃឆ្នើម ត្រូវបានដំឡើងតំណែង នៅក្នុងចំណោមក្រុមការងារផងដែរ។

យើងបាននាំយកបណ្តាញទំនាក់ទំនងថ្នាក់តំបន់ របស់ស៊ីអាយអិមប៊ី គ្រុប សម្រាប់ផលប្រយោជន៍ទៅវិញទៅមក រវាងធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា និងទីផ្សារសំខាន់ៗផ្សេងទៀត របស់ស៊ីអាយអិមប៊ី គ្រុប នៅក្នុងប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបុរី វៀតណាម និងថៃ។ ជាមួយនឹងក្របខណ្ឌទំនាក់ទំនងថ្នាក់តំបន់នេះ យើងបានបង្កើតនូវគុណតម្លៃល្អប្រសើរបន្ថែមទៀត សម្រាប់អតិថិជនរបស់យើង ដោយសម្រួល ដល់ការស្វែងរកធនធាន និងការពង្រីកអាជីវកម្មឆ្លងប្រទេស សម្រាប់ពួកគេ។




## ផែនការ សម្រាប់ឆ្នាំ២០២៥

ជាមួយនឹងមូលដ្ឋានគ្រឹះដ៏រឹងមាំ និងសមត្ថភាពបុគ្គលិកដ៏ខ្លាំងក្លា យើងជឿជាក់យ៉ាងមុតមាំថា យើងនឹងបន្តភាពរីកចម្រើន និងនៅតែរក្សាបានគុណភាពទ្រព្យសកម្មល្អប្រសើរ ក្នុងឆ្នាំ២០២៥។ ក្នុងអំឡុងពេលមានភាពតានតឹងអស់រយៈពេលជាង ៤ឆ្នាំកន្លងមកនេះ ជាពិសេសក្នុងឆ្នាំ២០២៤ ដែលជះឥទ្ធិពល ពីជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចសាកល អនុបាតឥណទានមិនដំណើរការ ក្នុងវិស័យធនាគារ បានហក់ឡើងខ្ពស់ គួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងណាក៏ដោយ យើងរំពឹងថា ស្ថានភាពនេះនឹងវិវឌ្ឍទៅរកភាពប្រសើរឡើងវិញ ហើយប្រទេសកម្ពុជានៅតែរក្សាបានកំណើនសេដ្ឋកិច្ចល្អប្រសើរ ក្នុងឆ្នាំ២០២៥ ដោយផ្តល់នូវឱកាសអាជីវកម្មកាន់តែច្រើន នៅក្នុងប្រទេស។

ក្នុងឆ្នាំ២០២៥ យើងនឹងបន្តលើកកម្ពស់ដំណើរការ នៃការងាររបស់យើង ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើង នូវសេវាកម្មបម្រើអតិថិជន ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស ក៏ដូចជាការអភិវឌ្ឍផលិតភាពជារួមផងដែរ។ យើងនឹងបន្តវិនិយោគ លើការអភិវឌ្ឍសមត្ថភាពនិយោជិត តាមរយៈកម្មវិធីបណ្តុះបណ្តាល និងផែនការលើកកម្ពស់ជំនាញបន្ថែមទៀត។

### ផលិតផលសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មទាំងអស់

# សេវាកម្មហិរញ្ញវត្ថុបុគ្គល

**នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល គឺជាគ្រឹះយ៉ាងសំខាន់ សម្រាប់ដំណើរការអាជីវកម្មរបស់ធនាគារ ស៊ីអាយអិមប៊ី គីអិលស៊ី ក្នុងប្រទេសកម្ពុជា ដែលមានបុគ្គលិកប្រមាណ ៥០% នៃចំនួនបុគ្គលិកសរុបរបស់ធនាគារ។ នាយកដ្ឋាននេះ ផ្តល់ជូននូវផលិតផល និងសេវាកម្មធនាគារដ៏សម្បូរបែប ដល់អតិថិជន។**

គំរូប្រតិបត្តិការ នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល ត្រូវបានបែងចែក ដោយផ្តោតសំខាន់ លើអង្គភាពបណ្តាញចែកចាយការលក់ និងប្រតិបត្តិការ ដូចខាងក្រោម៖

## អង្គភាពបណ្តាញចែកចាយការលក់ នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល

- ផ្នែកប្រាក់បញ្ញើ
- ផ្នែកឥណទាន សម្រាប់អតិថិជនបុគ្គល
- ផ្នែកគ្រប់គ្រងសមិទ្ធផលការងារ
- ផ្នែកអាជីវកម្មបើងកាសូរេន និងការចាប់ដៃគូសហការ

## អង្គភាពប្រតិបត្តិការ នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល

- ផ្នែកបណ្តាញសាខា និងចែកចាយផលិតផល
- ផ្នែកគាំទ្រអាជីវកម្ម សម្រាប់អតិថិជនបុគ្គល
- ផ្នែកប័ណ្ណ
- ផ្នែកបទពិសោធន៍សេវាកម្មអតិថិជន
- ផ្នែកឥណទាន និងគុណភាពទ្រព្យសកម្ម សម្រាប់អតិថិជនបុគ្គល

## សមិទ្ធផលសំខាន់ៗ ក្នុងឆ្នាំ២០២៤

ទោះបីជាស្ថិតក្នុងបរិយាកាសប្រឈម ក្នុងវិស័យឥណទាន និងការបន្តប្រកួតប្រជែងខ្ពស់ ក្នុងការកំណត់អត្រាការប្រាក់ សម្រាប់ទីផ្សារប្រាក់បញ្ញើ សម្រាប់អតិថិជនបុគ្គលក៏ដោយ នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល នៅតែបន្តសម្រេចបានកំណើនល្អប្រសើរ សម្រាប់ផ្នែកឥណទានរថយន្ត និងអត្រា នៃការប្រើប្រាស់ប័ណ្ណឥណទានរឹងមាំ ព្រមទាំងកំណើនជាវិជ្ជមាន ផ្នែកប្រាក់បញ្ញើសរុប។ គួរឱ្យកត់សម្គាល់ គណនីចរន្ត/គណនីសន្សំ មានកំណើនល្អប្រសើរ ដែលជំរុញកម្រិតប្រាក់បញ្ញើ និងពង្រឹងការផ្តល់តណទានរបស់ធនាគារ ព្រមទាំងកំណត់ត្រាល្អ នៃឥណទានមិនដំណើរការ ក្នុងកម្រិតដ៏ទាបមួយ។

### សមិទ្ធផលសំខាន់ៗ

- សម្រេចបានកំណើនប្រាក់បញ្ញើ ប្រចាំឆ្នាំ ក្នុងកម្រិត **១៣%** ធៀបនឹងឆ្នាំ២០២៣
- សម្រេចបានកំណើនទឹកប្រាក់គណនីចរន្ត/គណនីសន្សំប្រចាំឆ្នាំ ក្នុងកម្រិត **២៧%** បើធៀបនឹងឆ្នាំ២០២៣
- សម្រេចបានកំណើនឥណទានរថយន្ត ប្រចាំឆ្នាំ ក្នុងកម្រិត **៣៤%** បើធៀបនឹងឆ្នាំ២០២៣
- ធ្វើឱ្យប្រសើរឡើង នូវប្រព័ន្ធ និងដំណើរការធនាគារ ដើម្បីលើកកម្ពស់បទពិសោធន៍សេវាកម្ម ដល់អតិថិជនផ្ទៃក្នុង និងខាងក្រៅ
- ដាក់ដំណើរការកម្មវិធីធនាគារចល័ត **CIMB MOBILE ជំនាន់ទី២** ដើម្បីទាក់ទាញអតិថិជនកាន់តែច្រើន និងធ្វើឱ្យប្រសើរឡើងនូវបទពិសោធន៍សេវាកម្មអតិថិជន
- រក្សាបានគុណភាពទ្រព្យសកម្ម ជាមួយនឹងឥណទានមិនដំណើរការ ក្នុងកម្រិត **៣,៧9%**

កម្មវិធីអភិវឌ្ឍន៍សមត្ថភាពនិយោជិត គឺជាអាទិភាពចម្បងមួយ ក្នុងចំណោមអាទិភាពផ្សេងៗរបស់ធនាគារ។ តាមរយៈការគាំទ្រ ពីក្រុមការងារអភិវឌ្ឍន៍ធនធានមនុស្ស ធនាគារបានរៀបចំវគ្គសិក្សាជំនាញ និងបណ្តុះបណ្តាលសមត្ថភាពដ៏សម្បូរបែប ដែលជាអត្ថប្រយោជន៍បន្ថែម ដល់និយោជិតរបស់យើង។ វគ្គបណ្តុះបណ្តាលទាំងអស់នោះ ផ្តោតលើចំណេះដឹង និងជំនាញអនុវត្តន៍ការងារ រួមមានការពង្រឹងសេវាកម្ម និងជំនាញផ្នែកលក់ ការសិក្សាវាយតម្លៃឥណទាន ការគ្រប់គ្រងហានិភ័យ បទប្បញ្ញត្តិនានា ដែលទាក់ទងនឹងការអនុវត្តច្បាប់ ព្រមទាំងកម្មវិធីបង្កើនការយល់ដឹង ពីប្រព័ន្ធ និងដំណើរការរបស់ធនាគារផងដែរ។

## ផែនការ សម្រាប់ឆ្នាំ២០២៥

ក្នុងឆ្នាំ២០២៥ នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល នឹងផ្តោតចម្បង លើការពង្រឹងសមត្ថភាព ផ្នែកលក់ ពង្រីកភាពជាដៃគូសហការ លើកកម្ពស់ការផ្តល់ជូនផលិតផលធនាគារ និងបង្កើនឱកាសអាជីវកម្មថ្មីៗ ដើម្បីសម្រេចបានកំណើន ប្រកបដោយចីរភាព។

### ចំណុចផ្តោតសំខាន់ៗ

- ពង្រឹងកំណើនឥណទាន
- ពង្រឹងភាពជាដៃគូសហការអាជីវកម្ម
- លើកកម្ពស់ការយល់ដឹងស្លាកសញ្ញា និងបទពិសោធន៍បម្រើសេវាកម្មអតិថិជន
- ពង្រីកផលិតផលប័ណ្ណឥណទាន និងអាជីវកម្មបើងកាសូរេន
- លើកកម្ពស់ផលិតភាព នៅគ្រប់ផ្នែកលក់
- ចាប់យកចំណែកទីផ្សារថ្មីៗ

# សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ

**សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ ទទួលបន្ទុកលើការទំនាក់ទំនងរបស់ធនាគារ ជាមួយនឹងអតិថិជន ជាប្រភេទក្រុមហ៊ុន ដែលរួមមានក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនថ្នាក់តំបន់ និងគ្រឹះស្ថានហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនសាកល របស់ស៊ីអាយអិមប៊ី គ្រុប ដែលកំពុងដំណើរការអាជីវកម្ម ក្នុងប្រទេសកម្ពុជា។ វិសាលភាព នៃនាយកដ្ឋាននេះ គឺរួមមានការស្វែងរកចំណូល ពីប្រាក់កម្ចី សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ការគ្រប់គ្រងសាច់ប្រាក់ និងសេវាកម្មប្រតិបត្តិការ ព្រមទាំងភាពច្នៃប្រឌិតផលិតផលជាដើម។**

## សេចក្តីសង្ខេប ក្នុងឆ្នាំ២០២៤

ទោះបីជាបានជួបប្រទះនឹងបញ្ហាប្រឈមនានា និងកំណើនកម្រិតឥណទានមិនដំណើរការ ក្នុងឧស្សាហកម្មហិរញ្ញវត្ថុក៏ដោយ ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ដែលជាពិសេសសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៅតែបន្តរក្សាបានគុណភាពទ្រព្យសកម្មល្អប្រសើរ ដោយសម្រេចបានសមិទ្ធផលគួរជាទីគាប់ចិត្ត ក្នុងឆ្នាំ២០២៤។

កិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិ នៃកម្ពុជា ក្នុងការដាក់ឱ្យអនុវត្តបទប្បញ្ញត្តិច្បាប់ដ៏រឹងមាំ បានជួយរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យ ដែលបណ្តាលមកពីកម្រិតឥណទានមិនដំណើរការខ្ពស់។ បទប្បញ្ញត្តិច្បាប់ទាំងអស់នេះ បានផ្តល់ឱកាស ដល់ធនាគារនានា ក្នុងការបង្កើនការបញ្ចេញឥណទានរបស់ខ្លួន។ មិនតែប៉ុណ្ណោះ ភាពរីកចម្រើន នៃសេវាធនាគារឌីជីថល និងបច្ចេកវិទ្យាផ្នែកហិរញ្ញវត្ថុ បានលើកកម្ពស់សេវាកម្មធនាគារ ឱ្យកាន់តែសម្បូរបែប និងកាន់តែងាយស្រួលប្រើប្រាស់ សម្រាប់ប្រជាជនកាន់តែច្រើន។

## ទស្សនវិស័យ ក្នុងឆ្នាំ២០២៥

សេដ្ឋកិច្ចសាកលលោក បន្តឆ្លងកាត់បញ្ហាស្មុគស្មាញ នៃការងើបឡើងវិញ ក្រោយជំងឺរាតត្បាតកន្លងមក ខណៈដែលភាពរអាក់រអួល នៃខ្សែចង្វាក់ផ្គត់ផ្គង់ និងភាពតានតឹង ផ្នែកភូមិសាស្ត្រនយោបាយ នៅតែមានផលប៉ះពាល់ ដល់ថាមវន្តទីផ្សារ។ សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថាកើនឡើង ដែលជំរុញដោយការងើបឡើងវិញ នៃវិស័យទេសចរណ៍ ជាមួយនឹងកំណើនគួរឱ្យកត់សម្គាល់ នៃភ្ញៀវទេសចរ ក្នុងស្រុក។ គម្រោងហេដ្ឋារចនាសម្ព័ន្ធថ្មីៗ នឹងជួយគាំទ្រ ដល់កំណើនសេដ្ឋកិច្ចរយៈពេលវែង លើកកម្ពស់បណ្តាញភ្ជាប់ទំនាក់ទំនង និងទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត។ វិស័យវាយនភណ្ឌកាត់ដេរ និងមិនមែនកាត់ដេរ ត្រូវបានរំពឹងថាកើនឡើង។ ការបន្តលំហូរវិនិយោគ ពីបរទេស នឹងជួយគាំទ្រ ដល់វិស័យផ្សេងៗ រួមមានវិស័យវាយនភណ្ឌ ទេសចរណ៍ និងអចលនទ្រព្យជាដើម។

ធនាគារជាតិ នៃកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញ ដល់វិស័យធនាគារ និងលើកស្ទួយសេដ្ឋកិច្ចជាតិ។ វិស័យធនាគារ រក្សាបានភាពធន់ ក្នុងការសម្របនឹងបរិយាកាសសេដ្ឋកិច្ច ដែលមានការវិវឌ្ឍឥតឈប់ឈរ។

សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ បានប្តេជ្ញាចិត្ត ក្នុងការអនុវត្តយុទ្ធសាស្ត្រដ៏រឹងមាំ និងពង្រីកការផ្តល់កម្ចី ដល់វិស័យថ្មីៗ ព្រមទាំងវិនិយោគ លើផ្នែកធនាគារឌីជីថល ដើម្បីលើកកម្ពស់បទពិសោធន៍សេវាកម្មអតិថិជន និងប្រសិទ្ធភាពប្រតិបត្តិការ។ មិនតែប៉ុណ្ណោះ យើងនឹងបន្តស្វែងរកឱកាសថ្មីៗ លើការផ្តល់ហិរញ្ញប្បទានបៃតង ដើម្បីជួយគាំទ្រ ដល់គម្រោងអភិវឌ្ឍន៍នានាប្រកបដោយចីរភាព។ យើងនឹងផ្តោតសំខាន់ លើការលើកកម្ពស់បទពិសោធន៍សេវាកម្មអតិថិជន និងកម្មវិធីភ្ជាប់ទំនាក់ទំនង តាមប្រព័ន្ធឌីជីថល ដែលធានាពង្រឹងនូវវិធានការសន្តិសុខ តាមប្រព័ន្ធអ៊ីនធើណេត។ ការបន្តការធ្វើបច្ចុប្បន្នភាព ស្របតាមការវិវឌ្ឍ នៃបទប្បញ្ញត្តិច្បាប់ និងការធានានូវការអនុលោមតាមសេចក្តីណែនាំរបស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារអន្តរជាតិ នឹងនៅតែជារបៀបវារៈសំខាន់។

# រតនាភិបាល និងទីផ្សារ

**នាយកដ្ឋានរតនាភិបាល និងទីផ្សារ នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដោយមានកិច្ចសហការ ជាមួយនឹងអង្គភាពអាជីវកម្មផ្សេងទៀត តែងតែផ្តល់នូវដំណោះស្រាយសេវាកម្មចម្រុះបែប ដល់អតិថិជន ទាំងក្នុងប្រទេស និងថ្នាក់តំបន់ សម្រាប់តម្រូវការពាណិជ្ជកម្ម វិនិយោគ និងហិរញ្ញវត្ថុ។ សេវាកម្មទាំងអស់នេះ គឺរួមមានប្រតិបត្តិការទិញលក់រូបិយវត្ថុ-រូបិយប័ណ្ណ សម្រាប់ការទូទាត់ភ្លាមៗ និងការព្រមព្រៀងគ្នាទុកជាមុន ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស និងសេវាផ្ទេរប្រាក់ក្រៅប្រទេសជាដើម។ នាយកដ្ឋានរតនាភិបាល និងទីផ្សារ ក៏ទទួលបន្ទុក លើការចាត់ចែងគ្រប់គ្រងមូលនិធិរបស់ធនាគារ ដោយធានាឱ្យបាននូវកម្រិតសន្ទនីយភាពមួយ ដែលល្មមគ្រប់គ្រាន់ និងមានប្រសិទ្ធភាពលំហូរសាច់ប្រាក់ខ្ពស់ ដល់ធនាគារ ព្រមទាំងបង្កើតប្រភពផ្សេងៗគ្នា សម្រាប់មូលនិធិតាមរយៈការរក្សាទំនាក់ទំនង ជាមួយធនាគារដៃគូផ្សេងៗ នៅលើទីផ្សារ។**

## ការពិនិត្យមើលសមិទ្ធផល ក្នុងឆ្នាំ២០២៤

ក្នុងឆ្នាំ២០២៤ ទីផ្សារអន្តរធនាគារ ក្នុងប្រទេសកម្ពុជា បានប្រែប្រួល ពីការកើនឡើងតម្លៃមូលនិធិ ក្នុងឆ្នាំ២០២៣ មកកាន់ស្ថានភាព និងស្ថិរភាពល្អជាងមុន។ ការផ្លាស់ប្តូរនេះ គឺបណ្តាលមកពីស្ថិរភាពជាសាកល នៃអត្រាការប្រាក់ដុល្លារអាមេរិក និងការបន្តយកចិត្តទុកដាក់ក្នុងស្រុក អំពីហានិភ័យឥណទាន ស្របពេលការធ្លាក់ចុះសេដ្ឋកិច្ចជារួម។ ធនាគារទាំងអស់បានប្រឈមនឹងផលវិបាក ក្នុងការរក្សានូវប្រាក់ចំណេញប្រចាំឆ្នាំរបស់ខ្លួន ដោយសារកំណើនទ្រព្យសកម្មមានភាពយឺតជាងមុន និងបញ្ហាកើនឡើង លើការគ្រប់គ្រងគុណភាពទ្រព្យសកម្ម។ ជាមួយគ្នានេះ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការជំរុញប្រតិបត្តិការធនាគារប្រចាំថ្ងៃ និងចំណែកទីផ្សាររបស់ខ្លួន ដោយបន្តផ្តល់ផលិតផល និងសេវាកម្មធនាគារ ប្រកបដោយគុណតម្លៃខ្ពស់ ដល់អតិថិជន។ ក្នុងអំឡុងពេលដំណាក់កាលប្រឈមនេះ នាយកដ្ឋានរតនាភិបាល និងទីផ្សារ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការធានានូវស្ថិរភាពរបស់ធនាគារ និងបង្កើនប្រសិទ្ធភាព នៃតារាងតុល្យការរបស់ខ្លួន តាមរយៈទីផ្សារអន្តរធនាគារ។

ដើម្បីសម្រេចបានកិច្ចការងារទាំងអស់នេះ ក្រុមការងារ ផ្នែកគ្រប់គ្រងមូលនិធិ របស់នាយកដ្ឋានរតនាភិបាល និងទីផ្សារ បានខិតខំយ៉ាងស្វាហាប់ និងបង្កើតនូវកិច្ចសហការអាជីវកម្មថ្មីៗ ជាមួយនឹងដៃគូពាក់ព័ន្ធ ទាំងនៅក្នុងស្រុក និងអន្តរជាតិ។ ក្រុមការងាររបស់យើង បានបន្តពង្រីកបណ្តាញដៃគូបន្ថែម ដើម្បីធ្វើពិពិធកម្មប្រភពមូលនិធិ កាត់បន្ថយតម្លៃ និងពង្រីកការវិនិយោគ។ ក្រុមការងាររបស់យើង សម្រេចបានសមិទ្ធផលល្អប្រសើរ ដែលបានរួមចំណែកគួរឱ្យកត់សម្គាល់ ក្នុងការបន្តរក្សាបានប្រាក់ចំណេញប្រចាំឆ្នាំរបស់ធនាគារ ក្នុងឆ្នាំ២០២៤។ ទន្ទឹមជាមួយគ្នាផងដែរ នាយកដ្ឋានរតនាភិបាល និងទីផ្សារ ដោយមានកិច្ចសហការ ជាមួយនឹងនាយកដ្ឋានគ្រប់គ្រងហានិភ័យ បានបំពេញតាមការត្រូវ ដោយជោគជ័យ សម្រាប់ការពិនិត្យមើល និងការធ្វើតេស្តប្រចាំឆ្នាំ នៃផែនការមូលនិធិបម្រុងទុក។ ការធ្វើតេស្តនេះ ត្រូវបានបង្កើតឡើង ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង អំពីហានិភ័យសន្ទនីយភាព និងដើម្បីប្រមើលមើលទុកជាមុន ក៏ដូចជាការទប់ស្កាត់ ចំពោះបញ្ហាប្រឈម ផ្នែកមូលនិធិ ដែលអាចកើតមានឡើង។

សម្រាប់ផ្នែកអត្រាប្តូរប្រាក់បរទេស នាយកដ្ឋានរតនាភិបាល និងទីផ្សារ សម្រេចបានគោលដៅប្រាក់ចំណេញ និងចំណែកទីផ្សាររបស់ខ្លួន ដោយជោគជ័យ លើប្រតិបត្តិការទិញលក់រូបិយវត្ថុ-រូបិយប័ណ្ណក្នុងស្រុក និងបរទេស ក្នុងអំឡុងឆ្នាំ២០២៤ ដោយទទួលបាននូវកំណើនប្រចាំឆ្នាំ ក្នុងកម្រិតខ្ពស់ប្រហែល ៣០% ដូចទៅនឹងឆ្នាំ២០២៣ ផងដែរ។ ភាពរីកចម្រើនគួរឱ្យកត់សម្គាល់នេះ សម្រេចបានតាមរយៈកិច្ចសហការផ្ទៃក្នុងយ៉ាងរឹងមាំ ពីអង្គភាពអាជីវកម្មផ្សេងៗ បរិយាកាសប្រកួតប្រជែង លើការកំណត់តម្លៃ ដែលមានភាពទាក់ទាញ និងគុណតម្លៃបន្ថែម ដែលធនាគារ ស៊ីអាយអិមប៊ី បានផ្តល់ទៅដល់អតិថិជន និងដៃគូរបស់ខ្លួន។ បន្ថែមពីលើនេះ នាយកដ្ឋានរតនាភិបាល និងទីផ្សារ បានផ្តល់ជូននូវភាពខុសប្លែកពីគេ នៃសេវាកម្ម តាមរយៈបណ្តាញដ៏ទូលំទូលាយ និងកិត្តិសព្ទថ្នាក់តំបន់ របស់ស៊ីអាយអិមប៊ី គ្រុប។

## ទស្សនវិស័យ និងយុទ្ធសាស្ត្រ ក្នុងឆ្នាំ២០២៥

ទោះបីជាអាចមានការរឹតបន្តឹងគោលនយោបាយរូបិយប័ណ្ណ ពីនិយ័តករកម្ពុជា ដែលនឹងដាក់បន្ទុកកាន់តែខ្លាំង ដល់ប្រតិបត្តិការអាជីវកម្ម ក្នុងវិស័យធនាគារ រួមទាំងភាពមិនប្រាកដប្រជា នៃស្ថានភាពទីផ្សារហិរញ្ញវត្ថុ បញ្ហាអត្រាអតិផរណាខ្ពស់ជាសាកល និងការបន្តជម្លោះភូមិសាស្ត្រនយោបាយក៏ដោយ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា នៅតែបង្ហាញពីកំណើនដ៏រឹងមាំ។ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ បានព្យាករថា សេដ្ឋកិច្ចកម្ពុជា នឹងកើនឡើង ពីកម្រិត ៥,៥% ក្នុងឆ្នាំ២០២៤ ដល់កម្រិត ៥,៨% ក្នុងឆ្នាំ២០២៥ ខណៈដែលធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានព្យាករថា នឹងមានកំណើន រហូតដល់ ៦% ក្នុងឆ្នាំ២០២៥។

ជាមួយនឹងការព្យាករណ៍ ប្រកបដោយសុទិដ្ឋិនិយម និងវិធីសាស្ត្របែបរៀបចំត្រៀមទុកជាមុន របស់ធនាគារជាតិ នៃកម្ពុជា នាយកដ្ឋានរតនាភិបាល និងទីផ្សារ បានបន្តការប្តេជ្ញាចិត្តខ្ពស់ ក្នុងការពង្រឹងយុទ្ធសាស្ត្ររយៈពេលវែងរបស់ខ្លួន។ នាយកដ្ឋានរតនាភិបាល និងទីផ្សារ នឹងបន្តកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយនឹងអង្គភាពអាជីវកម្មដទៃទៀត ក្នុងការជូនផ្តល់នូវផលិតផល និងសេវាកម្មរតនាភិបាលដ៏ទាក់ទាញ ទៅដល់អតិថិជន ដែលមានស្រាប់ និងអតិថិជនថ្មីៗ។ ផែនការគន្លឹះ ដែលកំពុងបន្តផ្តោតការយកចិត្តទុកដាក់ គឺការពង្រីកការទូទាត់ប្រាក់ជារូបិយប័ណ្ណក្នុងស្រុក (ប្រាក់រៀល)។ ស្របពេលដែលទីផ្សារប្រាក់រៀល ក្នុងឆ្នាំ២០២៥ នឹងរំពឹងថា ហាក់ឡើងខ្ពស់ លើសពីកម្រិតប្រើប្រាស់ពីមុន នាយកដ្ឋានរតនាភិបាល និងទីផ្សារ នឹងបន្តខិតខំពង្រឹងតួនាទីរបស់ខ្លួន ក្នុងការធ្វើពិពិធកម្ម ទៅលើភាគីដៃគូ និងត្រៀមខ្លួនឱ្យបានគ្រប់គ្រាន់ សម្រាប់ការកើនឡើង លើតារាងតុល្យការ និងសេវាកម្មទូទាត់ជាប្រាក់រៀល នៅក្នុងធនាគារ ស្របតាមផែនការផ្តួចផ្តើមរយៈពេលវែង របស់ធនាគារជាតិ នៃកម្ពុជាផងដែរ។

សម្រាប់ផ្នែកគ្រប់គ្រងមូលនិធិ និងទីផ្សារអន្តរធនាគារ នាយកដ្ឋានរតនាភិបាល និងទីផ្សារ មានគោលដៅលើកកម្ពស់សមត្ថភាពការងាររបស់ខ្លួន ដោយពង្រីកបណ្តាញឱ្យកាន់តែទូលំទូលាយ ជាមួយនឹងធនាគារដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូផ្សេងទៀតផងដែរ។ កិច្ចខិតខំប្រឹងប្រែងនេះ នឹងគាំទ្របន្ថែមទៀត ដល់សមត្ថភាពបង្កើតប្រាក់ចំណេញរបស់ធនាគារ ព្រមទាំងធានានូវការគ្រប់គ្រងសន្ទនីយភាពដ៏រឹងមាំ។ មិនតែប៉ុណ្ណោះ នាយកដ្ឋានរតនាភិបាល និងទីផ្សារ នឹងត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ លើផែនការមូលនិធិបម្រុងទុករបស់ធនាគារ ដើម្បីធានានូវភាពបត់បែនខ្ពស់ ក្នុងការឆ្លើយតបនឹងហេតុការណ៍បន្ទាន់ចាំបាច់ណាមួយ ក៏ដូចជារក្សាភាពខ្លាំង នៃសន្ទនីយភាព ដើម្បីបំពេញតម្រូវការរបស់អតិថិជន ឱ្យបានពេញលេញ។

# ហិរញ្ញវត្ថុ

**នាយកដ្ឋានហិរញ្ញវត្ថុ មានតួនាទីរៀបចំ និងអនុវត្តគោលការណ៍ និងនីតិវិធីគណនេយ្យ ដើម្បីឱ្យស្របតាមគំរូស្តង់ដារគណនេយ្យកម្ពុជា និងបទប្បញ្ញត្តិ ដែលបានរៀបចំ ដោយធនាគារជាតិ នៃកម្ពុជា។ នាយកដ្ឋាននេះ ក៏ដើរតួនាទីគ្រប់គ្រងរបាយការណ៍ និងការវិភាគលទ្ធផលហិរញ្ញវត្ថុ ជូនគ្រប់អង្គភាពអាជីវកម្មផងដែរ។**

ក្នុងការរៀបចំគណនេយ្យហិរញ្ញវត្ថុ យើងធានាថា រាល់ដំណើរការ នៃការរៀបចំបញ្ជីគណនេយ្យ មានភាពសុក្រឹត តម្លាភាព និងមានការរក្សាទុកយ៉ាងត្រឹមត្រូវ។ យើងក៏ធានាការប្រតិបត្តិតាមបទប្បញ្ញត្តិគ្រប់ពេលផងដែរ នូវរាល់របាយការណ៍ ដែលតម្រូវ ស្របតាមបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃកម្ពុជា ក៏ដូចជាការប្រកាសពន្ធ ជូននាយកដ្ឋានពន្ធដារ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ យ៉ាងសុក្រឹត និងទាន់ពេលវេលា សម្រាប់គណៈគ្រប់គ្រង និងក្រុមហ៊ុនមេផងដែរ។

## សមិទ្ធផលសំខាន់ៗ សម្រាប់ឆ្នាំ ២០២៤

យើងបានពិនិត្យមើល និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងនីតិវិធីគណនេយ្យ ដើម្បីពង្រឹងដំណើរការគ្រប់គ្រង និងទិដ្ឋភាពអភិបាលកិច្ចជារួម ពីដើមដល់ចប់ នៃការកត់ត្រា ការដំណើរការ ការធ្វើឯកជ្ជាត់ និងការរៀបចំរបាយការណ៍ នៃការរួមបញ្ចូលគ្នា សម្រាប់សកម្មភាពចំណាយ (GL) និងគណនីរួម។

ក្រុមការងារអនុវត្តគម្រោង បានបញ្ចប់គម្រោង នៃការពិនិត្យតាមដានមូលដ្ឋាន សម្រាប់ការគណនា ECL ដោយមានការគាំទ្រ និងបណ្តុះបណ្តាល ដោយក្រុមការងារជំនាញ ពីនាយកដ្ឋានហិរញ្ញវត្ថុ របស់ស៊ីអាយអិមប៊ី គ្រុប។ ការបន្តពិនិត្យតាមដានមូលដ្ឋាន សម្រាប់ការគណនា ECL គឺជាផ្នែកមួយ នៃដំណើរការអភិបាលកិច្ច ដើម្បីធានាថា មូលដ្ឋាន នៃការគណនានេះ មានភាពត្រឹមត្រូវ និងនៅតែមានសុពលភាព សម្រាប់ការអនុវត្ត។ កិច្ចការនេះ ក៏បានជួយបង្កើននូវប្រសិទ្ធភាព និងប្រសិទ្ធផលការងារ លើប្រតិបត្តិការ នៃនាយកដ្ឋានហិរញ្ញវត្ថុផងដែរ។

ជាផ្នែកមួយ នៃការបង្កើនប្រសិទ្ធភាពដើមទុន យើងបានទូទាត់អនុបំណុលមួយ ចំនួន ១៥លានដុល្លារអាមេរិក ក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ និងទទួលបានការអនុម័ត ដើម្បីបន្តអនុបំណុលពីរផ្សេងទៀត ចំនួន ១៥លានដុល្លារអាមេរិក និង ១០លានដុល្លារអាមេរិក ក្នុងត្រីមាសទីមួយ នៃឆ្នាំ២០២៥។

យើងបានធ្វើការសាកល្បង ដោយជោគជ័យ ក្នុងដំណើរការអនុវត្ត នៃការរៀបចំរបាយការណ៍ថ្មី សម្រាប់សេចក្តីប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ចាប់ពីខែមិថុនា ឆ្នាំ២០២៣ ដល់ខែធ្នូ ឆ្នាំ២០២៤ អំពីដើមទុនបទប្បញ្ញត្តិ ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យតណាទាន ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យទីផ្សារ ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យប្រតិបត្តិការ និងអនុបាតភាពគ្រប់គ្រាន់ នៃដើមទុន។ ការដាក់ប្រគល់ជូនរបាយការណ៍ផ្លូវការ នឹងប្រព្រឹត្តទៅ ចាប់ពីខែមករា ឆ្នាំ២០២៥។

## ផែនការ សម្រាប់ឆ្នាំ២០២៥

ការធ្វើឱ្យប្រសើរឡើង លើប្រព័ន្ធប្រតិបត្តិការផ្ទៃក្នុង និងការរៀបចំរបាយការណ៍ នឹងបន្តផ្តោត សម្រាប់ឆ្នាំ២០២៥ ដែលរួមមានស្វ័យប្រវត្តិភាព នៃរបាយការណ៍ផ្សេងៗ ដោយផ្នែកលើការធ្វើបច្ចុប្បន្នភាពថ្មី នៃទម្រង់របាយការណ៍ ពីនិយតករ ស្វ័យប្រវត្តិភាព នៃរបាយការណ៍បែងចែកតណាទាន តាមប្រភេទអាជីវកម្ម និងសកម្មភាពសេដ្ឋកិច្ច ព្រមទាំងការធ្វើឱ្យប្រសើរឡើង នៃប្រព័ន្ធបច្ចេកវិទ្យា លើកម្មវិធី GFMS។ ក្រុមការងាររបស់យើង នឹងបន្តធ្វើការ ជាមួយនឹងក្រុមការងារ ផ្នែកបច្ចេកវិទ្យាព័ត៌មាន និងក្រុមការងារជំនាញរបស់ក្រុមហ៊ុនមេ សម្រាប់គម្រោងទាំងនេះ ដែលជាផ្នែកមួយ នៃការបង្កើនផលិតភាពការងារ ការពន្លឿនពេលវេលាបិទបញ្ជីចុងខែ និងការថែរក្សាមូលដ្ឋានទិន្នន័យ ឱ្យកាន់តែប្រសើរឡើង។

ក្របខណ្ឌ នៃផល លើមូលធន ក្រោយថ្លឹងហានិភ័យ (RAROC) នឹងត្រូវបានអនុម័ត និងអនុវត្ត ក្នុងឆ្នាំ២០២៥ ដើម្បីជាមធ្យោបាយមួយ សម្រាប់ការវាស់វែងផលចំណេញ នៃអាជីវកម្មមួយ ដោយវាយតម្លៃលើហានិភ័យ និងការប្រើប្រាស់ដើមទុន។ មធ្យោបាយនេះ នឹងផ្តល់នូវទិដ្ឋភាពដូចគ្នា នៃផលចំណេញ ពីគ្រប់អង្គភាពអាជីវកម្ម ហើយផ្តល់នូវការប្រៀបធៀបកាន់តែល្អប្រសើរ នៃសមិទ្ធផលការងារ អាស្រ័យលើហានិភ័យ នៃអាជីវកម្មផ្សេងៗគ្នា។ RAROC នឹងផ្តល់នូវទិដ្ឋភាពរួមគ្នា ដែលភ្ជាប់គ្នា រវាងការរៀបចំផែនការយុទ្ធសាស្ត្រ ទៅនឹងការគ្រប់គ្រងហានិភ័យ និងដើមទុន ព្រមទាំងការបង្កើនប្រសិទ្ធភាពផល នៃដើមទុនធនាគារ ធៀបនឹងហានិភ័យ។

ការគ្រប់គ្រងដើមទុន នឹងនៅតែជាចំណុចផ្តោតសំខាន់ ក្នុងឆ្នាំ២០២៤ ខណៈដែលធនាគារជាតិ នៃកម្ពុជា បានដាក់ចេញនូវសេចក្តីប្រកាសថ្មី អំពីដើមទុនបទប្បញ្ញត្តិទ្រព្យសកម្មក្រោយថ្លឹងហានិភ័យតណាទាន ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យទីផ្សារ ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យប្រតិបត្តិការ សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ យើងនឹងបន្តត្រួតពិនិត្យដើមទុន ទាំងថ្នាក់ទី១ និងថ្នាក់ទី២ ដើម្បីអនុលោមតាមដើមទុនបទប្បញ្ញត្តិអប្បបរមារបស់ធនាគារ ក៏ដូចជាការប្រើប្រាស់ឱ្យអស់លទ្ធភាព នៃដើមទុនបទប្បញ្ញត្តិ ដើម្បីគាំទ្រកំណើនអាជីវកម្មស្នូលរបស់ធនាគារ ក្នុងឆ្នាំ២០២៥-២០២៧។

# ធនធានសាជីវកម្ម

**នាយកដ្ឋានធនធានសាជីវកម្ម ទទួលបន្ទុក ផ្នែកធនធានមនុស្ស រដ្ឋបាល និងការគ្រប់គ្រងទ្រព្យសម្បត្តិ ព្រមទាំងដំណើរការយុទ្ធសាស្ត្រលទ្ធកម្ម។ តួនាទីសំខាន់របស់ផ្នែកធនធានមនុស្ស គឺរួមមានការជ្រើសរើសបុគ្គលិកសក្តានុពល / ការអភិវឌ្ឍស្ថាប័ន និងការធ្វើផែនការបុគ្គលិករបស់អង្គភាព / ការគិតគូរ ពីប្រាក់រង្វាន់ និងការគ្រប់គ្រងការអនុវត្តការងារ / ការសិក្សា និងការអភិវឌ្ឍទេពកោសល្យ / ការរួមបញ្ចូលវប្បធម៌ការងារ / ការកសាងកិត្តិនាមស្ថាប័ន / កម្មវិធីទំនួលខុសត្រូវសង្គម និងការចូលរួមរបស់បុគ្គលិក ក្នុងស្ថាប័ន។ ផ្នែករដ្ឋបាល និងគ្រប់គ្រងទ្រព្យសម្បត្តិ ព្រមទាំងដំណើរការលទ្ធកម្មយុទ្ធសាស្ត្រ ចាត់ចែងការងាររដ្ឋបាលទូទៅ ការរៀបចំគម្រោង និងការថែរក្សាទ្រព្យសម្បត្តិក្រុមហ៊ុន រួមទាំងដំណើរការលទ្ធកម្ម / ដេញថ្លៃ និងសន្តិសុខ។**

## ការអភិវឌ្ឍធនធានមនុស្ស និងទេពកោសល្យ

**“ យើងពេញចិត្ត ជាមួយការអភិវឌ្ឍទេពកោសល្យ ហើយយើងផ្តល់តម្លៃ ដល់បុគ្គលិកគ្រប់រូប ដែលរួមចំណែកជួយគាំទ្រធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី រហូតដល់មានថ្ងៃនេះ។ ”**

## ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺទីកន្លែង

### បណ្តុះទេពកោសល្យ

ក្នុងនាមជាស្ថាប័នមួយ ដែលមានភាពរីកចម្រើន តាមរយៈធនធានមនុស្ស ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ត្រូវបានទទួលស្គាល់ថាជាទីកន្លែងដ៏ល្អមួយ ដែលបណ្តុះទេពកោសល្យ។ យើងតែងតែខិតខំទាក់ទាញ រក្សា និងបណ្តុះសមត្ថភាពនិយោជិតរបស់យើង ដើម្បីឱ្យពួកគេបានត្រៀមខ្លួនរួចជាស្រេច សម្រាប់អនាគត។ ជាការពិតណាស់ យើងក៏ផ្តល់ឱ្យពួកគេ នូវឱកាសនៅខាងក្នុង ឬឆ្លងនាយកដ្ឋាន ទាំងនៅក្នុងស្រុក និងថ្នាក់តំបន់ផងដែរ។ យើងផ្តល់ឱកាស ដល់និយោជិត ក្នុងការបង្ហាញសមត្ថភាព ទៅតាមក្របខណ្ឌ និងយន្តការ ដែលមានប្រសិទ្ធភាពផ្សេងៗ ដើម្បីធានាដល់ការបង្កើនចំណេះដឹង ការបន្ថែមគុណតម្លៃ ភាពច្នៃប្រឌិត និងការចែករំលែក នៃការអនុវត្តការងារល្អៗរបស់ពួកគេ។ ចំនួនម៉ោងសិក្សាសរុប ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ដែលជារង្វាស់ នៃការវិនិយោគ លើធនធានមនុស្សរបស់យើង បានកើនដល់ ១៨.៥០០ម៉ោង ក្នុងមួយឆ្នាំ ដែលស្មើនឹង ៣៨ម៉ោងសិក្សា ក្នុងបុគ្គលិកម្នាក់។ លទ្ធផល ដែលបានមកពីកិច្ចខិតខំរបស់យើងនេះ បានជំរុញដល់ការកើនឡើងសមត្ថភាពការងាររបស់និយោជិត ដែលបានកសាង និងពង្រីកចំណុចខ្លាំងខ្ពស់បំផុតរបស់យើង ដើម្បីទាំយកគុណប្រយោជន៍ល្អបំផុត ក្នុងការរក្សាភាពរឹងមាំរបស់ធនាគារ សម្រាប់ការប្រកួតប្រជែងដ៏យូរអង្វែង នៅក្នុងទីផ្សារ។

### ភ្ជាប់ទំនាក់ទំនងនិយោជិត

យើងខិតខំបំពេញការងារ ដើម្បីធានាថា ការភ្ជាប់ទំនាក់ទំនងនិយោជិត និងការបំពេញការងារជាក្រុម គឺស្ថិតក្នុងកម្រិតខ្ពស់បំផុតមួយ ដែលត្រូវបានបណ្តុះ តាមរយៈការរៀបចំកម្មវិធីសំខាន់ៗ ដូចជាវគ្គបណ្តុះបណ្តាលចែករំលែកយុទ្ធសាស្ត្រភាពជាអ្នកដឹកនាំ កិច្ចប្រជុំបង្ហាញលទ្ធផលការងារប្រចាំឆ្នាំ (Town Hall) កម្មវិធីជួបជុំជាមួយបុគ្គលិកថ្ងៃអង្គារ កម្មវិធីកសាងភាពជាក្រុមការងារ និងកម្មវិធីជួបជុំបុគ្គលិកទូទាំងធនាគារជាដើម។ ជារៀងរាល់ឆ្នាំ យើងក៏បានរៀបចំកម្មវិធីស្វង់មតិការបំពេញការងារផ្ទៃក្នុង ដើម្បីអនុញ្ញាតឱ្យបុគ្គលិករបស់យើង ចែករំលែកសំឡេងរបស់ពួកគេ ដោយជំរុញឱ្យស្ថាប័នទាំងមូល កាន់តែប្រសើរមួយកម្រិតទៀត។ យើងបណ្តុះផ្តត់គំនិត នៃវប្បធម៌បើកចំហរ ដើម្បីនាំយកភាពរីកចម្រើន និងភាពប្រសើរឡើង ក្នុងស្ថាប័នការងារ។ យើងជឿជាក់ថា និយោជិត ដែលមានការភ្ជាប់ទំនាក់ទំនងល្អ គឺជាបុគ្គលិក ដែលប្រកបដោយជំនឿមជឿដែរ។

### មានសមាមាត្រគ្នា រវាងលទ្ធផលការងារ និងប្រាក់រង្វាន់

យើងមានប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារដ៏រឹងមាំ ដែលកំណត់ដោយសូចនាករអនុវត្តន៍ការងារ (KPI)។ យើងធានាថា សូចនាករអនុវត្តន៍ការងារ គឺស្របទៅតាមគោលដៅអាជីវកម្ម និងទិសដៅរបស់ស៊ីអាយអិមប៊ី គ្រប។ សូចនាករអនុវត្តន៍ការងារ តម្រូវឱ្យមានសមាសធាតុប្រតិបត្តិតាម (Compliance) និងអភិបាលកិច្ច (Governance) ដែលផ្សារភ្ជាប់ភាពសមាមាត្រគ្នា រវាងលទ្ធផលការងារ និងប្រាក់រង្វាន់។ ក្រៅពីសូចនាករអនុវត្តន៍ការងារ យើងលើកកម្ពស់វប្បធម៌ នៃការបន្តសម្រេចសមិទ្ធផល នៅក្នុងស្ថាប័ន ដើម្បីធានាថា និយោជិតរបស់យើង គឺស្ថិតក្នុងលក្ខខណ្ឌល្អប្រសើរ និងអាចទទួលបានការលើកទឹកចិត្តទៀងទាត់ ដែលជួយឱ្យពួកគេអាចសម្រេចបានលទ្ធផលការងារកាន់តែល្អប្រសើរ។

### ផ្តោតអាទិភាព លើការជួយត្រឡប់ ដល់សង្គម

អាទិភាពចម្បង នៃកម្មវិធីទំនួលខុសត្រូវសង្គមរបស់យើង គឺរួមមានវិស័យអប់រំ សុខាភិបាល បរិស្ថាន និងអភិវឌ្ឍន៍សង្គម។ និយោជិតរបស់យើង មានឱកាសទាំងជាលក្ខណៈស្ថាប័ន និងបុគ្គល ក្នុងការរួមចំណែកជួយដល់សហគមន៍ ដែលយើងកំពុងប្រកបអាជីវកម្ម។ ការជួយត្រឡប់ ដល់សង្គមនេះ មិនត្រឹមតែជាអាទិភាពចម្បងរបស់យើងប៉ុណ្ណោះទេ តែវាថែមទាំងបានក្លាយជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នាផងដែរ ដើម្បីឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តដ៏រឹងមាំរបស់យើង ក្នុងនាមជាស្ថាប័នគំរូមួយ ក៏ដូចជាការបណ្តុះក្តីស្រឡាញ់ និងផ្តត់គំនិត នៃការផ្តល់ឱ្យ ក្នុងចំណោមនិយោជិតរបស់យើង។

### លើកកម្ពស់វប្បធម៌ របស់ធនាគារ ស៊ីអាយអិមប៊ី

ក្នុងនាមជាស្ថាប័នមួយ ដែលឆ្ពោះទៅមុខ តាមចក្ខុវិស័យ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចាក់គ្រឹះវប្បធម៌ការងារ EPICC ដែលផ្តោតលើគុណតម្លៃស្នូលទាំង៥ រួមមានការបណ្តុះបណ្តាល និងគាំទ្របុគ្គលិកសក្តានុពល ការមានឆន្ទៈខ្ពស់ សុចរិតភាព និងការទទួលខុសត្រូវ កិច្ចសហប្រតិបត្តិការ និងការផ្តោត លើអតិថិជនជាសំខាន់។ គោលការណ៍ណែនាំនេះ ត្រូវប្រកាន់ខ្ជាប់ នៅគ្រប់សកម្មភាព ដែលយើងប្រព្រឹត្ត ដែលរួមបញ្ចូលទាំងការលើកកម្ពស់ទេពកោសល្យរបស់យើង ដើម្បីបង្កើតសមិទ្ធផល ដល់ស្ថាប័ន ការបណ្តុះផ្តត់គំនិត ដើម្បីសម្រេចបានភាពល្អប្រសើរការបំពេញការងារឱ្យបានត្រឹមត្រូវ ទោះបីគ្មានអ្នកណាកំពុងពិនិត្យមើលយើងក៏ដោយ ព្រមទាំងការប្រឹងប្រែង ដើម្បីសម្រេចជោគជ័យរួម ស្របពេលដែលយើងខិតខំអស់ពីសមត្ថភាព ក្នុងការផ្តល់ជូនបទពិសោធន៍បម្រើសេវាកម្មដ៏ល្អប្រសើរ។

# បច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ

**នាយកដ្ឋានបច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ គឺជាអង្គភាពស្នូលដ៏សំខាន់ នៃដំណើរការផ្លាស់ប្តូររបស់ធនាគារ ដើម្បីលើកកម្ពស់ប្រព័ន្ធឌីជីថល នៅក្នុងស្ថាប័ន។ នាយកដ្ឋានបច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ ជួយដល់ផ្នែកអាជីវកម្ម ក្នុងការបង្កើត និងនាំយកបទពិសោធន៍ហិរញ្ញវត្ថុដ៏វិឆ្លាត ងាយស្រួល និងរលូន ដែលអាចបំពេញតាមតម្រូវការរបស់អតិថិជនយ៉ាងពិតប្រាកដ។ នាយកដ្ឋាននេះ អនុវត្តវិធីសាស្ត្ររហ័សរហួន នៃការបំពេញការងារ និងបំពាក់បំប៉នក្រុមការងារ ជាមួយនឹងជំនាញ ផ្នែកឌីជីថល ដើម្បីធានានូវការផ្តល់ជូនបទពិសោធន៍ថ្មី បានលឿនជាងមុន ទៅកាន់ទីផ្សារ ដោយរក្សាបាននូវគុណភាព និងសុវត្ថិភាពខ្ពស់ទៀតផង។ ជាមួយគ្នានេះ មុខងារបច្ចេកវិទ្យា និងទិន្នន័យរបស់នាយកដ្ឋាននេះ នឹងធានាថា ធនាគារមានហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប្រកបដោយសមាមាត្រ និងស្ថិរភាពល្អ ហើយទិន្នន័យ ត្រូវបានរៀបចំទុករួចរាល់ សម្រាប់ជាព័ត៌មានជំនួយនៃការយល់ដឹង ផ្នែកអាជីវកម្មផងដែរ។**

ក្នុងឆ្នាំ២០២៤ នាយកដ្ឋានបច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ សម្រេចបានគម្រោងយុទ្ធសាស្ត្រចម្បង។ រួមមាន -គម្រោងទី១៖ ការដាក់ឱ្យប្រើប្រាស់កម្មវិធីធនាគារចល័ត CIMB Mobile ជំនាន់ទី២ -គម្រោងទី២៖ ការដាក់ឱ្យប្រើប្រាស់កម្មវិធីទូទាត់ និងប្រមូលប្រាក់ តាមរយៈ KHQR -គម្រោងទី៣៖ ការស្នើសុំប្រើប្រាស់សេវាកម្មធនាគារផ្សេង។ ពីកម្មវិធីធនាគារចល័ត CIMB Mobile តាមរយៈទម្រង់បែបបទអេឡិកត្រូនិក -គម្រោងទី៤៖ ការធ្វើបច្ចុប្បន្នភាព លើប្រព័ន្ធបច្ចេកវិទ្យា នៃការគ្រប់គ្រងដំណើរការបណ្តាញ (NAC) -គម្រោងទី៥៖ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន -គម្រោងទី៦៖ ការកែលម្អប្រព័ន្ធធនាគារស្នូល -គម្រោងទី៧៖ ការបង្កើតផ្ទាំងគ្រប់គ្រង នៃរបាយការណ៍ដោយស្វយ័ប សម្រាប់ជំនួយដល់ថ្នាក់ដឹកនាំ ក្នុងការសម្រេចចិត្តលើអាជីវកម្ម ពន្លឿនការរាយការណ៍ទាន់ពេលវេលា និងពង្រឹងគុណភាពទិន្នន័យ នៅគ្រប់ដំណើរការ និង -គម្រោងទី៨៖ ការបង្កើត និងលើកកម្ពស់ប្រព័ន្ធ MIS ដើម្បីកាត់បន្ថយការងារ ដែលប្រតិបត្តិការដោយដៃ គាំទ្រដល់ភាពរីកចម្រើន នៃអាជីវកម្ម និងអនុលោមតាមនិយ័តករ និងបទប្បញ្ញត្តិច្បាប់។

## គម្រោងយុទ្ធសាស្ត្រ ដែលសម្រេចបាន ផ្នែកបច្ចេកវិទ្យាព័ត៌មាន ក្នុងឆ្នាំ២០២៤

- ការដាក់ឱ្យប្រើប្រាស់ កម្មវិធីធនាគារចល័ត CIMB Mobile ជំនាន់ទី២
- ការដាក់ឱ្យប្រើប្រាស់ កម្មវិធីទូទាត់ និងប្រមូលប្រាក់ តាមរយៈ KHQR
- ការស្នើសុំប្រើប្រាស់សេវាកម្មធនាគារផ្សេង។ ពីកម្មវិធីធនាគារចល័ត CIMB Mobile តាមរយៈទម្រង់បែបបទអេឡិកត្រូនិក
- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យាព័ត៌មាន
- ការធ្វើបច្ចុប្បន្នភាព លើប្រព័ន្ធ បច្ចេកវិទ្យា នៃការគ្រប់គ្រង ដំណើរការបណ្តាញ (NAC)
- ការបង្កើតផ្ទាំងគ្រប់គ្រង នៃរបាយការណ៍ដោយស្វយ័ប
- ការបង្កើត និងលើកកម្ពស់ ប្រព័ន្ធ MIS
- ការកែលម្អ ប្រព័ន្ធធនាគារស្នូល

ក្នុងឆ្នាំ២០២៥ នាយកដ្ឋានបច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ នឹងផ្តោតលើគម្រោងឌីជីថលថ្មីៗ សម្រាប់គ្រប់អង្គភាពអាជីវកម្ម ជាពិសេសសម្រាប់សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម / ប្រតិបត្តិការ និងសហគ្រាសធុនតូច និងមធ្យម។ មិនតែប៉ុណ្ណោះ នាយកដ្ឋានបច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ នឹងបន្តកែលម្អប្រព័ន្ធដំណើរការ ដោយស្វ័យប្រវត្តិ ដើម្បីកាត់បន្ថយការងារ ដែលប្រតិបត្តិការដោយដៃ និងកំហុសផ្សេងៗ និងធ្វើបច្ចុប្បន្នភាព លើប្រព័ន្ធបច្ចេកវិទ្យា ដែលហួសសម័យទាំងអស់ ព្រមទាំងបន្តពង្រឹងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសុវត្ថិភាពផងដែរ។

## គម្រោងផ្តោតសំខាន់ ក្នុងឆ្នាំ២០២៥

- គម្រោងឌីជីថលថ្មីៗ សម្រាប់គ្រប់អង្គភាពអាជីវកម្ម
- ប្រព័ន្ធដំណើរការ ដោយស្វ័យប្រវត្តិ
- ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យាព័ត៌មាន
- បច្ចុប្បន្នភាព លើប្រព័ន្ធបច្ចេកវិទ្យា ដែលហួសសម័យទាំងអស់
- ប្រព័ន្ធសុវត្ថិភាព

# ប្រតិបត្តិការ

**នាយកដ្ឋានប្រតិបត្តិការ ប្រតិបត្តិការងារទូទាំងធនាគារ ដោយបំពេញមុខងារគាំទ្រ ដើម្បីធានាថា រាល់ប្រតិបត្តិការប្រចាំថ្ងៃរបស់អតិថិជន ត្រូវបានប្រព្រឹត្តទៅតាមលក្ខខណ្ឌត្រឹមត្រូវ និងទាន់ពេលវេលា។ តួនាទីចម្បងរបស់នាយកដ្ឋានប្រតិបត្តិការ គឺរួមមានប្រតិបត្តិការផ្ទេរប្រាក់ ក្នុងប្រទេស និងក្រៅប្រទេស ហិរញ្ញប្បទានពាណិជ្ជកម្ម ការទូទាត់មូលប្បទានបត្រ ការគ្រប់គ្រងម៉ាស៊ីនប្រតិបត្តិការស្វ័យប្រវត្តិ ការគ្រប់គ្រងសាច់ប្រាក់របស់ធនាគារទាំងមូល សេវាធនាគារតាមប្រព័ន្ធអ៊ីនធើណេត កម្មវិធីធនាគារតាមទូរសព្ទដៃ និងសេវាកម្មបើកប្រាក់បៀវត្ស ប្រតិបត្តិការរតនាគារ ការបញ្ចេញ ឬបង់ផ្គាច់ឥណទាន និងការរក្សាទុកឯកសារសុវត្ថិភាព ព្រមទាំងប្រតិបត្តិការទូទាត់ប្រាក់ តាមប្រព័ន្ធបាគង និងសេវាកម្មដទៃទៀត។**

ក្នុងឆ្នាំ២០២៤ ក្រៅពីគាំទ្រអង្គភាពអាជីវកម្ម និងអង្គភាពគាំទ្រអាជីវកម្មផ្សេងៗទៀតរបស់ធនាគារ នាយកដ្ឋានប្រតិបត្តិការ សម្រេចបានគម្រោងការងារចំនួន ២០ និងឈ្នះពានរង្វាន់ចំនួន ១ ដូចខាងក្រោម៖

- ១៧គម្រោង ទៅលើការកែលម្អដំណើរការផ្ទៃក្នុង និងពេលវេលាប្រតិបត្តិការ ការបង្កើនផលិតភាពបុគ្គលិក ការទប់ស្កាត់ហានិភ័យ និងអនុលោមតាមបទប្បញ្ញត្តិច្បាប់
- ៣គម្រោង ទៅលើការកាត់បន្ថយការព្រីនក្រដាស ស្របតាមផែនការចីរភាពរបស់ធនាគារ
- ការឈ្នះពានរង្វាន់ចំនួន១ គឺពានរង្វាន់ «ប្រតិបត្តិការទូទាត់ប្រាក់ឆ្នើម ឆ្នាំ២០២៣» ពីស្ថាប័ន BNY Mellon

## តួនាទីចម្បងរបស់នាយកដ្ឋានប្រតិបត្តិការ

- ប្រតិបត្តិការផ្ទេរប្រាក់ ក្នុងប្រទេស និងក្រៅប្រទេស
- ហិរញ្ញប្បទានពាណិជ្ជកម្ម
- ការទូទាត់មូលប្បទានបត្រ
- ការគ្រប់គ្រងម៉ាស៊ីន ប្រតិបត្តិការស្វ័យប្រវត្តិ
- ការគ្រប់គ្រងសាច់ប្រាក់ របស់ធនាគារទាំងមូល
- សេវាធនាគារ តាមប្រព័ន្ធអ៊ីនធើណេត
- កម្មវិធីធនាគារ តាមទូរសព្ទដៃ និងសេវាកម្មបើកប្រាក់បៀវត្ស
- ការបញ្ចេញ ឬបង់ផ្គាច់ឥណទាន និងការរក្សាទុកឯកសារសុវត្ថិភាព
- ប្រតិបត្តិការរតនាគារ
- ប្រតិបត្តិការទូទាត់ប្រាក់ តាម ប្រព័ន្ធបាគង និងសេវាកម្មដទៃទៀត

ក្នុងឆ្នាំ២០២៥ នាយកដ្ឋានប្រតិបត្តិការ នឹងបន្តយកចិត្តទុកដាក់ លើផែនការ ដែលបានដាក់ចេញ កាលពីឆ្នាំ២០២៤ និងរក្សារការផ្តោតសំខាន់ ទៅលើការកែសម្រួលប្រព័ន្ធ និងដំណើរការ ពង្រឹងហានិភ័យប្រតិបត្តិការ និងអភិវឌ្ឍសមត្ថភាពបុគ្គលិក តាមរយៈកម្មវិធីបណ្តុះបណ្តាលជំនាញផ្ទាល់ខ្លួន និងជំនាញអនុវត្តន៍ការងារ។ ក្រៅពីនេះ យើងនឹងទទួលយកមុខងារមួយចំនួន ពីការិយាល័យគាំទ្រសាខាធនាគារ ដោយធ្វើវិមជ្ឈការ នៅនាយកដ្ឋានប្រតិបត្តិការ ស្របតាមយុទ្ធសាស្ត្ររបស់ធនាគារ។

## គម្រោងផ្តោតសំខាន់ ក្នុងឆ្នាំ២០២៥

- កែសម្រួលប្រព័ន្ធ និងដំណើរការ
- ពង្រឹងហានិភ័យប្រតិបត្តិការ
- អភិវឌ្ឍសមត្ថភាពបុគ្គលិក
- ទទួលយកមុខងារមួយចំនួន ពីការិយាល័យគាំទ្រសាខាធនាគារ

# ទីផ្សារ និងទំនាក់ទំនង

**នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង ដើរតួនាទីយ៉ាងសំខាន់ ក្នុងការគាំទ្រកម្មវិធីទំនាក់ទំនងរបស់ធនាគារ ដើម្បីលើកកម្ពស់សាវតារ និងស្លាកសញ្ញា របស់ធនាគារ ស៊ីអាយអិមប៊ី នៅក្នុងប្រទេសកម្ពុជា។ នាយកដ្ឋាននេះ ត្រួតពិនិត្យ លើការទំនាក់ទំនងផ្ទៃក្នុង និងសកម្មភាពទំនាក់ទំនងខាងក្រៅ ដើម្បីជំរុញការលក់ផលិតផល និងសេវាកម្មរបស់ធនាគារ។ នាយកដ្ឋាននេះ អភិវឌ្ឍ និងលើកកម្ពស់ការកំណត់ទិសដៅស្លាកសញ្ញាធនាគារ និងរបៀបវារៈទំនាក់ទំនង តាមរយៈក្របខណ្ឌចម្រុះមួយ ដែលមានមុខងារផ្សេងៗគ្នា ដូចជាការផ្សព្វផ្សាយពាណិជ្ជកម្ម និងទីផ្សារ/ទំនាក់ទំនងសាធារណៈ និងសារព័ត៌មាន/ការគ្រប់គ្រងការឧបត្ថម្ភ និងការរៀបចំកម្មវិធីទីផ្សារ ព្រមទាំងការគ្រប់គ្រងទំនាក់ទំនងផ្ទៃក្នុង។**

យើងបានកំណត់ទិសដៅយ៉ាងជាក់លាក់ របស់ធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសកម្ពុជា ក្នុងនាមជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុ និងជាដៃគូពាណិជ្ជកម្ម ដែលមានមូលដ្ឋានគ្រឹះយ៉ាងរឹងមាំ នៅក្នុងស្រុក និងមានបណ្តាញដ៏ទូលំទូលាយ នៅទូទាំងតំបន់អាស៊ាន។ ក្រៅពីបង្កើតយុទ្ធសាស្ត្រ ក្នុងការចាក់គ្រឹះអត្តសញ្ញាណ នៅក្នុងស្រុករបស់ធនាគារ ស៊ីអាយអិមប៊ី យើងបានពឹងផ្អែកលើធនធាន ក្នុងតំបន់ របស់ស៊ីអាយអិមប៊ី គ្រុប និងភ្ជាប់សេវាកម្មថ្នាក់តំបន់ ដែលសមស្របបំផុត សម្រាប់អតិថិជន ក្នុងប្រទេសកម្ពុជា ដែលរួមមានសេវាកម្មបណ្តាញអេធីអឹម ក្នុងតំបន់អាស៊ាន សេវាផ្ទេរប្រាក់តេលេក្រាម ក្នុងថ្ងៃតែមួយ សម្រាប់ ៥ប្រទេស ក្នុងតំបន់អាស៊ាន ព្រមទាំងកម្មវិធី និងបុព្វសិទ្ធិពិសេសថ្នាក់តំបន់ សម្រាប់ការទិញទំនិញក្នុងហាង ការទទួលទានអាហារ និងដំណើរកម្សាន្តជាដើម។ មិនតែប៉ុណ្ណោះ យើងបានផ្សព្វផ្សាយលក្ខណៈស្លាកសញ្ញាថ្មី របស់ស៊ីអាយអិមប៊ី គ្រុប គឺ «រីកចម្រើនទៅមុខ ជាមួយអ្នក» ដែលត្រូវបានប្រើប្រាស់រួមគ្នា នៅគ្រប់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ស៊ីអាយអិមប៊ី គ្រុប ពីការប្តេជ្ញាចិត្តរបស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងការលើកកម្ពស់ភាពរីកចម្រើនរបស់អតិថិជន និងសង្គម ដោយជំរុញការបន្តគាំទ្ររបស់យើង ចំពោះភាគីពាក់ព័ន្ធទាំងអស់ ចំពោះការកសាងជីវិត និងជីវភាពរស់នៅរបស់ពួកគេ ឱ្យកាន់តែប្រសើរឡើង។

ឆ្នាំ២០២៥ នឹងក្លាយជាឆ្នាំដ៏គួរឱ្យកត់សម្គាល់មួយ សម្រាប់នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង។ ជាមួយនឹងមូលដ្ឋានគ្រឹះ និងកេរដំណែលដ៏រឹងមាំ នៃភាពជឿទុកចិត្ត និងភាពរីកចម្រើនរបស់ខ្លួន ធនាគារ ស៊ីអាយអិមប៊ី នឹងអបអរសាទរខួបគម្រប់១៥ឆ្នាំ នៃដំណើរការ និងការសម្រេចគោលដៅអាជីវកម្មរបស់ខ្លួន ក្នុងប្រទេសកម្ពុជា។ ជាមួយនឹងការឈ្នះពានរង្វាន់ «ទីកន្លែងការងារល្អបំផុត» ចំនួនពីរដង ដែលផ្តល់ដោយ HR Asia យើងនឹងលើកកម្ពស់ស្លាកសញ្ញា នៃទីកន្លែងការងាររបស់យើង ទៅដល់អ្នកដែលកំពុងស្វែងរកការងារដំបូង និងបុគ្គលិកជំនាញ ដែលមានបទពិសោធន៍ការងារ តាមរយៈការផ្សព្វផ្សាយអំពីគោលនយោបាយលើកកម្ពស់ធនធានមនុស្ស និងអត្ថប្រយោជន៍ ព្រមទាំងការគាំទ្រសុខុមាលភាពបុគ្គលិករបស់ធនាគារ។ តួនាទីស្នូលរបស់យើង គឺលើកកម្ពស់ស្លាកសញ្ញារបស់ធនាគារ ស៊ីអាយអិមប៊ី ជាមួយនឹងនិយមន័យថ្មី «រីកចម្រើនឈានមុខ ជាមួយអ្នក» តាមរយៈក្របខណ្ឌផ្សព្វផ្សាយ និងយុទ្ធនាការទីផ្សារផ្សេងៗគ្នា ក្នុងនាមជាធនាគារអន្តរជាតិ ដែលអាចជំរុញឱ្យបំណងប្រាថ្នា និងគោលដៅទាំងផ្ទាល់ខ្លួន និងអាជីវកម្មរបស់អតិថិជន ឈានទៅរកភាពជោគជ័យ។

អបអរសាទរខួបគម្រប់ ១៥ឆ្នាំ នៃដំណើរការ
និងការសម្រេចគោលដៅអាជីវកម្មរបស់ខ្លួន
ក្នុងប្រទេសកម្ពុជា

ប្រែក្លាយទៅជា
«ធនាគារក្នុងស្រុកថ្នាក់តំបន់»

ស្របតាមយុទ្ធសាស្ត្ររបស់ស៊ីអាយអិមប៊ី គ្រុប យើងនឹងបន្តរក្សា និងពង្រីកអត្តសញ្ញាណ និងកេរ្តិ៍ឈ្មោះ នៃស្លាកសញ្ញាធនាគារ ក្នុងនាមជា «ធនាគារ ដែលផ្តោតលើតំបន់អាស៊ាន» ព្រមទាំងប្រែក្លាយទៅជា «ធនាគារក្នុងស្រុកថ្នាក់តំបន់»។ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារបច្ចុប្បន្ន យើងនឹងបន្តជំរុញ និងផ្សព្វផ្សាយផលិតផល និងសេវាកម្មសំខាន់ៗ តាមរយៈយុទ្ធនាការទីផ្សារ ដែលពេញនិយម និងច្នៃប្រឌិតខ្ពស់។ មិនតែប៉ុណ្ណោះ យើងនឹងបន្តពង្រីកកម្មវិធីទំនាក់ទំនងសាធារណៈរបស់ធនាគារ ដោយភ្ជាប់ទំនាក់ទំនងកាន់តែទូលំទូលាយ ជាមួយនឹងស្ថាប័នសារព័ត៌មាននានា ទាំងបែបប្រពៃណី និងឌីជីថល។ យើងនឹងបន្តធ្វើឱ្យកាន់តែសកម្ម និងកាន់តែទាក់ទាញ នៅលើបណ្តាញទំនាក់ទំនងសង្គម ស្របតាមទំនោរថ្លាស់ប្តូររបស់អតិថិជន។ តាមរយៈចំណុចខ្លាំងរបស់ធនាគារ ក្នុងការកសាង និងអភិវឌ្ឍធនធានមនុស្ស យើងនឹងពង្រីកការផ្សព្វផ្សាយឱកាសការងាររបស់ធនាគារ ស៊ីអាយអិមប៊ី ព្រមទាំងបង្ហាញវត្តមានកាន់តែច្រើន និងខ្លាំងជាងមុន ក្នុងទីផ្សារ ជាមួយនឹងក្របខណ្ឌ និងទម្រង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗគ្នា។

# គ្រប់គ្រងផលិតផល

**អង្គភាពគ្រប់គ្រងផលិតផល គឺជាផ្នែកដ៏សំខាន់មួយ នៃសកម្មភាពអាជីវកម្មរបស់ធនាគារ។ មុខងាររបស់នាយកដ្ឋាននេះ គឺជួយជំរុញធនាគារឱ្យរក្សាបាននូវភាពប្រកួតប្រជែង និងបន្តបង្កើនចំណែកទីផ្សារ ដោយធ្វើការណែនាំផលិតផល និងសេវាកម្មថ្មីៗបន្ថែមទៀត ដើម្បីបំពេញតម្រូវការអតិថិជន។**

---

នាយកដ្ឋានគ្រប់គ្រងផលិតផល រួមចំណែករក្សានូវភាពប្រកួតប្រជែង នៅក្នុងទីផ្សាររបស់ធនាគារ តាមរយៈការណែនាំ និងលើកកម្ពស់ផលិតផល និងសេវាកម្មថ្មីៗបន្ថែមទៀត។ ទាំងអស់នេះជួយជំរុញធនាគារ ក្នុងការបំពេញតម្រូវការអតិថិជន និងបន្តពន្លឿន តាមការវិវឌ្ឍ ដែលកំពុងកើនឡើងឥតឈប់ឈរ នៃតម្រូវការ ពីអតិថិជន ការប្រកួតប្រជែងខ្ពស់ ក្នុងទីផ្សារ និងបច្ចេកវិទ្យាទំនើប។ មិនតែប៉ុណ្ណោះ យើងបានសហការ ជាមួយនឹងអង្គភាពពាក់ព័ន្ធនានា រួមមានផ្នែកសេវាកម្មធនាគារឌីជីថល និងប្រតិបត្តិការ ដើម្បីលើកកម្ពស់សេវាកម្មធនាគារឌីជីថល។ សេវាកម្មទាំងអស់នេះ គឺរួមមានកម្មវិធីធនាគារចល័ត CIMB Mobile និងសេវាកម្មបណ្តាញអេធីអិម ប្រចាំតំបន់។

ការបំពេញចិត្តអតិថិជន គឺជាទិសដៅស្នូល នៃយុទ្ធសាស្ត្រផលិតផលរបស់យើង។ យើងនឹងបន្តជំរុញឱ្យផលិតផលឥណទាន និងប្រាក់បញ្ញើរបស់យើង កាន់តែមានភាពងាយស្រួល និងទាក់ទាញ ដោយធ្វើការទទួលយករាល់មតិយោបល់ដ៏មានតម្លៃ ពីអតិថិជន និងប្រើប្រាស់ការអនុវត្តយុទ្ធសាស្ត្រទីផ្សារល្អបំផុត។ មិនតែប៉ុណ្ណោះ យើងមានផែនការនាំយកសេវាកម្ម និងផលិតផលបន្ថែមទៀត ដែលផ្តល់ផលវិជ្ជមាន ដល់សង្គម និងសហគមន៍ ស្របតាមគោលការណ៍អភិវឌ្ឍន៍ ប្រកបដោយចីរភាព។

---

# ការគ្រប់គ្រងហានិភ័យ

**ភាពរីកចម្រើនយ៉ាងឆាប់រហ័ស នៃវិស័យធនាគារ ក្នុងប្រទេសកម្ពុជា ការផ្លាស់ប្តូរ លើតម្រូវការបទប្បញ្ញត្តិ និងហានិភ័យថ្មីៗ បានកើតចេញពីទស្សនវិស័យ នៃបរិបទបច្ចុប្បន្ន នៃវិស័យធនាគារ ការអនុលោមតាមច្បាប់ និងផ្នែកបច្ចេកវិទ្យាជាដើម។ ដូច្នេះ ហើយធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានបង្កើតនូវប្រព័ន្ធគ្រប់គ្រងហានិភ័យដ៏រឹងមាំ និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីបន្តសម្រេចបានផលចំណេញ ដែលសមតុល្យនឹងហានិភ័យ និងបង្កើតគុណតម្លៃរបស់ភាគហ៊ុនិក។ ធនាគារបានចាត់ទុកថា ការគ្រប់គ្រងហានិភ័យ គឺជាផ្នែកមួយយ៉ាងសំខាន់ នៃយុទ្ធសាស្ត្រ ផែនការអាជីវកម្ម ប្រតិបត្តិការ និងដំណើរការសម្រេចចិត្តរបស់ធនាគារ។ នាយកដ្ឋានគ្រប់គ្រងហានិភ័យ បានចូលរួមតាំងពីដំណាក់កាលដំបូង នៃកិច្ចពិភាក្សា អំពីយុទ្ធសាស្ត្រ និងដំណើរការទទួលយកហានិភ័យ ដើម្បីផ្តល់នូវទស្សនៈឯករាជ្យ រួមមានការវាយតម្លៃផែនការ ការវិភាគសេណារីយ៉ូ ការវាយតម្លៃតណទាន ការវាយតម្លៃ និងកំណត់ផលិតផលថ្មីៗ នៃតម្រូវការដើមទុន ព្រមទាំងការវិភាគ / ធ្វើតេស្តផលវិបាក នៃហានិភ័យ ដែលពាក់ព័ន្ធផងដែរ។ ការងារគាំទ្រទាំងអស់នេះ អនុញ្ញាតឱ្យអង្គភាពអាជីវកម្ម ក្នុងការប៉ាន់ស្មាននូវហានិភ័យ ធៀបនឹងផលចំណេញ ពីការសម្រេចចិត្តរបស់ពួកគេ។**

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលជាផ្នែកមួយ នៃស៊ីអាយអិមប៊ី គ្រុប បានប្រើប្រាស់ក្របខណ្ឌ គ្រប់គ្រងហានិភ័យទូទៅមួយ សម្រាប់សហគ្រាសទាំងមូល (EWRM) ដើម្បីគ្រប់គ្រងហានិភ័យ និងឱកាសរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព។ ក្របខណ្ឌ EWRM ផ្តល់ជូនក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង នូវឧបករណ៍មួយ ដើម្បីធ្វើការប្រមើលមើលទុកជាមុន និងគ្រប់គ្រងហានិភ័យ ដែលមានស្រាប់ និងហានិភ័យ ដែលអាចនឹងកើតមាន ដោយធ្វើការពិចារណា ទៅលើការកែប្រែទម្រង់ហានិភ័យ ស្របតាមការផ្លាស់ប្តូរយុទ្ធសាស្ត្រអាជីវកម្ម បរិយាកាសពីខាងក្រៅ និង/ឬ បទប្បញ្ញត្តិច្បាប់។

គណៈកម្មាធិការហានិភ័យ គឺជាគណៈកម្មាធិការមួយ ដែលទទួលសិទ្ធិអំណាច ពីក្រុមប្រឹក្សាភិបាល និងរាយការណ៍ ទៅក្រុមប្រឹក្សាភិបាល នូវរាល់បញ្ហា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ។ កិច្ចប្រជុំរបស់គណៈកម្មាធិការហានិភ័យ បានធ្វើឡើងជារៀងរាល់ខែ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តការងារ ចំពោះការគ្រប់គ្រងហានិភ័យ និងសកម្មភាពការងារទាំងអស់របស់ធនាគារ។

ដោយមានការគាំទ្រ ពីគណៈកម្មាធិការតណទានកម្ពុជា គណៈកម្មាធិការគុណភាពទ្រព្យសកម្មកម្ពុជា និងក្រុមការងារគ្រប់គ្រងហានិភ័យ គណៈកម្មាធិការហានិភ័យ មានទំនួលខុសត្រូវ ក្នុងការធានានូវការប្រកាន់ខ្ជាប់ ទៅនឹងវិសអាប់តែថាយកម្រិតហានិភ័យ និងតរិយាបថហានិភ័យ ដែលត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាភិបាល។ ទំនួលខុសត្រូវបន្ថែមលើនោះ គឺរួមមានការត្រួតពិនិត្យ និងការវិភាគនិន្នាការ វិសាលភាព គុណភាពទ្រព្យសកម្ម របាយការណ៍បញ្ជីតាមដាន និងការត្រួតពិនិត្យគោលនយោបាយ។ គណៈកម្មាធិការហានិភ័យ ក៏មានទំនួលខុសត្រូវ ក្នុងការបញ្ជាក់ភាពគ្រប់គ្រាន់ នៃវិធានការ សម្រាប់ដោះស្រាយបញ្ហាតណទានសំខាន់ៗផងដែរ។

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម មានទំនួលខុសត្រូវប្រចាំថ្ងៃ ក្នុងការគ្រប់គ្រងហានិភ័យសន្ទនីយភាព ទម្រង់សាច់ប្រាក់ តារាងតុល្យការ និងយុទ្ធសាស្ត្រការពារ ហានិភ័យអត្រាការប្រាក់ជារួម ក្នុងទម្រង់បញ្ជីធនាគារ ព្រមទាំងការធានានូវទម្រង់ហានិភ័យផ្សេងៗ ស្ថិតក្នុងវិសអាប់តែថាយកម្រិតហានិភ័យ ដែលបានកំណត់។ កិច្ចប្រជុំ នៃគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ត្រូវបានប្រព្រឹត្តទៅ ជារៀងរាល់ខែ ហើយរាយការណ៍បន្ត ទៅគណៈកម្មាធិការហានិភ័យ។

## ហានិភ័យតណទាន

ហានិភ័យតណទាន សំដៅដល់លទ្ធភាព នៃការខាតបង់ ដោយសារអតិថិជន ដែលមានបំណុល ជាមួយធនាគារ ដៃគូទីផ្សារ ឬអ្នកចេញមូលបត្រ ឬភាគីពាក់ព័ន្ធដទៃទៀត បរាជ័យក្នុងការបំពេញកាតព្វកិច្ច សម្រាប់ការទូទាត់សងមកធនាគារវិញ តាមការសន្យា។

គោលបំណង នៃការគ្រប់គ្រងហានិភ័យតណទាន គឺដើម្បីរក្សាបាននូវហានិភ័យតណទាន ស្ថិតក្នុងកម្រិតសមស្របមួយ ធៀបនឹងដើមទុន ហើយធានាថា ផលចំណេញ គឺសមស្របទៅនឹងហានិភ័យ។ បើគ្មានការគ្រប់គ្រងហានិភ័យតណទានទេ ផលប៉ះពាល់ ពីការខាតបង់នានា អាចនឹងកើតមានឡើងខ្ពស់។

ក្របខណ្ឌផ្តល់សិទ្ធិវាយតម្លៃហានិភ័យ មានបញ្ជូលអ្នកជំនាញវាយតម្លៃរួមគ្នា ដែលធ្វើឱ្យប្រសើរឡើង នូវដំណើរការអនុម័តតណទាន និងការកំណត់ច្បាស់លាស់ នៃគោលនយោបាយ និងនីតិវិធី ដែលចែងពីដែនកំណត់ និងប្រភេទ នៃសិទ្ធអំណាច ដែលផ្តល់ឱ្យបុគ្គលឯករាជ្យនោះ។ ធនាគារបានអនុវត្តការអនុម័តតណទានច្រើនកម្រិត គិតចាប់ពីអ្នកជំនាញវាយតម្លៃ នៅកម្រិតអាជីវកម្ម អ្នកជំនាញវាយតម្លៃរួមគ្នា រវាងអង្គភាពអាជីវកម្ម និងកត្តាហានិភ័យ រហូតដល់គណៈកម្មាធិការតណទាន និង/ឬ កម្រិតលើសពីនេះទៀត។

ទំហំតណទាន ត្រូវបានតាមដានយ៉ាងសកម្ម ពិនិត្យមើលជាប្រចាំ និងរាយការណ៍យ៉ាងទៀងទាត់ ជូនគណៈកម្មាធិការហានិភ័យ និងក្រុមប្រឹក្សាភិបាល។ គុណភាពទ្រព្យសកម្ម ត្រូវបានតាមដានយ៉ាងជិតស្និទ្ធ ហើយផលអវិជ្ជមាន ត្រូវបានកំណត់អត្តសញ្ញាណ វិភាគ និងពិភាក្សា ជាមួយនឹងអង្គភាពអាជីវកម្ម ដែលពាក់ព័ន្ធ ដើម្បីចាត់វិធានការកែលម្អឱ្យបានសមស្រប បើចាំបាច់។

ការអនុវត្តបច្ចេកទេសកាត់បន្ថយហានិភ័យតណទាន ដូចជាការរៀបចំតណទាន និងការដាក់ទ្រព្យបញ្ចាំ និង/ឬ ការគាំទ្រភាគីទីបី គឺជាផ្នែកដ៏សំខាន់មួយ នៃដំណើរការគ្រប់គ្រងហានិភ័យតណទាន។ អ្នកជំនាញកាត់បន្ថយហានិភ័យតណទាន ត្រូវបានបង្កើតឡើង តាមកាលៈទេសៈជាក់ស្តែង ហើយត្រូវបានចាត់ទុកជាបុគ្គលសំខាន់បន្ទាប់ សម្រាប់ការសិក្សាហានិភ័យតណទានរបស់អតិថិជន។

## ហានិភ័យសន្ទនីយភាព និងប្រភពទុន

ហានិភ័យសន្ទនីយភាព និងប្រភពទុន សំដៅដល់ហានិភ័យ ដែលកំពុងមាន និងអាចកើតមាន ដែលប៉ះពាល់ដល់ប្រាក់ចំណូល ប្រភពទុនរបស់ភាគហ៊ុនិក ឬកេរ្តិ៍ឈ្មោះរបស់ធនាគារ ដែលបណ្តាលមកពីធនាគារពុំមានលទ្ធភាព ក្នុងការបំពេញតម្រូវការសាច់ប្រាក់ នាពេលបច្ចុប្បន្ន និងពេលអនាគត ឬមិនអាចបំពេញកាតព្វកិច្ច តាមបទប្បញ្ញត្តិ ហើយអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ និងរងការខាតបង់ លើសពីការរំពឹងទុក។ ហានិភ័យសន្ទនីយភាព កើតចេញពីភាពមិនត្រូវគ្នា នៃពេលវេលាលំហូរសាច់ប្រាក់។

គោលបំណង ក្នុងការគ្រប់គ្រងហានិភ័យសន្ទនីយភាព គឺដើម្បីធានាថា ធនាគារអាចបំពេញតាមកាតព្វកិច្ចលំហូរសាច់ប្រាក់ទាន់ពេលវេលា និងគ្រប់គ្រងខ្វង់ចំណាយ ដោយប្រសិទ្ធភាពខ្ពស់។ ការតាមដាន និងគ្រប់គ្រងហានិភ័យសន្ទនីយភាពប្រចាំថ្ងៃ គឺផ្អែកលើមូលដ្ឋាន នៃការព្យាករលំហូរសាច់ប្រាក់របស់ធនាគារ ទាំងស្ថិតក្រោមស្ថានភាពអាជីវកម្មធម្មតា និងស្ថានភាពកំពុងមានវិបត្តិ។ អនុបាតក្របខណ្ឌសន្ទនីយភាព គឺជាឧបករណ៍ត្រិតសន្ទនីយភាពមួយដ៏សំខាន់ និងជាតម្រូវការបទប្បញ្ញត្តិ ដែលកំណត់ឡើង ដើម្បីធានាថា ធនាគារមានទ្រព្យសកម្មសន្ទនីយ ដែលមានគុណភាពខ្ពស់គ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការសន្ទនីយភាព ក្នុងស្ត្រេសសេណារីយ៉ូ សម្រាប់រយៈពេល ៣០ថ្ងៃ ។

ធនាគារក៏បានធ្វើស្ត្រេសតេស្ត (Stress Test) យ៉ាងទៀងទាត់ជារៀងរាល់ឆមាស រួមទាំងការធ្វើស្ត្រេសតេស្ត ទៅលើសន្ទនីយភាព ដើម្បីកំណត់ប្រភព នៃវិបត្តិសន្ទនីយភាព ដែលអាចកើតមាន និងទំហំផលបត្រ ដែលងាយរងគ្រោះ ដើម្បីប៉ាន់ស្មានផលប៉ះពាល់ ផ្នែកហិរញ្ញវត្ថុ និងបង្កភាពងាយស្រួល ដល់គណៈគ្រប់គ្រងរបស់ធនាគារ ក្នុងការចាត់វិធានការ ទុកជាមុន។

បន្ថែមពីលើការអនុវត្ត ស្របតាមបទប្បញ្ញត្តិ ដែលតម្រូវដោយនិយ័តករ ធនាគារបានបង្កើតដែនកំណត់ផ្ទៃក្នុង និងកម្រិតរឹសអាប់តែថាយ សម្រាប់គ្រប់គ្រងហានិភ័យសន្ទនីយភាព។ ចំណាត់ការគ្រប់គ្រងត្រូវបានបង្កើតឡើង ដើម្បីជូនដំណឹងដល់គណៈគ្រប់គ្រង ចំពោះវិបត្តិសន្ទនីយភាពចម្បង។ ដែលអាចនឹងកើតមាន។ ដែនកំណត់ និងកម្រិតរឹសអាប់តែថាយ ព្រមទាំងគោលនយោបាយ និងនីតិវិធី ដែលពាក់ព័ន្ធទាំងអស់នេះ ត្រូវបានត្រួតពិនិត្យយ៉ាងទៀងទាត់ ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរបទប្បញ្ញត្តិ ការផ្លាស់ប្តូរតម្រូវការអាជីវកម្ម និងលក្ខខណ្ឌបម្រែបម្រួលទីផ្សារ។ ការធ្វើតេស្ត លើគោលនយោបាយ ផែនការទុនយថាភាព ត្រូវបានធ្វើឡើងជាប្រចាំ ដើម្បីផ្តល់ជាសញ្ញា ដល់ថ្នាក់គ្រប់គ្រង ក្នុងការឆ្លើយតប ប្រកបដោយប្រសិទ្ធភាព និងមានប្រសិទ្ធផល អំឡុងពេលមានវិបត្តិសន្ទនីយភាព និងស្ថិតក្រោមលក្ខខណ្ឌទីផ្សារអវិជ្ជមាន។

នាយកដ្ឋានគ្រប់គ្រងហានិភ័យ មានទំនួលខុសត្រូវ ក្នុងការពិនិត្យតាមដាន ដោយឯករាជ្យ ចំពោះហានិភ័យសន្ទនីយភាពរបស់ធនាគារ និងរៀបចំរបាយការណ៍ប្រចាំខែ ជូនគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ។ ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ កិច្ចពិភាក្សា និងការត្រួតពិនិត្យជាច្រើន លើផែនការផ្តួចផ្តើម និងយុទ្ធសាស្ត្រអាជីវកម្ម ត្រូវបានរៀបចំឡើងជាប្រចាំ ក្នុងគោលបំណងពង្រីកទំហំប្រាក់បញ្ញើរបស់អតិថិជន និងផលចំណេញរបស់ធនាគារ។

## ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ សំដៅដល់ហានិភ័យ ដែលធ្វើឱ្យខាតបង់ ដោយសារការប្រែប្រួល លើអត្រាការប្រាក់ ក្នុងទីផ្សារ អត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស គម្លាតឥណទាន តម្លៃមូលធន និងតម្លៃវត្ថុធាតុដើម ព្រមទាំងកត្តាប្រែប្រួល ដែលពាក់ព័ន្ធមួយចំនួនទៀត។

ហានិភ័យអត្រាការប្រាក់ សំដៅដល់ហានិភ័យ ដែលធ្វើឱ្យខាតបង់ ដល់ទំហំសេដ្ឋកិច្ច និងប្រាក់ចំណូលរបស់ធនាគារ ដោយសារការប្រែប្រួលនៃអត្រាការប្រាក់។ ហានិភ័យអត្រាការប្រាក់ ត្រូវបានគ្រប់គ្រងដោយរឹសអាប់តែថាយកម្រិតហានិភ័យ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល។

## ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ សំដៅដល់ហានិភ័យ នៃការខាតបង់ដោយផ្ទាល់ ឬប្រយោល ដែលបណ្តាលមកពីភាពមិនគ្រប់គ្រាន់ ឬបរាជ័យ នៃដំណើរការស្តង់ដារផ្ទៃក្នុង មនុស្ស ប្រព័ន្ធកុំព្យូទ័រ ឬកត្តា ពីខាងក្រៅ។ ហានិភ័យប្រតិបត្តិការ គឺរាប់បញ្ចូលនូវហានិភ័យនីតិកម្ម តែមិនជាប់ពាក់ព័ន្ធនឹងហានិភ័យយុទ្ធសាស្ត្រឡើយ។

ធនាគារបានបង្កើតស្តង់ដារវិធីសាស្ត្រ ឧបករណ៍ និងដំណើរការ ក្នុងការកំណត់ វាយតម្លៃ រាយការណ៍ និងគ្រប់គ្រងហានិភ័យប្រតិបត្តិការ សម្រាប់អ្នកគ្រប់គ្រងហានិភ័យគ្រប់គ្នា នៅទូទាំងធនាគារ។ ធនាគារបានដាក់ដំណើរការឧបករណ៍គ្រប់គ្រងហានិភ័យប្រតិបត្តិការ រួមមានការគ្រប់គ្រងទិន្នន័យបាត់បង់ ការវាយតម្លៃដោយខ្លួនឯង លើការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងបញ្ហាត្រួតពិនិត្យ និងសូចនាករកំណត់ហានិភ័យគន្លឹះ។

យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យប្រតិបត្តិការរបស់ធនាគារ គឺអាស្រ័យលើក្របខណ្ឌគ្រប់គ្រងហានិភ័យរឹងមាំមួយ ដែលផ្តល់នូវគោលការណ៍ណែនាំរួម ជាមួយនឹងរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ ដើម្បីបណ្តុះនូវវប្បធម៌គ្រប់គ្រងហានិភ័យដ៏សកម្មមួយ។ ការពិនិត្យតាមដាន ដើម្បីកំណត់ហានិភ័យ ត្រូវបានបង្កើតឡើងជាចម្បង ដោយក្រុមការងារគ្រប់គ្រងហានិភ័យ តាមរយៈការផ្តល់របាយការណ៍ប្រចាំខែជូនគណៈកម្មាធិការហានិភ័យ ដែលចាត់ចែង និងពិនិត្យតាមដានបរិយាកាសគ្រប់គ្រងរួមរបស់ធនាគារ។

## ហានិភ័យក្លែងបន្លំ

ហានិភ័យក្លែងបន្លំ សំដៅដល់ហានិភ័យ នៃការខាតបង់ ដែលបណ្តាលមកពីសកម្មភាព ឬស្ថានភាព នៃការបោកបញ្ឆោត ឬឆ្វេសប្រហែស ដោយមានចេតនាលាក់បាំង លុបលាង បំភ្លៃ ក្លែងបន្លំ ។ល។ ដើម្បី -(១). កេងចំណេញផលប្រយោជន៍ផ្ទាល់ខ្លួន ដោយខុសច្បាប់ និងអយុត្តិធម៌ -(២). ប្រើប្រាស់បុគ្គល ឬក្រុមណាមួយ ឱ្យចុះចាញ់ដោយឆន្ទៈ ឬដោយគ្មានឆន្ទៈ នៃកម្មសិទ្ធិ/សិទ្ធិស្របច្បាប់ -(៣). ធ្វើឱ្យខូចខាតដល់បុគ្គល ឬក្រុមណាមួយ។

ធនាគារបានបង្កើតគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យក្លែងបន្លំ ដើម្បីបង្ការ កំណត់ និងឆ្លើយតបនឹងហានិភ័យ ដែលពាក់ព័ន្ធនឹងផ្លូវច្បាប់ បទប្បញ្ញត្តិច្បាប់ កេរ្តិ៍ឈ្មោះ និងហិរញ្ញវត្ថុ ចំពោះឧប្បត្តិហេតុក្លែងបន្លំ ដែលបានកើតឡើង និងជៈឥទ្ធិពល ដល់ធនាគារ អតិថិជន និងភាគីពាក់ព័ន្ធនានា។

ក្រុមការងារគ្រប់គ្រងហានិភ័យ ត្រួតពិនិត្យ និងតាមដានសកម្មភាពក្លែងបន្លំ ដែលបានទទួលការរាយការណ៍ និងពេលវេលាឆ្លើយតប នៃការស៊ើបអង្កេតការក្លែងបន្លំ ដើម្បីធានាថា សកម្មភាពក្លែងបន្លំ ដែលសង្ស័យទាំងអស់ ត្រូវបានដោះស្រាយទាន់ពេលវេលា ជាមួយនឹងការធ្វើបច្ចុប្បន្នភាព និងការត្រួតពិនិត្យប្រចាំខែ ដោយគណៈកម្មាធិការហានិភ័យ។

## ការគ្រប់គ្រងនិរន្តរភាពនៃ អាជីវកម្ម

កម្មវិធីគ្រប់គ្រងនិរន្តរភាព នៃអាជីវកម្ម ដែលបានចែង នៅក្នុងគោលនយោបាយ និងនីតិវិធីគ្រប់គ្រងនិរន្តរភាព នៃអាជីវកម្មរបស់ធនាគារ ត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយវិបត្តិ ធានានូវនិរន្តរភាពនៃសេវាកម្ម ដល់អតិថិជន និងគាំទ្រដំណើរការអាជីវកម្ម។ កម្មវិធីគ្រប់គ្រងនិរន្តរភាព នៃអាជីវកម្ម ដើរតួនាទីចម្បង ក្នុងការបង្កើតវិធីសាស្ត្រ និងឧបករណ៍ជំនួយ សម្រាប់ការអនុវត្តផែនការគ្រប់គ្រងនិរន្តរភាព នៃអាជីវកម្ម នៅទូទាំងធនាគារ ក៏ដូចជាធានានូវការសម្របសម្រួល និងការត្រួតពិនិត្យដ៏មានប្រសិទ្ធភាព លើគ្រប់សកម្មភាពគ្រប់គ្រងនិរន្តរភាព នៃអាជីវកម្ម។

ការពិនិត្យមើល ការវាយតម្លៃឡើងវិញ និងការធ្វើបច្ចុប្បន្នភាពទៀងទាត់ សម្រាប់ការរៀបចំឯកសារ និងផែនការរបស់កម្មវិធីគ្រប់គ្រងនិរន្តរភាព នៃអាជីវកម្ម ត្រូវបានបង្កើតឡើង ដើម្បីធានានូវភាពគ្រប់គ្រាន់ ប្រសិទ្ធភាព និងផ្នែកពាក់ព័ន្ធ នៃយុទ្ធសាស្ត្រស្តារអាជីវកម្មឡើងវិញ។ ផែនការទាំងអស់នេះ បានដាក់បញ្ចូលការហាត់សម និងធ្វើតេស្តជាទៀងទាត់។ គណៈកម្មាធិការគ្រប់គ្រងនិរន្តរភាព នៃអាជីវកម្ម របស់ធនាគារ ផ្តល់មតិយោបល់ លើកម្មវិធីគ្រប់គ្រងនិរន្តរភាព នៃអាជីវកម្ម ដើម្បីធានាថា ធនាគារប្រកាន់ខ្ជាប់នូវការអនុវត្តឱ្យបានល្អប្រសើរបំផុត និងស្របតាមចក្ខុវិស័យ និងយុទ្ធសាស្ត្រ នៃអាជីវកម្ម។

## ហានិភ័យបច្ចេកវិទ្យា

ហានិភ័យបច្ចេកវិទ្យា សំដៅដល់ហានិភ័យ នៃការខាតបង់ ដែលបណ្តាលមកពីការគ្រប់គ្រងខ្វះចន្លោះ នៃបុគ្គលិក ដំណើរការ និង/ឬ បច្ចេកវិទ្យា ដែលរួមមានហានិភ័យប្រតិបត្តិការ ហានិភ័យហិរញ្ញវត្ថុ ហានិភ័យការអនុលោមតាមច្បាប់ និងហានិភ័យកេរ្តិ៍ឈ្មោះ ដែលបណ្តាលមកពីការបញ្ចេញព័ត៌មាន ដោយគ្មានការអនុញ្ញាត ការកែប្រែ ឬការរំខាន ការបំពានទិន្នន័យ និងការបាត់បង់ ឬការខូចខាត។

ក្រុមការងារគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា មានទំនួលខុសត្រូវ ក្នុងការធានានូវការអនុវត្តរួម នៃក្របខណ្ឌគ្រប់គ្រងហានិភ័យបច្ចេកវិទ្យារបស់ធនាគារ ដោយធានានូវការអនុលោមតាមបទប្បញ្ញត្តិច្បាប់ គោលនយោបាយ និងគោលការណ៍ណែនាំ ដែលពាក់ព័ន្ធ។ ក្រុមការងារគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា បំពេញការងារយ៉ាងសកម្ម ជាមួយនឹងក្រុមការពារជួរមុខ ក្នុងការកំណត់ហានិភ័យបច្ចេកវិទ្យា និងផ្ទៀងផ្ទាត់ភាពពេញលេញ និងប្រសិទ្ធភាព នៃការគ្រប់គ្រង ដើម្បីចៀសវាងហានិភ័យ ពីការរំខានផ្សេងៗ។ បន្ថែមពីលើនេះ ក្រុមការងារគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា ពិនិត្យមើលការវាយតម្លៃហានិភ័យ ដែលធ្វើឡើងដោយអង្គភាពអាជីវកម្ម សម្រាប់ផ្នែកបច្ចេកវិទ្យា ដែលពាក់ព័ន្ធនឹងកម្មវិធី និងដំណើរការ ហើយផ្តល់យោបល់ អំពីការកែលម្អដ៏សមរម្យមួយ។

ស្ថិតក្រោមក្របខណ្ឌអភិបាលកិច្ចហានិភ័យ ក្រុមការងារគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា រាយការណ៍យ៉ាងទៀងទាត់ ជូនដល់ក្រុមការងារគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា របស់ស៊ីអាយអិមប៊ី គ្រុប ដើម្បីផ្តល់នូវការត្រួតពិនិត្យ និងការវាយតម្លៃពិចារណា ដោយឯករាជ្យ អំពីហានិភ័យបច្ចេកវិទ្យា ផ្អែកលើវីសអាប់ភៃថាយកម្រិតហានិភ័យបច្ចេកវិទ្យា ដែលបានអនុម័តរួច។

## ហានិភ័យតតិយភាព

ហានិភ័យតតិយភាព សំដៅដល់ហានិភ័យ ដែលបណ្តាលមកពីការរៀបចំតតិយភាព ដែលអាចបង្កឱ្យមានការរំខាន ដល់ប្រតិបត្តិការអាជីវកម្ម ការខាតបង់ ផ្នែកហិរញ្ញវត្ថុ ឬការខូចខាតកេរ្តិ៍ឈ្មោះរបស់ធនាគារ។

ធនាគារបានកែសម្រួលគោលនយោបាយ និងនីតិវិធីគ្រប់គ្រងតតិយភាព ដែលបញ្ជាក់ពីការគ្រប់គ្រងរៀបចំតតិយភាព ជាមួយនឹងអ្នកផ្តល់សេវាកម្មណាមួយ។ វិធីសាស្ត្រទាំងអស់នេះ គឺរួមមានការពិនិត្យតាមកាលកំណត់ លើការបំពេញការងាររបស់អ្នកផ្តល់សេវាកម្ម ក្នុងការកំណត់កម្រិតគុណភាពសេវាកម្ម និងកិច្ចសហការ ជាមួយនឹងក្រុមការងារគ្រប់គ្រងនិរន្តរភាព នៃអាជីវកម្ម និងក្រុមការងារគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា ដើម្បីពង្រឹងនិរន្តរភាព នៃអាជីវកម្ម និងផ្នែកបច្ចេកវិទ្យា។

## ការគ្រប់គ្រងហានិភ័យផ្សេងៗ

ក្រុមការងារគ្រប់គ្រងហានិភ័យ បំពេញការងារពិនិត្យមើលគោលនយោបាយ និងនីតិវិធី នៃអង្គភាពអាជីវកម្ម និងអង្គភាពគាំទ្រអាជីវកម្ម ដែលជាផ្នែកមួយ នៃមុខងារអនុលោមតាមហានិភ័យសវនកម្ម។ តួនាទីរបស់ក្រុមការងារនេះ គឺជាប់ពាក់ព័ន្ធនៅដំណាក់កាលដំបូង និងការបន្តពិនិត្យមើលគោលនយោបាយ និងនីតិវិធី ដោយផ្តល់នូវការវាយតម្លៃជាឯករាជ្យ កំណត់គោលដៅហានិភ័យខ្ពស់ និងផ្តល់នូវព័ត៌មាន ដើម្បីធានានូវប្រតិបត្តិការអាជីវកម្ម ដែលមានតុល្យភាព ទៅនឹងហានិភ័យ។

# ប្រតិបត្តិតាម

**នាយកដ្ឋានប្រតិបត្តិតាម ទទួលបន្ទុក ក្នុងការធានាថា គ្រប់នាយកដ្ឋាន ក៏ដូចជាបុគ្គលិកទាំងអស់ នៅក្នុងធនាគារ មានការយល់ដឹង អំពីកាតព្វកិច្ច និងផលប៉ះពាល់នានា នៃបទប្បញ្ញត្តិពាក់ព័ន្ធ។ តួនាទីចម្បងរបស់នាយកដ្ឋាននេះ គឺរួមមានការត្រួតពិនិត្យ និងផ្តល់យោបល់ ដល់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ដើម្បីធានាការអនុវត្តអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំផ្ទៃក្នុងរបស់ធនាគារ។**

សម្រាប់មុខងារត្រួតពិនិត្យ លើការប្រតិបត្តិតាម នាយកដ្ឋាននេះបានធ្វើការត្រួតពិនិត្យ ដល់ទីកន្លែង និងវាយតម្លៃ អំពីប្រសិទ្ធភាព នៃការធ្វើតេស្តដោយខ្លួនឯង (Self-testing) ទៅលើការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំផ្ទៃក្នុងនានា ដើម្បីធានាថា រាល់ដំណើរការ និងនីតិវិធីរបស់ធនាគារ ត្រូវបានអនុលោម។ មិនតែប៉ុណ្ណោះ នាយកដ្ឋាននេះបានជំរុញឱ្យមានការចូលរួមយ៉ាងសកម្ម ពីភាគីពាក់ព័ន្ធនានា ក្នុងការបំពេញកាតព្វកិច្ចរបស់ធនាគារ ចំពោះបទប្បញ្ញត្តិផ្សេងៗ ដូចជាច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ច្បាប់ ស្តីពីការប្រឆាំងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យ (AFP) ច្បាប់ ស្តីពីគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារ និងបទប្បញ្ញត្តិ ដែលត្រូវបានបង្កើតថ្មី និងធ្វើវិសោធនកម្មដទៃទៀត។

នាយកដ្ឋានប្រតិបត្តិតាម បំពេញការងារដោយឯករាជ្យ និងរាយការណ៍ដោយផ្ទាល់ ទៅកាន់ក្រុមប្រឹក្សាភិបាល ដែលជាអ្នកត្រួតពិនិត្យ និងអនុម័តផែនការការងារប្រតិបត្តិតាមប្រចាំឆ្នាំ ដែលស្នើសុំដោយនាយកដ្ឋានប្រតិបត្តិតាម។ ផ្អែកលើក្របខណ្ឌ នៃការប្រតិបត្តិតាម នាយកដ្ឋាននេះ ត្រូវបានដឹកនាំ តាមគោលនយោបាយ និងនីតិវិធីរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ស្តីពីការប្រតិបត្តិតាម និងស្តីពីការប្រឆាំងការសម្អាតប្រាក់ ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម និងទណ្ឌកម្មហិរញ្ញវត្ថុ (AML/CFT & TFS) និងគោលនយោបាយ និងនីតិវិធីពាក់ព័ន្ធផ្សេងទៀត ដែលត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាភិបាល។ ជាមួយគ្នានេះដែរ នាយកដ្ឋានប្រតិបត្តិតាម ក៏បានសហការ ជាមួយនឹងនាយកដ្ឋានដទៃទៀត ដើម្បីបង្កើតគោលការណ៍ណែនាំ និងក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗ រួមមានគោលការណ៍ណែនាំ អំពីការបើកគណនីធនាគារ គោលការណ៍ណែនាំ អំពីការត្រួតពិនិត្យប្រតិបត្តិការ ដែលមានសញ្ញាប្រុងប្រយ័ត្ន ក្រមសីលធម៌ នៃការលក់ផលិតផល និងសេវាកម្ម ។ល។

## សមិទ្ធផល ក្នុងឆ្នាំ២០២៤

ក្នុងឆ្នាំ២០២៤ នាយកដ្ឋានប្រតិបត្តិតាម បានបញ្ចប់ការត្រួតពិនិត្យ ដល់ទីកន្លែង សម្រាប់ផ្នែកអាជីវកម្ម ផ្នែកគាំទ្រអាជីវកម្ម និងសាខាចំនួន ៩។ បន្ថែមពីនេះ នាយកដ្ឋានប្រតិបត្តិតាម ក៏បានអនុវត្តការត្រួតពិនិត្យ ដោយផ្អែកលើការវិភាគទិន្នន័យ ដែលអាចគ្របដណ្តប់ចំនួនប្រតិបត្តិការ នៅតាមសាខាបានចំនួនច្រើន។ មិនតែប៉ុណ្ណោះ និតីវិធី ក្នុងការត្រួតពិនិត្យអតិថិជន និងប្រតិបត្តិការនានា របស់នាយកដ្ឋានប្រតិបត្តិតាម ត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព ដើម្បីពង្រឹង និងកែលម្អដំណើរការ នៃការរាយការណ៍ តាមបទប្បញ្ញត្តិច្បាប់ ការរាយការណ៍ ទៅធនាគារមេ ការត្រួតពិនិត្យការប្រតិបត្តិតាមបទប្បញ្ញត្តិ និងការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

កម្មវិធីបណ្តុះបណ្តាលចំណេះដឹង និងជំនាញ ក៏ជាផ្នែកផ្តោតសំខាន់មួយ សម្រាប់នាយកដ្ឋានប្រតិបត្តិតាមផងដែរ។ និយោជិតថ្មីទាំងអស់ ត្រូវបានតម្រូវឱ្យចូលរួមវគ្គបណ្តុះបណ្តាល ក្នុងអំឡុងពេលបីខែគិតចាប់ពីថ្ងៃចូលបម្រើការងារ ក្នុងធនាគារ ហើយនិយោជិត ដែលបាន និងកំពុងបម្រើការងារស្រាប់ តម្រូវឱ្យចូលរៀនវគ្គសិក្សាប្រចាំឆ្នាំ អំពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមប្រព័ន្ធអេឡិកត្រូនិក។ ក្នុងឆ្នាំ២០២៤ នាយកដ្ឋានប្រតិបត្តិតាម បានរៀបចំវគ្គបណ្តុះបណ្តាលសរុបចំនួន ២៨ដង អំពីបទប្បញ្ញត្តិ និងច្បាប់ រួមទាំងច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ការត្រួតពិនិត្យ ដល់ទីកន្លែង សម្រាប់ ផ្នែកអាជីវកម្ម ផ្នែកគាំទ្រអាជីវកម្ម និងសាខាចំនួន **៩**

វគ្គបណ្តុះបណ្តាលសរុប ចំនួន **២៨** លើក អំពី បទប្បញ្ញត្តិ និងច្បាប់ រួមទាំងច្បាប់ ស្តីពីការប្រឆាំង ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

## ផែនការ សម្រាប់ឆ្នាំ២០២៥

នាយកដ្ឋានប្រតិបត្តិតាម នឹងធ្វើការផ្សព្វផ្សាយ ដល់មន្ត្រីធនាគារទាំងអស់ នូវគោលការណ៍ និងនីតិវិធីរបស់ខ្លួន ដែលបានធ្វើបច្ចុប្បន្នភាពរួច ដើម្បីផ្តល់នូវភាពច្បាស់លាស់បន្ថែមទៀត និងរួមបញ្ចូលបទប្បញ្ញត្តិពាក់ព័ន្ធថ្មីៗ។ ទន្ទឹមនឹងនេះ នាយកដ្ឋាននេះ នឹងបន្តការត្រួតពិនិត្យ ដល់ទីកន្លែង និងការត្រួតពិនិត្យ ដោយផ្អែកលើការវិភាគទិន្នន័យ ដែលជាផ្នែកមួយ នៃការត្រួតពិនិត្យការប្រតិបត្តិតាម និងបន្តអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ស្តីពីការប្រឆាំងការសម្អាតប្រាក់ ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម និងទណ្ឌកម្មហិរញ្ញវត្ថុ (AML/CFT & TFS) គោលការណ៍ និងនីតិវិធី ស្តីពីការដាក់ទណ្ឌកម្ម គោលការណ៍ និងនីតិវិធី ស្តីពីការគ្រប់គ្រងបញ្ជីឈ្មោះបុគ្គល និងអង្គភាពហាមឃាត់ គោលការណ៍ និងនីតិវិធី ស្តីពីការប្រឆាំងការស៊ីសំណូក និងអំពើពុករលួយ ព្រមទាំងគោលការណ៍ និងនីតិវិធី ស្តីពីការប្រតិបត្តិតាម។

# យុទ្ធសាស្ត្រ

**នាយកដ្ឋានយុទ្ធសាស្ត្រ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើត និងត្រួតពិនិត្យមើលគម្រោងយុទ្ធសាស្ត្រផ្សេងៗគ្នា និងពង្រឹងនូវកិច្ចសហការ និងភាពជាដៃគូ ជាមួយនឹងភាគីខាងក្នុង និងខាងក្រៅស្ថាប័ន។ ក្រុមការងារ នៃនាយកដ្ឋាននេះ ធ្វើការវិភាគទីផ្សារ កំណត់ឱកាសរីកចម្រើន និងវាយតម្លៃទិដ្ឋភាពប្រកួតប្រជែង ដើម្បីបង្កើតយុទ្ធសាស្ត្រ ដែលបង្កើនប្រាក់ចំណេញ និងប្រសិទ្ធភាព។ នាយកដ្ឋាននេះ សហការជាមួយនាយកដ្ឋានផ្សេងៗ ដើម្បីធានាឱ្យស្របទៅនឹងគោលបំណងរួម តាមដាននិន្នាការ ឧស្សាហកម្ម និងសម្របខ្លួន ទៅនឹងការផ្លាស់ប្តូរបទប្បញ្ញត្តិ។ តាមរយៈការប្រើប្រាស់ទិន្នន័យ ការវិភាគទិន្នន័យ ព្រមទាំងការយល់ដឹង នាយកដ្ឋានយុទ្ធសាស្ត្រ នឹងជួយធនាគារអុករកបញ្ហាប្រឈម និងចាប់យកឱកាសថ្មីៗ ដែលចុងក្រោយជំរុញឱ្យទទួលបានជោគជ័យជានិរន្តរភាព និងការច្នៃប្រឌិត ក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុ។**

នាយកដ្ឋានយុទ្ធសាស្ត្រ បានរួមចំណែក ក្នុងការអនុវត្តយ៉ាងមានប្រសិទ្ធភាព នូវផែនការយុទ្ធសាស្ត្រ Forward23+ ព្រមទាំងទទួលខុសត្រូវ លើការពិនិត្យមើលគម្រោងផ្លាស់ប្តូររបស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ការបំពេញការងារ ប្រកបដោយកិច្ចសហការគ្នា ការបង្កើតនូវតុល្យភាព នៃសមត្ថភាពការងារ និងការការពារសវត្ថិភាពរបស់ធនាគារ ដើម្បីសម្រេចបានកំណើនងើបឡើងវិញយ៉ាងរឹងមាំ និងភាពរីកមច្រើនដ៏គាប់ប្រសើរផងដែរ។

សម្រាប់ផែនការអនាគត នាយកដ្ឋានយុទ្ធសាស្ត្រ នៅតែរក្សាការប្តេជ្ញាចិត្ត ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងបញ្ជ្រាបគុណតម្លៃការងារ EPICC ដែលដឹកនាំការអនុវត្តផែនការផ្តួចផ្តើមនានា ឱ្យកាន់តែងាយស្រួលជាងមុន កាន់តែល្អប្រសើរជាងមុន និងកាន់តែលឿនជាងមុន ដើម្បីលើកកម្ពស់សមិទ្ធផលការងារ និងធានានូវកំណើន ប្រកបដោយចីរភាព ដល់ធនាគារ។

# ចីរភាព

**ធនាគារ ស៊ីអាយអិមប៊ី ប្តេជ្ញាចិត្ត ក្នុងការកសាងស្ថាប័នមួយ ប្រកបដោយចីរភាព ដែលជួយដល់អតិថិជន និងសង្គមទាំងមូល។ តាមរយៈគោលការណ៍ចីរភាព ដែលបានចែងក្នុងផែនការអាជីវកម្មរបស់ធនាគារ យើងប្តេជ្ញាចិត្ត ក្នុងការធ្វើប្រតិបត្តិការអាជីវកម្មផ្អែកលើបរិបទមួយ ដែលយើងទទួលខុសត្រូវ លើសកម្មភាពរបស់យើង។ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ចីរភាព យើងរួមបញ្ចូលការយកចិត្តទុកដាក់ អំពីសង្គម បរិស្ថាន និងសេដ្ឋកិច្ច នៅគ្រប់ការសម្រេចចិត្ត ផ្អែកអាជីវកម្មរបស់យើង ដែលរួមមានការផ្តល់ហិរញ្ញប្បទាន ការទទួលភ្រាក់បញ្ញើ ដំណើរការលទ្ធកម្ម និងប្រតិបត្តិការអាជីវកម្មផ្សេងទៀត។**

វត្ថុបំណងរបស់យើង គឺដើម្បីបង្កើតផលវិជ្ជមាន ក្នុងប្រតិបត្តិការអាជីវកម្មរបស់យើង។ យើងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដោយបង្កើតនូវផលិតផល និងសេវាកម្មធនាគារ សម្រាប់សហគមន៍ភាគតិចក្នុងប្រទេសកម្ពុជា។ យើងយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងខ្ពស់ ក្នុងការវាយតម្លៃ និងបង្កើតវិធានការ ដែលកាត់បន្ថយផលវិបាក ដល់បរិស្ថាន ក៏ដូចជាលើកស្ទួយសមភាពសង្គម ដែលរួមមានការការពារសិទ្ធិមនុស្ស នៅគ្រប់ប្រតិបត្តិការធនាគាររបស់យើង។ ហានិភ័យចីរភាព ត្រូវបានគ្រប់គ្រង តាមរយៈការអង្កេត និងដំណើរការស្នើសុំអនុម័ត ដែលមានរចនាសម្ព័ន្ធច្បាស់លាស់។ យើងភ្ជាប់ទំនាក់ទំនង ដោយលើកចំហរ ជាមួយនឹងអតិថិជន និងភាគីពាក់ព័ន្ធ ហើយព្យាយាមជៈតទ្ទិពលជាវិជ្ជមាន លើការបំពេញការងារ និងការប្តេជ្ញាចិត្ត នៃចីរភាពផ្ទាល់ខ្លួនរបស់ពួកគេ។

អាជីវកម្ម ប្រកបដោយចីរភាព គឺជាឱកាសទីផ្សារ ដែលកំពុងកើនឡើងគួរឱ្យកត់សម្គាល់។ ក្នុងនាមជាគ្រឹះស្ថានហិរញ្ញវត្ថុមួយ យើងស្គាល់ច្បាស់ នូវសមត្ថភាព និងទំនួលខុសត្រូវរបស់យើង ក្នុងការបង្កើតនូវបណ្តាញធនធាន ដើម្បីសម្រេចបានសេដ្ឋកិច្ចបៃតង និងសមភាពមួយ។ ស្របតាមតម្រូវការលើទីផ្សារ យើងនឹងអភិវឌ្ឍផលិតផល និងសេវាកម្ម ជាមួយនឹងការជៈតទ្ទិពលជាវិជ្ជមាន ដែលលើកកម្ពស់ស្តង់ដារជីវិតរបស់អតិថិជន ហើយជាមួយគ្នានេះដែរ អាចរួមចំណែកដល់បរិស្ថាន និងសង្គមទាំងមូល។

# សវនកម្មផ្ទៃក្នុង

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់នូវការធានា ដោយឯករាជ្យ និងអព្យាក្រឹត ព្រមទាំងសេវាកម្ម ជាមួយនឹងគុណតម្លៃបន្ថែម ទៅលើប្រសិទ្ធភាព នៃការគ្រប់គ្រងហានិភ័យ ដំណើរការអភិបាលកិច្ច ប្រតិបត្តិការ ការបំពេញកិច្ចការ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដែលអនុវត្តដោយគណៈគ្រប់គ្រងរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។**

ការវាយតម្លៃរបស់នាយកដ្ឋាននេះ គឺធ្វើទៅតាមស្ថានភាព នៃការគ្រប់គ្រងរបស់ធនាគារ ការអនុវត្ត ក្នុងការវាយតម្លៃកម្រិតហានិភ័យ សកម្មភាពគ្រប់គ្រង ប្រភពព័ត៌មាន ប្រសិទ្ធភាព នៃទំនាក់ទំនង និងការអនុវត្ត លើការត្រួតពិនិត្យ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ក៏មានភារកិច្ចរាយការណ៍ដោយផ្ទាល់ ជូនគណៈកម្មាធិការសវនកម្ម និងមានឯករាជ្យភាព ពីផ្នែកប្រតិបត្តិការអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មផ្សេងៗ។

នៅក្នុងឆ្នាំ២០២៤ ដោយមានការគាំទ្រ ពីនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃស៊ីអាយអិមប៊ី គ្រុប នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី សម្រេចបានការងារចំនួន ១៧គម្រោង ដែលបានគ្របដណ្តប់ផ្នែកសំខាន់ៗ រួមមានសវនកម្មសាខា សវនកម្មនាយកដ្ឋាន សវនកម្មផ្នែកពាក់ព័ន្ធ និងគម្រោងចាំបាច់ផ្សេងៗ ។

ផែនការរបស់យើង ក្នុងឆ្នាំ២០២៥ គឺបន្តការងារសវនកម្ម ស្របទៅតាមការវាយតម្លៃហានិភ័យ របស់សវនកម្មផ្ទៃក្នុង ការបន្តអនុវត្តវិធីសាស្ត្រកែលម្អហានិភ័យ និងការពង្រីកការវិភាគទិន្នន័យ / វិធីសាស្ត្រ Agile ទៅក្នុងការងារសវនកម្ម ព្រមទាំងការអនុវត្តគម្រោងចាំបាច់ផ្សេងៗទៀត។

# នីតិកម្ម និងលេខាធិការក្រុមហ៊ុន



**នាយកដ្ឋាននីតិកម្ម និងលេខាធិការក្រុមហ៊ុន មានផ្នែកនីតិកម្ម និងលេខាធិការក្រុមហ៊ុន។ ផ្នែកនីតិកម្ម ត្រួតពិនិត្យ លើទិដ្ឋភាពផ្នែកច្បាប់ នៃសកម្មភាព ដែលអនុវត្តដោយធនាគារ និងទទួលខុសត្រូវ លើការសម្របសម្រួល ផ្តល់ដំបូន្មាន និងពិនិត្យមើលលើផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ដើម្បីធានាការអនុវត្តអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗ។**

ផ្នែកនីតិកម្ម ដើរតួនាទីចម្បង ក្នុងការផ្តល់ដំបូន្មានផ្នែកច្បាប់ ទៅបុគ្គលិកទាំងអស់ នៅក្នុងធនាគារ ក្នុងការអនុវត្តការងាររបស់ពួកគេ ដើម្បីធានាបានថា អត្ថប្រយោជន៍របស់ធនាគារ ត្រូវបានការពារ ក្នុងការធ្វើអាជីវកម្ម លើគ្រប់វិស័យ។ ក្នុងនោះផងដែរ ផ្នែកនីតិកម្ម ក៏សម្របសម្រួលកិច្ចការ ទាក់ទងនឹងរឿងក្តីតុលាការ ដែលទទួលបាន ពីនាយកដ្ឋានផ្សេងៗរបស់ធនាគារ រួចហើយសហការជាមួយក្រុមមេធាវីខាងក្រៅ ដើម្បីតាមដានរឿងក្តីទាំងអស់របស់ធនាគារ។

ដើម្បីឱ្យស្របជាមួយនឹងអភិបាលកិច្ចល្អ ផ្នែកលេខាធិការក្រុមហ៊ុន ផ្តល់ការគាំទ្រផ្សេងៗ ទៅដល់ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ក្នុងការអនុវត្តកាតព្វកិច្ច និងទំនួលខុសត្រូវរបស់ពួកគាត់។ បន្ថែមពីនេះ លេខាធិការក្រុមហ៊ុន មានតួនាទីផ្តល់ដំបូន្មាន លើការងារអភិបាលកិច្ច រួមមានតម្រូវការ ផ្នែកច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ទៅគ្រប់ផ្នែក ក្នុងធនាគារ។ លេខាធិការក្រុមហ៊ុន ក៏ចាត់ចែងកិច្ចការ និងមុខងារប្រចាំថ្ងៃ ទាក់ទងនឹងលេខាធិការក្រុមហ៊ុនរបស់ធនាគារ រួមទាំងនីតិវិធីនានា ជាមួយអាជ្ញាធរ និងនិយ័តករពាក់ព័ន្ធ។

នាយកដ្ឋាននីតិកម្ម និងលេខាធិការក្រុមហ៊ុន ក៏ចូលរួមធ្វើការងារ ជាមួយក្រុមការងារគម្រោងផ្សេងៗរបស់ធនាគារ ដើម្បីធានាដល់ទំនួលខុសត្រូវរបស់ធនាគារ ចំពោះបទប្បញ្ញត្តិនានា។



# ๐๓

## អភិបាលកិច្ចធនាគារ


๓๖ ..... សេចក្តីថ្លែងការណ៍ ស្តីពីអភិបាលកិច្ចធនាគារ

๔๘ ..... របាយការណ៍គណៈកម្មាធិការសវនកម្ម

๕๑ ..... សេចក្តីថ្លែងការណ៍ ស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

๕๔ ..... រចនាសម្ព័ន្ធក្រុមហ៊ុនមេ

๕๕ ..... រចនាសម្ព័ន្ធក្រុមហ៊ុន

๕๖ ..... របាយការណ៍ព័ត៌មានរបស់ធនាគារ

# សេចក្តីថ្លែងការណ៍ ស្តីពីអភិបាលកិច្ចធនាគារ

ក្រុមប្រឹក្សាភិបាល មានជំនឿថា អភិបាលកិច្ចធនាគារដ៏រឹងមាំមួយ មានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការផ្តល់នូវតម្លៃជានិរន្តរ៍ ការលើកកម្ពស់សុចរិតភាព ក្នុងការធ្វើធុរៈកិច្ច និងការរក្សានូវទំនុកចិត្តរបស់វិនិយោគិន ចំពោះធនាគារឆ្ពោះទៅរកការសម្រេចបាននូវគោលដៅ និងទស្សនវិស័យរបស់ធនាគារ។

វប្បធម៌ និងរចនាសម្ព័ន្ធអភិបាលកិច្ច ប្រកបដោយប្រសិទ្ធភាព គឺជាធាតុសំខាន់បំផុត ក្នុងការកំណត់ អំពីរបៀបរបប ដែលធនាគារដំណើរការ ហើយថ្នាក់ដឹកនាំធនាគារ តែងតែសង្កត់ធ្ងន់ លើចំណុចនេះ ក្នុងការណែនាំ ដល់គ្រប់បុគ្គលិករបស់ខ្លួនទាំងអស់ ជាបន្តបន្ទាប់។ ក្របខណ្ឌអភិបាលកិច្ច ដែលធនាគារសម្រេចយក ត្រូវបានរៀបចំឡើង ដោយផ្អែកលើគោលការណ៍នានា និងការអនុវត្តល្អបំផុត ដូចមានចែងក្នុងប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងប្រកាស ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប សម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណ និងការអនុវត្តល្អបំផុត ជាលក្ខណៈអន្តរជាតិ ក្នុងអភិបាលកិច្ចធនាគារ ដែលពាក់ព័ន្ធ។

## ក្រុមប្រឹក្សាភិបាល

### ក្រុមប្រឹក្សាភិបាល និងតុល្យភាព នៃក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ននេះ ក្រុមប្រឹក្សាភិបាល មានសមាជិកចំនួន ០៦ រូប ដែលរួមមានអភិបាលប្រតិបត្តិចំនួន ០១ រូប និងអភិបាលមិនប្រតិបត្តិចំនួន ០៥ រូប ហើយក្នុងចំណោមអភិបាលទាំងអស់ មានអភិបាលចំនួន ០២ រូប ជាអភិបាលឯករាជ្យ គិតចាប់ពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥។ ក្រុមប្រឹក្សាភិបាល បានបញ្ជាក់ថា សមាសភាពក្រុមប្រឹក្សាភិបាល មានចំនួនអភិបាលឯករាជ្យគ្រប់គ្រាន់ ដែលអាចធ្វើការវិនិច្ឆ័យ ដោយឯករាជ្យបំផុត នៅក្នុងកិច្ចពិភាក្សានានា របស់ក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាល ក៏គោរពដំណើរការ នៃការធ្វើសេចក្តីសម្រេចរួមផងដែរ។

ក្រុមប្រឹក្សាភិបាល ទទួលបានអត្ថប្រយោជន៍ ពីការចូលរួមចំណែកនានា របស់អភិបាលមិនប្រតិបត្តិម្នាក់ៗ នៅក្នុងគ្រប់វិស័យទាំងអស់ នៃអាជីវកម្មរបស់ធនាគារ។ បន្ថែមពីលើជំនាញ និងបទពិសោធន៍ ផ្នែកអាជីវកម្មជាច្រើនឆ្នាំរបស់អភិបាលម្នាក់ៗ អភិបាលមិនប្រតិបត្តិ ក៏ធ្វើការវិនិច្ឆ័យ ដោយឯករាជ្យ ក្នុងកិច្ចពិភាក្សា ស្តីពីបញ្ហាយុទ្ធសាស្ត្រ សវនកម្ម ប្រតិបត្តិការ និងហានិភ័យផងដែរ។

រចនាសម្ព័ន្ធ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល ត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវ ដែលមានចែងក្នុងប្រកាសរបស់ ធនាគារជាតិ នៃកម្ពុជា។

សង្ខេប អំពីសមាសភាព នៃក្រុមប្រឹក្សាភិបាល គិតចាប់តាំងពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥ មានដូចក្នុងតារាងខាងក្រោម៖

| | |
|---|---|
| **សមាសភាពក្រុមប្រឹក្សាភិបាល** | • ៣៣% អភិបាលឯករាជ្យ<br>• ៦៧% អភិបាលមិនឯករាជ្យ |
| **ភេទ** | • ស្រី៖ ១ នាក់ ឬ ១៧%<br>• បុរស៖ ៥ នាក់ ឬ ៨៣% |
| **សញ្ជាតិ** | • ខ្មែរ៖ ២ នាក់ ឬ ៣៣%<br>• ម៉ាឡេស៊ី៖ ៣ នាក់ ឬ ៥០%<br>• ឥណ្ឌា៖ ១ នាក់ ឬ ១៧% |
| **អាយុ** | • ក្រោម ៥០ ឆ្នាំ៖ ២ នាក់<br>• ៥០ ឆ្នាំ និង លើស៖ ៤ នាក់ |
| **អាណត្តិ** | • ក្រោម ៣ ឆ្នាំ៖ ២ នាក់<br>• ៣ ឆ្នាំ និង លើស៖ ៤ នាក់ |

ដើម្បីធានាឱ្យបាននូវតុល្យភាព នៃអំណាច ការបង្កើននូវគណនេយ្យភាព និងសមត្ថភាព ក្នុងការធ្វើសេចក្តីសម្រេច ប្រកបដោយឯករាជ្យភាព នោះតួនាទីរបស់ប្រធានក្រុមប្រឹក្សាភិបាល និងតួនាទីរបស់អភិបាលប្រតិបត្តិ ត្រូវបានបែងចែក និងដាក់ឱ្យនៅដាច់ពីគ្នា ដោយមានការបែងចែកយ៉ាងច្បាស់លាស់ អំពីការទទួលខុសត្រូវ រវាងប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលប្រតិបត្តិ ដើម្បីចៀសវាងកុំឱ្យបុគ្គលណាម្នាក់ ឬក្រុមណាមួយ អាចត្រួតត្រា លើដំណើរការ នៃការធ្វើសេចក្តីសម្រេចបាន។

### ប្រធានក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ត្រូវបានដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល គឺ Tan Sri Mohd Nasir Bin Ahmad ដែលមានសញ្ជាតិម៉ាឡេស៊ី និងដែលបានតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាល នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។ Tan Sri Mohd Nasir Bin Ahmad ទទួលខុសត្រូវ លើការដឹកនាំ និងការគ្រប់គ្រងក្រុមប្រឹក្សាភិបាល និងធានាប្រសិទ្ធភាព នៃការបំពេញមុខងារ របស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា របស់ក្រុមប្រឹក្សាភិបាល។ ប្រធានក្រុមប្រឹក្សាភិបាល បំពេញតួនាទីផ្លូវការជាថ្នាក់ដឹកនាំ និងធ្វើជាអធិបតី ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលទាំងអស់ ដឹកនាំការពិភាក្សា រវាងអភិបាល ព្រមទាំងតម្រង់ទិសក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យ លើការគ្រប់គ្រងធនាគារផងដែរ។ ប្រធានក្រុមប្រឹក្សាភិបាល ធ្វើការសម្របសម្រួលលំហូរព័ត៌មាន រវាងគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល ព្រមទាំងប្រឹក្សាយោបល់ ជាមួយគណៈគ្រប់គ្រង ដើម្បីដាក់ចេញនូវរបៀបវារៈ សម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនីមួយៗ។

### អភិបាលប្រតិបត្តិ

លោក ប៊ុន យីន ដែលមានសញ្ជាតិខ្មែរ គឺជាប្រធាននាយកប្រតិបត្តិរបស់ធនាគារ ហើយក៏ជាអភិបាលប្រតិបត្តិផងដែរ។ លោកត្រូវបានតែងតាំងជា ប្រធាននាយកប្រតិបត្តិ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ និងតែងតាំងជាអភិបាលប្រតិបត្តិ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥។ លោក ប៊ុន យីន ក៏ជាបុគ្គលដំបូង ដែលដឹកនាំធនាគារបរទេសលំដាប់អន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

ក្នុងនាមជាអភិបាលប្រតិបត្តិ / ប្រធាននាយកប្រតិបត្តិ លោក ប៊ុន យីន ទទួលខុសត្រូវរួម លើការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល រៀបចំអាជីវកម្មរបស់ធនាគារ និងដឹកនាំប្រតិបត្តិការ ស្របតាមគោលដៅយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្ម។ លោកធ្វើការដឹកនាំគណៈគ្រប់គ្រង ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្នុងឋានៈជាអភិបាលប្រតិបត្តិ / ប្រធាននាយកប្រតិបត្តិ លោកទទួលខុសត្រូវ ចំពោះមុខក្រុមប្រឹក្សាភិបាល លើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ។

### ទំហំ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល

ទំហំ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានពិនិត្យឡើងវិញ ជាទៀងទាត់ ដោយពិនិត្យមើល ទៅលើវិសាលភាព លក្ខណៈ ភាពខុសប្លែកគ្នា និងការពង្រីកអាជីវកម្មធនាគារ។ ក្រុមប្រឹក្សាភិបាល យល់ឃើញ និងអះអាងថា សមាសភាពក្រុមប្រឹក្សាភិបាល នាពេលបច្ចុប្បន្ន មានលក្ខណៈគ្រប់គ្រាន់ សម្រាប់ការគ្រប់គ្រងអាជីវកម្មទាំងមូលរបស់ធនាគារ។ សមាជិកក្រុមប្រឹក្សាភិបាល បច្ចុប្បន្ន បាននាំយកនូវចំណេះដឹង បទពិសោធន៍ និងជំនាញដ៏មានតម្លៃ មកកាន់ក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំធនាគារ ឆ្ពោះទៅសម្រេចទស្សនវិស័យ របស់ក្រុមហ៊ុនមេ ស៊ីអាយអិមប៊ី គ្រុប (CIMB Group)។

អភិបាលទាំងអស់របស់ធនាគារ សុទ្ធតែបានបំពេញ តាមលក្ខខណ្ឌវិនិច្ឆ័យគ្រប់គ្រាន់ ដើម្បីទទួលបានមុខតំណែងជា អភិបាល ដូចមានចែងក្នុងប្រកាស របស់ធនាគារជាតិ នៃកម្ពុជា។ គ្រប់អភិបាលឯករាជ្យទាំងអស់របស់ធនាគារ បង្ហាញពីការវិនិច្ឆ័យ ដោយឯករាជ្យ និងអាចទទួលយកបាន និងមិនចូលរួម ក្នុងប្រតិបត្តិការអាជីវកម្មណា ដែលអាចមានផលប៉ះពាល់ ដល់ការវិនិច្ឆ័យ និងការធ្វើសេចក្តីសម្រេច ដោយឯករាជ្យរបស់ខ្លួន។

ប្រវត្តិសង្ខេបរបស់អភិបាលម្នាក់ៗ មានបង្ហាញនៅលើទំព័រ ៦៦ ដល់ ៧៧ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

### ក្រមសីលធម៌របស់អភិបាល

ក្រុមប្រឹក្សាភិបាល គោរពតាមវិធាន នៃក្រមសីលធម៌ ដែលមានចែងក្នុងប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា និងក្រមប្រតិបត្តិ សម្រាប់អភិបាលរបស់ធនាគារ។

អភិបាលធនាគារ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ដែលជាគោលការណ៍ណែនាំ សម្រាប់ការអនុវត្តនូវបទដ្ឋានក្រមសីលធម៌មួយដ៏ត្រឹមត្រូវ និងការអនុវត្តអាជីវកម្ម ប្រកបដោយភាពប្រុងប្រយ័ត្ន។ នេះក៏ដូចជាបទដ្ឋានអាកប្បកិរិយា ប្រកបដោយក្រមសីលធម៌ សម្រាប់អភិបាលម្នាក់ៗ ដោយផ្អែកទៅលើគោលការណ៍សុចរិតភាព ការទទួលខុសត្រូវ ភាពស្មោះត្រង់ និងការទទួលខុសត្រូវ ចំពោះសង្គម។

## កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល គឺជាអង្គភាពមួយរបស់ធនាគារ ដែលធ្វើសេចក្តីសម្រេចចុងក្រោយបង្អស់លើកលែងតែបញ្ហាណា ដែលទាមទារឱ្យមានការអនុម័តយល់ព្រម ពីភាគទុនិក។ ក្រុមប្រឹក្សាភិបាលដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវទាំងស្រុង លើការដឹកនាំ គ្រប់គ្រង ណែនាំ និងត្រួតពិនិត្យ លើគ្រប់ប្រតិបត្តិការទាំងមូលរបស់ធនាគារ និងពង្រឹងបទដ្ឋាន នៃគណនេយ្យភាព ក្នុងគោលគំនិតជួយដល់គណៈគ្រប់គ្រង ដើម្បីអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវរួម លើការបង្កើតក្របខណ្ឌការងារ នៃអភិបាលកិច្ចល្អ នៅក្នុងធនាគារ រាប់បញ្ចូលទាំងដំណើរការ នៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាមច្បាប់។ សមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប នាំយកនូវការវិនិច្ឆ័យឯករាជ្យ ចំណេះដឹងផ្សេងៗគ្នា និងបទពិសោធន៍នានា ដើម្បីធ្វើការពិភាក្សា អំពីបញ្ហានានា ទាក់ទងនឹងយុទ្ធសាស្ត្រ ប្រតិបត្តិការ ធនធាន និងការធ្វើអាជីវកម្ម។

ក្រុមប្រឹក្សាភិបាល បានអនុម័ត លើរបៀបវារៈ នៃបញ្ហាមួយចំនួន ដែលត្រូវបានរៀបចំ សម្រាប់សុំការអនុម័ត ពីក្រុមប្រឹក្សាភិបាល រាប់បញ្ចូលទាំង (ក្នុងចំណោមចំណុចផ្សេងៗទៀតជាច្រើន) ការត្រួតពិនិត្យឡើងវិញ និងការយល់ព្រម លើចំណុច ដូចខាងក្រោម៖

- ផែនការយុទ្ធសាស្ត្រ/អាជីវកម្ម និងគម្រោងថវិកាប្រចាំឆ្នាំ។
- ការវិនិយោគថ្មីៗ ការផ្គាច់ខ្លួន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញក្រុមហ៊ុន ការរៀបចំរចនាសម្ព័ន្ធក្រុមហ៊ុនឡើងវិញ រាប់បញ្ចូលទាំងការបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធ ការចូលហ៊ុន ឬសម្ព័ន្ធយុទ្ធសាស្ត្រ ទាំងនៅក្នុងស្រុក និងក្រៅស្រុក។
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងភាគលាភបណ្តោះអាសន្ន និងការផ្តល់យោបល់ លើភាគលាភ ចុងក្រោយ ដែលត្រូវចែកជូនភាគហ៊ុនិក នៅមុនពេលផ្សព្វផ្សាយ និងប្រកាសផ្សាយជាសាធារណៈអំពីការបែងចែកភាគលាភ។
- ការតែងតាំងអភិបាល និងប្រធាននាយកប្រតិបត្តិថ្មី និងការកំណត់ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ ផ្សេងៗរបស់ពួកគាត់។

ការទទួលខុសត្រូវរួមសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាល មានដូចខាងក្រោម៖

- ផ្តល់នូវគោលដៅ និងគោលនយោបាយច្បាស់លាស់ សម្រាប់ឱ្យមន្ត្រីប្រតិបត្តិជាន់ខ្ពស់អនុវត្ត។
- ធានាឱ្យមាននូវការត្រួតពិនិត្យគ្រប់គ្រាន់ ព្រមទាំងមានប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រាន់ ដើម្បីសម្រួល ដល់ការអនុវត្តគោលនយោបាយរបស់ធនាគារផងដែរ។
- តាមដាន អំពីភាពជោគជ័យរបស់គណៈគ្រប់គ្រង ក្នុងការអនុវត្តយុទ្ធសាស្ត្រ ផែនការ និងគម្រោងថវិកា ដែលបានអនុម័តរួច។
- ស្វែងយល់ ពីហានិភ័យចម្បងៗ ដែលទាក់ទងនឹងអាជីវកម្មរបស់ធនាគារ និងធានាថា មានប្រព័ន្ធបច្ចេកវិទ្យា ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រង លើហានិភ័យ ប្រកបដោយប្រសិទ្ធភាព ក្នុងទស្សនវិស័យ ទទួលបានលទ្ធផល និងភាពជោគជ័យរយៈពេលវែង សម្រាប់ធនាគារ។
- តាមដានត្រួតពិនិត្យ និងសិក្សាវាយតម្លៃ លើការអភិវឌ្ឍ ដែលអាចជៈឥទ្ធិពល ដល់ផែនការយុទ្ធសាស្ត្រនានារបស់ធនាគារ។
- ពិនិត្យឡើងវិញ លើភាពគ្រប់គ្រាន់ និងសុចរិតភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងប្រព័ន្ធព័ត៌មានគ្រប់គ្រង រាប់បញ្ចូលទាំងប្រព័ន្ធ នៃការប្រតិបត្តិតាមវិធានច្បាប់ បទបញ្ជាសារាចរ និងគោលការណ៍ណែនាំនានាជាធរមាន។
- បញ្ជៀសវិញទផលប្រយោជន៍ និងធានាការផ្សព្វផ្សាយព័ត៌មាន អំពីវិវាទផលប្រយោជន៍ដែលអាចកើតមាន។
- ប្រកាន់ខ្ជាប់ និងអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិ ស្តីពីធនាគារ ព្រមទាំងច្បាប់ វិធាន និងបទប្បញ្ញត្តិផ្សេងទៀតផងដែរ។

ក្រៅពីការទទួលខុសត្រូវសំខាន់ៗ ដែលបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាភិបាល ក៏ប្រគល់ការទទួលខុសត្រូវជាក់លាក់មួយចំនួន ឱ្យគណៈកម្មាធិការនានាផងដែរ។ ក្នុងខណៈដែលគណៈកម្មាធិការទាំងនេះ មានសិទ្ធិអំណាចពិភាក្សា និងសម្រេច លើបញ្ហាជាក់លាក់ណាមួយ គណៈកម្មាធិការនោះក៏ត្រូវរាយការណ៍ ជូនក្រុមប្រឹក្សាភិបាល អំពីសេចក្តីសម្រេច និង/ឬ អនុសាសន៍របស់ខ្លួន ហើយការទទួលខុសត្រូវចុងក្រោយ ចំពោះបញ្ហាទាំងអស់នោះ នៅតែជារបស់ក្រុមប្រឹក្សាភិបាលទាំងមូល។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវ របស់គណៈកម្មាធិការនានា មានបង្ហាញនៅទំព័រ ៤០ ដល់ ៤៧។

## ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល

ធនាគារអនុវត្ត តាមសេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ (Group Nomination and Remuneration Committee) ដែលជាគណៈកម្មាធិការមួយ របស់ស៊ីអាយអិមប៊ីគ្រុប ហូលឌីង ប៊ើហាដ (CIMB Group Holdings Berhad)។ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ នៃក្រុមហ៊ុនមេ ទទួលបន្ទុកកំណត់ និងបញ្ជូនបេក្ខភាព ដែលសក្តិសម សម្រាប់តំណែងអភិបាល ទៅក្រុមប្រឹក្សាភិបាល ដើម្បីសុំការអនុម័តយល់ព្រម លើការតែងតាំង មិនថាសម្រាប់បំពេញតំណែង ដែលទំនេរ ឬបន្ថែមលើតំណែង ដែលមានស្រាប់ ដើម្បីបំពេញតាមតម្រូវការប្រែប្រួលរបស់ធនាគារ។ មុនពេលផ្តល់អនុសាសន៍ លើការតែងតាំងអភិបាល ទៅក្រុមប្រឹក្សាភិបាល គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេ នឹងអនុវត្តការវាយតម្លៃហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយ លើបេក្ខភាពជាអភិបាល ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនានា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ ធនាគារក៏ពិចារណា ទៅលើប្រភេទអាជីវកម្មរបស់ធនាគារ និងផ្គូផ្គង ជាមួយសមត្ថភាព និងការរួមចំណែក ដែលរំពឹងទុក ពីបេក្ខភាព ដែលទទួលតំណែងនេះផងដែរ។

នីតិវិធី នៃការតែងតាំង ត្រូវធ្វើឡើង ស្របតាមប្រកាស និងក្របខណ្ឌរបស់ក្រុមហ៊ុនមេ ស្តីពីបណ្តុំជំនាញ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល ដែលក្របខណ្ឌនេះ បានដាក់ចេញនូវគោលការណ៍ណែនាំជាក់លាក់ សម្រាប់ការវាយតម្លៃរបស់គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ ក្នុងការកំណត់ តែងតាំង និងជ្រើសរើសអភិបាលថ្មី ស្របពេលដែលផែនការបន្តតំណែងរបស់ក្រុមប្រឹក្សាភិបាល ក៏ត្រូវបានយកចិត្តទុកដាក់។ គោលការណ៍ណែនាំទាំងនោះ កំណត់នូវបទពិសោធន៍ និងជំនាញសំខាន់ ដែលចាំបាច់ និងចែង អំពីចំនួនអប្បបរមា នៃសមាជិកក្រុមប្រឹក្សាភិបាល តម្រូវសម្រាប់បណ្តុំជំនាញនីមួយៗ និងចែង អំពីតម្រូវការអភិបាលកិច្ចផ្សេងទៀត លើទំហំក្រុមប្រឹក្សាភិបាល អាណត្តិ នៃការតែងតាំង អាយុ និងភេទ។

គោលការណ៍ និងនីតិវិធីរបស់ក្រុមហ៊ុនមេ ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប សម្រាប់បុគ្គលកាន់មុខងារ ដែលមានការទទួលខុសត្រូវសំខាន់របស់ក្រុមហ៊ុន (គោលការណ៍ ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប) ក៏តម្រូវឱ្យមានការវាយតម្លៃត្រឹមត្រូវ លើអភិបាលថ្មីៗ ដើម្បីធានាថា បេក្ខភាពនោះ មានលក្ខខណ្ឌសក្តិសម និងត្រឹមត្រូវ សម្រាប់មុខតំណែង ដែលត្រូវតែងតាំង។

គោលការណ៍ ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប ចែងអំពីលក្ខណៈវិនិច្ឆ័យមួយចំនួន សម្រាប់ធ្វើការវាយតម្លៃ ពីភាពសក្តិសមរបស់បេក្ខភាព ដែលត្រូវតែងតាំង ដូចខាងក្រោម៖

(i) សុចរិតភាព ភាពស្មោះត្រង់ និងកេរ្តិ៍ឈ្មោះបុគ្គល ដែលបេក្ខភាពម្នាក់ៗត្រូវមាន ដូចជាមានភាពស្មោះត្រង់ សុចរិតភាព ភាពឧស្សាហ៍ព្យាយាម គំនិតឯករាជ្យ និងមិនលម្អៀង។
(ii) សមត្ថភាព ដែលបេក្ខជនត្រូវមាន ដូចជាជំនាញ បទពិសោធន៍ការងារ សមត្ថភាព និងការប្តេជ្ញាចិត្ត ដែលចាំបាច់ ដើម្បីអនុវត្តតួនាទីរបស់ខ្លួន។
(iii) សុចរិតភាព ផ្នែកហិរញ្ញវត្ថុ ដែលបេក្ខជន ត្រូវគ្រប់គ្រងតណាទាន ឬកិច្ចការហិរញ្ញវត្ថុរបស់ខ្លួនដោយប្រុងប្រយ័ត្នបំផុត។

នីតិវិធី សម្រាប់កំណត់អត្តសញ្ញាណ និងស្នើឈ្មោះបេក្ខជន ដោយគណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ របស់ក្រុមហ៊ុនមេ សម្រាប់ការតែងតាំងតំណែងនេះមាន ០៥ ដំណាក់កាល ដូចខាងក្រោម៖

### ក្របខណ្ឌ នៃការស្នើឈ្មោះបេក្ខជន




សំណើសុំតែងតាំងអភិបាលថ្មី គឺអាស្រ័យលើការពិនិត្យ និងអនុម័តយល់ព្រមជាមុន របស់ធនាគារជាតិ នៃកម្ពុជា។

### ការតែងតាំង និងការបោះឆ្នោតជ្រើសតាំងអភិបាលជាថ្មីម្តងទៀត

លក្ខន្តិក:ធនាគារតម្រូវថា នៅក្នុងរយៈពេល ០៣ ឆ្នាំម្តង អភិបាលទាំងអស់ ត្រូវបញ្ចប់ ពីមុខតំណែង យ៉ាងហោចណាស់ឱ្យបានម្តង ប៉ុន្តែពួកគាត់នៅមានសិទ្ធិឈរឈ្មោះ ឱ្យគេបោះឆ្នោតជ្រើសរើសសាជាថ្មីបាន នៅក្នុងមហាសន្និបាតប្រចាំឆ្នាំ។ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេ ត្រូវផ្តល់អនុសាសន៍ លើសំណើសុំតែងតាំង និងបោះឆ្នោតជ្រើសរើសអភិបាលសាជាថ្មី ជូនក្រុមប្រឹក្សាភិបាល មុននឹងដាក់ជូនភាគទុនិកអនុម័ត នៅក្នុងមហាសន្និបាតប្រចាំឆ្នាំ។

## កិច្ចប្រជុំ និងការផ្តល់ព័ត៌មាន ទៅក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ត្រូវជួបប្រជុំជាប្រចាំ ដើម្បីពិភាក្សា លើយុទ្ធសាស្ត្រអាជីវកម្ម ប្រតិបត្តិការ ហិរញ្ញវត្ថុ បញ្ហាដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិ និងអភិបាលកិច្ច ក៏ដូចជារបាយការណ៍ ស្តីពីបញ្ហា ដែលគណៈកម្មាធិការនីមួយៗ បានពិភាក្សាគ្នា។ ក្រុមប្រឹក្សាភិបាល ជួបប្រជុំយ៉ាងហោចណាស់នៅរៀងរាល់ ០២ ខែម្តង ហើយក្នុងចំណោមរបៀបវារៈទាំងអស់ ដែលដាក់ចូលក្នុងកិច្ចប្រជុំ ដើម្បីទទួលការពិភាក្សា ឬការអនុម័ត ពីក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាភិបាល ពិនិត្យឡើងវិញ លើប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ ការគ្រប់គ្រងហានិភ័យ និងរបាយការណ៍ ស្តីពីការអនុវត្តបទប្បញ្ញត្តិ។ ជារៀងរាល់ឆ្នាំ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវបានកំណត់កាលបរិច្ឆេទមុនរួចជាស្រេច ដើម្បីអាចឱ្យអភិបាលទាំងអស់ មានភាពងាយស្រួល ក្នុងការរៀបចំធ្វើកាលវិភាគប្រជុំផ្ទាល់ខ្លួនរបស់អភិបាល។ ឯកសារ សម្រាប់កិច្ចប្រជុំ ដែលមានសំណើ និងរបាយការណ៍ផ្សេងៗទៀត ត្រូវបានចែកជូនក្រុមប្រឹក្សាភិបាល ឱ្យបានមុនពេលដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីអាចឱ្យអភិបាលទាំងអស់មានពេលវេលាគ្រប់គ្រាន់ ក្នុងការធ្វើការវាយតម្លៃ លើសំណើទាំងនោះ ហើយប្រសិនបើចាំបាច់ ស្នើសុំព័ត៌មានបន្ថែម ដើម្បីជួយសម្រួលអភិបាល ក្នុងការបំពេញកាតព្វកិច្ច ប្រកបដោយប្រសិទ្ធភាព។ នីតិវិធីនានា ត្រូវបានបង្កើតឡើង ទាក់ទងនឹងទម្រង់ ខ្លឹមសារ បទបង្ហាញ និងការចែកជូនឯកសារ សម្រាប់កិច្ចប្រជុំ។ ឯកសារ សម្រាប់កិច្ចប្រជុំ បញ្ជាក់យ៉ាងច្បាស់ អំពីប្រវត្តិ គោលបំណង បញ្ហាសំខាន់ៗ សនិទានភាព ផលប៉ះពាល់ និងព័ត៌មានផ្សេងៗទៀត ដែលទាក់ទងនឹងសំណើនីមួយៗ ដើម្បីជួយឱ្យក្រុមប្រឹក្សាភិបាល អាចធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព។

អភិបាល មានលទ្ធភាពទទួលបានគ្រប់ព័ត៌មានទាំងអស់របស់ធនាគារ។ តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដែលធ្វើឡើងជាទៀងទាត់ ក្រុមប្រឹក្សាភិបាល ទទួលនូវព័ត៌មាន ដែលបានធ្វើបច្ចុប្បន្នភាព អំពីការអភិវឌ្ឍ និងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ក៏ដូចជាទទួលបានផងដែរ នូវឯកសារមួយឈុត រាប់បញ្ចូលទាំងរបាយការណ៍ ជាទៀងទាត់ ស្តីពីការវិវឌ្ឍ នៃអាជីវកម្ម និងឯកសារផ្សេងៗ សម្រាប់ពិភាក្សា ទាក់ទងនឹងបញ្ហាជាក់លាក់ណាមួយ។

អភិបាល ក៏ត្រូវបានអនុញ្ញាតឱ្យចូលរួម ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល តាមរយៈប្រព័ន្ធទូរសព្ទផងដែរ។ រាល់ការពិភាក្សាដេញដោល នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល រាប់បញ្ចូលទាំងការឆ្ងែងគំនិតគ្នា ត្រូវបានកត់ត្រាទុកទាំងស្រុង សម្រាប់ធ្វើជាកំណត់ហេតុ នៃដំណើរការពិភាក្សារបស់អភិបាល។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានផ្ញើទៅគណៈគ្រប់គ្រង យ៉ាងយូរក្នុងរយៈពេលបីថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកិច្ចប្រជុំ ត្រូវបានបញ្ចប់ ដើម្បីជានាថា សេចក្តីសម្រេច និងការណែនាំផ្សេងៗ ត្រូវបានអនុវត្ត ទាន់ពេលវេលា។ សេចក្តីព្រាងកំណត់ហេតុ ត្រូវបានបញ្ជូនទៅអភិបាលទាំងអស់ ដើម្បីធ្វើការពិនិត្យ និងផ្តល់អនុសាសន៍ មុនពេលដាក់បញ្ជូនកំណត់ហេតុចុងក្រោយ ទៅក្នុងរបៀបវារៈសម្រាប់អនុម័តយល់ព្រម នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលបន្ទាប់។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អភិបាលប្រតិបត្តិ ត្រូវធ្វើការពន្យល់ឱ្យបានក្បោះក្បាយ អំពីបញ្ហាសំខាន់ៗ ទាក់ទងនឹងអាជីវកម្ម និងប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ។ ប្រធានគណៈកម្មាធិការសវនកម្ម ផ្តល់សេចក្តីសង្ខេប អំពីរបាយការណ៍សវនកម្ម ដែលបានពិភាក្សា នៅកិច្ចប្រជុំគណៈកម្មាធិការសវនកម្ម ដើម្បីជាកំណត់ត្រា សម្រាប់ក្រុមប្រឹក្សាភិបាល ដែលរួមមានលទ្ធផលសវនកម្មសំខាន់ៗ ដែលធ្វើឡើងដោយសវនករផ្ទៃក្នុង ដើម្បីឱ្យក្រុមប្រឹក្សាភិបាល ធ្វើការពិភាក្សា និងណែនាំ។ បន្ថែមពីលើនេះទៀត របាយការណ៍ ពីនាយក នៃនាយកដ្ឋានប្រតិបត្តិតាម អំពីស្ថានភាព នៃការគោរពច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ និងនីតិវិធីផ្ទៃក្នុង ដែលបានអនុម័តដោយធនាគារ ក៏ត្រូវបានរាយការណ៍ ជូនក្រុមប្រឹក្សាភិបាល ដើម្បីជ្រាបជាព័ត៌មានផងដែរ។ គណៈគ្រប់គ្រង ក៏ត្រូវបានអញ្ជើញឱ្យធ្វើបទបង្ហាញ អំពីសំណើ និងឆ្លើយតបសំណួរផ្សេងៗ ដែលក្រុមប្រឹក្សាភិបាល ចោទសួរតាមការចាំបាច់ផងដែរ។ គណៈគ្រប់គ្រង ត្រូវចាត់វិធានការជាបន្ទាន់ លើរាល់បញ្ហា ដែលលើកឡើងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងត្រូវធ្វើបច្ចុប្បន្នភាព ទៅក្រុមប្រឹក្សាភិបាល អំពីស្ថានភាព នៃបញ្ហាទាំងនោះ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកក្រោយ ឬប្រសិនបើយល់ថាបន្ទាន់ ត្រូវបញ្ជូនតាមការជូនដំណឹង ជាលាយលក្ខណ៍អក្សរ។

អភិបាលណាម្នាក់ ដែលមានជាប់ពាក់ព័ន្ធទទួលបានផលប្រយោជន៍ ពីសំណើណាមួយ ឬប្រតិបត្តិការណាមួយ ត្រូវប្រកាសប្រាប់ អំពីផលប្រយោជន៍ ដែលពាក់ព័ន្ធនឹងខ្លួន ហើយត្រូវដកខ្លួនចេញពីការពិភាក្សា និងការបោះឆ្នោតគាំទ្រសំណើ ឬកិច្ចការ ដែលបានស្នើនោះ។ នីតិវិធីនេះ ត្រូវបានកត់ត្រាទុកទាំងស្រុង នៅក្នុងកំណត់ហេតុ នៃដំណើរការកិច្ចប្រជុំ។

នៅដើមឆ្នាំហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាល ពិចារណា លើចរិកប្រចាំឆ្នាំរបស់ធនាគារ ស្របជាមួយនឹងយុទ្ធសាស្ត្រ និងផែនការរបស់ធនាគារ ដែលបានបង្កើតឡើង នៅក្នុងកិច្ចប្រជុំពិភាក្សាថ្នាក់គ្រប់គ្រងប្រចាំឆ្នាំ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសរុបចំនួន ០៧ លើក (កិច្ចប្រជុំពិសេសចំនួន ០១ លើក និងកិច្ចប្រជុំ តាមកាលវិភាគ ដែលបានកំណត់ចំនួន ០៦ លើក) ត្រូវបានរៀបចំឡើង នៅឆ្នាំ២០២៤ ដោយមានវត្តមានរបស់អភិបាល ដូចមានរៀបរាប់ខាងក្រោម៖

| អភិបាល | បានចូលរួម | ចំនួនកិច្ចប្រជុំ |
|---|---|---|
| **Tan Sri Mohd Nasir Bin Ahmad**[*9]<br>ប្រធានក្រុមប្រឹក្សាភិបាល / អភិបាលមិនឯករាជ្យមិនប្រតិបត្តិ | ៧ | ៧ |
| **ឡុង ចិង**<br>អភិបាលឯករាជ្យមិនប្រតិបត្តិ | ៧ | ៧ |
| **Aisyah Lam Binti Abdullah**<br>អភិបាលឯករាជ្យមិនប្រតិបត្តិ | ៧ | ៧ |
| **Ahmad Shazli Bin Kamarulzaman**[*២]<br>អភិបាលមិនឯករាជ្យមិនប្រតិបត្តិ | ៧ | ៧ |
| **Cheong Weng Teong**[*២]<br>អភិបាលមិនឯករាជ្យមិនប្រតិបត្តិ | ៧ | ៧ |
| **ប៊ុន យីន**<br>អភិបាលមិនឯករាជ្យប្រតិបត្តិ និងជា ប្រធាននាយកប្រតិបត្តិ | ៦ | ៧ |

**កំណត់សម្គាល់៖**

*[*9] Tan Sri Mohd Nasir Bin Ahmad ដែលជាប្រធានក្រុមប្រឹក្សាភិបាល បានផ្លាស់ប្តូរតួនាទីពី អភិបាលឯករាជ្យមិនប្រតិបត្តិ ទៅ អភិបាលមិនឯករាជ្យមិនប្រតិបត្តិ គិតចាប់ពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥*

*[*២] ចូលនិវត្តន៍ ពីធនាគារ គិតចាប់ពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥*

### ការបណ្តុះបណ្តាល និងការអភិវឌ្ឍរបស់អភិបាល

កម្មវិធីបណ្តុះបណ្តាលអភិបាល គឺជាដំណើរការដ៏សំខាន់មួយ ក្នុងការតែងតាំងអភិបាលថ្មី។ ក្រុមប្រឹក្សាភិបាល ក៏ត្រូវយកចិត្តទុកដាក់ លើតម្រូវការ ក្នុងការយល់ដឹង អំពីច្បាប់ បទប្បញ្ញត្តិថ្មីៗ បទដ្ឋានគណនេយ្យ ការប្រែប្រួលហានិភ័យអាជីវកម្ម និន្នាការទីផ្សារ និងការវិវឌ្ឍចុងក្រោយ បញ្ហាប្រឈមសំខាន់ៗ នៅក្នុងទីផ្សារក្នុងស្រុក និងក្នុងតំបន់ និងក្នុងវិស័យធនាគារ។ ក្នុងគោលបំណងនេះ ក្រុមប្រឹក្សាភិបាល ធ្វើការវាយតម្លៃ លើតម្រូវការបណ្តុះបណ្តាល ដោយឈរលើមូលដ្ឋានវាយតម្លៃតាមដំណាក់កាល ហើយកំណត់អំពីចំណុច ដែលអាចពង្រីកចំណេះដឹងរបស់អភិបាល អំពីបញ្ហាដែលទាក់ទងនឹងធនាគារ។

វគ្គបណ្តុះបណ្តាល ដែលអភិបាលបានចូលរួម នៅក្នុងឆ្នាំ ២០២៤៖

| ប្រធានបទ | ចូលរួមដោយ |
|---|---|
| Cambodia-Malaysia Business Forum 2024 | Tan Sri Mohd Nasir Bin Ahmad |
| Engagement with Chairpersons & CEOs of Banking Institutions | |
| Common Reporting Standard and FATCA | |
| IASB-MASB Virtual Outreach ED Business Combinations - Disclosures, Goodwill & Impairment | |
| Khazanah Event Sharing Session on The Future of Cybersecurity with Artificial Intelligence (AI)) | |
| Technology Update on Artificial Intelligence (AI) | |
| FIDE FORUM Board Culture One-to-One Session | |
| INCEIF Forum Session: Navigating Ethical Challenges in Leadership: Building a Sustainable Corporate Culture | |
| Cybersecurity Awareness for Board of Directors | |
| Navigating the Future with Emerging Technologies | |
| Cyber Threat Landscape and Why It Matters to CIMB | |
| Making Sustainability a Priority in the Company's Strategy and Actions | |
| Sustainability Strategy for 2025-2030 | |
| Board Strategic Offsite 2024 | |
| AICB - Fireside Chat Session | |
| FIDE FORUM x ICAEW Engagement Session - Achieving Equity: A Practical Approach to Diversity, Equity, and Inclusion (DEI) | |
| Regional Audit Planning Summit 2024 | លោកស្រី Aisyah Lam Binti Abdullah |
| Joint Board Meeting on Risk Posture | |
| Joint Board for Group Sustainability / Joint Board Meeting on Sustainability Reporting | |
| Embedding Business and Human Rights in Financial Institutions | |
| Regional Audit Planning Summit 2024 | លោក ឡុង ប៊ាង |
| Joint Board for Group Sustainability / Joint Board Meeting on Sustainability Reporting | |
| 2025 CIMB Group Risk Posture Combined Boards Workshop | |
| Civil Law System as Basis of Business Law and Recognition of Facts and Evidence in Civil Procedure | |
| Effective Dispute Resolution by Mediation | |
| Embedding Business and Human Rights in Financial Institutions | |
| Regional Audit Planning Summit 2024 | លោក Cheong Weng Teong |
| Scenario-Based FSA/IFSA 2013: Financial Services/Islamic Financial Services Act 2013 for Consumer Banking | |
| Anti-Money Laundering/Counter Financing of Terrorism | |
| Data Protection | |
| Information Security Awareness | |
| Islamic Finance | |
| Operational Risk Management – Level 1 | លោក ប៊ុន យ៉ីន |
| Workshop on Laws on Financial Institutions | |
| Trust Mechanism in Cambodia | |
| Workshop Self and Team Alignment & Growth Mindset and Moving Forward | |
| Best Practices in Sales Sharing | |

## លេខាធិការក្រុមហ៊ុន

លេខាធិការក្រុមហ៊ុន បង្ហាញពីការគាំទ្រជាបន្តបន្ទាប់ ក្នុងការផ្តល់យោបល់ និងជួយក្រុមប្រឹក្សាភិបាល លើបញ្ហា ដែលទាក់ទងនឹងកិច្ចការរបស់ធនាគារ រាប់បញ្ចូលទាំងបញ្ហា ដែលទាក់ទងនឹងការអនុវត្ត ស្របតាមបទប្បញ្ញត្តិរបស់ក្រុមហ៊ុន អភិបាលកិច្ចក្រុមហ៊ុន និងការអនុវត្តល្អបំផុត ប្រសិទ្ធភាព នៃសាលប្រជុំ និងកាតព្វកិច្ច និងការទទួលខុសត្រូវរបស់អភិបាល។ ក្នុងអំឡុងឆ្នាំ២០២៤ ដំណើរការផ្សេងៗ របស់ក្រុមប្រឹក្សាភិបាល ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ជាមួយនឹងទស្សនៈលើកកម្ពស់ដំណើរការ នៃការធ្វើសេចក្តីសម្រេច និងប្រសិទ្ធភាព នៃមុខងារក្រុមប្រឹក្សាភិបាល។

លេខាធិការក្រុមហ៊ុន ធានាថា កិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិក ត្រូវបានរៀបចំឡើង ស្របតាមវិធានច្បាប់ និងការអនុវត្តល្អបំផុតរបស់ធនាគារ ហើយធានាថា ការកត់ត្រាដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិក ត្រូវបានកត់ត្រាទុកទាំងស្រុង សម្រាប់ធ្វើជាកំណត់ហេតុ និងរក្សាទុកបានយ៉ាងល្អ។

លេខាធិការក្រុមហ៊ុន ក្រៅពីចូលរួមជួយការងារប្រធានក្រុមប្រឹក្សាភិបាល ក្នុងការរៀបចំរបៀបវារៈ និងរៀបចំដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិក ក៏ត្រូវសម្របសម្រួលការទំនាក់ទំនង និងផ្សព្វផ្សាយសេចក្តីសម្រេចសំខាន់ៗ និងគោលការណ៍នានា រវាងក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងថ្នាក់គ្រប់គ្រងប្រតិបត្តិជាន់ខ្ពស់ផងដែរ។

អភិបាលទាំងអស់ មានលទ្ធភាពពេញលេញ ក្នុងការស្នើយោបល់ ពីលេខាធិការក្រុមហ៊ុន និងអាចស្វែងរកការពិគ្រោះយោបល់បែបវិជ្ជាជីវៈ ដោយឯករាជ្យ ពីប្រភពខាងក្រៅ ក្រោមបន្ទុកចំណាយរបស់ធនាគារ ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

## គណៈកម្មាធិការនានា

ក្រុមប្រឹក្សាភិបាល ផ្ទេរការទទួលខុសត្រូវជាក់លាក់ ដល់គណៈកម្មាធិការនានា ដែលរួមមានគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការហានិភ័យ។ គណៈកម្មាធិការទាំងនេះ ធ្វើប្រតិបត្តិការ តាមតួនាទី និងកាតព្វកិច្ច ដែលបានកំណត់យ៉ាងច្បាស់លាស់ ដូចមានចែងនៅក្នុងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការនីមួយៗ ដែលបានអនុម័តយ៉ាងត្រឹមត្រូវ។

គណៈកម្មាធិការ ត្រូវរាយការណ៍ ជូនក្រុមប្រឹក្សាភិបាល អំពីកិច្ចពិភាក្សា សេចក្តីសម្រេច និងអនុសាសន៍របស់ខ្លួន។ ប្រធានគណៈកម្មាធិការសវនកម្ម និងប្រធានគណៈកម្មាធិការហានិភ័យ ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីបញ្ហា ដែលបានលើកយកមកពិភាក្សា និងដោះស្រាយ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការរបស់ខ្លួន។ ក្រុមប្រឹក្សាភិបាល បានទទួលស្គាល់ថា ខណៈដែលគណៈកម្មាធិការទាំងនេះមានសិទ្ធិអំណាចធ្វើការពិភាក្សា លើបញ្ហានានា ដែលបានប្រគល់ជូនរាល់សេចក្តីសម្រេច និង/ឬ អនុសាសន៍របស់គណៈកម្មាធិការទាំងនេះ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ ហើយគណៈកម្មាធិការទាំងនេះ និងក្រុមប្រឹក្សាភិបាល ជារួមទទួលខុសត្រូវ លើភាពជោគជ័យ អាជីវកម្ម យុទ្ធសាស្ត្រ ការគ្រប់គ្រងហានិភ័យ សកម្មភាពប្រតិបត្តិការអាជីវកម្ម និងប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ។

ក្រុមប្រឹក្សាភិបាល អនុវត្តនីតិវិធីវាយតម្លៃប្រចាំឆ្នាំ លើប្រសិទ្ធភាព នៃគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការហានិភ័យ ក៏ដូចជាការចូលរួមចែករំលែករបស់សមាជិកម្នាក់ៗ ដើម្បីមើលថាគណៈកម្មាធិការទាំងពីរ និងសមាជិក បានបំពេញកាតព្វកិច្ច ស្របតាមតួនាទី និងកាតព្វកិច្ច ដែលបានចែងឬទេ។

ព័ត៌មានលម្អិត អំពីគណៈកម្មាធិការនានា មានបង្ហាញនៅក្នុងផ្នែកខាងក្រោម ជាបន្តបន្ទាប់។

### គណៈកម្មាធិការសវនកម្ម

គិតចាប់ពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥ សមាជិកគណៈកម្មាធិការសវនកម្ម មានអភិបាលឯករាជ្យមិនប្រតិបត្តិចំនួន ០២ រូប និងអភិបាលមិនឯករាជ្យមិនប្រតិបត្តិចំនួន ០១ រូប ដែលសុទ្ធតែមានចំណេះដឹង និងបទពិសោធន៍ ផ្នែកហិរញ្ញវត្ថុ។ ជារួម គណៈកម្មាធិការសវនកម្ម មានសមាជិកជាអភិបាល ដែលមានវិជ្ជាជីវៈ ចំណេះដឹង និងបទពិសោធន៍ ពាក់ព័ន្ធនឹងទំនួលខុសត្រូវ របស់គណៈកម្មាធិការសវនកម្ម។ គណៈកម្មាធិការសវនកម្ម ដឹកនាំដោយអភិបាលឯករាជ្យ ដែលមានជំនាញ ផ្នែកច្បាប់ និងគណនេយ្យ។ ប្រធានគណៈកម្មាធិការសវនកម្ម មិនមែនជាប្រធានក្រុមប្រឹក្សាភិបាលទេ ដែលនេះគឺដើម្បីជំរុញការពិភាក្សាបើកចំហ និងស្វាហាប់ នូវរាល់បញ្ហា ដែលលើកឡើងដោយគណៈកម្មាធិការសវនកម្ម។ តំណែងទំនេរ នៅក្នុងគណៈកម្មាធិការសវនកម្ម ត្រូវបំពេញក្នុងរយៈពេលបី (៣) ខែ។

ការទទួលខុសត្រូវចម្បង របស់គណៈកម្មាធិការសវនកម្ម គឺធានាឱ្យមានការអនុវត្តអភិបាលកិច្ច របស់ធនាគារបានល្អប្រសើរ ស្របពេលដែលធ្វើការពិនិត្យ លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ការផ្សព្វផ្សាយព័ត៌មាន ការគោរពបទប្បញ្ញត្តិច្បាប់ ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។ គណៈកម្មាធិការសវនកម្ម ជួបប្រជុំជាប្រចាំ ដើម្បីពិនិត្យ លើលទ្ធផលការងារប្រចាំត្រីមាស របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របាយការណ៍សវនកម្ម ដែលរាប់បញ្ចូលទាំងការអនុវត្ត ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ក៏ដូចជាប្រតិបត្តិការ ជាមួយភាគីសម្ព័ន្ធញាតិ។

គណៈកម្មាធិការសវនកម្ម បានជួបប្រជុំចំនួន ០៦ ដង ក្នុងឆ្នាំ២០២៤ ដែលមានវត្តមានសមាជិកចូលរួម ដូចខាងក្រោម៖

| សមាជិក | បានចូលរួម | ចំនួនកិច្ចប្រជុំ |
|---|---|---|
| **ឡុង ប៊ិង**<br>ប្រធានគណៈកម្មាធិការសវនកម្ម / អភិបាលឯករាជ្យមិនប្រតិបត្តិ | ៦ | ៦ |
| **Tan Sri Mohd Nasir Bin Ahmad**[*9]<br>អភិបាលមិនឯករាជ្យមិនប្រតិបត្តិ | ៦ | ៦ |
| **Aisyah Lam Binti Abdullah**<br>អភិបាលឯករាជ្យមិនប្រតិបត្តិ | ៦ | ៦ |

**កំណត់សម្គាល់៖**

*[*9] Tan Sri Mohd Nasir Bin Ahmad បានផ្លាស់ប្តូរតួនាទីពី អភិបាលឯករាជ្យមិនប្រតិបត្តិ ទៅ អភិបាលមិនឯករាជ្យមិនប្រតិបត្តិ គិតចាប់ពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥*

បន្ថែមលើកិច្ចប្រជុំគណៈកម្មាធិការសវនកម្មទាំង ០៦ លើក ដែលរៀបចំឡើង ដើម្បីដោះស្រាយកិច្ចការ ក្នុងធនាគារ គណៈកម្មាធិការសវនកម្ម បានរៀបចំកិច្ចប្រជុំរួម ០១ លើក ជាមួយគណៈកម្មាធិការសវនកម្ម របស់ស៊ីអាយអិមប៊ី គ្រុប ហូលឌីង និងស៊ីអាយអិមប៊ី ប៊ែងយើង (Banking) គ្រុប។

តួនាទី និងភាតព្វកិច្ចរបស់គណៈកម្មាធិការសវនកម្ម មានដូចខាងក្រោម៖

| ចំណុចគន្លឹះ នៃការទទួលខុសត្រូវ | ការទទួលខុសត្រូវ |
|---|---|
| ការត្រួតពិនិត្យផ្ទៃក្នុង / ការគ្រប់គ្រងហានិភ័យ / អភិបាលកិច្ច | ពិនិត្យឡើងវិញ លើប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ច ក្នុងសម្ព័ន្ធធនាគារ ស្របតាមលក្ខខណ្ឌតម្រូវ នៅក្នុងប្រកាស ស្តីពីអភិបាលកិច្ច នៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ |
| សវនកម្មផ្ទៃក្នុង | ក. ធានាថា មុខងារសវនកម្មផ្ទៃក្នុង បានរៀបចំល្អប្រសើរ ដើម្បីធ្វើការត្រួតពិនិត្យ ឬអង្កេត ក្នុងនាមគណៈកម្មាធិការសវនកម្ម ហើយមុខងារនេះ ត្រូវស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងផ្ទាល់ ពីគណៈកម្មាធិការសវនកម្ម។<br>ខ. ពិនិត្យ និងអនុម័តវិសាលភាពការងារសវនកម្មផ្ទៃក្នុង នីតិវិធី ចំនួនដង នៃការធ្វើសវនកម្មផ្ទៃក្នុង និងគម្រោងសវនកម្មប្រចាំឆ្នាំ។<br>គ. មើលការខុសត្រូវ លើប្រសិទ្ធភាព នៃមុខងារសវនកម្មផ្ទៃក្នុង សមត្ថភាពបុគ្គលិក និងភាពគ្រប់គ្រាន់ នៃធនធានរបស់សវនកម្មផ្ទៃក្នុង និងពិនិត្យមើលថាតើមុខងារនោះ បានទទួលអំណាចចាំបាច់ ដើម្បីបំពេញការងារឬនៅ។<br>ឃ. ពិនិត្យរបាយការណ៍សំខាន់ៗ និងធានាថា គណៈគ្រប់គ្រង ចាត់វិធានការណ៍កែតម្រូវទាន់ពេលវេលា ដើម្បីដោះស្រាយចំណុចខ្សោយ ក្នុងការគ្រប់គ្រងការមិនបាន អនុវត្តពេញលេញ តាមគោលនយោបាយ ការតម្រូវរបស់ច្បាប់ និងបទប្បញ្ញត្តិនានា និងបញ្ហាផ្សេងទៀត ដែលរកឃើញដោយសវនករផ្ទៃក្នុង ក៏ដូចជាផ្នែក ដែលទទួល ខុសត្រូវការគ្រប់គ្រងផ្ទៃក្នុងដទៃទៀត។<br>ង. កត់សម្គាល់ការមិនឯកភាពសំខាន់ៗ រវាងនាយកសវនកម្មផ្ទៃក្នុង និងគណៈគ្រប់គ្រងដទៃទៀត មិនថាការមិនឯកភាពនោះ ត្រូវបានដោះស្រាយរួច ដើម្បីកំណត់ផល ប៉ះពាល់ ដែលការមិនឯកភាពទាំងនោះអាចមាន ចំពោះដំណើរការសវនកម្ម ឬលទ្ធផលសវនកម្ម ដែលលើកឡើងដោយសវនករ។<br>ច. ធានាការគោរពតាមច្បាប់ និងបទប្បញ្ញត្តិ ដែលអនុវត្ត ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងធានាថា របាយការណ៍របស់សវនករផ្ទៃក្នុង នឹងមិនតម្រូវឱ្យត្រួតពិនិត្យ ដោយគណៈគ្រប់គ្រងឡើយ។<br>ឆ. បង្កើតយន្តការ ដើម្បីវាយតម្លៃការបំពេញតួនាទី និងប្រសិទ្ធភាពរបស់មុខងារសវនកម្មផ្ទៃក្នុង។<br>ជ. វាយតម្លៃសមត្ថភាពប្រតិបត្តិការ និងធ្វើសេចក្តីសម្រេច អំពីកញ្ចប់តម្លៃការរបស់នាយកសវនកម្មផ្ទៃក្នុង។<br>ឈ.អនុម័ត លើការតែងតាំង ផ្លាស់ប្តូរ និងបណ្តេញចេញនាយកសវនកម្មផ្ទៃក្នុង ឬបុគ្គលិកជាន់ខ្ពស់ ដែលចំពេញមុខងារជា សវនករផ្ទៃក្នុង និងត្រូវទទួលការជូនដំណឹង អំពី ការលាឈប់របស់បុគ្គលិកជាន់ខ្ពស់ជា សវនករផ្ទៃក្នុង ហើយត្រូវផ្តល់ឱកាសឱ្យសមាជិក ដែលបានដាក់ពាក្យលាឈប់នោះ បញ្ជាក់ច្រាប់ពីមូលហេតុ នៃការលាឈប់។ |
| សវនកម្មខាងក្រៅ | ក. ផ្តល់អនុសាសន៍ ដល់ក្រុមប្រឹក្សាភិបាល លើការតែងតាំង ឬការបញ្ឈប់សវនករខាងក្រៅ។<br>ខ. ពិភាក្សា និងពិនិត្យមើលឡើងវិញ ជាមួយសវនករខាងក្រៅ មុននឹងចាប់ផ្តើមធ្វើសវនកម្ម អំពីលក្ខណៈ និងទំហំការងារសវនកម្ម ហើយធានា លើការសម្របសម្រួល ក្នុងករណីមានក្រុមហ៊ុនសវនកម្មច្រើនចូលរួម។<br>គ. វាយតម្លៃ អំពីគោលដៅ ការបំពេញការងារ និងឯករាជ្យភាពរបស់សវនករខាងក្រៅ (ឧទាហរណ៍ ដោយការពិនិត្យ និងវាយតម្លៃ ពីទំនាក់ទំនងផ្សេងៗ រវាងសវនករ ខាងក្រៅ និងធនាគារ)។<br>ឃ. អនុម័ត លើការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្ម ដែលផ្តល់ដោយសវនករខាងក្រៅ និងតាមដាន និងធ្វើការវាយតម្លៃថាតើសេវានោះអាចនឹងប៉ះពាល់ ដល់ឯករាជ្យភាពរបស់ពួកគាត់ឬទេ។<br>ង. ធានាថា មានការពិនិត្យច្បាស់លាស់ លើលក្ខខណ្ឌ នៃការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្ម ដើម្បីចៀសវៀងការប៉ះពាល់ ដល់ការវិនិច្ឆ័យ ប្រកបដោយ ឯករាជ្យភាពរបស់សវនករខាងក្រៅ។<br>ច. ធានាថា របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា ដោយមានការត្រួតពិនិត្យឡើងវិញជាប្រចាំ លើភាពគ្រប់គ្រាន់ នៃការធ្វើសំវិធានធន ដែលចាំបាច់ និងចំពោះបំណុលអាក្រក់ និងសង្ស័យ។<br>ឆ. រក្សាការទំនាក់ទំនងស្មោះត្រង់ បើកចំហ ទាន់ពេលវេលា និងទៀងទាត់ ជាមួយសវនករខាងក្រៅ និងតម្រូវឱ្យសវនករខាងក្រៅ រាយការណ៍មកកាន់គណៈកម្មាធិការ សវនកម្ម អំពីបញ្ហាសំខាន់ៗ (ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ប្រសិនបើចាំបាច់)។<br>ជ. ពិនិត្យឡើងវិញ លើរបាយការណ៍គ្រប់គ្រងផ្ទៃក្នុងរបស់សវនករខាងក្រៅ និងធានាថា គណៈគ្រប់គ្រង ចាត់វិធានការណ៍កែតម្រូវ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលសវនកម្ម ខាងក្រៅ និងអនុសាសន៍ ដែលលើកឡើង ដោយសវនករខាងក្រៅ ទាន់ពេលវេលា។<br>ឈ.តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងាររបស់សវនករខាងក្រៅ រួមទាំងជួបប្រជុំ ជាមួយសវនករខាងក្រៅ យ៉ាងហោចណាស់ម្តង ក្នុងមួយឆ្នាំ ដោយមិនមានវត្តមាន របស់គណៈគ្រប់គ្រង ដើម្បីពិភាក្សា លើបញ្ហាគន្លឹះសំខាន់ៗ និងស្នើសុំយោបល់ ពីសវនករខាងក្រៅវិញ។ |
| លទ្ធផលសវនកម្ម ការត្រួតពិនិត្យផ្ទៃក្នុង និងបញ្ហា នៃការប្រតិបត្តិតាមច្បាប់ | ពិនិត្យឡើងវិញ លើលទ្ធផល នៃការអង្កេតសំខាន់ៗ លទ្ធផលសវនកម្មជាប្រចាំ និងការត្រួតពិនិត្យផ្ទៃក្នុង និងការប្រតិបត្តិតាមច្បាប់ ដែលរាយការណ៍ ដោយសវនករផ្ទៃក្នុង សវនករខាងក្រៅ និងសវនកររបស់និយ័តករ។ |
| របាយការណ៍ហិរញ្ញវត្ថុ | ពិនិត្យ លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ មុនពេលទទួលការអនុម័ត ពីក្រុមប្រឹក្សាភិបាល ដោយផ្តោតសំខាន់ លើ៖<br>• ការផ្លាស់ប្តូរណាមួយ នៅក្នុងការអនុវត្ត និងគោលការណ៍គណនេយ្យ<br>• បញ្ហាសំខាន់ៗ ដែលបានលើកឡើង រួមទាំងបញ្ហា ទាក់ទងនឹងការរាយការណ៍ហិរញ្ញវត្ថុ ការវិនិច្ឆ័យសំខាន់ៗរបស់គណៈគ្រប់គ្រង ព្រឹត្តិការណ៍ ឬប្រតិបត្តិការមិនប្រក្រតី និងសំខាន់ៗ និងរបៀប ដែលបញ្ហាទាំងអស់ ត្រូវបានបង្ហាញ<br>• ការធ្វើសេចក្តីសន្និដ្ឋាន ពីបញ្ហា ដែលកំពុងកើតឡើង និង<br>• ការប្រតិបត្តិតាមស្តង់ដារគណនី និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិច្បាប់ដទៃផ្សេងទៀត |
| ប្រតិបត្តិការរបស់ភាគីសម្ព័ន្ធញាតិ | ពិនិត្យរាល់ប្រតិបត្តិការធ្វើឡើង ជាមួយភាគីសម្ព័ន្ធញាតិ និងជូនដំណឹង ដល់ក្រុមប្រឹក្សាភិបាល ពីប្រតិបត្តិការទាំងនោះ។ |
| ការពិនិត្យរបាយការណ៍ ពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ | ពិនិត្យភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់ នៃសេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល នៅក្នុងរបាយការណ៍ក្រុមប្រឹក្សាភិបាល ការបង្ហាញពីអភិបាលកិច្ចធនាគារ របាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីប្រកាសដំបូង ពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ |
| ការតាមដានការអនុវត្ត តាមគោលនយោបាយ ទំនាស់ផលប្រយោជន៍ | តាមដានការអនុវត្ត តាមគោលនយោបាយ ស្តីទីទំនាស់ផលប្រយោជន៍របស់ធនាគារ |
| ការពិនិត្យក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុង | ពិនិត្យមតិយោបល់របស់ភាគីទីបី ចំពោះរចនាសម្ព័ន្ធ និងប្រសិទ្ធភាព នៃក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារ |
| ផ្សេងៗ | ក. ជូនដំណឹង ដល់គណៈគ្រប់គ្រងជាន់ខ្ពស់ ជាទៀងទាត់ អំពីបញ្ហា ដែលប៉ះពាល់ ដល់ធនាគារ។<br>ខ. កោះប្រជុំ ជាមួយសវនករផ្ទៃក្នុង សវនករខាងក្រៅ ឬទាំងពីរ ក្នុងពេលតែមួយ លើយល់ថា ចាំបាច់។<br>គ. ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងប្រចាំឆ្នាំ សម្រាប់ដាក់បញ្ជូនទៅឱ្យក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងធានានូវការបោះពុម្ពផ្សាយរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំបានរហ័ស។ |

## គណៈកម្មាធិការហានិភ័យ

គណៈកម្មាធិការហានិភ័យ គឺជាគណៈកម្មាធិការ ដែលបានបង្កើតឡើង ដោយក្រុមប្រឹក្សាភិបាល ដើម្បីកំណត់គោលបំណងរបស់គោលនយោបាយគ្រប់គ្រងហានិភ័យរបស់ធនាគារ និងទទួលខុសត្រូវជំនួសក្រុមប្រឹក្សាភិបាល លើការត្រួតពិនិត្យ និងការគ្រប់គ្រងហានិភ័យ។ ការទទួលខុសត្រូវប្រចាំថ្ងៃ នៃការត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យ ត្រូវបានប្រគល់ជូនគណៈកម្មាធិការហានិភ័យ ដែលរាយការណ៍ដោយផ្ទាល់ ទៅក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការហានិភ័យ ជួបប្រជុំជាប្រចាំខែ ឬនៅពេលចាំបាច់។

គណៈកម្មាធិការហានិភ័យ បានជួបប្រជុំចំនួន ១២ ដង ក្នុងឆ្នាំ២០២៤ ដែលមានវត្តមានសមាជិកចូលរួម ដូចខាងក្រោម៖

| សមាជិក | បានចូលរួម | ចំនួនកិច្ចប្រជុំ |
|---|---|---|
| **Aisyah Lam Binti Abdullah**<br>ប្រធានគណៈកម្មាធិការ / អភិបាលឯករាជ្យមិនប្រតិបត្តិ | ១២ | ១២ |
| **ប៊ុន យ៉ីន**<br>ប្រធានជំនួស / ប្រធាននាយកប្រតិបត្តិ / អភិបាលប្រតិបត្តិ | ១០ | ១២ |
| **ង៉ៀន វឡានា**<br>នាយកគ្រប់គ្រងហានិភ័យ | ១១ | ១២ |
| **ហុង ង៉ៀប**<br>នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម | ១២ | ១២ |
| **គី សាណា**<br>នាយិកាសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ | ១២ | ១២ |
| **ប៊ុច សុម៉ាលី**[*9]<br>សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល | ១២ | ១២ |
| **ហេង រិបុត្រ**<br>នាយកបច្ចេកវិទ្យា និងទិន្នន័យ | ១១ | ១២ |
| **ហេង រុទ្ធី**<br>នាយកហិរញ្ញវត្ថុ | ១១ | ១២ |
| **ហេង ភួងរចនា**<br>នាយិកាប្រតិបត្តិការ | ១២ | ១២ |
| **ហេង ឆូរ៉ង់**<br>នាយករតនាគារ និងទីផ្សារ | ១១ | ១២ |

**កំណត់សម្គាល់៖**

*[*9] ផ្លាស់ប្តូរមុខតំណែងជា សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤*

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការហានិភ័យ មានដូចខាងក្រោម៖

| ចំណុចគន្លឹះ នៃការទទួលខុសត្រូវ | ការទទួលខុសត្រូវ |
|---|---|
| កម្រិតរឹសអាប់តែថាយ | ក. ពិនិត្យ និងផ្តល់អនុសាសន៍ ដល់ក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តកម្រិតរឹសអាប់តែថាយ និងឥរិយាបថហានិភ័យ របស់ធនាគារ សម្រាប់ពិចារណា លើចរិកា ផែនការអាជីវកម្ម ដែលបានស្នើ និងលក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលបានរំពឹងទុក<br>ខ. ដើម្បីធានាបាននូវការអនុវត្ត ប្រកបដោយប្រសិទ្ធភាព នៃកម្រិតរឹសអាប់តែថាយ និងឥរិយាបថហានិភ័យរបស់ធនាគារ ដោយ៖<br>- ការផ្តល់អនុសាសន៍ លើការផ្លាស់ប្តូរ កម្រិតរឹសអាប់តែថាយ និងឥរិយាបថហានិភ័យប្រចាំឆ្នាំ ដល់ក្រុមប្រឹក្សាភិបាល ដោយផ្អែកទៅលើបរិយាកាសម៉ាក្រូសេដ្ឋកិច្ច បទប្បញ្ញត្តិ សន្ទនីយភាព និងទម្រង់មូលធន។ល។<br>- ការតាមដាន និងរាយការណ៍ការអនុលោមតាមកម្រិតរឹសអាប់តែថាយ និងឥរិយាបថហានិភ័យ<br>- ការចាត់តាំង ការពិនិត្យ និង/ឬ ការអនុម័ត លើការកំណត់កម្រិតផលបត្រ ព្រមទាំងការស្នើសុំ និងពិនិត្យឡើងវិញ លើទិដ្ឋភាពផលបត្រ និង<br>- ការសម្រេច លើផែនការសកម្មភាព ក្នុងករណីដែលមិនមានអនុលោមភាព ជាមួយនឹងកម្រិតរឹសអាប់តែថាយ ស្របតាមគោលនយោបាយ និងនីតិវិធី ដែលបានអនុម័ត |
| វប្បធម៌គ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម | ក. បញ្ជាក់ អំពីតំរូ នៃការការពារហានិភ័យ (3 lines of defence) របស់ធនាគារ<br>ខ. លើកកម្ពស់ការយល់ដឹង អំពីហានិភ័យ និងធានានូវវប្បធម៌គ្រប់គ្រងហានិភ័យដ៏សកម្ម ដើម្បីឱ្យដំណើរការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យ ត្រូវបានអនុវត្ត នៅក្នុងសកម្មភាពអាជីវកម្ម និងប្រតិបត្តិការប្រចាំថ្ងៃ<br>គ. ធានានូវវប្បធម៌គ្រប់គ្រងហានិភ័យអនុលោមតាម តាមរយៈការណែនាំ និងការគាំទ្រ ទាក់ទងទៅនឹងកិច្ចខិតខំប្រឹងប្រែងអនុលោមតាមរបស់ធនាគារ |
| ការគ្រប់គ្រងដើមទុន | ក. បែងចែកដើមទុន ដែលមានហានិភ័យ (capital-at-risk) ទៅតាមប្រភេទជំនួញ និងហានិភ័យផ្សេងៗពីគ្នា ដើម្បីធានាថា ការបែងចែកហានិភ័យ បានធ្វើគ្រប់គ្រាន់ អនុលោមតាមលក្ខខណ្ឌកំណត់ដោយបទប្បញ្ញត្តិច្បាប់ និងធានាថា ធនាគារមានដើមទុនបម្រុងគ្រប់គ្រាន់ ដើម្បីប្រឈមមុខនឹងស្ថានភាពវិបត្តិផ្សេងៗ។<br>ខ. បង្កើនតម្លៃភាគទុនិក តាមរយៈការវាយតម្លៃ លើប្រាក់ចំណេញ និងហានិភ័យ (risk-return profiles) ពីដំណើរការប្រតិបត្តិការ ហើយធានាថា កម្រិតហានិភ័យ ដែលទទួលយក ស្ថិតនៅក្នុងដែនកម្រិត ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារ។ |

| ចំណុចគន្លឹះ នៃការទទួលខុសត្រូវ | ការទទួលខុសត្រូវ |
|---|---|
| ក្របខណ្ឌ / គោលនយោបាយគ្រប់គ្រងហានិភ័យ | ក. ពិនិត្យ និងផ្តល់អនុសាសន៍ លើក្របខណ្ឌ / គោលនយោបាយ ហានិភ័យថ្មី និងការធ្វើវិសោធនកម្ម ដល់ក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត និងអនុម័ត លើវិធីសាស្ត្រ / ស្តង់ដារ ហានិភ័យ ដែលមិនស្ថិតនៅក្នុងវិសាលភាព របស់អនុគណៈកម្មាធិការហានិភ័យ<br>ខ. ពិនិត្យ និងគាំទ្រ លើការផ្លាស់ប្តូរក្របខណ្ឌ / គោលនយោបាយហានិភ័យ តាមកម្រិតអនុម័ត ដែលបានចែងនៅក្នុងស្តង់ដារ នៃការគ្រប់គ្រង និងអនុម័តគោលនយោបាយ ហានិភ័យ នៅកម្ពុជា។ |
| ការកំណត់ និងវាស់វែងហានិភ័យ | ក. ត្រួតពិនិត្យ លើការប៉ះពាល់ហានិភ័យរបស់ធនាគារ ក៏ដូចជាហានិភ័យ នៃសកម្មភាពអាជីវកម្ម និងស្នើកែលម្អក្របខណ្ឌគោលនយោបាយ វិធីសាស្ត្រ និងនីតិវិធី នៃការគ្រប់គ្រងហានិភ័យរបស់ធនាគារ និង/ឬ ការត្រួតពិនិត្យផ្សេងៗ ដើម្បីទប់ស្កាត់ហានិភ័យ<br>ខ. ពិនិត្យ និងផ្តល់អនុសាសន៍ លើប៉ារ៉ាម៉ែត្រ គំរូ ហានិភ័យ និងលទ្ធផល សម្រាប់ក្រុមប្រឹក្សាភិបាលអនុម័ត<br>គ. ធានាថា ក្របខណ្ឌត្រូវបានដាក់ចេញ ដើម្បីសម្រួលដល់វប្បធម៌ប្រតិបត្តិតាមដ៏ត្រឹមត្រូវមួយ នៅក្នុងសកម្មភាពប្រតិបត្តិការ និងអាជីវកម្ម ពីមួយថ្ងៃទៅមួយថ្ងៃ<br>ឃ. ពិនិត្យ លើហានិភ័យ ដែលកំពុងកើតមាន ព្រមទាំងការផ្លាស់ប្តូរ លើបទប្បញ្ញត្តិ និងទំនួលខុសត្រូវ និងពិភាក្សា អំពីការទប់ស្កាត់ហានិភ័យ។ |
| ហានិភ័យទីផ្សារ និងរតនាគារ | ក. ពិនិត្យមើលរបាយការណ៍ហានិភ័យទីផ្សារ ដើម្បីធានាថា ហានិភ័យទីផ្សារ កំពុងត្រូវបានគ្រប់គ្រងយ៉ាងត្រឹមត្រូវ និងឆ្លើយតប លើការបំពាន លើដែនកំណត់ផ្ទៃក្នុង<br>ខ. អនុម័តផលិតផលរតនាគារថ្មី និងផលិតផល ដែលមានការប្រែប្រួលច្រើន លើផលិតផល ដែលមានស្រាប់។ |
| ហានិភ័យប្រតិបត្តិការ | ក. ពិនិត្យ លើបញ្ហា ពាក់ព័ន្ធនឹងហានិភ័យប្រតិបត្តិការ និងការគ្រប់គ្រង លើកម្រិតហានិភ័យរបស់នាយកដ្ឋាន ឬផ្នែក<br>ខ. អនុម័ត លើការពន្យា លើការដោះស្រាយបញ្ហា / ទទួលយកបញ្ហា តាមសិទ្ធិអនុម័ត<br>គ. អនុម័តផលិតផលមិនមែនរតនាគារថ្មី និងផលិតផល ដែលមានការប្រែប្រួលច្រើន លើផលិតផល ដែលមានស្រាប់។ |
| ការត្រួតពិនិត្យហានិភ័យបច្ចេកវិទ្យា | ក. ផ្តល់នូវការត្រួតពិនិត្យហានិភ័យបច្ចេកវិទ្យា<br>ខ. ត្រួតពិនិត្យជាប្រចាំ លើបញ្ហា ដែលទាក់ទងនឹងហានិភ័យបច្ចេកវិទ្យា ដែលរួមមានហានិភ័យអ៊ីនធើណេត និងទម្រង់គ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងឧប្បត្តិហេតុធ្ងន់ធ្ងរ / ការមិនគោរពតាម ដើម្បីធានាថា បញ្ហាទាំងនេះ ត្រូវបានដោះស្រាយ ប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស។<br>គ. ត្រួតពិនិត្យ លើហានិភ័យបច្ចេកវិទ្យា រួមទាំងធ្វើការវាយតម្លៃហានិភ័យជាមុន លើសេវាកម្មធនាគារអេឡិចត្រូនិក<br>ឃ. ការអនុវត្តការគ្រប់គ្រងហានិភ័យ ប្រកបដោយប្រសិទ្ធភាព និងការត្រួតពិនិត្យផ្ទៃក្នុង គួរតែត្រូវបានកំណត់ ដើម្បីរក្សានូវទិន្នន័យសម្ងាត់ សន្តិសុខប្រព័ន្ធ ទំនុកចិត្ត ការស្តារឡើងវិញ នូវភាពសុាំ នៅក្នុងអង្គការ<br>ង. ធានាឱ្យមានការត្រួតពិនិត្យ ឱ្យបានគ្រប់គ្រាន់ និងរឹងមាំ លើប្រព័ន្ធបច្ចេកវិទ្យា និងការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា។ |
| យុទ្ធសាស្ត្រប្រតិបត្តិតាម និងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | ក. ផ្តល់អនុសាសន៍ សម្រាប់ការប្រតិបត្តិតាម និងយុទ្ធសាស្ត្រ សម្រាប់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ធនាគារ<br>ខ. ជួយ ក្នុងការកំណត់គោលដៅ សម្រាប់ការប្រតិបត្តិតាម និងគ្រប់គ្រងហានិភ័យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅគ្រប់បណ្តាញអាជីវកម្ម។ |
| ក្របខណ្ឌការប្រតិបត្តិតាម | ក. ធ្វើការពិភាក្សា អំពីបញ្ហាការប្រតិបត្តិតាម និងបញ្ហាហានិភ័យ ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីធានាថា បញ្ហាទាំងនេះ ត្រូវបានដោះស្រាយ ប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស។<br>ខ. ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ក្របខណ្ឌ / គោលនយោបាយ ការប្រតិបត្តិតាម និងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការកែសម្រួលសំខាន់ ចំពោះក្របខណ្ឌ / គោលនយោបាយហានិភ័យ ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។<br>គ. វាយតម្លៃ លើប្រសិទ្ធភាព នៃការគ្រប់គ្រងរបស់ធនាគារ ក្នុងការអនុលោមតាម និងបញ្ហាហានិភ័យ ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>ឃ. ដើម្បីទទួលបាននូវការយកចិត្តទុកដាក់ខ្ពស់ និងពង្រឹង លើមុខងារអនុលោមតាម ធនធាន និងហេដ្ឋារចនាសម្ព័ន្ធ<br>ង. ត្រួតពិនិត្យឡើងវិញ និងអនុម័ត នូវការវាស់វែង វិធីសាស្ត្រ និងនីតិវិធី ដែលទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ |
| ការត្រួតពិនិត្យហានិភ័យតតិយភាព | ក. ពិនិត្យ និងកត់សម្គាល់ លើផែនការតតិយភាពប្រចាំឆ្នាំ<br>ខ. គាំទ្រការរៀបចំតតិយភាពថ្មី និងតតិយភាព ដែលមានការកែប្រែច្រើន លើវិសាលភាព សម្រាប់ក្រុមប្រឹក្សាភិបាលអនុម័ត<br>គ. កត់ចំណាំ អំពីការរៀបចំតតិយភាពថ្មី និងតតិយភាព ដែលមានការកែប្រែតិច<br>ឃ. មានការត្រួតពិនិត្យ លើការអភិវឌ្ឍ ដោយផលប៉ះពាល់ណាមួយ ដែលមិនបានអនុលោមតាមលក្ខខណ្ឌ នៃកិច្ចព្រមព្រៀង និងរំលោភ លើបទប្បញ្ញត្តិ ដោយអ្នកផ្តល់សេវា ដែលត្រូវបានរាយការណ៍ ដោយផ្នែកអាជីវកម្ម។ |
| ការតែងតាំងសមាជិកគណៈកម្មាធិការហានិភ័យ និងតែងតាំងអនុគណៈកម្មាធិការ | ក. អនុម័តរាល់ការផ្លាស់ប្តូរសមាជិក នៅក្នុងមុខងារ នៃសាជីវកម្ម (corporate function) ដដែល ដោយធ្វើការជូនដំណឹង ទៅកាន់ក្រុមប្រឹក្សាភិបាល។ រីឯរាល់ការផ្លាស់ប្តូរសមាជិក នៅក្រៅមុខងារ នៃសាជីវកម្ម ឬសំណើសុំកែប្រែ លើលក្ខន្តិក: (Terms of Reference) ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល មុននឹងអនុវត្ត។<br>ខ. ពិនិត្យ និងអនុម័ត លើលក្ខន្តិក: និងសមាសភាព នៃគណៈកម្មាធិការ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការហានិភ័យ រួមបញ្ចូលទាំងការតែងតាំង និងការដកចេញនូវសមាជិក និងអ្នកចូលរួម ក្នុងគណៈកម្មាធិការទាំងនេះ។ |
| សិទ្ធិអំណាច នៃការអនុម័ត | ក. អនុម័តលក្ខន្តិក: នៃអនុគណៈកម្មាធិការហានិភ័យ របស់គណៈកម្មាធិការហានិភ័យ ដែលរួមមានគណៈកម្មាធិការឥណទានកម្ពុជា និងគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មកម្ពុជា។<br>ខ. ពិនិត្យ និងផ្តល់អនុសាសន៍ ជូនក្រុមប្រឹក្សាភិបាល សម្រាប់ការអនុម័តក្របខណ្ឌ / គោលនយោបាយ ដែលមិនមែនគ្រប់គ្រងដោយនាយកដ្ឋានគ្រប់គ្រងហានិភ័យ និងអនុម័តនីតិវិធី ដែលគ្រប់គ្រងដោយនាយកដ្ឋានគ្រប់គ្រងហានិភ័យ។<br>គ. ពិនិត្យ និងអនុម័តគម្រោង ឬកម្មវិធីកម្ចីផ្សេង។<br>ឃ. ពិនិត្យ និងអនុម័តការវិភាគ និងលទ្ធផល ពីការពិសោធន៍របស់ធនាគារទាំងមូល។<br>ង. ពិនិត្យសំណើផ្សេងៗ លើកឡើងដោយអនុគណៈកម្មាធិការហានិភ័យ របស់គណៈកម្មាធិការហានិភ័យ ទាក់ទងនឹងដែនកំណត់ផ្ទៃក្នុង ចំណាត់ការគ្រប់គ្រង<br>ច. (Management Action Triggers «MAT») និង/ឬ ការបំពាន លើដែនកំណត់ផ្ទៃក្នុង (ដែលមិនពាក់ព័ន្ធនឹងបទប្បញ្ញត្តិច្បាប់)។<br>ផ្តល់អនុសាសន៍ ជូនក្រុមប្រឹក្សាភិបាល សម្រាប់ការអនុម័ត លើកម្រិតសិទ្ធិអំណាចអនុម័ត ក៏ដូចជាកែប្រែ និង/ឬ ព្យួរសិទ្ធិអំណាចអនុម័តកម្ចី ទៅឱ្យមន្ត្រីតណទាន / ផ្នែកអាជីវកម្ម / អ្នកទទួលសិទ្ធិអំណាច។ |
| ផ្សេងៗ | ក. បំពេញមុខងារផ្សេងៗ ក្នុងនាមជា និងនៅពេលមានការចង្អុលបង្ហាញ និង/ឬ កំណត់ដោយក្រុមប្រឹក្សាភិបាល។ |

## គណៈកម្មាធិការគ្រប់គ្រងនានា

គណៈកម្មាធិការគ្រប់គ្រង ដូចមានរៀបរាប់ខាងក្រោម ត្រូវបានបង្កើតឡើង ដើម្បីជួយការងាររបស់ប្រធាននាយកប្រតិបត្តិ និងគណៈគ្រប់គ្រង លើប្រតិបត្តិការអាជីវកម្មផ្សេងៗ និងជួយគាំទ្រ ដល់សកម្មភាពនានារបស់ធនាគារ៖

- គណៈកម្មាធិការគ្រប់គ្រង
- គណៈកម្មាធិការឥណទានកម្ពុជា
- គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មកម្ពុជា

### គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រង រាយការណ៍ជូនក្រុមប្រឹក្សាភិបាល នូវបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ធនាគារ។

| សមាជិក | |
|---|---|
| **ប៊ុន យ៉ីន**<br>ប្រធាននាយកប្រតិបត្តិ | ប្រធាន |
| **ហុង ជៀប**<br>នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម | សមាជិក |
| **គី សាណា**<br>នាយិកាសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ | សមាជិក |
| **ប៉ិច សុម៉ាលី**[1]<br>សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល | សមាជិក |
| **Teo Hong Joo**[2]<br>សហនាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល | សមាជិក |
| **ហេង វុទ្ធី**<br>នាយកហិរញ្ញវត្ថុ | សមាជិក |
| **អ៊ុំ ចិន្តាភក្តី**<br>នាយិកាធនធានសាជីវកម្ម | សមាជិក |
| **Nguyen Thi Thu Huong (aka Rachel Nguyen)**[3]<br>នាយិកាបច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ | សមាជិក |
| **ហេង វិបុត្រ**<br>នាយកបច្ចេកវិទ្យា និងទិន្នន័យ | សមាជិក |
| **ម៉ៀន វឌ្ឍនា**<br>នាយកគ្រប់គ្រងហានិភ័យ | សមាជិក |
| **ហេង តូរ៉ង់**<br>នាយករតនាគិបាល និង ទីផ្សារ | សមាជិក |
| **អ៊ុក ថានិន**<br>នាយកគ្រប់គ្រងផលិតផល និងចីរភាព | សមាជិក |
| **ហេង ភួងរចនា**<br>នាយិកាប្រតិបត្តិការ | សមាជិក |

**កំណត់សម្គាល់៖**

*អ្នកចូលរួមអចិន្ត្រៃយ៍របស់គណៈកម្មាធិការ រួមមាននាយកសំនេងការផ្ទៃក្នុង នាយកប្រតិបត្តិតាម និងអ្នកតំណាង ពីនាយកដ្ឋានយុទ្ធសាស្ត្រ*

*[1] ផ្លាស់ប្តូរមុខតំណែងជា សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤*
*[2] តែងតាំង នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤*
*[3] តែងតាំង នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤*

## តួនាទី និងភារកិច្ច របស់គណៈកម្មាធិការគ្រប់គ្រង មានដូចខាងក្រោម៖

- ផ្តល់ការប្រឹក្សា ជូនប្រធាននាយកប្រតិបត្តិ។
- ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពប្រតិបត្តិការ របស់នាយកដ្ឋានអាជីវកម្មនីមួយៗ រួមមានតែមិនកំណត់ត្រឹម ការត្រួតពិនិត្យ លើមុខងារ នៃគណៈកម្មាធិការនានា ឬក្រុមការងារ ដែលបានបង្កើតឡើងដោយគណៈកម្មាធិការគ្រប់គ្រង ដើម្បីអនុវត្តតួនាទីណាមួយ ប្រសិនបើចាំបាច់។
- ពិនិត្យរបាយការណ៍គ្រប់គ្រងហិរញ្ញវត្ថុ និងរបាយការណ៍គ្រប់គ្រងផ្សេងៗទៀតរបស់ធនាគារ។
- បង្កើតយុទ្ធសាស្ត្រ ផែនការអាជីវកម្ម និងផែនការថវិកា សម្រាប់ធនាគារ (រាប់បញ្ចូលទាំងចំណុច ដែលទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន)
- កំណត់ការងារ ដែលទាមទារឱ្យមានការសហការ ពីនាយកដ្ឋានច្រើន។
- ពិភាក្សា លើច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗ។

- តាមដានសកម្មភាពរបស់គណៈគ្រប់គ្រង ក្នុងគោលបំណងកែលម្អបរិយាកាសដឹកនាំ ដើម្បីគ្រប់គ្រងហេតុការណ៍ហានិភ័យ និងការបំពានណាមួយ ផ្នែកប្រតិបត្តិតាម ដែលបង្កើនការយកចិត្តទុកដាក់របស់គណៈកម្មាធិការគ្រប់គ្រង។
- ពិភាក្សា និងផ្តល់អនុសាសន៍ លើការបង្កើតគណៈកម្មាធិការគ្រប់គ្រង ក៏ដូចជាសមាសភាព និងលក្ខន្តិកៈរបស់គណៈកម្មាធិការ។
- ការងារផ្សេងៗទៀត តាមការណែនាំរបស់ក្រុមប្រឹក្សាភិបាល/ប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុនមេ/ប្រធាននាយកប្រតិបត្តិ។

## គណៈកម្មាធិការឥណទានកម្ពុជា

គណៈកម្មាធិការឥណទានកម្ពុជា រាយការណ៍ជូនគណៈកម្មាធិការគ្រប់ក្រងហានិភ័យ នូវរាល់បញ្ហាទាក់ទងនឹងការងារឥណទានរបស់ធនាគារ។

| សមាជិក | |
|---|---|
| **ម៉ៀន វឌ្ឍនា**<br>នាយកគ្រប់គ្រងហានិភ័យ | ប្រធាន |
| **ប៊ុន យ៉ីន**<br>ប្រធាននាយកប្រតិបត្តិ | ប្រធានជំនួស |
| **ហុង ម៉ៀប**<br>នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម | សមាជិក |
| **ប៊ុច សុម៉ាលី**[*9]<br>សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល | សមាជិក |
| **ចំណាន វនិតា**<br>នាយិកាគ្រប់គ្រងឥណទាន | សមាជិក |
| **គី សាណា**<br>នាយិកាសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ | សមាជិក |
| **Chong Kok Ping**[*2]<br>សហនាយកគ្រប់គ្រងហានិភ័យឥណទានថ្នាក់តំបន់ (នៃធនាគារមេ) | សមាជិក |
| **Lim Gek Peng**[*3]<br>ប្រធានគ្រប់គ្រងឥណទានពាណិជ្ជកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុ (នៃធនាគារមេ) | សមាជិក |
| **Michael Ng Mun Seng**[*4]<br>នាយកវិភាគហានិភ័យឥណទានថ្នាក់តំបន់ (នៃធនាគារមេ) | សមាជិក |
| **Ganga Devi Katheraveloo**[*5]<br>នាយកតំបន់ ផ្នែកគ្រប់គ្រងឥណទានពាណិជ្ជកម្ម នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម (នៃធនាគារមេ) | សមាជិក |

**កំណត់សម្គាល់៖**

*[*9] ប៊ុច សុម៉ាលី៖ សម្រាប់សំណើឥណទាន ពីនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គលតែប៉ុណ្ណោះ*

*[*2] Chong Kok Ping ឬ Liew Chee How ((ប្រធានគ្រប់គ្រងឥណទានថ្នាក់តំបន់) ជាសមាជិកជំនួស ក្នុងពេលអវត្តមានរបស់ Chong Kok Ping) ជាសមាជិក ដែលមានសំឡេងបោះឆ្នោតចាំបាច់ សម្រាប់សំណើឥណទាន ដែលហួសពីសិទ្ធិអំណាចសម្រេចរបស់គណៈកម្មាធិការឥណទានកម្ពុជា*

*[*3] Lim Gek Peng ឬ Charly Kojongian ((ប្រធានគ្រប់គ្រងឥណទានពាណិជ្ជកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុ) ជាសមាជិកជំនួស ក្នុងពេលអវត្តមានរបស់ Lim Gek Peng) ជាសមាជិក ដែលមានសំឡេងបោះឆ្នោត សម្រាប់តែសំណើឥណទាន ពាក់ព័ន្ធនឹងរតនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុតែប៉ុណ្ណោះ*

*[*4] Michael Ng Mun Seng ឬ Leong Wai Chyi (នាយកគ្រប់គ្រងឥណទានគ្រឹះស្ថានហិរញ្ញវត្ថុថ្នាក់តំបន់) ជាសមាជិកជំនួស ក្នុងពេលអវត្តមានរបស់ Michael Ng Mun Seng) ជាសមាជិក ដែលមានសំឡេងបោះឆ្នោត សម្រាប់សំណើឥណទាន ពីនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម នាយកដ្ឋានរតនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុធនាគារតែប៉ុណ្ណោះ*

*[*5] Ganga Devi Katheraveloo ឬ Nor Akmar Abd Hamid (ប្រធានគ្រប់គ្រងឥណទានពាណិជ្ជកម្ម នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ដែលមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣)៖ សម្រាប់សំណើឥណទាន ពីនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មតែប៉ុណ្ណោះ និងជាសមាជិក ដែលមានសំឡេងបោះឆ្នោតចាំបាច់ សម្រាប់សំណើឥណទាន ពីនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ដែលស្ថិតនៅក្នុងកម្រិតឥណទានរបស់គណៈកម្មាធិការឥណទានកម្ពុជា ដោយមិនរាប់បញ្ចូលសំណើឥណទាន ពីនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុអាជីវកម្ម ដែលស្នើឡើងដោយអ្នកទទួលសិទ្ធិរួម ទៅកាន់គណៈកម្មាធិការឥណទាន សម្រាប់ការអនុម័ត។*

**តួនាទី និងភារកិច្ច របស់គណៈកម្មាធិការឥណទាន មានដូចខាងក្រោម៖**

**ការអនុម័ត ពាក់ព័ន្ធនឹងឥណទាន**

- ត្រួតពិនិត្យឡើងវិញ និងអនុម័ត លើឥណទានទីមួយៗរបស់ធនាគារ ក្នុងកម្រិតកំណត់ឥណទាន ដែលក្រុមប្រឹក្សាភិបាល ផ្តល់សិទ្ធិឱ្យ។
- ផ្តល់អនុសាសន៍ សម្រាប់ការសម្រេចរបស់ក្រុមប្រឹក្សាភិបាល លើរាល់សំណើឥណទាន ដែលហួសពីសិទ្ធិអំណាចសម្រេចរបស់គណៈកម្មាធិការឥណទានកម្ពុជា។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តចំណាត់ថ្នាក់ឥណទានផ្ទៃក្នុងរបស់អ្នកខ្ចីម្នាក់ៗ តាមដែលអាចអនុវត្តបាន។
- ធានាថា សមតុល្យឥណទានទាំងមូលរបស់ធនាគារ ស្របតាមគោលការណ៍ណែនាំ បទប្បញ្ញត្តិច្បាប់ និងស្របតាមគោលការណ៍ និងនីតិវិធីឥណទាន ដែលបានអនុម័ត ហើយស្ថិតនៅក្នុងកម្រិតហានិភ័យ ដែលអាចទទួលយកបាន ដោយធនាគារ។
- វាយតម្លៃសមតុល្យហានិភ័យ នៅពេលអនុម័តឥណទាន ដើម្បីធានាថា ឥណទានដែលផ្តល់ គឺស្ថិតនៅក្នុងកម្រិតហានិភ័យ ដែលអាចទទួលយកបាន ដោយធនាគារ។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តលើហ្វាស៊ីលីធីរៀបចំឡើងវិញ និងវិធានការទារសំណង ដែលរួមមានការទូទាត់សង ដោយសម្រុះសម្រួល និងឥណទាន ដែលត្រូវលុបចេញពីបញ្ជី ដែលនឹងត្រូវអនុវត្តស្របតាមលក្ខខណ្ឌពិន័យ។
- ត្រួតពិនិត្យឡើងវិញ និងវាយតម្លៃផលិតផលឥណទានផ្សេងៗរបស់ធនាគារ ដើម្បីធានាថា ផលិតផលទាំងនោះ ត្រូវបានអនុវត្តតាមបទដ្ឋាន និងគោលការណ៍ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល។
- អនុម័តការតែងតាំងដៃគូវិជ្ជាជីវៈ ដូចជាមេធាវី ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ។

**មុខងារដទៃទៀត**

- ផ្ទេរការទទួលខុសត្រូវ លើការតាមដានជាក់លាក់ណាមួយ អនុម័តដោយគណៈកម្មាធិការឥណទាន ទៅសមាជិកគណៈកម្មាធិការឥណទាន និង/ឬ អ្នកទទួលសិទ្ធិរួមដទៃទៀត (ដែលជាសមាជិក នៃនាយកដ្ឋានគ្រប់គ្រងហានិភ័យ និង/ឬ សមាជិក នៃផ្នែកអាជីវកម្ម) លើបញ្ហាពាក់ព័ន្ធឯកសារស្មើ ដែលមានការផ្លាស់ប្តូរច្រើន ឬតិច (ដោយមិនរាប់បញ្ចូលការផ្លាស់ប្តូរចំនួនប្រាក់កម្ចី រយៈពេលកម្ចី និងទ្រព្យបញ្ចាំ ដែលត្រូវលម្អិត ក្នុងកំណត់ហេតុប្រជុំរបស់គណៈកម្មាធិការឥណទាន)។
- អនុម័តរាល់ការកែលម្អ លើឥណទាន ដែលមិនមានការផ្លាស់ប្តូរ លើមូលដ្ឋាន ឬកម្រិតកំណត់ឥណទានទាបជាង ដែលបានអនុម័ត ដោយក្រុមប្រឹក្សាភិបាល ពីមុន ស្របតាមការកំណត់សិទ្ធិ ដោយក្រុមប្រឹក្សាភិបាល។
- បំពេញមុខងារដទៃទៀត តាមការណែនាំរបស់គណៈកម្មាធិការហានិភ័យ និង/ឬ ក្រុមប្រឹក្សាភិបាល។

## គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មកម្ពុជា

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មកម្ពុជា រាយការណ៍ទៅគណៈកម្មាធិការហានិភ័យ អំពីហានិភ័យសន្ទនីយភាព និងបញ្ហានានា ដែលទាក់ទងនឹងទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ធនាគារ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ជួបប្រជុំចំនួន ១២ ដង ក្នុងឆ្នាំ២០២៤។

| **សមាជិក** | |
|---|---|
| **ហេង វុទ្ធី**<br>នាយកហិរញ្ញវត្ថុ | ប្រធាន |
| **ហេង តូរ៉ង់**<br>នាយករតនាភិបាល និង ទីផ្សារ | ប្រធានជំនួស / សមាជិក |
| **ប៊ុន យីន**<br>ប្រធាននាយកប្រតិបត្តិ / អភិបាលប្រតិបត្តិ | សមាជិក |
| **ប៊ុច សុម៉ាលី**[1]<br>សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល | សមាជិក |
| **ហុង ធៀប**<br>នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម | សមាជិក |
| **គី សាណា**<br>នាយិកាសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ | សមាជិក |
| **ឆៀន វឌ្ឍនា**<br>នាយកគ្រប់គ្រងហានិភ័យ | សមាជិក |
| **Teo Hong Joo**[2]<br>សហនាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល | សមាជិក |

**កំណត់សម្គាល់៖**

*[1] ផ្លាស់ប្តូរមុខតំណែងជា សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤*
*[2] តែងតាំង នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤*

**តួនាទី និងភារកិច្ច របស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មកម្ពុជា មានដូចខាងក្រោម៖**

**ត្រួតពិនិត្យតារាងតុល្យការ និងចំណូលការប្រាក់សុទ្ធ**

- ត្រួតពិនិត្យឡើងវិញ និងវិភាគផែនការណ៍តារាងតុល្យការ តាមផ្នែកអាជីវកម្ម ទ្រព្យសកម្ម និងទ្រព្យអកម្មចម្រុះ រូបិយប័ណ្ណ ភាពរឹកចម្រើន និងប្រាក់ចំណេញ។
- ត្រួតពិនិត្យឡើងវិញ អំពីភាពខុសគ្នា រវាងតារាងតុល្យការជាក់ស្តែង ធៀបនឹងផែនការ ដែលអាចប៉ះពាល់ ទៅលើចំណូលការប្រាក់សុទ្ធ ផែនការហិរញ្ញប្បទាន និងថាតើធនាគារនៅតែបន្តអនុវត្ត ក្នុងកម្រិតហានិភ័យ ដែលបានកំណត់ឬទេ។
- ត្រួតពិនិត្យឡើងវិញ អំពីចំណូលការប្រាក់សុទ្ធ និងនិន្នាការ ដោយរួមបញ្ចូលការព្យាករស្ថានភាព និងភាពខុសគ្នា ពីផែនការចំណូលការប្រាក់សុទ្ធ និងធ្វើការលម្អិត អំពីសកម្មភាព ដែលបានតម្រូវ ឱ្យបានត្រឹមត្រូវ។
- ត្រួតពិនិត្យឡើងវិញ អំពីផលប៉ះពាល់ លើប្រាក់ចំណេញ ទាំងក្នុងករណីសេដ្ឋកិច្ចធម្មតា និងក្នុងករណីមានវិបត្តិសេដ្ឋកិច្ចផ្សេងៗ តាមការកំណត់សេណារីយ៉ូ ដែលអាចធ្វើបាន។
- ត្រួតពិនិត្យឡើងវិញ និងធានាថា ការកំណត់ថ្លៃផ្ទេរ នៃហិរញ្ញប្បទាន គឺត្រឹមត្រូវ និងធ្វើជាអាជ្ញាកណ្តាល រវាងផ្នែកអាជីវកម្មទាំងអស់ ក្នុងការរៀបចំ និងការអនុវត្តការកំណត់ថ្លៃផ្ទេរ នៃហិរញ្ញប្បទាន និងលើកកម្ពស់តម្លាភាព ក្នុងធនាគារ។
- ពិនិត្យមើលកម្រិតតម្លៃ នៃចំណុចមូលដ្ឋាន ក្នុងបញ្ជីធនាគារ និងធានាថា ផលប៉ះពាល់ គឺស្ថិតនៅក្នុងដែនកំណត់ ក្នុងបញ្ជីធនាគារ (បើមាន)។

**ផែនការយថាភាព នៃហិរញ្ញប្បទាន**

- ត្រួតពិនិត្យឡើងវិញ អំពីផែនការយថាភាព នៃហិរញ្ញប្បទាន ដែលត្រូវបានចាត់ទុកថា ផែនការប្រតិបត្តិការ នៃអាជីវកម្ម និងសិក្ខាលទ្ធភាព ដើម្បីធានាថា សកម្មភាព ដែលតម្រូវដោយអ្នកគ្រប់គ្រង អាចអនុវត្តទៅបាន។
- ធានាថា សូចនាករក្រើនរំលឹកមុន ត្រូវបានធ្វើបច្ចុប្បន្នភាព និងសមស្រប។

**ការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម**

- ត្រួតពិនិត្យ លើក្របខណ្ឌគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម និងគោលការណ៍ (បើមាន) ដើម្បីធានាថា វាសមស្រប តាមទំហំ និងភាពពេញលក្ខណៈ នៃប្រតិបត្តិការរបស់ធនាគារ នាពេលបច្ចុប្បន្ន និងអនាគត។
- លើកកម្ពស់ភាពស្របគ្នា រវាងគោលការណ៍ និងការអនុវត្ត នៅក្នុងធនាគារ។
- ត្រួតពិនិត្យឡើងវិញ និងគាំទ្រ/អនុម័ត លើចំណាត់ការគ្រប់គ្រង (Management Action Triggers «MAT») សម្រាប់ហានិភ័យសន្ទនីយភាព និងហានិភ័យអត្រាការប្រាក់ នៅក្នុងបញ្ជីធនាគារ (interest rate risk in the banking book) អនុលោមតាមដែនកំណត់ហានិភ័យសន្ទនីយភាព និងក្របខណ្ឌអភិបាលកិច្ចហានិភ័យអត្រាការប្រាក់ នៅក្នុងបញ្ជីធនាគារ ដែលបានអនុម័ត។
- កំណត់ ពិនិត្យតាមដាន និងត្រួតពិនិត្យឡើងវិញ លើយុទ្ធសាស្ត្រជម្លៀសរបស់ធនាគារ (បើមាន)។
- ត្រួតពិនិត្យឡើងវិញ និងធានាថា ទម្រង់ហានិភ័យរបស់ធនាគារ គឺស្ថិតនៅក្រោមចំណាត់ការគ្រប់គ្រង ឬដែនកំណត់ នៃហានិភ័យសន្ទនីយភាព និងហានិភ័យអត្រាការប្រាក់ នៅក្នុងបញ្ជីធនាគារ រួមទាំងលទ្ធផល ពីការពិសោធន៍ផ្ទៃក្នុង និងការពិសោធន៍ តាមបទប្បញ្ញត្តិពេលមានវិបត្តិ ដោយរូបិយប័ណ្ណគោល។
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍គំរូថ្មី សម្រាប់គ្រប់គ្រងហានិភ័យទ្រព្យសកម្ម និងទ្រព្យអសកម្ម ពីគំរូអាកប្បកិរិយាផ្ទៃក្នុង ទៅគណៈកម្មាធិការហានិភ័យ ដើម្បីអនុម័ត។
- កំណត់ និងត្រួតពិនិត្យឡើងវិញ លើសន្ទនីយភាពរបស់ធនាគារ តម្រូវការហិរញ្ញប្បទាន និងការអនុវត្តសមស្រប តាមតម្រូវការទាំងនេះ។

**ការគ្រប់គ្រងហានិភ័យទីផ្សារ**

- ត្រួតពិនិត្យវិធីសាស្ត្រវាស់វែងហានិភ័យទីផ្សាររបស់ធនាគារ ទាំងវិធីសាស្ត្រ និងប្រព័ន្ធផ្ទៃក្នុង និងបទប្បញ្ញត្តិណា ដែលអនុវត្តបាន។
- ពិនិត្យ និងផ្តល់អនុសាសន៍ លើលទ្ធផល ប៉ារ៉ាម៉ែត្រគំរូ ការផ្ទៀងផ្ទាត់គំរូ សម្រាប់គណៈកម្មាធិការហានិភ័យអនុម័ត។

**ការតាមដានហានិភ័យទីផ្សារ**

- ពិនិត្យ និងស្នើកម្រិតហានិភ័យទីផ្សារប្រចាំឆ្នាំ និងផ្តល់អនុសាសន៍ ជូនដល់គណៈកម្មាធិការហានិភ័យ ដើម្បីអនុម័ត។
- ពិនិត្យ និងអនុម័តការផ្លាស់ប្តូរបណ្តោះអាសន្ន តាមពេលវេលាកំណត់ ចំពោះកម្រិតហានិភ័យទីផ្សារ។
- ពិនិត្យស្ថានភាពចំហសុទ្ធ នៃរូបិយប័ណ្ណ និងហានិភ័យអត្រាការប្រាក់។

**សិទ្ធិអំណាច នៃការអនុម័ត**

- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ក្របខណ្ឌគ្រប់គ្រងហានិភ័យទ្រព្យសកម្ម និងទ្រព្យអកម្ម និងគោលការណ៍ (បើមាន) ទៅគណៈកម្មាធិការហានិភ័យ ដើម្បីអនុម័ត។
- ត្រួតពិនិត្យឡើងវិញ និងអនុម័ត លើវិធីសាស្ត្រ និងបទដ្ឋានគ្រប់គ្រងហានិភ័យទ្រព្យសកម្ម និងទ្រព្យអកម្ម (បើមាន) ដើម្បីគោរពតាមគោលការណ៍ ដែលបានអនុម័ត។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តការត្រិត តាមខ្នាតប្រចាំឆ្នាំ រួមទាំងលទ្ធផលតេស្តត្រឡប់ ដែលត្រូវបានប្រើ សម្រាប់កំណត់ដែនកំណត់សន្ធនីយភាព និងហានិភ័យអត្រាការប្រាក់នៅក្នុងបញ្ជីធនាគារ ។
- ត្រួតពិនិត្យឡើងវិញ និងអនុម័ត លើវិធីសាស្ត្រ គោលការណ៍ ក្របខណ្ឌ នៃការកំណត់ថ្លៃផ្ទេរ នៃហិរញ្ញប្បទាន សម្រាប់ធនាគារ។
- ត្រួតពិនិត្យឡើងវិញ និងគាំទ្រដែនកំណត់ និងកម្រិតហានិភ័យ សម្រាប់ហានិភ័យសន្ធនីយភាព និងហានិភ័យអត្រាការប្រាក់ នៅក្នុងបញ្ជីធនាគារ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល។
- គាំទ្រគោលការណ៍ និងគោលនយោបាយហានិភ័យទីផ្សារ និងផ្តល់អនុសាសន៍ ដល់គណៈកម្មាធិការហានិភ័យរបស់ធនាគារ ដើម្បីអនុម័ត។
- អនុម័តវិធីសាស្ត្រ និងបទដ្ឋានហានិភ័យទីផ្សារ ស្របតាមស្តង់ដារអនុម័ត និងគោលការណ៍អភិបាលកិច្ចហានិភ័យរបស់ធនាគារ។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តការកំណត់តម្លៃ ដែលតម្រូវឱ្យមានការអនុម័ត ពីនិយ័តករ ឬជូនដំណឹង ទៅនិយ័តករ និងការកំណត់តម្លៃផលិតផលថ្មី ឱ្យស្របតាមគោលដៅយុទ្ធសាស្ត្រ និងផែនការអាជីវកម្មរបស់ធនាគារ។ អនុម័តការផ្ទេរការទទួលខុសត្រូវ លើការកំណត់តម្លៃ នៃប្រាក់បញ្ញើធនាគារ។
- អនុម័ត លើសំណើតម្លៃ ផ្អែកលើសិទ្ធិអំណាច ដែលបានផ្តល់ជូន។
- លើកឡើង ទៅគណៈកម្មាធិការហានិភ័យ រាល់ការបំពានចំណាត់ការគ្រប់គ្រង ឬដែនកំណត់ (ដែលមិនពាក់ព័ន្ធនឹងច្បាប់) ដែលមិនខុសឆ្គាយ ពីដែនកំណត់ហានិភ័យ ដែលបានកំណត់ និងដើមទុន ឬសន្ធនីយភាព ឬកេរ្តិ៍ឈ្មោះធនាគារ។

## គណនេយ្យភាព និងសវនកម្ម

### ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ

ដោយយោងតាមច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ឆ្នាំហិរញ្ញវត្ថុនីមួយៗ ត្រូវរៀបចំឡើង។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (Camboidan International Finanical Reporting Standards ហៅកាត់ថា CIFRS) ហើយបានបង្ហាញត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាព ជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឱ្យក្រុមប្រឹក្សាភិបាល៖

i) ប្រើប្រាស់គោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន បន្ទាប់ពីនោះ ត្រូវអនុវត្តគោលការណ៍ទាំងនោះ ឱ្យបានស៊ីសង្វាក់គ្នា។
ii) អនុវត្ត តាមការលាតត្រដាងព័ត៌មានរបស់ CIFRS ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះ ត្រូវលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
iii) រក្សាទុកបញ្ជីគណនេយ្យ ឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ប្រកបដោយប្រសិទ្ធភាព។
iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តភាព នៃអាជីវកម្ម លើកលែងតែមានករណីមិនសមរម្យ ក្នុងការសន្មតថា ធនាគារអាចនឹងបន្តប្រតិបត្តិការអាជីវកម្ម នៅពេលអនាគតដ៏ខ្លី និង
v) ត្រួតពិនិត្យ និងដឹកនាំធនាគារ ដោយចូលរួមលើរាល់ការសម្រេចចិត្តសំខាន់ៗទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថា កិច្ចការទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល មានសេចក្តីពេញចិត្តនឹងការបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការបង្ហាញនូវសមតុល្យភាព និងការវាយតម្លៃ អំពីស្ថានភាពហិរញ្ញវត្ថុ និងការព្យាករ នាថ្ងៃអនាគត ប្រកបដោយភាពត្រឹមត្រូវ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដូចមានបង្ហាញ នៅក្នុងរបាយការណ៍របស់អភិបាល នៅក្នុងទំព័រ ៩០ ដល់ ៩១ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

### គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម ជួយក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យដំណើរការ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ លទ្ធផលហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆមាសរបស់ធនាគារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវត្រួតពិនិត្យឡើងវិញ ដោយគណៈកម្មាធិការសវនកម្ម និងអនុម័តដោយក្រុមប្រឹក្សាភិបាល មុនពេលផ្តល់ជូនធនាគារជាតិ នៃកម្ពុជា។

### ការត្រួតពិនិត្យផ្ទៃក្នុង

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវរួម លើការរក្សានូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឱ្យមានភាពល្អប្រសើរ ដែលរួមមានដូចជាការត្រួតពិនិត្យ លើហិរញ្ញវត្ថុ ការធ្វើប្រតិបត្តិការ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ការគោរពច្បាប់ និងបទប្បញ្ញត្តិនានា ក៏ដូចជាការគ្រប់គ្រងហានិភ័យ។ ទំហំ និងភាពស្មុគស្មាញ នៃអាជីវកម្មរបស់ធនាគារ ទាមទារឱ្យមានជាចាំបាច់ នូវការគ្រប់គ្រង និងការបែងចែកហានិភ័យត្រឹមត្រូវ។ លក្ខណៈ នៃហានិភ័យទាំងនេះ មានន័យថា ព្រឹត្តិការណ៍ទាំងឡាយ អាចនឹងកើតមានឡើង ហើយបណ្តាលឱ្យមានការខាតបង់ ដោយមិនអាចដឹងមុន និងចៀសវាងបាន។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវការធានាដ៏សមហេតុផលមួយ បើទោះបីជាវាមិនអាចធានាទាំងស្រុង ចំពោះហានិភ័យ ដែលកើតចេញ ពីកំហុសធ្ងន់ធ្ងរ ការកេងបន្លំ ឬការខាតបង់ ដែលកើតមានក្តី។

ក្រុមប្រឹក្សាភិបាល បានចាត់ទុកថា ក្របខណ្ឌ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធី ត្រូវបានអនុវត្តដោយគណៈគ្រប់គ្រងរបស់ធនាគារ ក្នុងឆ្នាំហិរញ្ញវត្ថុ រហូតដល់កាលបរិច្ឆេទ នៃរបាយការណ៍នេះ និងមានគ្រប់គ្រាន់ ស្របតាមតម្រូវការរបស់ធនាគារ ក្នុងបរិយាកាសអាជីវកម្ម នាពេលបច្ចុប្បន្ន។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានរៀបចំឡើង សម្រាប់ផ្តល់នូវការធានាដ៏សមស្របមួយ បើទោះបីជាវាមិនអាចធានាទាំងស្រុង ដើម្បីបង្កើតឱ្យបាននូវបទដ្ឋានជាក់លាក់មួយ សម្រាប់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងជួយធនាគារ ក្នុងការគ្រប់គ្រងហានិភ័យ លើការបរាជ័យ ក្នុងការសម្រេចគោលដៅអាជីវកម្មក្តី ប៉ុន្តែវាប្រសើរជាងការលុបចោលនូវប្រព័ន្ធត្រួតពិនិត្យនេះដែរ។

សេចក្តីថ្លែងការណ៍ អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលបង្ហាញពីស្ថានភាពត្រួតពិនិត្យផ្ទៃក្នុង របស់ធនាគារ មានបង្ហាញនៅក្នុងទំព័រ ៥១ ដល់ ៥៣ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

សេចក្តីថ្លែងការណ៍ ស្តីពីអភិបាលកិច្ចធនាគារ ត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៥។

# របាយការណ៍គណៈកម្មាធិការសវនកម្ម

## សេចក្តីសង្ខេប

គណៈកម្មាធិការសវនកម្ម នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ប្តេជ្ញាចំពេញតួនាទីរបស់ខ្លួន ក្នុងការធានានូវការអនុវត្តអភិបាលកិច្ចយ៉ាងល្អប្រសើរ ព្រមទាំងធានានូវការត្រួតពិនិត្យ លើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

### ១. សមាជិកចូលរួមកិច្ចប្រជុំ

ព័ត៌មានលម្អិត នៃសមាសភាពគណៈកម្មាធិការសវនកម្ម និងកិច្ចប្រជុំគណៈកម្មាធិការសវនកម្ម ដែលបានរៀបចំឡើង ក្នុងឆ្នាំ២០២៤ មានរៀបរាប់ ដូចខាងក្រោម៖

| សមាជិក | មុខងារ | បានចូលរួម | ចំនួនកិច្ចប្រជុំ |
|---|---|---|---|
| ឡុង ចិង | អភិបាលឯករាជ្យមិនប្រតិបត្តិ / ប្រធាន | ៦ | ៦ |
| Tan Sri Mohd Nasir Bin Ahmad[*9] | អភិបាលមិនឯករាជ្យមិនប្រតិបត្តិ | ៦ | ៦ |
| Aisyah Lam Binti Abdullah | អភិបាលឯករាជ្យមិនប្រតិបត្តិ | ៦ | ៦ |

**កំណត់សម្គាល់៖**

*[*9] ចាប់ពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥ Tan Sri Mohd Nasir Bin Ahmad បានផ្លាស់ប្តូរតួនាទីពី អភិបាលឯករាជ្យមិនប្រតិបត្តិ ទៅ អភិបាលមិនឯករាជ្យមិនប្រតិបត្តិ*

បន្ថែមលើកិច្ចប្រជុំគណៈកម្មាធិការសវនកម្មទាំង ៦ លើក ដែលរៀបចំឡើង ដើម្បីដោះស្រាយកិច្ចការ ក្នុងធនាគារ គណៈកម្មាធិការសវនកម្ម បានរៀបចំកិច្ចប្រជុំរួម ១ លើក ជាមួយគណៈកម្មាធិការសវនកម្ម របស់ស៊ីអាយអិមប៊ី គ្រុប ហូលឌីង និង ស៊ីអាយអិមប៊ី ប៊ែងយីង (Banking) គ្រុប។

ប្រធានគណៈកម្មាធិការសវនកម្ម ធ្វើសេចក្តីរាយការណ៍ ជូនក្រុមប្រឹក្សាភិបាល ដោយសង្ខេប អំពីបញ្ហាទាំងឡាយណា ដែលត្រូវបានលើកឡើង ក្នុងកិច្ចប្រជុំគណៈកម្មាធិការសវនកម្មរបស់ខ្លួន។

កិច្ចពិភាក្សាផ្សេងៗ នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការសវនកម្ម មានភាពស្វាហាប់ និងពិស្តារ និងជាទូទៅមានរយៈពេលប្រជុំប្រហែល ២ ទៅ ៣ ម៉ោង។ កំណត់ហេតុ នៃកិច្ចប្រជុំគណៈកម្មាធិការសវនកម្ម ក៏បានដាក់ជូនសមាជិកក្រុមប្រឹក្សាភិបាលផងដែរ។

### ២. សិទ្ធិអំណាច

គណៈកម្មាធិការសវនកម្ម គឺជាគណៈកម្មាធិការមួយ ដែលទទួលបានការផ្ទេរសិទ្ធិ ពីក្រុមប្រឹក្សាភិបាល។ នៅក្នុងការអនុវត្តតួនាទីរបស់ខ្លួន គណៈកម្មាធិការសវនកម្ម មានសិទ្ធិអំណាចពេញលេញ ក្នុងការធ្វើការស៊ើបអង្កេត លើបញ្ហានានា ដូចមានចែង នៅក្នុងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម។ គណៈកម្មាធិការនេះ មានសិទ្ធិពេញលេញ ក្នុងការចូលរួម និងទាមទារឱ្យមានការសហការ ពីគណៈគ្រប់គ្រង ព្រមទាំងមានឆន្ទានុសិទ្ធិពេញលេញ ក្នុងការអញ្ជើញអភិបាល ឬមន្ត្រីប្រតិបត្តិណាម្នាក់ចូលរួម ក្នុងកិច្ចប្រជុំរបស់ខ្លួន។ គណៈកម្មាធិការសវនកម្ម មានសិទ្ធិពេញលេញ និងគ្មានដែនកំណត់ ក្នុងការទទួលបាននូវព័ត៌មានផ្សេងៗ ព្រមទាំងការទទួលយកការប្រឹក្សាយោបល់ ពីអ្នកជំនាញឯករាជ្យ ក្នុងករណីចាំបាច់ ដោយរាល់ចំណាយ ដែលពាក់ព័ន្ធទាំងអស់ ជាបន្ទុករបស់ធនាគារ។ ធនាគារត្រូវផ្តល់ធនធានចាំបាច់នានា ដល់គណៈកម្មាធិការសវនកម្ម ដើម្បីឱ្យគណៈកម្មាធិការសវនកម្ម បំពេញការងាររបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។

## ៣. តួនាទី និងភារកិច្ច របស់គណៈកម្មាធិការសវនកម្ម

តួនាទី និងកាតព្វកិច្ច របស់គណៈកម្មាធិការសវនកម្ម មានដូចខាងក្រោម៖

| ចំណុចគន្លឹះ នៃការទទួលខុសត្រូវ | ការទទួលខុសត្រូវ |
|---|---|
| ការត្រួតពិនិត្យផ្ទៃក្នុង / ការគ្រប់គ្រងហានិភ័យ / អភិបាលកិច្ច | ពិនិត្យឡើងវិញ លើប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ច ក្នុងសម្ព័ន្ធធនាគារ ស្របតាមលក្ខខណ្ឌតម្រូវ នៅក្នុងប្រកាសស្តីពីអភិបាលកិច្ច នៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ |
| សវនកម្មផ្ទៃក្នុង | ក. ធានាថា មុខងារសវនកម្មផ្ទៃក្នុង បានរៀបចំល្អប្រសើរ ដើម្បីធ្វើការត្រួតពិនិត្យ ឬអង្កេត ក្នុងនាមគណៈកម្មាធិការសវនកម្ម ហើយមុខងារនេះ ត្រូវស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងផ្ទាល់ ពីគណៈកម្មាធិការសវនកម្ម។<br>ខ. ពិនិត្យ និងអនុម័តវិសាលភាពការងារសវនកម្មផ្ទៃក្នុង នីតិវិធី ចំនួនដង នៃការធ្វើសវនកម្មផ្ទៃក្នុង និងគម្រោងសវនកម្មប្រចាំឆ្នាំ។<br>គ. មើលការខុសត្រូវ លើប្រសិទ្ធភាព នៃមុខងារសវនកម្មផ្ទៃក្នុង សមត្ថភាពបុគ្គលិក និងភាពគ្រប់គ្រាន់ នៃធនធានរបស់សវនកម្មផ្ទៃក្នុង និងពិនិត្យមើលថាតើមុខងារនោះ បានទទួលអំណាចចាំបាច់ ដើម្បីបំពេញការងារឬនៅ។<br>ឃ. ពិនិត្យរបាយការណ៍សំខាន់ៗ និងធានាថា គណៈគ្រប់គ្រង ចាត់វិធានការណ៍កែតម្រូវទាន់ពេលវេលា ដើម្បីដោះស្រាយចំណុចខ្សោយ ក្នុងការគ្រប់គ្រងការមិនបានអនុវត្តពេញលេញ តាមគោលនយោបាយ ការតម្រូវរបស់ច្បាប់ និងបទប្បញ្ញត្តិនានា និងបញ្ហាផ្សេងទៀត ដែលរកឃើញដោយសវនករផ្ទៃក្នុង ក៏ដូចជាផ្នែក ដែលទទួលខុសត្រូវការគ្រប់គ្រងផ្ទៃក្នុងដទៃទៀត។<br>ង. កត់សម្គាល់ការមិនឯកភាពសំខាន់ៗ រវាងនាយកសវនកម្មផ្ទៃក្នុង និងគណៈគ្រប់គ្រងដទៃទៀត មិនថាការមិនឯកភាពនោះ ត្រូវបានដោះស្រាយរួច ដើម្បីកំណត់ផលប៉ះពាល់ ដែលការមិនឯកភាពទាំងនោះអាចមាន ចំពោះដំណើរការសវនកម្ម ឬលទ្ធផលសវនកម្ម ដែលលើកឡើង ដោយសវនករ។<br>ច. ធានាការគោរព តាមច្បាប់ និងបទប្បញ្ញត្តិ ដែលអនុវត្ត ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងធានាថា របាយការណ៍របស់សវនករផ្ទៃក្នុង នឹងមិនតម្រូវឱ្យត្រួតពិនិត្យដោយគណៈគ្រប់គ្រងឡើយ។<br>ឆ. បង្កើតយន្តការ ដើម្បីវាយតម្លៃការបំពេញតួនាទី និងប្រសិទ្ធភាពរបស់មុខងារសវនកម្មផ្ទៃក្នុង។<br>ជ. វាយតម្លៃសកម្មភាពប្រតិបត្តិការ និងធ្វើសេចក្តីសម្រេច អំពីកញ្ចប់តម្លៃការរបស់នាយកសវនកម្មផ្ទៃក្នុង។<br>ឈ.អនុម័ត លើការតែងតាំង ការផ្លាស់ប្តូរ និងការបណ្តេញចេញនាយកសវនកម្មផ្ទៃក្នុង ឬបុគ្គលិកជាន់ខ្ពស់ ដែលបំពេញមុខងារជា សវនករផ្ទៃក្នុង និងត្រូវទទួលការជូនដំណឹងអំពីការលាឈប់របស់បុគ្គលិកជាន់ខ្ពស់ជាសវនករផ្ទៃក្នុង ហើយត្រូវផ្តល់ឱកាសឱ្យសមាជិក ដែលបានដាក់ពាក្យលាឈប់នោះ បញ្ជាក់ច្រាបពីមូលហេតុ នៃការលាឈប់។ |
| សវនកម្មខាងក្រៅ | ក. ផ្តល់អនុសាសន៍ ដល់ក្រុមប្រឹក្សាភិបាល លើការតែងតាំង ការបញ្ឈប់ និងកញ្ចប់តម្លៃការរបស់សវនករខាងក្រៅ។<br>ខ. ពិភាក្សា និងពិនិត្យមើលឡើងវិញ ជាមួយសវនករខាងក្រៅ មុននឹងចាប់ផ្តើមធ្វើសវនកម្ម អំពីលក្ខណៈ និងទំហំការងារសវនកម្ម ហើយធានា លើការសម្របសម្រួលក្នុងករណីមានក្រុមហ៊ុនសវនកម្មច្រើនចូលរួម។<br>គ. វាយតម្លៃ អំពីគោលដៅ ការបំពេញការងារ និងឯករាជ្យភាពរបស់សវនករខាងក្រៅ (ឧទាហរណ៍ ដោយការពិនិត្យ និងវាយតម្លៃ ពីទំនាក់ទំនងផ្សេងៗ រវាងសវនករខាងក្រៅ និងធនាគារ)។<br>ឃ. អនុម័ត លើការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្ម ដែលផ្តល់ដោយសវនករខាងក្រៅ និងតាមដាន និងធ្វើការវាយតម្លៃថាតើសេវានោះ អាចនឹងប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគាត់ឬទេ។<br>ង. ធានាថា មានការពិនិត្យច្បាស់លាស់ លើលក្ខខណ្ឌ នៃការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្ម ដើម្បីចៀសវៀងការប៉ះពាល់ ដល់ការវិនិច្ឆ័យ ប្រកបដោយឯករាជ្យភាពរបស់សវនករខាងក្រៅ។<br>ច. ធានាថា របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា ដោយមានការត្រួតពិនិត្យឡើងវិញជាប្រចាំ លើភាពគ្រប់គ្រាន់ នៃការធ្វើសំវិធានធន ដែលចាំបាច់ និងចំពោះបំណុលអាក្រក់ និងសង្ស័យ។<br>ឆ. រក្សាការទំនាក់ទំនងស្មោះត្រង់ បើកចំហ ទាន់ពេលវេលា និងទៀងទាត់ ជាមួយសវនករខាងក្រៅ និងតម្រូវឱ្យសវនករខាងក្រៅ រាយការណ៍មកកាន់គណៈកម្មាធិការសវនកម្ម អំពីបញ្ហាសំខាន់ៗ (ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ប្រសិនបើចាំបាច់)។<br>ជ. ពិនិត្យឡើងវិញ លើរបាយការណ៍គ្រប់គ្រងផ្ទៃក្នុងរបស់សវនករខាងក្រៅ និងធានាថា គណៈគ្រប់គ្រង ចាត់វិធានការណ៍កែតម្រូវ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលសវនកម្មខាងក្រៅ និងអនុសាសន៍ ដែលលើកឡើងដោយសវនករខាងក្រៅ ទាន់ពេលវេលា។<br>ឈ.តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងាររបស់សវនករខាងក្រៅ រួមទាំងជួបប្រជុំ ជាមួយសវនករខាងក្រៅយ៉ាងហោចណាស់ម្តង ក្នុងមួយឆ្នាំ ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ដើម្បីពិភាក្សា លើបញ្ហាគន្លឹះសំខាន់ៗ និងស្នើសុំយោបល់ ពីសវនករខាងក្រៅវិញ។ |
| លទ្ធផលសវនកម្ម ការត្រួតពិនិត្យផ្ទៃក្នុង និងបញ្ហានៃការប្រតិបត្តិតាមច្បាប់ | ពិនិត្យឡើងវិញ លើលទ្ធផល នៃការអង្កេតសំខាន់ៗ លទ្ធផលសវនកម្មជាប្រចាំ និងការត្រួតពិនិត្យផ្ទៃក្នុង និងការប្រតិបត្តិតាមច្បាប់ ដែលរាយការណ៍ដោយសវនករផ្ទៃក្នុង សវនករខាងក្រៅ និងសវនកររបស់និយ័តករ។ |
| របាយការណ៍ហិរញ្ញវត្ថុ | ពិនិត្យ លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ មុនពេលទទួលការអនុម័ត ពីក្រុមប្រឹក្សាភិបាល ដោយផ្តោតសំខាន់ លើ៖<br>• ការផ្លាស់ប្តូរណាមួយ នៅក្នុងការអនុវត្ត និងគោលការណ៍គណនេយ្យ<br>• បញ្ហាសំខាន់ៗ ដែលបានលើកឡើង រួមទាំងបញ្ហា ទាក់ទងនឹងការរាយការណ៍ហិរញ្ញវត្ថុ ការវិនិច្ឆ័យសំខាន់ៗរបស់គណៈគ្រប់គ្រង ព្រឹត្តិការណ៍ ឬប្រតិបត្តិការមិនប្រក្រតី និងសំខាន់ៗ និងរបៀប ដែលបញ្ហាទាំងអស់ ត្រូវបានបង្ហាញ<br>• ការធ្វើសេចក្តីសន្និដ្ឋាន ពីបញ្ហា ដែលកំពុងកើតឡើង និង<br>• ការប្រតិបត្តិតាមស្តង់ដារគណនី និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិច្បាប់ដទៃផ្សេងទៀត |
| ប្រតិបត្តិការរបស់ភាគីសម្ព័ន្ធញាតិ | ពិនិត្យរាល់ប្រតិបត្តិការធ្វើឡើង ជាមួយភាគីសម្ព័ន្ធញាតិ និងជូនដំណឹង ដល់ក្រុមប្រឹក្សាភិបាល ពីប្រតិបត្តិការទាំងនោះ។ |
| ការពិនិត្យរបាយការណ៍ ពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ | ពិនិត្យភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់ នៃសេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល នៅក្នុងរបាយការណ៍ក្រុមប្រឹក្សាភិបាល ការបង្ហាញពីអភិបាលកិច្ចធនាគារ របាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីប្រកាសដំបូង ពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ |
| ការតាមដានការអនុវត្ត តាមគោលនយោបាយ ទំនាស់ផលប្រយោជន៍ | តាមដានការអនុវត្ត តាមគោលនយោបាយ ស្តីទីទំនាស់ផលប្រយោជន៍របស់ធនាគារ |
| ការពិនិត្យក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុង | ពិនិត្យមតិយោបល់របស់ភាគីទីបី ចំពោះរចនាសម្ព័ន្ធ និងប្រសិទ្ធភាព នៃក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារ |
| ផ្សេងៗ | ក. ទាក់ទង ជាមួយគណៈគ្រប់គ្រងជាន់ខ្ពស់ ជាទៀងទាត់ ដើម្បីទទួលបានព័ត៌មាន អំពីបញ្ហា ដែលប៉ះពាល់ដល់ធនាគារ។<br>ខ. កោះប្រជុំ ជាមួយសវនករផ្ទៃក្នុង សវនករខាងក្រៅ ឬទាំងពីរ ក្នុងពេលតែមួយ បើយល់ថាចាំបាច់។<br>គ. ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងប្រចាំឆ្នាំ សម្រាប់ដាក់បញ្ជូនទៅឱ្យក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងធានានូវការចោះពុម្ពផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំបានរហ័ស។ |

## ៤. សេចក្តីសង្ខេបសកម្មភាពផ្សេងៗ ក្នុងឆ្នាំ២០២៤

### ៤.១. គណៈកម្មាធិការសវនកម្ម

ក. បានត្រួតពិនិត្យឡើងវិញ និងអនុម័តយល់ព្រម លើផែនការសវនកម្មប្រចាំឆ្នាំ វិសាលភាពការងារ និងតម្រូវការ ផ្នែកធនធានរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។
ខ. បានត្រួតពិនិត្យឡើងវិញ នូវភាពគ្រប់គ្រាន់ និងប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យនានា ការធ្វើរបាយការណ៍ និងការគ្រប់គ្រងហានិភ័យ ដើម្បីធានាថា មានវិធីសាស្ត្រជាប្រព័ន្ធមួយ ក្នុងការកំណត់ វាយតម្លៃ និងកាត់បន្ថយហានិភ័យ លើវិស័យនានា។
គ. បានត្រួតពិនិត្យ និងអនុម័តរបាយការណ៍ ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ២០២៤ ដើម្បីផ្ញើជូនទៅធនាគារជាតិ នៃកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។
ឃ. បានត្រួតពិនិត្យ និងផ្តល់អនុសាសន៍ លើរបាយការណ៍សវនកម្ម ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីផ្ញើជូនទៅធនាគារជាតិ នៃកម្ពុជា។
ង. បានត្រួតពិនិត្យឡើងវិញ នូវប្រសិទ្ធភាព នៃប្រតិបត្តិការ និងការប្រើប្រាស់ធនធានទាំងអស់ នៅក្នុងធនាគារ ដោយសន្សំសំចៃ។
ច. បានត្រួតពិនិត្យឡើងវិញ អំពីការតែងតាំងសវនករខាងក្រៅ ព្រមទាំងឯករាជ្យភាព និងប្រសិទ្ធភាពការងាររបស់សវនករខាងក្រៅផងដែរ។
ឆ. បានត្រួតពិនិត្យឡើងវិញ នូវផែនការសវនកម្មរបស់សវនករខាងក្រៅ វិសាលភាពការងារ និងលទ្ធផល នៃសវនកម្មប្រចាំឆ្នាំរបស់ធនាគារ។
ជ. បានជួប ជាមួយសវនករខាងក្រៅ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ដោយពុំមានវត្តមានរបស់គណៈគ្រប់គ្រង និងអភិបាលប្រតិបត្តិ ដើម្បីពិភាក្សាបញ្ហាពាក់ព័ន្ធនានា និងស្នើសុំយោបល់កែតម្រូវ ពីសវនករខាងក្រៅ។
ឈ. បានត្រួតពិនិត្យឡើងវិញ នូវបញ្ហាពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង ដែលរកឃើញដោយសវនករផ្ទៃក្នុង និងសវនករខាងក្រៅ ព្រមទាំងភាពត្រឹមត្រូវ នៃការឆ្លើយតបរបស់គណៈគ្រប់គ្រង ចំពោះ អនុសាសន៍របស់សវនករ និងការឯកភាព លើផែនការសកម្មភាព ដែលត្រូវអនុវត្ត ឱ្យទាន់ពេលវេលា។
ញ. បានត្រួតពិនិត្យឡើងវិញ នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសរបស់ធនាគារ។
ដ. បានជានា នូវការប្រតិបត្តិតាមវិធានច្បាប់ និងគោលការណ៍ផ្ទៃក្នុង ព្រមទាំងការវិវឌ្ឍ នៃសកម្មភាពការងារនានា របស់គណៈគ្រប់គ្រង ក្នុងការអនុវត្ត តាមអនុសាសន៍របស់សវនកម្មផ្ទៃក្នុង និងសវនកម្ម ខាងក្រៅ។
ឋ. បានវាយតម្លៃប្រតិបត្តិការប្រចាំឆ្នាំរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ជាមួយនឹងការសម្រេច លើកញ្ចប់តម្លៃការ ព្រមទាំងផ្តល់នូវមតិយោបល់ ដើម្បីកែលម្អ។
ឌ. បានពិភាក្សា លើលទ្ធផល នៃការត្រួតពិនិត្យ លើការធានាគុណភាព (Quality Assurance)។

### ៤.២. មុខងារសវនកម្មផ្ទៃក្នុង

ក. ការធ្វើសវនកម្មផ្ទៃក្នុង សម្រាប់ធនាគារ មានការជួយគាំទ្រ ពីនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រុមហ៊ុនមេ។
ខ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានអនុវត្តការងារ ប្រកបដោយឯករាជ្យភាព និងជានា លើភាពគ្រប់គ្រាន់ និងប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលបានអនុវត្តដោយគណៈគ្រប់គ្រង។
គ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានជួយគណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រង ក្នុងការអនុវត្តការងារ ប្រកបដោយប្រសិទ្ធភាព ចំពោះការត្រួតពិនិត្យ លើប្រសិទ្ធភាពចំណាយ ការវាយតម្លៃ លើ ការគ្រប់គ្រងហានិភ័យ ការផ្តល់យោបល់ លើវិធានការកាត់បន្ថយហានិភ័យ ដែលបានរកឃើញ និងធានានូវដំណើរការអភិបាលកិច្ចត្រឹមត្រូវ។
ឃ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានផ្តល់របាយការណ៍ជាប្រចាំ ជូនដល់គណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រង អំពីលទ្ធផល នៃការធ្វើសវនកម្ម ដែលបញ្ជាក់អំពីប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យ ផ្ទៃក្នុង និងហានិភ័យសំខាន់ៗ។
ង. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានស៊ើបអង្កេត លើសកម្មភាពពាក់ព័ន្ធ ដែលសង្ស័យថា ជាការកេងបន្លំ និងសកម្មភាពមិនប្រក្រតីផ្សេងទៀត ស្របតាម ឬនៅពេលដែលមានតម្រូវការសមស្រប ពីអាជ្ញាធរ ឬគណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ។
ច. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បន្តផ្តល់នូវអនុសាសន៍បន្ថែម ដែលមានគុណតម្លៃ និងគុណភាព ពីការធ្វើសវនកម្ម។
ឆ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បន្តអនុវត្តផែនការផ្សេងៗ ដូចជាការរួមបញ្ចូលវិធីសាស្ត្រ Agile ក៏ដូចជាបញ្ចូលការវិភាគទិន្នន័យ ក្នុងដំណើរការសវនកម្ម ដែលជាផ្នែកមួយ នៃផែនការ Forward 23+។
ជ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង តាមដានការអនុវត្ត ពីគណៈគ្រប់គ្រង និងដាក់ជូននូវរបាយការណ៍ អំពីស្ថានភាពលទ្ធផលសវនកម្ម ជូនគណៈកម្មាធិការសវនកម្ម។
ឈ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានពង្រឹងទំនាក់ទំនង ជាមួយគណៈគ្រប់គ្រង តាមរយៈជំនួបធុរកិច្ចជាប្រចាំ ដើម្បីបង្កើនការយល់ដឹង អំពីដំណើរការអាជីវកម្ម និងទៅលើផ្នែក ដែលត្រូវផ្តោត ក្នុងការ ធ្វើសវនកម្ម។
ញ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានផ្តល់ជាមតិ លើគោលការណ៍ និងនីតិវិធី ដែលបានស្នើឡើង ដើម្បីបញ្ជាក់ថា ហានិភ័យ ដែលអាចកើតមាន ត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យ។

### ៤.៣. របាយការណ៍សវនកម្មផ្ទៃក្នុង

ក. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានបញ្ចប់ការធ្វើសវនកម្មចំនួន ១៧ លើក ដោយបានគ្របដណ្តប់ លើប្រតិបត្តិការសំខាន់ៗទាំងអស់។
ខ. រាល់បញ្ហា ដែលនាយកដ្ឋានសវនកម្មផ្ទៃក្នុង បានរកឃើញ ត្រូវបានកត់ត្រាទុក និងតាមដានបន្ត រហូតដល់បញ្ហាទាំងនោះ ត្រូវបានដោះស្រាយចប់ ហើយនឹងត្រូវរាយការណ៍រៀងរាល់ ០២ ខែម្តង ជូនគណៈកម្មាធិការសវនកម្ម។
គ. ការវិវឌ្ឍ នៃសកម្មភាពការងារ ក្នុងការអនុវត្ត តាមអនុសាសន៍របស់នាយកដ្ឋានសវនកម្ម ត្រូវបានរាយការណ៍ ជូនដល់គណៈកម្មាធិការសវនកម្មរៀងរាល់ ០២ ខែម្តងផងដែរ។

# សេចក្តីថ្លែងការណ៍ ស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ផ្តល់សារៈសំខាន់ ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងប្តេជ្ញារក្សាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនោះ ឱ្យមានលក្ខណៈល្អប្រសើរ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង បង្ហាញពីតម្រូវការចាំបាច់ចំពោះការប្រតិបត្តិការអាជីវកម្ម ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល និងដំណើរការ នៃការរៀបចំ និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ និងសមស្រប ព្រមទាំងការអនុវត្ត ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមានផងដែរ។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវជារួម លើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងការគ្រប់គ្រងលើប្រព័ន្ធព័ត៌មានវិទ្យា។ ក្រុមប្រឹក្សាភិបាល ក៏ទទួលស្គាល់ផងដែរថា ការត្រួតពិនិត្យឡើងវិញ លើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការរួមគ្នា និងត្រូវអនុវត្តជាបន្តបន្ទាប់ នៅក្នុងធនាគារ ហើយវាត្រូវធ្វើការផ្លាស់ប្តូរ ស្របទៅនឹងបច្ចេកវិទ្យា បរិយាកាសអាជីវកម្ម និងបទប្បញ្ញត្តិច្បាប់ ក្នុងន័យធ្វើឱ្យប្រសើរឡើង នូវដំណើរការ នៃការកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានបង្កើតឡើង ដើម្បីកំណត់ គ្រប់គ្រង និងត្រួតពិនិត្យហានិភ័យ រួមបញ្ចូលទាំងហានិភ័យប្រតិបត្តិការ ពោលគឺមិនមែនដើម្បីលុបបំបាត់ចោលនូវហានិភ័យ ដែលកើតចេញពីការបរាជ័យ ក្នុងការសម្រេចទិសដៅអាជីវកម្មនោះទេ។

## ការគ្រប់គ្រងហានិភ័យ និងក្របខណ្ឌ នៃការត្រួតពិនិត្យ

ធនាគារចាត់ទុកថា ការគ្រប់គ្រងហានិភ័យ គឺជាធាតុមួយយ៉ាងសំខាន់ នៃអាជីវកម្មរបស់ធនាគារ ហើយបញ្ហាលវប្បធម៌ហានិភ័យដ៏តឹងរឹង ទៅក្នុងប្រតិបត្តិការ និងដំណើរការសម្រេចចិត្តរបស់ធនាគារ។ ជាមួយនឹងការយល់ដឹង អំពីអត្ថប្រយោជន៍ នៃការគ្រប់គ្រងហានិភ័យ សម្រាប់ធនាគារ ដើម្បីសម្រេចបាននូវការរីកចម្រើន ប្រកបដោយនិរន្តរភាពបាន ក្រុមការងារគ្រប់គ្រងហានិភ័យ ចូលរួមតាំងពីដំណាក់កាលដំបូង នៃដំណើរការទទួលយកហានិភ័យ ដើម្បីផ្តល់នូវទស្សនៈឯករាជ្យ និងមតិយោបល់ រួមមានការវាយតម្លៃផលិតផលថ្មី អភិបាលកិច្ច លើសកម្មភាពតតិយភាគី ការត្រួតពិនិត្យ ការក្លែងបន្លំ ការកំណត់យុទ្ធសាស្ត្រការវាយតម្លៃឥណទាន។ល។

ធនាគារ ដែលជាផ្នែកមួយ នៃស៊ីអាយអិមប៊ី គ្រុប (CIMB Group) បានបញ្ចូលនូវក្របខណ្ឌគ្រប់គ្រងហានិភ័យទូទៅមួយ សម្រាប់សហគ្រាសទាំងមូល (Enterprise Wide Risk Management Framework «EWRM») ដើម្បីគ្រប់គ្រងហានិភ័យ និងឱកាសរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព។ ក្របខណ្ឌគ្រប់គ្រងហានិភ័យទូទៅ សម្រាប់សហគ្រាសទាំងមូល ផ្តល់ជូនក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងរបស់ខ្លួន នូវឧបករណ៍មួយ ដើម្បីធ្វើការប្រមើលមើលទុកជាមុន និងគ្រប់គ្រង លើហានិភ័យ ដែលមានស្រាប់ និងហានិភ័យ ដែលអាចនឹងកើតមាន ដោយធ្វើការពិចារណា ទៅលើការកែប្រែនូវទម្រង់ហានិភ័យ ស្រប តាមការផ្លាស់ប្តូរ នៃយុទ្ធសាស្ត្រអាជីវកម្ម បរិយាកាសខាងក្រៅ និង/ឬ បញ្ញត្តិច្បាប់នានា។

## សន្តិសុខព័ត៌មានវិទ្យា

សន្តិសុខព័ត៌មានវិទ្យា គឺតម្រូវឱ្យមានជាយុទ្ធសាស្ត្ររួម នៃការគ្រប់គ្រង ទៅលើវិន័យរបស់អ្នកប្រើប្រាស់ ដំណើរការប្រតិបត្តិ និងប្រព័ន្ធបច្ចេកវិទ្យា ក្នុងគោលបំណង ដើម្បីពង្រឹងបន្ថែម លើកម្រិតការគ្រប់គ្រងសន្តិសុខព័ត៌មានវិទ្យា ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានជ្រើសយកបច្ចេកវិទ្យា ដែលមានស្តង់ដារជាអន្តជាតិ ដំណើរការប្រតិបត្តិ និងបែបបទ នៃការគ្រប់គ្រង អនុលោមទៅតាមធនាគារមេ។ អនុវត្តតាមផែនការសន្តិសុខព័ត៌មានវិទ្យា យុទ្ធសាស្ត្រនៃការថែទាំ នឹងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខពត៌មានវិទ្យា ប្រកបដោយប្រសិទ្ធភាព ទៅតាមក្រុមហ៊ុនមេ ដើម្បីគាំទ្រដំណើរអាជីវកម្មរបស់ធនាគារ ឱ្យមានសុវត្ថិភាពខ្ពស់។

ដើម្បីឱ្យស្របទៅតាមការីកលូតលាស់ នៃអាជីវកម្មធនាគារ និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ការរៀបចំបទដ្ឋានបច្ចេកវិទ្យារបស់យើង តែងតែត្រូវបានពិនិត្យឡើងវិញជារឿយៗ និងធ្វើការពង្រឹងបន្ថែម ដើម្បីឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងហានិភ័យ នៃការគំរាមកំហែងទាំងខាងក្នុង និងក្រៅ។ លើសពីនេះទៅទៀត ធនាគារ ស៊ីអាយអិមប៊ី មានការពឹងផ្អែក ទៅលើមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខរបស់ក្រុមហ៊ុនមេ (Group's Security Operation Centre) ដែលបង្កើតឡើង ដើម្បីតាមដាន និងឆ្លើយតបទៅនឹងសកម្មភាពវាយប្រហារ តាមប្រព័ន្ធអ៊ីនធើណេត (cyber-attack) ដែលអាចនឹងកើតឡើង ដោយយថាហេតុ។

រីឯនៅកម្រិតសុវត្ថិភាព តាមបណ្តាញកុំព្យូទ័រវិញ ធនាគារ ស៊ីអាយអិមប៊ី បានតម្លើងបន្ថែមនូវប្រព័ន្ធបណ្តាញការពារសុវត្ថិភាព (Network Firewall) និងការកំណត់ លើការចូលប្រើប្រាស់ ដើម្បីគ្រប់គ្រងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ និងទិន្នន័យផ្សេងៗ ដែលមានក្នុងបណ្តាញ ទោះមើលឃើញ ឬមើលពុំឃើញក្តី ហើយវាអាចដាក់កំហិត ក្នុងការប្រើប្រាស់ និងការផ្តល់សិទ្ធិ នៅលើប្រព័ន្ធបណ្តាញកុំព្យូទ័រ។ លើសជាងនេះទៅទៀត ធនាគារក៏បានបំពាក់ នូវប្រព័ន្ធការពារគ្រប់កុំព្យូទ័រ និងម៉ាស៊ីនមេទាំងអស់ ដូចជាការប្រឆាំងមេរោគ (Anti-Malware) ការដឹងនូវការវាយប្រហារ ទៅលើប្រព័ន្ធ និងការទប់ស្កាត់ការវាយប្រហារ ដោយស្វ័យប្រវត្តិ ការបំលែងទិន្នន័យ (Encryption) រាល់កុំព្យូទ័រយួរដៃ ការទប់ស្កាត់ នៃការបាត់បង់ទិន្នន័យ (DLP) ការពារការជ្រៀតជ្រែក ពីជនខិលខូច តាមរយៈប្រព័ន្ធអ៊ីនធើណេត ការពារលើប្រព័ន្ធអ៊ីម៉ែល និងក្រោះ ឬទប់ស្កាត់រាល់មាតិកាព័ត៌មាន ដែលមានហានិភ័យ នៅលើវ៉ែបសាយ ដែលអាចជួយកាត់បន្ថយហានិភ័យ ផ្នែកសន្តិសុខព័ត៌មានវិទ្យា នៅពេលទិន្នន័យ ត្រូវបានបញ្ជូនឆ្លងកាត់ប្រព័ន្ធបណ្តាញរបស់ធនាគារ។ ការចំពាក់ប្រព័ន្ធ ដែលមានលទ្ធភាពឱ្យយើងដឹងឆ្លាមៗ នូវការវាយប្រហារ និងការទប់ស្កាត់ដោយស្វ័យប្រវត្តិ រួមទាំងនិយមន័យមេរោគ និងការកំណត់ ទៅលើប្រព័ន្ធសុវត្ថិភាពខាងលើ តែងតែទទួលបានការធ្វើបច្ចុប្បន្នភាព ឱ្យទាន់សភាពការណ៍ជានិច្ច ដើម្បីឱ្យពួកគេមានសមត្ថភាពការពារ ទប់ស្កាត់ និងកាត់បន្ថយនូវភាពងាយរងគ្រោះ ដែលបណ្តាលមកពីការរកឃើញថ្មីៗរបស់ជនខិលខូច។

ធនាគារក៏បានអនុវត្តកម្មវិធីលើកកម្ពស់សន្តិសុខព័ត៌មាន ដោយបានបណ្តុះបណ្តាលចំណេះដឹង ទៅដល់បុគ្គលិកថ្មី និងបុគ្គលិកចាស់ទាំងអស់ ដើម្បីបង្កើនការយល់ដឹង អំពីភាពជាឯកជន ការលេចធ្លាយ នៃព័ត៌មាន និងទំនួលខុសត្រូវ លើផ្នែកសន្តិសុខព័ត៌មានវិទ្យា។ កម្មវិធីទាំងនេះ មានដូចជាការបណ្តុះបណ្តាលតាមប្រព័ន្ធសិក្សាអេឡិចត្រូនិក និងត្រូវប្រលងជាប៉ាងរាល់ឆ្នាំ និងការចែកចាយជាព្រឹត្តិបត្រព័ត៌មានផ្សេងៗ។

## ដំណើរការ នៃការត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗ

ដំណើរការសំខាន់ៗ ដែលក្រុមប្រឹក្សាភិបាល បានបង្កើតឡើង ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញ នូវភាពគ្រប់គ្រាន់ និងសុចរិតភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង រួមបញ្ចូលទាំងការអនុវត្តតាមច្បាប់ បទប្បញ្ញត្តិវិធាន សេចក្តីណែនាំ និងគោលការណ៍ណែនាំ ដែលមានជាធរមាន ដូចខាងក្រោម៖

### គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម មានសមាជិកជា អភិបាលឯករាជ្យមិនប្រតិបត្តិ ចំនួន ០២ រូប និងអភិបាលមិនឯករាជ្យមិនប្រតិបត្តិ ចំនួន ០១ រូប។ គណៈកម្មាធិការសវនកម្ម គឺជាគណៈកម្មាធិការមួយ ដែលទទួលបានការផ្ទេរសិទ្ធិអំណាច ពីក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវ លើការត្រួតពិនិត្យការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ការផ្សព្វផ្សាយព័ត៌មាន ការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ការគ្រប់គ្រងហានិភ័យ ការអនុវត្តអភិបាលកិច្ច និងការតាមដានដំណើរការ នៃការគ្រប់គ្រង លើការត្រួតពិនិត្យផ្ទៃក្នុង នៅក្នុងធនាគារ។ គណៈគ្រប់គ្រងជាន់ខ្ពស់ សវនការផ្ទៃក្នុង និងសវនករខាងក្រៅ ផ្តល់របាយការណ៍ ជូនគណៈកម្មាធិការសវនកម្ម អំពីប្រសិទ្ធភាព និងប្រសិទ្ធផល នៃការត្រួតពិនិត្យផ្ទៃក្នុង។

រាល់បញ្ហាសំខាន់ៗ និងគួរឱ្យកត់សម្គាល់ ដែលបានរកឃើញ ដោយសវនករផ្ទៃក្នុង សវនករខាងក្រៅ និងនិយ័តករ ត្រូវរាយការណ៍ ទៅគណៈកម្មាធិការសវនកម្ម ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញ និងពិភាក្សា។ គណៈកម្មាធិការសវនកម្ម ត្រួតពិនិត្យឡើងវិញ និងធានា អំពីការអនុវត្តផែនការកាត់បន្ថយបញ្ហា ឬហានិភ័យរបស់គណៈគ្រប់គ្រង ដើម្បីការពារផលប្រយោជន៍របស់ធនាគារ និងរក្សាបានល្អ នូវអភិបាលកិច្ចដ៏សមស្រប។ ការគ្រប់គ្រងផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ដែលត្រូវបានចាត់ថ្នាក់ថា មាន «ហានិភ័យ លើសពីកម្រិតមធ្យម» ឬ «ហានិភ័យកម្រិតខ្ពស់» ដោយសវនករផ្ទៃក្នុង ត្រូវទទួលការពិគ្រោះយោបល់ ពីគណៈកម្មាធិការសវនកម្ម។

គណៈកម្មាធិការសវនកម្ម ក៏ធ្វើការត្រួតពិនិត្យឡើងវិញផងដែរ នូវរាល់ប្រតិបត្តិការ ជាមួយភាគីសម្ព័ន្ធញាតិ ថ្លៃចំណាយ លើសវនកម្ម និងថ្លៃចំណាយ មិនពាក់ព័ន្ធនឹងកិច្ចការសវនកម្ម ដែលស្នើដោយសវនករខាងក្រៅរបស់ធនាគារ។

ការធ្វើបទបង្ហាញនានា អំពីផែនការអាជីវកម្ម ការវិវឌ្ឍថ្មីៗ ប្រតិបត្តិការនានា ហានិភ័យ នៃអាជីវកម្ម និងការត្រួតពិនិត្យនានា ដើម្បីកាត់បន្ថយហានិភ័យ ត្រូវបានធ្វើឡើង ដោយផ្នែកអាជីវកម្មពាក់ព័ន្ធ និងផ្នែកគាំទ្រអាជីវកម្ម ប្រសិនបើគណៈកម្មាធិការសវនកម្ម គិតថាចាំបាច់។

សមាជិកគណៈកម្មាធិការសវនកម្ម ក៏ចូលរួមកិច្ចប្រជុំកំពូលរបស់គណៈគ្រប់គ្រងប្រចាំឆ្នាំរបស់ធនាគារ (Bank's Annual Management Summit) ផងដែរ ដែលនៅក្នុងកិច្ចប្រជុំនោះ ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មទីមួយ។ ធ្វើការត្រួតពិនិត្យឡើងវិញ នូវប្រតិបត្តិការនានារបស់ខ្លួន ដែលបានធ្វើឡើងសម្រាប់ឆ្នាំនេះ ព្រមទាំងធ្វើការបង្ហាញ អំពីយុទ្ធសាស្ត្រ និងផែនការនានា សម្រាប់ឆ្នាំបន្ទាប់ផងដែរ។

### គណៈកម្មាធិការហានិភ័យ

គណៈកម្មាធិការហានិភ័យ កំណត់អំពីកម្មវត្ថុ នៃគោលការណ៍ហានិភ័យរបស់ធនាគារ និងបំពេញតួនាទី និងកាតព្វកិច្ចជំនួសឱ្យក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យ លើការគ្រប់គ្រងហានិភ័យ។ ការទទួលខុសត្រូវ ចំពោះការត្រួតពិនិត្យ លើការគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ ត្រូវបានប្រគល់សិទ្ធិ ជូនទៅគណៈកម្មាធិការហានិភ័យ ដែលទទួលបន្ទុកវាយការណ៍ដោយផ្ទាល់ ទៅក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការហានិភ័យ ធ្វើការជួបប្រជុំជាប៉ាងរាល់ខែ ឬតាមការចាំបាច់។

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម រាយការណ៍អំពីហានិភ័យសាច់ប្រាក់ងាយស្រួលនិងបញ្ហា ទាក់ទងនឹងទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ធនាគារ ទៅគណៈកម្មាធិការហានិភ័យ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ធ្វើការប្រជុំជាប៉ាងរាល់ខែ ដោយមានតួនាទីចម្បង ក្នុងការពិនិត្យតាមដាន និងដោយប្រើប្រាស់ទ្រព្យសម្ភារគ្រប់គ្រង លើហានិភ័យហិរញ្ញវត្ថុ នៃតារាងតុល្យការ។ គណៈកម្មាធិការនេះមានការទទួលខុសត្រូវជាក់លាក់ ចំពោះការគ្រប់គ្រង លើថ្លៃដើមឥណទាន ការរៀបចំអភិវឌ្ឍបន្ថែម លើការផ្តល់ប្រឹក្សា ដែលសមស្រប ជូនគណៈកម្មាធិការហានិភ័យ ក្នុងការធ្វើសេចក្តីសម្រេច ទាក់ទងនឹងហានិភ័យ

សាច់ប្រាក់ងាយស្រួល និងហានិភ័យអត្រាការប្រាក់ ការបែងចែកប្រភពហិរញ្ញប្បទាន និងការត្រួតពិនិត្យឡើងវិញនូវ សមាសភាព ក្នុងតារាងតុល្យការ ពាក់ព័ន្ធនឹងគណទាន និងប្រាក់បញ្ញើរបស់ធនាគារ។ ជារួមមក គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ត្រួតពិនិត្យមើលការអនុវត្ត នៃដំណើរការគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាព សម្រាប់គ្រប់គ្រង លើអត្រាការប្រាក់ សាច់ប្រាក់ងាយស្រួល និងហានិភ័យ ស្រដៀងគ្នាផ្សេង។ទៀត ដែលទាក់ទងនឹងតារាងតុល្យការរបស់ធនាគារ និងកម្រិតពាក់ព័ន្ធផ្សេងទៀត។

## គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រង គឺជាគណៈកម្មាធិការ ដែលបង្កើតឡើង ដោយក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងបញ្ហា ដែលកើតពីការធ្វើប្រតិបត្តិការប្រចាំថ្ងៃ។ កិច្ចប្រជុំគណៈកម្មាធិការនេះ ធ្វើឡើងរៀងរាល់មួយខែម្តង គឺនៅសប្តាហ៍ទី៣ នៃខែនីមួយ។ ឬតាមការចាំបាច់។ សមាសភាពរបស់គណៈកម្មាធិការគ្រប់គ្រង រួមមានសមាជិក មកពីនាយកដ្ឋាននានា រួមបញ្ចូលទាំងតំណាង មកពីនាយកដ្ឋានសវនកម្មផ្ទៃក្នុងមួយរូប នាយកដ្ឋានប្រតិបត្តិតាមមួយរូប និងនាយកដ្ឋានយុទ្ធសាស្ត្រមួយរូប ដែលត្រូវបានអញ្ជើញចូលរួមប្រជុំជាអចិន្ត្រៃយ៍។

## គោលការណ៍ និងនីតិវិធីផ្ទៃក្នុង

រាល់គោលការណ៍ និងនីតិវិធីផ្ទៃក្នុង របស់ផ្នែកអាជីវកម្មទាំងអស់ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ គោលការណ៍ និងនីតិវិធីទាំងអស់នេះ ត្រូវបានប្រើប្រាស់ជាឧបករណ៍នាំផ្លូវមួយ សម្រាប់ការធ្វើប្រតិបត្តិការប្រចាំថ្ងៃ ដើម្បីធានា អំពីការប្រតិបត្តិតាម ការត្រួតពិនិត្យផ្ទៃក្នុង និងបទប្បញ្ញត្តិច្បាប់ ដែលមានជាធរមាន។ គោលការណ៍នេះ រៀបចំឡើង ក្នុងគោលបំណងធានាប្រសិទ្ធភាព នៃប្រតិបត្តិការឱ្យកាន់តែមានភាពប្រសើរឡើង ដោយធ្វើការពិចារណាផងដែរ ទៅលើបម្រែបម្រួល នៃវិស័យធនាគារ ដូចជាលក្ខខណ្ឌតម្រូវរបស់ច្បាប់ ហានិភ័យ និងវិធានការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីកាត់បន្ថយហានិភ័យ ព្រមទាំងផលិតផល និងសេវាកម្មថ្មី។ផងដែរ។

## សវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការរាយការណ៍ដោយឯករាជ្យ ជូនគណៈកម្មាធិការសវនកម្ម ហើយនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានឯករាជ្យភាពគ្រប់គ្រាន់ ពីផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មផ្សេងទៀត លើគ្រប់សកម្មភាព និងប្រតិបត្តិការទាំងអស់។ ការទទួលខុសត្រូវចម្បង របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺផ្តល់ការវាយតម្លៃឯករាជ្យ លើភាពគ្រប់គ្រាន់ ប្រសិទ្ធភាព និងប្រសិទ្ធផល នៃការគ្រប់គ្រងហានិភ័យ ដំណើរការគ្រប់គ្រង និងការត្រួតពិនិត្យ ដែលអនុវត្តដោយគណៈគ្រប់គ្រង។ ក្នុងការវាយតម្លៃ ទៅលើការត្រួតពិនិត្យផ្ទៃក្នុង នាយកដ្ឋានសវនកម្មផ្ទៃក្នុង អនុវត្តតាមសមាសភាគទាំងប្រាំ (៥) ដែលចែងនៅក្នុងក្របខណ្ឌរួម នៃការត្រួតពិនិត្យផ្ទៃក្នុង ដែលដាក់ចេញដោយគណៈកម្មាធិការ ដែលមានឈ្មោះ Committee of Sponsoring Organisations of the Treadway Commission (ហៅកាត់ថា COSO) ដែលសមាសភាគទាំងនោះ រួមមានស្ថានភាព នៃការត្រួតពិនិត្យ ការវាយតម្លៃហានិភ័យ សកម្មភាពត្រួតពិនិត្យ ការទំនាក់ទំនង និងព័ត៌មាន ហើយនឹងការពិនិត្យតាមដានសកម្មភាព។ COSO គឺជាអង្គភាពមួយ ដែលទទួលស្គាល់ជាអន្តរជាតិ ដែលផ្តល់ទស្សនៈ លើភាពជាអ្នកដឹកនាំ និងសេចក្តីណែនាំ លើការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យរបស់សហគ្រាស និងការទប់ស្កាត់ការកេងបន្លំ។

វិសាលភាពការងារ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង គ្របដណ្តប់លើគ្រប់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មទាំងអស់។ ការជ្រើសយកផ្នែកណាមួយ មកធ្វើសវនកម្ម ត្រូវធ្វើឡើងដោយផ្អែកលើផែនការសវនកម្មប្រចាំឆ្នាំ ដែលត្រូវបានអនុម័ត ដោយគណៈកម្មាធិការសវនកម្ម។

ការរួមបញ្ចូល នៃកត្តាហានិភ័យ ទៅក្នុងផែនការសវនកម្មប្រចាំឆ្នាំ ត្រូវបានធ្វើឡើង ដោយផ្អែកទៅលើ៖

- ១០០% នៃកត្តាហានិភ័យកម្រិតខ្ពស់ ត្រូវបានវាយតម្លៃ ដើម្បីធ្វើសវនកម្ម ក្នុងអំឡុង ៦ ទៅ១២ខែខាងមុខ ហើយ
- យ៉ាងហោចណាស់ ៨៥% នៃកត្តាហានិភ័យកម្រិតខ្ពស់ និងមធ្យម នៃផែនការសវនកម្ម
- កត្តាហានិភ័យកម្រិតមធ្យម ត្រូវបានវាយតម្លៃ ដើម្បីធ្វើសវនកម្ម ក្នុងអំឡុង ១២ ទៅ ២៤ខែខាងមុខ
- កត្តាហានិភ័យកម្រិតទាប ដែលសេសសល់ នឹងធ្វើការវាយតម្លៃឡើងវិញ ដើម្បីកំណត់ថានឹងត្រូវរួមបញ្ចូល ក្នុងផែនការសវនកម្ម នៅឆ្នាំខាងមុខ
- បទប្បញ្ញត្តិ ដែលពុំមានកំណត់ចេះវេលា ក្នុងការធ្វើសវនកម្មទៀងទាត់ នឹងត្រូវបានធ្វើសវនកម្មយ៉ាងតិចម្តង ក្នុងរយៈពេល ០២ឆ្នាំ

ដោយមិនគិតពីការវាយតម្លៃ លើហានិភ័យ វិសាលភាពការងាររបស់សវនកម្ម ត្រូវរួមបញ្ចូលនូវ នាយកដ្ឋាន ដែលទទួលបានការវាយតម្លៃថា មានហានិភ័យកម្រិតខ្ពស់ កាលពីឆ្នាំចាស់ ហើយនឹងត្រូវធ្វើសវនកម្មឡើងវិញ ក្នុងរយៈពេល ១២ខែ គិតចាប់ពីថ្ងៃ ដែលចេញរបាយការណ៍។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ក៏ធ្វើការស៊ើបអង្កេតផងដែរ លើការសង្ស័យ ចំពោះការលួចបន្លំ ដែលប្រព្រឹត្តដោយបុគ្គលិក អតិថិជន និងតតិយជន ហើយផ្តល់អនុសាសន៍កែលម្អឱ្យកាន់តែប្រសើរឡើង ដើម្បីបង្ការកុំឱ្យបញ្ហាដដែល កើតមានឡើងសាជាថ្មីម្តងទៀត និងចាត់វិធានការ ចំពោះបុគ្គលពាក់ព័ន្ធ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានសិទ្ធិទទួលបានគ្រប់ព័ត៌មានទាំងអស់ ដែលចាំបាច់ ដោយគ្មានការដាក់កំហិត ក្នុងក្របខណ្ឌ នៃការងាររបស់ខ្លួន។ វិសាលភាពការងារ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវបានបង្កើតឡើង ដោយយោងតាមស្តង់ដារអន្តរជាតិ នៃការប្រកបវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង របស់វិទ្យាស្ថានសវនករផ្ទៃក្នុង (The Institute of Internal Auditors ហៅកាត់ថា IIA) និងគោលការណ៍ណែនាំ ផ្នែកបទប្បញ្ញាត្តិច្បាប់ ដែលពាក់ព័ន្ធ។

របាយការណ៍សវនកម្ម គឺជាលទ្ធផលចុងក្រោយ នៃការងារសវនកម្ម ដែលបង្ហាញពីវិសាលភាពការងារសវនកម្មដែលបានចំពេញការវាយតម្លៃទូទៅ នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ជាមួយនឹងព័ត៌មានលម្អិតនៃការរកឃើញពីការធ្វើសវនកម្ម អនុសាសន៍កែលម្អឱ្យកាន់តែប្រសើរឡើង ព្រមទាំងការឆ្លើយតប ពីគណៈគ្រប់គ្រង។ បន្ទាប់មក ការអនុវត្តតាមអនុសាសន៍ ពីគណៈគ្រប់គ្រង ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃ ដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង។ គណៈកម្មាធិការសវនកម្ម ធ្វើការត្រួតពិនិត្យឡើងវិញ និងវាយតម្លៃរាល់អញ្ចត្តិកម្ម ឬការមិនប្រតិបត្តិតាមបទបញ្ញត្តិច្បាប់ ដែលបានលើកឡើង ដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងតាមដានសកម្មភាពនានា ដើម្បីធានាថា គណៈគ្រប់គ្រង បានចាត់វិធានការកែតម្រូវសមស្រប និងជាបន្ទាន់។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដាក់ជូននូវរបាយការណ៍ ទៅកាន់គណៈកម្មាធិការសវនកម្មរបស់ក្រុមហ៊ុនមេ ជារៀងរាល់មួយត្រីមាសម្តង។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង រៀបចំផែនការសវនកម្ម និងការចាត់ថ្នាក់សវនកម្ម ដោយអនុវត្តតាមវិធីសាស្ត្រដូចគ្នា ទៅនឹងវិធីសាស្ត្ររបស់សវនកម្ម នៃក្រុមហ៊ុនមេ ដោយធ្វើការកែសម្រួលប្រសិនបើចាំបាច់ ដើម្បីឱ្យសមស្រប ទៅនឹងបទប្បញ្ញត្តិ និងតម្រូវតាមស្ថានភាព ក្នុងប្រទេស។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានរួមបញ្ចូលនូវការវិភាគទិន្នន័យ វិធីសាស្ត្រ Agile ការពង្រឹងចំណេះដឹងបច្ចេកវិទ្យា និងការជំរុញការផ្លាស់ប្តូរ ដែលជាផ្នែកមួយ នៃការអនុវត្តផែនការ Forward23+ ដើម្បីស្របទៅតាមទិសដៅដឹកនាំរបស់ក្រុមហ៊ុនមេ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ជំរុញវិធីសាស្ត្រសវនកម្ម ដោយបញ្ចូលនូវការវិភាគទិន្នន័យ ដើម្បីសម្រួលដល់សវនករ ក្នុងការផ្តោតលើផ្នែក ដែលមានហានិភ័យជាចម្បង។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ក៏ផ្តល់យោបល់ដោះស្រាយបញ្ហា ក្នុងការគ្រប់គ្រងប្រសិទ្ធភាពចំណាយ ក៏ដូចជាពង្រឹងនូវគុណតម្លៃបន្ថែម (ឧទាហរណ៍៖ ការបង្កើតនីតិវិធីថ្មី) តាមរយៈការធ្វើសវកម្មក្នុងឆ្នាំ។

ដើម្បីពង្រឹងទំនាក់ទំនង ជាមួយគណៈគ្រប់គ្រង នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានរៀបចំជំនួបធុរកិច្ចប្រចាំត្រីមាស (Quarterly Business Monitoring ហៅកាត់ថា QBM) ជាមួយនឹងប្រធាននាយកដ្ឋាន ក៏ដូចជាប្រធានផ្នែក និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងគោលបំណងពង្រឹងទំនាក់ទំនង និងយល់ដឹងបន្ថែម អំពីដំណើរការអាជីវកម្ម សម្រាប់ការផ្តោត ក្នុងការធ្វើសវនកម្ម។ បន្ថែមពីនេះ នាយកដ្ឋានសវកម្មផ្ទៃក្នុង ក៏បានចូលរួមត្រួតពិនិត្យ និងផ្តល់មតិ លើសេចក្តីព្រាង នៃការកែប្រែ ឬការបង្កើតគោលការណ៍ថ្មី ដើម្បីរក្សាបាននូវភាពគ្រប់គ្រាន់ នៃអភិបាលកិច្ច ដែលស្នើឡើង និងដើម្បីដំណោះស្រាយហានិភ័យ។

## ក្របខណ្ឌ នៃការប្រតិបត្តិតាម

ក្រុមប្រឹក្សាភិបាល ទទួលស្គាល់ថា មុខងារប្រតិបត្តិតាម គឺជាផ្នែកមួយសំខាន់ នៃការគ្រប់គ្រង និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ពីព្រោះវប្បធម៌ នៃការប្រតិបត្តិតាមច្បាប់បទប្បញ្ញត្តិដ៏រឹងមាំ ឆ្លុះបញ្ចាំងពីវប្បធម៌សាជីវកម្ម ដែលប្រកបដោយសុចរិតភាព និងក្រមសីលធម៌ខ្ពស់។

មុខងារប្រតិបត្តិតាមរបស់ធនាគារ ត្រូវបានដឹកនាំ ដោយនាយកដ្ឋានប្រតិបត្តិតាម រួមជាមួយនឹងការប្រឹក្សាយោបល់ ក៏ដូចជាការណែនាំ ពីនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាមរបស់ក្រុមហ៊ុនមេ ដែលមានការិយាល័យ នៅប្រទេសម៉ាឡេស៊ី។ មុខងារចម្បងរបស់នាយកដ្ឋានប្រតិបត្តិតាម គឺជួយសម្រួលផ្តល់ប្រឹក្សាត្រួតពិនិត្យ និងផ្តល់ការណែនាំ ដល់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ឱ្យអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានា។ ស្របតាមអភិបាលកិច្ចល្អ នាយកដ្ឋានប្រតិបត្តិតាម ធ្វើការរាយការណ៍ដោយឯករាជ្យ ទៅកាន់ក្រុមប្រឹក្សាភិបាល។

ធនាគារបានបង្កើតក្របខណ្ឌ នៃការប្រតិបត្តិតាម ដែលតម្រូវឱ្យផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ទាំងអស់ បង្កើតទម្រង់ត្រួតពិនិត្យការប្រតិបត្តិតាម (Compliance Matrix) ដោយរួមបញ្ចូលនូវច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំផ្សេង។ ដែលពាក់ព័ន្ធនឹងការអនុវត្ត តាមផ្នែកនីមួយ។។ ជាមួយគ្នានេះដែរ ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ត្រូវបានតម្រូវឱ្យធ្វើការវិភាគ លើគម្លាត នៃច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំថ្មី ឬត្រូវបានធ្វើវិសោធនកម្ម និងអាចពិគ្រោះយោបល់ ជាមួយនាយកដ្ឋានប្រតិបត្តិតាម ទៅលើគម្លាត នៃច្បាប់ បទប្បញ្ញត្តិ និងផែនការ ដែលត្រូវអនុវត្ត ដើម្បីធានាឱ្យបានការប្រតិបត្តិតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំថ្មី ឬត្រូវបានធ្វើវិសោធនកម្មទាំងនោះ។ ទម្រង់ត្រួតពិនិត្យការប្រតិបត្តិតាមច្បាប់បទប្បញ្ញត្តិ តម្រូវឱ្យមានការត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព ជារៀងរាល់ឆ្នាំ។ ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ក៏ត្រូវធ្វើតេស្តដោយខ្លួនឯង (Self-Testing) តាមទម្រង់ត្រួតពិនិត្យការប្រតិបត្តិតាម (Compliance Matrix) ផងដែរ ហើយនៅរៀងរាល់ត្រីមាស នាយកដ្ឋានប្រតិបត្តិតាម នឹងធ្វើការឆ្លៀងផ្ទាត់ដោយឯករាជ្យ លើលទ្ធផល នៃការធ្វើតេស្តដោយខ្លួនឯងនោះ។ បន្ថែមពីនេះទៀត នាយកដ្ឋានប្រតិបត្តិតាម ក៏បានធ្វើការត្រួតពិនិត្យ លើការប្រតិបត្តិតាមច្បាប់បទប្បញ្ញត្តិ របស់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ផ្នែកតាមផែនការប្រចាំឆ្នាំ របស់នាយកដ្ឋានប្រតិបត្តិតាម ដែលបានអនុម័ត ដោយក្រុមប្រឹក្សាភិបាល។ លើសពីនេះទៅទៀត កម្មវិធីបណ្តុះបណ្តាលក៏ត្រូវបានកំណត់ទុក និងធ្វើឡើងយ៉ាងទៀងទាត់ ដើម្បីបង្កើនការយល់ដឹង និងសម្រួល ដល់ការអនុវត្តក្របខណ្ឌ នៃការប្រតិបត្តិតាម សម្រាប់ធនាគារទាំងមូល។

ក្រុមប្រឹក្សាភិបាល ក៏ត្រូវបានផ្តល់ជូន នូវរបាយការណ៍ប្រតិបត្តិតាមយ៉ាងទៀងទាត់ ដើម្បីឱ្យក្រុមប្រឹក្សាភិបាល យល់ច្បាស់ អំពីបញ្ហា ដែលពាក់ព័ន្ធនឹងការប្រតិបត្តិតាមរបស់ធនាគារ។

### គោលការណ៍ និងនីតិវិធី នៃការអនុម័ត លើផលិតផលថ្មី

គោលការណ៍ និងនីតិវិធី នៃការអនុម័ត លើផលិតផលថ្មី ត្រូវបានដាក់ឱ្យអនុវត្ត សម្រាប់គ្រប់ផលិតផល និងសេវាកម្មថ្មីៗទាំងអស់របស់ធនាគារ។ ផលិតផលថ្មី គឺសំដៅទៅលើផលិតផល និង/ឬ សេវាកម្មទាំងឡាយណា ដែលផ្តល់ជូនដំបូង ដោយធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ឬជាការបញ្ចូលផលិតផលច្រើនជាផលិតផលតែមួយ ឬបម្រែបម្រួលទម្រង់របស់ផលិតផល ដែលមានស្រាប់ និង/ឬ សេវាកម្ម ដែលមានការប្រែប្រួលខ្លាំងនូវទម្រង់ហានិភ័យ ដូចដែលបានកំណត់ ដោយនាយកដ្ឋានគ្រប់គ្រងហានិភ័យ។ គ្រប់សំណើសុំការអនុម័តលើផលិតផលថ្មី ត្រូវឆ្លងកាត់ដំណើរការ នៃការត្រួតពិនិត្យហានិភ័យ ឱ្យបានស៊ីជម្រៅ ដោយអ្នកពាក់ព័ន្ធនានាទាំងនៅក្នុងធនាគារ និងនៅក្នុងក្រុមហ៊ុនមេ ដើម្បីធានាថា គ្រប់ផ្នែកសំខាន់ៗ និងផ្នែក ដែលពាក់ព័ន្ធនឹងហានិភ័យ ត្រូវបានកំណត់ វាយតម្លៃ និងកាត់បន្ថយហានិភ័យ មុនពេលដំណើរការផលិតផល និង/ឬ សេវាកម្មថ្មីៗនោះ។ បន្ទាប់មក សំណើសុំការអនុម័ត លើផលិតផលថ្មីមួយរបស់ធនាគារ ត្រូវឆ្លងកាត់ការពិភាក្សាយ៉ាងហ្មត់ចត់ ដោយគណៈកម្មាធិការនានារបស់ធនាគារ និងក្រុមហ៊ុនមេ មុននឹងដាក់ជូនគណៈកម្មាធិការហានិភ័យ ដើម្បីធ្វើការអនុម័តចុងក្រោយ និងជូនដំណឹង អំពីការអនុម័តនេះ ទៅក្រុមប្រឹក្សាភិបាល។

### ការគ្រប់គ្រង លើអញ្ញត្តិកម្ម និងការផ្សព្វផ្សាយ

ធនាគារបន្តសង្កត់ធ្ងន់ លើសារៈសំខាន់ នៃការប្រកាន់ខ្ជាប់ នូវការគោរពតាមបទប្បញ្ញត្តិច្បាប់ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីផ្សេងទៀត ដើម្បីរក្សាកេរ្តិ៍ឈ្មោះរបស់ធនាគារ។ អញ្ញត្តិកម្ម ត្រូវបានលើកឡើង និងចាត់ចែងឱ្យបានទាន់ពេលវេលា ប្រកបដោយតម្លាភាព។ ដើម្បីឈានទៅសម្រេចគោលដៅនេះ ធនាគារបានបង្កើត នូវនីតិវិធីគ្រប់គ្រង លើករណីអញ្ញត្តិកម្ម និងការផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយករណីអញ្ញត្តិកម្មណាមួយកើតមានឡើង រួមមានការមិនប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ការមិនគោរពកាតព្វកិច្ច ការលួចបន្លំ និងការមិនគោរព តាមដំណើរការផ្ទៃក្នុង។ នីតិវិធីនេះជួយឱ្យមាន នូវវិធានការកែលម្អទាន់ពេលវេលា និងពង្រឹងតម្លាភាព និងការត្រួតពិនិត្យរបស់គណៈគ្រប់គ្រង។

ស្ថិតក្រោមនីតិវិធី នៃការគ្រប់គ្រង លើអញ្ញត្តិកម្ម និងការផ្សព្វផ្សាយរបាយការណ៍ ស្តីពីបញ្ហា ដែលកើតមាន ត្រូវធ្វើជូន ក្នុងអំឡុងពេល ២៤ម៉ោង នៃការរកឃើញ ឬនៃការជូនដំណឹងដំបូងបំផុត អំពីបញ្ហាដែលបានកើតឡើង។ ករណីអញ្ញត្តិកម្មទាំងនេះ នឹងត្រូវបានចាត់ចែងដោះស្រាយ ដោយផ្អែកលើភាពធ្ងន់ធ្ងរ និងផលប៉ះពាល់របស់វា ទៅលើធុរកិច្ច ប្រតិបត្តិការ និងកេរ្តិ៍ឈ្មោះរបស់ធនាគារ។ ករណីអញ្ញត្តិកម្មនេះ ត្រូវសង្ខេប និងរាយការណ៍ ទៅគណៈកម្មាធិការហានិភ័យប្រចាំខែ។

### ក្រមសីលធម៌

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មានស្តង់ដារក្រមសីលធម៌អប្បបរមាមួយ សម្រាប់គ្រប់និយោជិតទាំងអស់របស់ខ្លួនអនុវត្ត ដែលរួមបញ្ចូលគ្រប់ទិដ្ឋភាពទាំងអស់ នៃប្រតិបត្តិការធុរកិច្ចប្រចាំថ្ងៃ។ គោលការណ៍ណែនាំ អំពីក្រមសីលធម៌ ត្រូវបានអនុម័តយកតាមក្រមសីលធម៌ របស់ក្រុមហ៊ុនមេ និងបានដាក់បញ្ចូលនៅក្នុង នៃកិច្ចសន្យាការងារ ដែលយល់ព្រម និងចុះហត្ថលេខា ដោយគ្រប់និយោជិតទាំងអស់។

### គោលការណ៍ និងនីតិវិធី ស្តីពីធនធានមនុស្ស

គោលការណ៍ និងនីតិវិធី ស្តីពីធនធានមនុស្ស ត្រូវបានបង្កើតឡើង និងប្រើប្រាស់ នៅក្នុងក្រុមហ៊ុនមេទាំងមូល ដោយមានវិសាលភាព លើគ្រប់ទិដ្ឋភាពទាំងអស់ នៃការគ្រប់គ្រងធនធានមនុស្ស ក្នុងធនាគារ។ គោលការណ៍នេះ បានកំណត់យ៉ាងច្បាស់លាស់ អំពីការជ្រើសរើសនិយោជិត ការដំឡើងឋានៈ ការផ្ទេរកន្លែងការងារ និងការបញ្ឈប់និយោជិត នៅក្នុងក្រុមហ៊ុនមេទាំងមូល។ គោលការណ៍ និងនីតិវិធីទាំងនេះ ត្រូវបានបង្កើតឡើង ស្របតាមបទប្បញ្ញត្តិក្នុងស្រុក ដែលពាក់ព័ន្ធ ដើម្បីធានាការប្រតិបត្តិតាមបទប្បញ្ញត្តិ ត្រូវបានអនុវត្ត។ និយោជិតទទួលការវាយតម្លៃការងាររបស់ខ្លួនជារៀងរាល់ឆ្នាំ ហើយការតម្លៃការងារនេះ ធ្វើឡើងដោយផ្អែកលើសូចនាករ នៃការវាយតម្លៃលទ្ធផលការងារ (Key Performance Indicator) និងការវាស់វែងសមត្ថភាពខ្លះៗ។ កម្មវិធីសិក្សា និងអភិវឌ្ឍន៍សមត្ថភាព ដែលរួមបញ្ចូលទាំងជំនាញវគ្គបណ្តុះបណ្តាលបច្ចេកទេស ត្រូវបានរៀបចំឡើង និងដាក់ឱ្យអនុវត្ត ក្នុងគោលដៅគាំទ្រ និងបង្កើនសមត្ថភាពនិយោជិត ដើម្បីធានាថា និយោជិតទាំងអស់អាចបំពេញភារកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។ ធនាគារបានក្រើនរំលឹក ដល់និយោជិតរបស់ខ្លួនជារឿយៗ អំពីគោលការណ៍ពាក់ព័ន្ធនានា តាមរយៈសារអេឡិកត្រូនិក ឬការជូនដំណឹង ជាលាយលក្ខណ៍អក្សរ និងវគ្គបណ្តុះបណ្តាល ដែលពាក់ព័ន្ធនានា។ វគ្គបណ្តុះបណ្តាលមួយក្នុងចំណោមវគ្គបណ្តុះបណ្តាលផ្សេងទៀត ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានធ្វើឡើងជារឿយៗ ដើម្បីការបញ្ជាក់ឱ្យឃើញ អំពីទស្សនាទានរបស់ក្រុមហ៊ុនមេ ដែលមិនអត្ថាស្រ័យចំពោះអំពើកេងបន្លំ។ ចំណុចនេះក៏បានធ្វើការសង្កត់ធ្ងន់ដែរ នៅក្នុងកម្មវិធីបណ្តុះបណ្តាលតម្រង់ទិសរបស់ក្រុមហ៊ុន។

## ការគ្រប់គ្រងនិរន្តរភាព នៃអាជីវកម្ម

ស៊ីអាយអិមប៊ី គ្រុប បានប្តេជ្ញាចិត្ត ក្នុងការការពារផលប្រយោជន៍របស់ម្ចាស់ភាគហ៊ុន កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន និងការបង្កើតគុណតម្លៃ ដោយធានាឱ្យបាននូវនិរន្តរភាពអាជីវកម្ម និងមុខងារបម្រើការផ្សេងៗ នៅក្នុងស៊ីអាយអិមប៊ី គ្រុប ទាំងមូល។ ទំនួលខុសត្រូវ នៃការអនុវត្ត និងដាក់ឱ្យដំណើរការ នូវគោលការណ៍គ្រប់គ្រងនិរន្តរភាពអាជីវកម្ម គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាលរបស់ធនាគារ។

ក្របខណ្ឌ នៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម (Business Continuity Management) ត្រូវបានជ្រើសយក ពីក្រុមហ៊ុនមេ (ស៊ីអាយអិមប៊ី គ្រុប) មកអនុម័ត ដើម្បីកំណត់ឱ្យបានជាអប្បរមា នូវកម្រិត នៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម ការបែងចែកនូវគោលការណ៍អនុវត្ត សម្រាប់គាំទ្រនាយកដ្ឋានផ្សេងៗ ហើយធ្វើឱ្យបាននូវនិរន្តរភាពអាជីវកម្ម និងសេវាកម្មសំខាន់ៗទាំងឡាយ នៅក្នុងពេលវេលាកំណត់ណាមួយ នៅពេលមានគ្រោះវិនាសកើតឡើង។ ក្របខណ្ឌខាងលើ មានចែងជាគោល ដូចខាងក្រោម៖

(១) រក្សានូវគុណភាពសេវាកម្ម ដើម្បីបង្កើនទំនុកចិត្ត ដូចការរំពឹងទុករបស់អតិថិជន
(២) កាត់បន្ថយផលប៉ះពាល់ ទៅលើអាជីវកម្ម នៅពេលមានគ្រោះវិនាសកើតឡើង
(៣) មិនធ្វើឱ្យមានផលអវិជ្ជមានប៉ះពាល់ ដល់កេរ្តិ៍ឈ្មោះរបស់ធនាគារ
(៤) រក្សានូវការអនុលោមតាមច្បាប់ គោលការណ៍និរន្តរភាពអាជីវកម្ម និងបទប្បញ្ញត្តិផ្សេងៗ

ក្របខណ្ឌ នៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម តែងតែមានការពិនិត្យឡើងវិញជានិច្ចកាល ដើម្បីធ្វើឱ្យស្របទៅតាមបទដ្ឋានរបស់ក្រុមហ៊ុនមេ ស្របទៅតាមនីតិវិធី នៃការគ្រប់គ្រង និងការអនុវត្តនិរន្តរភាពអាជីវកម្ម រួមបញ្ចូលទាំងការវិភាគ ទៅលើមុខងារអាជីវកម្ម និងការបង្កើតនូវយុទ្ធសាស្ត្រនិរន្តរភាពអាជីវកម្ម ការឆ្លើយតប ពេលមានគ្រោះវិនាស ការបង្កើតវប្បធម៌យល់ដឹង អំពីនិរន្តរភាពអាជីវកម្ម ការរៀបចំលំហាត់និរន្តរភាពអាជីវកម្ម និងការកែសម្រួល ទៅលើផែនការនិរន្តរភាពអាជីវកម្មរបស់នាយកដ្ឋាននីមួយៗ។

ដោយអនុលោមតាមក្របខណ្ឌ នៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម ផែនការនិរន្តរភាពអាជីវកម្ម ត្រូវបានធ្វើឡើង សម្រាប់មុខងារអាជីវកម្មសំខាន់ៗ ហើយផែនការនិរន្តរភាព ពីគ្រោះមហន្តរាយ ត្រូវបានធ្វើឡើងសម្រាប់ប្រព័ន្ធកម្មវិធីផ្សេងៗ។ លំហាត់សាកល្បង លើផែនការទាំងពីរនេះ តែងតែត្រូវបានធ្វើឡើងជាប្រចាំ។

លើសពីនេះទៀត ជារៀងរាល់ឆ្នាំ ធនាគាររៀបចំជាសិក្ខាសាលា អំពីការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម សម្រាប់នាយកដ្ឋានទាំងអស់ ឱ្យបានចូលរួម ដើម្បីបង្កើនការយល់ដឹងបន្ថែមទៀត អំពីតួនាទី មុខងារ និងទំនួលខុសត្រូវរបស់ពួកគាត់។

### ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ធនាគារសង្កត់ធ្ងន់ លើសារៈសំខាន់ នៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងប្តេជ្ញាបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឱ្យមានប្រសិទ្ធភាព លើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ គោលការណ៍ណែនាំ និងការអនុវត្ត ដែលល្អបំផុតសម្រាប់វិស័យធនាគារ។

ធនាគាររក្សាការអនុវត្ត តាមគោលនយោបាយ និងនីតិវិធី ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានអនុម័ត ដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់រៀងរាល់ពីរឆ្នាំម្តង ឬក្នុងករណីចាំបាច់ ដើម្បីឆ្លុះបញ្ចាំង ពីនិន្នាការ និងយន្តការថ្មីៗ លើការលាងសម្អាតប្រាក់ និងការផ្តល់ហិរញ្ញប្បទានភេរវកម្ម។

ប្រព័ន្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងប្រព័ន្ធគាំទ្រដទៃទៀតរបស់ធនាគារបានសម្រួល ដល់ការពិនិត្យហានិភ័យប្រឆាំងការសម្អាតប្រាក់ និងតាមដាន លើប្រតិបត្តិការអតិថិជន រួមមានការគ្រប់គ្រងបញ្ជីឈ្មោះបុគ្គល និងអង្គភាពហាមឃាត់ (Watchlist Management) ការយកចិត្តទុកដាក់ស្គាល់អតិថិជន (Customer Due Diligence/Know Your Customer) និងការត្រួតពិនិត្យប្រតិបត្តិការអតិថិជន ដើម្បីការពារ និងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT Alert Monitoring)។ ធនាគារបានធានាថា នីតិវិធី ធនធានមនុស្ស និងប្រព័ន្ធរបស់ធនាគារ មានលទ្ធភាព ក្នុងការរកឃើញ និងកំណត់ហានិភ័យ ព្រមទាំងរាយការណ៍ប្រតិបត្តិការសង្ស័យ ទៅកាន់និយ័តករ។

កម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង ត្រូវបានធ្វើឡើងជាទៀងទាត់។ កម្មវិធីនេះត្រូវបានបំពេញបន្ថែម ជាមួយនឹងការធ្វើបច្ចុប្បន្នភាពចុងក្រោយបំផុត លើបទប្បញ្ញត្តិ នៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ករណីសិក្សាលើប្រតិបត្តិការជាក់ស្តែង អំពីហានិភ័យ នៃការសម្អាតប្រាក់ និងការផ្តល់ហិរញ្ញប្បទានភេរវកម្ម ដោយធ្វើការសង្កត់ធ្ងន់ លើតួនាទី និងការទទួលខុសត្រូវរបស់និយោជិតនីមួយៗ។ ធនាគារបានចាត់វិធានការ ហើយនឹងបន្តចាត់វិធានការ ដើម្បីកាត់បន្ថយហានិភ័យ ដែលអាចកើតមាន ចំពោះធនាគារ ពាក់ព័ន្ធនឹងសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងស្របពេលជាមួយគ្នានេះ ដើម្បីធានាឱ្យបាននូវការប្រតិបត្តិតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំរបស់អាជ្ញាធរពាក់ព័ន្ធ។

## សេចក្តីសន្និដ្ឋាន

ក្រុមប្រឹក្សាភិបាល មានជំនឿថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលកំពុងអនុវត្ត មានលក្ខណៈគ្រប់គ្រាន់ក្នុងការការពារផលប្រយោជន៍របស់ភាគទុនិក និងទ្រព្យសកម្មរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាល ទទួលស្គាល់ថា ធនាគារមានដំណើរការ ប្រកបដោយប្រសិទ្ធភាពឥតឈប់ឈរ ចំពោះការកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យធំៗ នៅក្នុងធនាគារ និងបានប្តេជ្ញាបន្តធ្វើការត្រួតពិនិត្យឡើងវិញ នូវប្រតិបត្តិការ និងប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ រួមបញ្ចូលទាំងការត្រួតពិនិត្យ ផ្ទៃកហិរញ្ញវត្ថុ ប្រតិបត្តិការ និងការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ព្រមទាំងការគ្រប់គ្រងហានិភ័យផងដែរ។

# រចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនមេ

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

**ស៊ីអាយអិមប៊ី** គ្រុប ហូលឌីង បើហាដ

100%

**ស៊ីអាយអិមប៊ី** គ្រុប អេសឌីអិន បើហាដ

100%

ធនាគារ **ស៊ីអាយអិមប៊ី** បើហាដ

100%

ធនាគារ **ស៊ីអាយអិមប៊ី ភីអិលស៊ី**

# រចនាសម្ព័ន្ធក្រុមហ៊ុន

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)



# របាយការណ៍ព័ត៌មានរបស់ធនាគារ

(គិតត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥)

## ក្រុមប្រឹក្សាភិបាល

| | | |
|---|---|---|
| **Tan Sri Mohd Nasir Bin Ahmad** | _____ | ប្រធានក្រុមប្រឹក្សាភិបាល / អភិបាលមិនឯករាជ្យមិនប្រតិបត្តិ<br>*(ផ្លាស់ប្តូរពីអភិបាលឯករាជ្យមិនប្រតិបត្តិ នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥)* |
| **ឡុង ប៊ាង** | _____ | អភិបាលឯករាជ្យមិនប្រតិបត្តិ |
| **Aisyah Lam Binti Abdullah** | _____ | អភិបាលឯករាជ្យមិនប្រតិបត្តិ |
| **Mohd Haniz bin Mohd Nazlan** | _____ | អភិបាលមិនឯករាជ្យមិនប្រតិបត្តិ<br>*(តែងតាំង នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥)* |
| **Ankur Sehgal** | _____ | អភិបាលមិនឯករាជ្យមិនប្រតិបត្តិ<br>*(តែងតាំង នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥)* |
| **Ahmad Shazli Bin Kamarulzaman** | _____ | អភិបាលមិនឯករាជ្យមិនប្រតិបត្តិ<br>*(ចូលនិវត្តន៍ នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥)* |
| **Cheong Weng Teong** | _____ | អភិបាលមិនឯករាជ្យមិនប្រតិបត្តិ<br>*(ចូលនិវត្តន៍ នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥)* |
| **ប៊ុន យីន** | _____ | អភិបាលមិនឯករាជ្យប្រតិបត្តិ |

## គណៈកម្មាធិការសវនកម្ម

| | | |
|---|---|---|
| **ឡុង ប៊ាង** | _____ | ប្រធាន / អភិបាលឯករាជ្យមិនប្រតិបត្តិ |
| **Tan Sri Mohd Nasir Bin Ahmad** | _____ | អភិបាលឯករាជ្យមិនប្រតិបត្តិ<br>*(ផ្លាស់ប្តូរពី អភិបាលឯករាជ្យមិនប្រតិបត្តិ នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥)* |
| **Aisyah Lam Binti Abdullah** | _____ | អភិបាលឯករាជ្យមិនប្រតិបត្តិ |

## គណៈកម្មាធិការហានិភ័យ

| | | |
|---|---|---|
| **Aisyah Lam Binti Abdullah** | _____ | ប្រធាន / អភិបាលឯករាជ្យមិនប្រតិបត្តិ |
| **ប៊ុន យីន** | _____ | ប្រធានជំនួស / ប្រធាននាយកប្រតិបត្តិ / អភិបាលប្រតិបត្តិ |
| **គៀន វឌ្ឍនា** | _____ | នាយកគ្រប់គ្រងហានិភ័យ |
| **ហុង ជៀប** | _____ | នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម |
| **គី សាណា** | _____ | នាយិកាសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ |
| **ប៉ិច សុម៉ាលី** | _____ | សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល<br>*(ផ្លាស់ប្តូរជា សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល នាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤)* |
| **ហេង វិបុត្រ** | _____ | នាយកបច្ចេកវិទ្យា និងទិន្នន័យ |
| **ហេង វុទ្ធី** | _____ | នាយកហិរញ្ញវត្ថុ |
| **ហេង ភួងរចនា** | _____ | នាយិកាប្រតិបត្តិការ |
| **ហេង តូរ៉ង់** | _____ | នាយករតនាភិបាល និងទីផ្សារ |

## គណៈកម្មាធិការឥណទានកម្ពុជា

| | | |
|---|---|---|
| **គៀន វឌ្ឍនា** | _____ | ប្រធាន / នាយកគ្រប់គ្រងហានិភ័យ |
| **ប៊ុន យីន** | _____ | ប្រធានជំនួស / ប្រធាននាយកប្រតិបត្តិ / អភិបាលប្រតិបត្តិ |
| **ហុង ជៀប** | _____ | នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម |
| **ប៉ិច សុម៉ាលី** | _____ | សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល |
| **ចំណាន វនិតា** | _____ | នាយិកាគ្រប់គ្រងឥណទាន |
| **គី សាណា** | _____ | នាយិកាសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ |
| **Chong Kok Ping** | _____ | សហនាយកគ្រប់គ្រងហានិភ័យឥណទានតាមតំបន់ (នៃធនាគារមេ) |
| **Lim Gek Peng** | _____ | ប្រធានគ្រប់គ្រងឥណទានពាណិជ្ជកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុ (នៃធនាគារមេ) |
| **Michael Ng Mun Seng** | _____ | នាយកវិភាគហានិភ័យឥណទានតាមតំបន់ (នៃធនាគារមេ) |
| **Ganga Devi Katheraveloo** | _____ | នាយិកាតំបន់ផ្នែកគ្រប់គ្រងឥណទានពាណិជ្ជកម្ម នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម (នៃធនាគារមេ) |

## គណៈកម្មាធិការគ្រប់គ្រង

| | | |
|---|---|---|
| **ប៊ុន យីន** | _____ | ប្រធាន / ប្រធាននាយកប្រតិបត្តិ |
| **ហុង ជៀប** | _____ | នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម |
| **គី សាណា** | _____ | នាយិកាសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ |
| **ប៊ុច សុម៉ាលី** | _____ | សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល<br>*(ផ្លាស់ប្តូរជា សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល នាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤)* |
| **Teo Hong Joo** | _____ | សហនាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល<br>*(តែងតាំង នាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤)* |
| **ហេង វុទ្ធី** | _____ | នាយកហិរញ្ញវត្ថុ |
| **អ៊ុំ ចិន្តាភក្តី** | _____ | នាយកធនធានសាជីវកម្ម |
| **Nguyen Thi Thu Huong** *(aka Rachel Nguyen)* | _____ | នាយិកាបច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ<br>*(តែងតាំង នាថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤)* |
| **ហេង វិបុត្រ** | _____ | នាយកបច្ចេកវិទ្យា និងទិន្នន័យ |
| **គៀន វឌ្ឍនា** | _____ | នាយកគ្រប់គ្រងហានិភ័យ |
| **ហេង តូរ៉ង់** | _____ | នាយករតនាភិបាល និងទីផ្សារ |
| **អ៊ុក ចានីន** | _____ | នាយកគ្រប់គ្រងផលិតផល និងចីរភាព |
| **ហេង តួងរចនា** | _____ | នាយិកាប្រតិបត្តិការ |

*(អ្នកចូលរួមអចិន្ត្រៃយ៍របស់គណៈកម្មាធិការ រួមមាននាយកសវនកម្មផ្ទៃក្នុង នាយិកាប្រតិបត្តិតាម និងអ្នកតំណាង នៃនាយកដ្ឋានយុទ្ធសាស្ត្រ)*

## គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មកម្ពុជា

| | | |
|---|---|---|
| **ហេង វុទ្ធី** | _____ | ប្រធាន / នាយកហិរញ្ញវត្ថុ |
| **ហេង តូរ៉ង់** | _____ | ប្រធានជំនួស / នាយករតនាភិបាល និងទីផ្សារ |
| **ប៊ុន យីន** | _____ | ប្រធាននាយកប្រតិបត្តិ / អភិបាលប្រតិបត្តិ |
| **ប៊ុច សុម៉ាលី** | _____ | សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល<br>*(ផ្លាស់ប្តូរជាសហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល នាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤)* |
| **ហុង ជៀប** | _____ | នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម |
| **គី សាណា** | _____ | នាយិកាសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ |
| **គៀន វឌ្ឍនា** | _____ | នាយកគ្រប់គ្រងហានិភ័យ |
| **Teo Hong Joo** | _____ | សហនាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល<br>*(តែងតាំង នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤)* |

## លេខាធិការក្រុមហ៊ុន៖

**លី សោភា**
**Datin Rossaya Mohd Nashir**

## លេខចុះបញ្ជី៖

00010524

## ការិយាល័យចុះបញ្ជី៖

ផ្ទះលេខ៦០ មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
១២០២១១ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ ៖ +៨៥៥ ២៣ ៩៨៨ ៣៨៨
ទូរសព្ទ ៖ +៨៥៥ ២៣ ៩៨៨ ០៩៩
គេហទំព័រ ៖ www.cimbbank.com.kh

## សវនករ៖

**ព្រ្រេនសនវ៉ុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា ៣១៥ ផ្លូវព្រះអង្គឌួង (តែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ ៖ +៨៥៥ ២៣ ៩៦៦ ៥២០
គេហទំព័រ ៖ www.pwc.com.kh



# ០៤

# ព្រឹត្តិការណ៍សំខាន់ៗ និងការចុះផ្សាយ ក្នុងសារព័ត៌មាន នៅឆ្នាំ២០២៤


៦០ ..... ព្រឹត្តិការណ៍សំខាន់ៗ

៦៤ ..... ការចុះផ្សាយ ក្នុងសារព័ត៌មាន

# ព្រឹត្តិការណ៍សំខាន់ៗ

## កម្មវិធីទំនួលខុសត្រូវសង្គម

### កម្មវិធីបរិច្ចាគឈាម របស់ធនាគារ ស៊ីអាយអិមប៊ី

ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ នៅការិយាល័យកណ្តាលរបស់ធនាគារ ស៊ីអាយអិមប៊ី រាជធានីភ្នំពេញ

ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ នៅការិយាល័យកណ្តាលរបស់ធនាគារ ស៊ីអាយអិមប៊ី រាជធានីភ្នំពេញ

### កម្មវិធីបរិច្ចាគ ដល់សាលាបឋមសិក្សា គោក តាចន្ទ

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤ នៅសាលាបឋមសិក្សា គោក តាចន្ទ ខេត្តសៀមរាប

### កម្មវិធីបរិច្ចាគ ដល់កម្មវិធីព្យាបាលភ្នែក របស់ធនាគារជាតិ នៃកម្ពុជា

ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤ នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត រាជធានីភ្នំពេញ

### ពិធីសម្ពោធជាផ្លូវការ នៃឧទ្យានអង្គរ-ស៊ីអាយអិមប៊ី

ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅឧទ្យានអង្គរ-ស៊ីអាយអិមប៊ី ខេត្តសៀមរាប

## កម្មវិធី និងព្រឹត្តិការណ៍

### ពិធីចុះកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រ លើអាជីវកម្មធានារ៉ាប់រងតាមរយៈធនាគារ

ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ នៅការិយាល័យកណ្តាលរបស់ក្រុមហ៊ុន ហ្វតតេ រាជធានីភ្នំពេញ

### កិច្ចប្រជុំបុគ្គលិក របស់ធនាគារ ស៊ីអាយអិមប៊ី

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន រាជធានីភ្នំពេញ

### កម្មវិធីបណ្តុះបណ្តាល ស្តីពីយន្តការបរធនបាលកិច្ច នៅកម្ពុជា

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ នៅសណ្ឋាគារ សុខា ភ្នំពេញ រាជធានីភ្នំពេញ

### ពានរង្វាន់ជើងឯកបាល់ទាត់ EPICC របស់ធនាគារ ស៊ីអាយអិមប៊ី

ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ

### កម្មវិធីភ្ជាប់ទំនាក់ទំនងអតិថិជន ដើម្បីចីរភាព របស់ធនាគារ ស៊ីអាយអិមប៊ី

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ នៅសាខាចំការមន របស់ធនាគារ ស៊ីអាយអិមប៊ី រាជធានីភ្នំពេញ

### កម្មវិធីជប់លៀង និងកិច្ចប្រជុំបុគ្គលិកប្រចាំឆ្នាំ របស់ធនាគារ ស៊ីអាយអិមប៊ី

ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅសណ្ឋាគារ អង្គរ អេវ៉ា ខេត្តសៀមរាប

## ការឧបត្ថម្ភកម្មវិធី

### ពិព័រណ៍កុមារ និងគ្រួសារ លើកទី១០

ថ្ងៃទី១៦-១៧ ខែកុម្ភៈ ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍ កោះពេជ្រ រាជធានីភ្នំពេញ

### វេទិកាធុរកិច្ចកម្ពុជា-ម៉ាឡេស៊ី

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ នៅរាជធានីកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី

### ទិវាគ្រួសារម៉ាឡេស៊ី

ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៤ នៅស្ថានទូតម៉ាឡេស៊ី រាជធានីភ្នំពេញ

### ជើងឯក នៃពានរង្វាន់បាល់ទាត់ឯកអគ្គរាជទូតម៉ាឡេស៊ី

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ

### កម្មវិធីជំនួបសហគ្រិនវ័យក្មេង លើកទី៣

ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤ នៅភោជនីយដ្ឋាន វាយោ នរា រាជធានីភ្នំពេញ

### ពិព័រណ៍ការងារ CJCC

ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន រាជធានីភ្នំពេញ

### ពិធីបុណ្យឯករាជ្យជាតិម៉ាឡេស៊ី លើកទី៦៧

ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤ នៅណាហ្គា វើល រាជធានីភ្នំពេញ

### ពិធីប្រគល់ពានរង្វាន់ ពី HR ASIA

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ នៅរាជធានីបាងកក ប្រទេសថៃ

### ពិព័រណ៍ការងារ AUPP

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ នៅសាកលវិទ្យាល័យ អាមេរិកាំងភ្នំពេញ រាជធានីភ្នំពេញ

### ពិព័រណ៍ការងារ CAMED

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ នៅវិទ្យាស្ថាន ខេមអេដ រាជធានីភ្នំពេញ

### កិច្ចពិភាក្សា អំពីហិរញ្ញវត្ថុបៃតង

ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៤ នៅវិទ្យាស្ថាន ខេមអេដ រាជធានីភ្នំពេញ

### ទិវារំលឹកគុណអង្គរ

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤ នៅប្រាសាទ អង្គរវត្ត ខេត្តសៀមរាប

# ការចុះផ្សាយ ក្នុងសារព័ត៌មាន

ខេមបូលូមិស
MONEY TALKS
លោក ប៊ុន យីន
ប្រធាននាយកប្រតិបត្តិធនាគារ CIMB

ខេមបូលូមិស
លោក ហុង ជៀប
នាយកសេវាហិរញ្ញវត្ថុកាណាឌូតម្ម នៃធនាគារ CIMB

លោក ហុង ជៀប


ពិធី
ប្រគល់កិច្ចព្រមព្រៀង និងសម្ពោធគម្រោង
«ឧទ្យានអង្គរ - ស៊ីអាយអិមប៊ី»
ឧទ្យានអង្គរ-ស៊ីអាយអិមប៊ី លើផ្ទៃដី ៥ហិចតា ត្រូវបានបើកសម្ពោធជាផ្លូវការ
ដើម្បីលើកស្ទួយ និងអភិរក្សតំបន់រមណីយដ្ឋានអង្គរ

វីដីហិរញ្ញវត្ថុ

sabay tv
ហេតុអ្វីធនាគារ CIMB
គឺជាទីកន្លែងការងារល្អបំផុត?

sabay tv
CIMB BANK

ខេមបូលូមិស

# ក្រុមប្រឹក្សាភិបាល

## TAN SRI MOHD NASIR AHMAD

### ប្រធានក្រុមប្រឹក្សាភិបាល / អភិបាលមិនឯករាជ្យមិនប្រតិបត្តិ

- សញ្ជាតិម៉ាឡេស៊ី
- អាយុ ៧០ ឆ្នាំ
- ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧ លើក ក្នុងឆ្នាំ ២០២៤
- ជាសមាជិកគណៈកម្មាធិការសវនកម្ម

Tan Sri Mohd Nasir Ahmad ជាសមាជិក នៃសមាគមគណនេយ្យករ ជំនាញអន្តរជាតិ (Association of Chartered Certified Accountants (ACCA)) នៃចក្រភពអង់គ្លេស ព្រមទាំង ជាគណនេយ្យករជំនាញមួយរូប នៃវិទ្យាស្ថាន គណនេយ្យករម៉ាឡេស៊ី (Malaysian Institute of Accountants (MIA)) ហើយលោកបានទទួលសញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រង ពាណិជ្ជកម្ម (ឯកទេសហិរញ្ញវត្ថុ) ពីសាកលវិទ្យាល័យ កេបាងសាន ម៉ាឡេស៊ី (Universiti Kebangsaan Malaysia) ប្រទេសម៉ាឡេស៊ី។

បច្ចុប្បន្ន លោកគឺជា ប្រធានក្រុមប្រឹក្សាភិបាល នៃស៊ីអាយអិមប៊ី គ្រុប ហូលឌីង ប៊ើហាដ (ស៊ីអាយអិមប៊ី គ្រុប) ធនាគារ ស៊ីអាយអិមប៊ី ប៊ើហាដ និង ថាច់ អេន ហ្គូ អេសឌីអិន ប៊ើហាដ (Touch 'N Go Sdn Bhd)។ លោកត្រូវបានតែងតាំងជា អភិបាលឯករាជ្យ នៃស៊ីអាយអិមប៊ី គ្រុប នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ និងត្រូវបានតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាល នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៨។ លោកក៏ត្រូវបានតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាល នៃ ថាច់ អេន ហ្គូ អេសឌីអិន ប៊ើហាដ នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤។ Tan Sri Mohd Nasir បានផ្លាស់ប្តូរតួនាទី ជាប្រធានក្រុមប្រឹក្សាភិបាលមិនឯករាជ្យ នៃស៊ីអាយអិមប៊ី គ្រុប និងធនាគារ ស៊ីអាយអិមប៊ី ប៊ើហាដ (ធនាគារ ស៊ីអាយអិមប៊ី) នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤។ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បន្ទាប់ពីលោកត្រូវបានតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាល / អភិបាលឯករាជ្យមិនប្រតិបត្តិ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ Tan Sri Mohd Nasir ក៏បានផ្លាស់ប្តូរតួនាទីជា ប្រធានក្រុមប្រឹក្សាភិបាល / អភិបាលមិនឯករាជ្យមិនប្រតិបត្តិ គិតចាប់ពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥។

Tan Sri Mohd Nasir ក៏ធ្លាប់កាន់មុខតំណែងជា នាយកវិទ្យាស្ថាន គណនេយ្យករ ម៉ាឡេស៊ី (MIA) ក្នុងអំឡុងពីខែសីហា ឆ្នាំ២០១១ រហូតដល់ខែកក្កដា ឆ្នាំ២០១៣។ នៅក្នុងខែកញ្ញា ឆ្នាំ២០១៣ លោកត្រូវបានជ្រើសតាំងធ្វើជា សមាជិកក្រុមប្រឹក្សារបស់ ACCA នៃចក្រភពអង់គ្លេស និងបានបញ្ចប់អាណត្តិអតិបរិមារយៈពេល ៩ឆ្នាំ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២ បន្ទាប់ពីលោកត្រូវបានជ្រើសតាំងម្តងទៀត នៅខែកញ្ញា ឆ្នាំ២០១៦ និងខែវិច្ឆិកា ឆ្នាំ២០១៩។

នាថ្ងៃទី១ ខែឧសភា ឆ្នាំ២០២១ លោកត្រូវបានតែងតាំងជា សមាជិក នៃមូលនិធិរាយការណ៍ហិរញ្ញវត្ថុ (Financial Reporting Foundation) និងតែងតាំងជា ប្រធាន នៃក្រុមប្រឹក្សាស្តង់ដារ គណនេយ្យ ម៉ាឡេស៊ី (Malaysian Accounting Standards Board (MASB))។

លោកបាននាំយកនូវបទពិសោធន៍ដ៏ទូលំទូលាយ លើផ្នែកដឹកនាំ គ្រប់គ្រង ហិរញ្ញវត្ថុ និងគណនេយ្យ ដែលលោកមាន ក្នុងអំឡុងពេលជាង ៤០ឆ្នាំនេះ ដោយលោកបានចាប់ផ្តើមការងារដំបូង ជាកម្មសិក្សាការីគណនេយ្យ ជាមួយក្រុមហ៊ុន តេណាហ្គា ណេសិនណល ប៊ើហាដ (Tenaga Nasional Berhad (TNB)) នៅក្នុងឆ្នាំ១៩៧៩ ហើយលោកបានផ្លាស់ប្តូរមុខតំណែងជាច្រើន នៅក្នុងនាយកដ្ឋានហិរញ្ញវត្ថុរបស់ក្រុមហ៊ុននេះ។

នៅក្នុងខែមករា ឆ្នាំ១៩៩៣ Tan Sri Mohd Nasir ត្រូវបានតែងតាំងជា អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ នៅក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ TNB គឺក្រុមហ៊ុន ម៉ាឡេស៊ី ត្រែនស្ទ៊ែរមើរ មេនូហ្វែកត្យើរីង អេសឌីអិន ប៊ើហាដ (Malaysia Transformer Manufacturing Sdn Bhd) មុនពេលដែលលោកត្រូវបានតែងតាំងជា ប្រធាននាយកប្រតិបត្តិ ក្នុងខែមិថុនា ឆ្នាំ១៩៩៤។

នៅក្នុងខែមករា ឆ្នាំ២០០០ លោកបានចូលបម្រើការឱ្យក្រុមហ៊ុន ស្សារីកាត់ ពឺម៉ូដាឡាន កេបាងសាន ប៊ើហាដ (Sharikat Permodalan Kebangsaan Berhad) ក្នុងតំណែងជា ប្រធាន នាយកប្រតិបត្តិ ។ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ លោកត្រូវបានតែងតាំងជា ប្រធាននាយកប្រតិបត្តិ នៃក្រុមហ៊ុន ពឺបាដាណាន អ៊ុសាហាវ៉ាន ណេសិនណល ប៊ើហាដ (Perbadanan Usahawan Nasional Berhad) ហើយលោកបន្តកាន់តំណែងនេះ រហូតដល់ពេលលោកចូលនិវត្តន៍ នាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១១។

Tan Sri Mohd Nasir ក៏មានតំណែងជា ប្រធានក្រុមប្រឹក្សាភិបាល នៅមូលនិធិ ស៊ីអាយអិមប៊ី (CIMB Foundation) តំណែងជា បរធនបាលមួយរូប នៃមូលនិធិ យ៉ាយ៉ាសាន់ ខែនសែឡឺ យូនីតិន (Yayasan Canselor UNITEN) និងនៅមូលនិធិ ពឺដាណា លីដឺស្ហ៊ីប (Perdana Leadership Foundation) និងមានតំណែងជា អភិបាល នៅអេហ្វអាយឌីអ៊ី ហ្វូរឹម (FIDE Forum)។

## AISYAH LAM BINTI ABDULLAH

**អភិបាលឯករាជ្យមិនប្រតិបត្តិ**

- សញ្ជាតិម៉ាឡេស៊ី
- អាយុ ៦០ ឆ្នាំ
- ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧ លើក ក្នុងឆ្នាំ ២០២៤
- ជាប្រធានគណៈកម្មាធិការហានិភ័យ
- ជាសមាជិកគណៈកម្មាធិការសវនកម្ម

លោកស្រី Aisyah Lam ត្រូវបានតែងតាំងជា អភិបាលឯករាជ្យ និងជាប្រធាន នៃគណៈកម្មាធិការហានិភ័យរបស់ធនាគារ ចាប់តាំងពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨។ លោកស្រីក៏ជា អភិបាលឯករាជ្យ នៃធនាគារ ស៊ីអាយអិមប៊ី វៀតណាម នៅប្រទេសវៀតណាម។

លោកស្រីបានចាប់ផ្តើមអាជីពការងារដំបូង ក្នុងវិស័យធនាគារ នៅធនាគារ Standard Chartered Bank។ បន្ទាប់មក លោកស្រីបានប្តូរទៅបំពេញការងារ នៅធនាគារ Deutsche (ប្រទេសម៉ាឡេស៊ី) ក្នុងឆ្នាំ១៩៩៤ ដែលនៅកន្លែងនោះ លោកស្រីបានកាន់តួនាទីជា ប្រធានគ្រប់គ្រងសាច់ប្រាក់សាជីវកម្ម ដោយបានបង្កើតពាណិជ្ជកម្មសាជីវកម្ម និងអាជីវកម្មប្រតិបត្តិការ តាមប្រព័ន្ធអ៊ីនធើណេតដំបូងគេ សម្រាប់ធនាគារ Deutsche នៅក្នុងប្រទេសម៉ាឡេស៊ី ហើយបន្ទាប់មកទៀត ចូលរួមក្នុងក្រុមផ្នែកលក់ថ្នាក់តំបន់ នៅប្រទេសសិង្ហបុរី។ នៅក្នុងឆ្នាំ២០០១ លោកស្រីបានផ្លាស់ប្តូរការងារ ទៅក្រុមហ៊ុន IslamicQ.com Asia (ទីក្រុងឌូបៃ) ដែលនៅទីនោះ លោកស្រីជាអ្នកគ្រប់គ្រងប្រចាំប្រទេស ទទួលខុសត្រូវ លើការគ្រប់គ្រង អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រអាជីវកម្ម នៅក្នុងតំបន់អាស៊ី នៃក្រុមហ៊ុននោះ។

នៅឆ្នាំ២០០៣ លោកស្រី Aisyah បានវិលត្រឡប់មកប្រទេសម៉ាឡេស៊ី មកកាន់តួនាទីជា អគ្គនាយកគ្រប់គ្រងទ្រព្យសម្បត្តិ នៃធនាគារ Hong Leong Bank Berhad។ ជាមួយតំណែងនេះ លោកស្រីទទួលខុសត្រូវ លើការពង្រីកអាជីវកម្ម ការបង្កើនផតហ្វូលីយ៉ូ នៃទ្រព្យសកម្ម ក្រោមការគ្រប់គ្រង ការអភិវឌ្ឍ និងការគ្រប់គ្រងអាទិភាពរបស់ធនាគារ ក៏ដូចជាចាត់ចែងបណ្តាញ ផ្នែកលក់នៃធនាគារជាន់ខ្ពស់ បន្ថែមទៅលើផ្នែកទំនាក់ទំនងសាខា។ លោកស្រី Aisyah ក៏បានផ្លាស់ទៅបម្រើការងារ នៅធនាគារ Citibank ក្នុងឆ្នាំ២០០៦ ដើម្បីគ្រប់គ្រង និងអភិវឌ្ឍផតហ្វូលីយ៉ូរបស់ផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ធនាគារនេះ នៅប្រទេសក្នុងម៉ាឡេស៊ី។

លោកស្រី Aisyah បានសម្រេចចិត្តចាកចេញ ពីទីក្រុងហាណូយ ប្រទេសវៀតណាម ក្នុងឆ្នាំ២០១០ ដើម្បីចាប់យកបទពិសោធន៍ថ្មី ក្នុងការបង្កើតផ្នែកអាជីវកម្មលក់រាយ ឱ្យធនាគារ Ngan Hang TMCP Bac A។ បេសកម្មនាពេលនោះ គឺដើម្បីដាក់ចេញនូវហេដ្ឋារចនាសម្ព័ន្ធ ក្នុងធនាគារ ដើម្បីគាំទ្រ ដល់សេវាកម្ម និងផលិតផលអាជីវកម្មលក់រាយសំខាន់ៗ ស្របតាមគម្រោងយុទ្ធសាស្ត្រ ក្នុងការកសាង និងបណ្តុះផ្នែកនេះ ឱ្យក្លាយជាអាជីវកម្មចម្បងរបស់ធនាគារ។ បន្ទាប់ពីគម្រោងចប់សព្វគ្រប់អស់ លោកស្រីបានវិលត្រឡប់ទៅធនាគារ Hong Leong Bank Vietnam ដែលនៅទីនោះ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ លោកស្រីបានអភិវឌ្ឍ និងកសាងអាជីវកម្មសេវាកម្មហិរញ្ញវត្ថុបុគ្គល សម្រាប់ធនាគារនេះ នៅក្នុងប្រទេសវៀតណាម។

បន្ទាប់ពីអាជីពការងារ ក្នុងវិស័យធនាគារ លោកស្រី Aisyah បានប្តូរការងារ ទៅវិស័យថែរក្សាសុខភាពវិញ នៅក្នុងឆ្នាំ២០១៦ ដោយលោកស្រីបានកសាង និងគ្រប់គ្រងក្រុមគ្លីនិកចាប់សសៃ ក្នុងប្រទេសវៀតណាម ទាំងលើគ្រប់ផ្នែក នៃប្រតិបត្តិការ ក៏ដូចជាការអភិវឌ្ឍអាជីវកម្ម។ នៅក្នុងឆ្នាំ២០២២ ក្រុមគ្លីនិកចាប់សសៃ ក៏បានរួមបញ្ចូលគ្នាបង្កើតជាមន្ទីរពេទ្យធំបំផុតមួយ នៅក្នុងប្រទេសវៀតណាម ហើយក្រោយមក មន្ទីរពេទ្យនេះ ក៏ត្រូវបានទិញយកដោយ ថមសាន់ មេឌីឧល គ្រុប (Thomson Medical Group) នៅប្រទេសសិង្ហបុរី។ ក្រោយការរួមបញ្ចូល និងទិញយកនេះ លោកស្រីនៅបន្តធ្វើជាអ្នកប្រឹក្សា ដើម្បីគាំទ្រអាជីវកម្មនេះ។

លោកស្រី Aisyah Lam បានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែក Chartered Marketing ពី Chartered Institute of Banking ចក្រភពអង់គ្លេស។

## ឡុង ប៊ាង

**អភិបាលឯករាជ្យមិនប្រតិបត្តិ**

- សញ្ជាតិខ្មែរ
- អាយុ ៤៥ ឆ្នាំ
- ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧ លើក ក្នុងឆ្នាំ ២០២៤
- ជាប្រធានគណៈកម្មាធិការសវនកម្ម

លោក ឡុង ប៊ាង ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិក នៃមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការ ផ្នែកពាណិជ្ជកម្ម។ លោកបានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ឯកទេសនីតិពាណិជ្ជកម្មអន្តរជាតិ និងសហគ្រាសប្រឹក្សា ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។

លោកត្រូវបានតែងតាំងជាអភិបាលឯករាជ្យមិនប្រតិបត្តិ និងជាប្រធានគណៈកម្មាធិការសវនកម្ម របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចាប់តាំងពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២។

លោកត្រូវបានតែងតាំងជា អភិបាលឯករាជ្យមួយរូប នៃក្រុមហ៊ុន លី ហួរ អ៊ិនសួរេន នៅក្នុងខែមីនា ឆ្នាំ២០១៩ និងតែងតាំងជា ប្រធានគណៈកម្មាធិការសវនកម្ម របស់ក្រុមហ៊ុននេះ នាដើមឆ្នាំ២០២០ រហូតដល់ពេលលោកលាឈប់ ពីតំណែងទាំងពីរ នៅក្នុងក្រុមហ៊ុននេះ នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២១។

លោកបាននាំយកនូវបទពិសោធន៍ដ៏ទូលំទូលាយ លើការដឹកនាំ គ្រប់គ្រង រួមទាំងវិជ្ជាជីវៈ ផ្នែកច្បាប់ ដោយលោកបានផ្តល់ការប្រឹក្សា ជូនអតិថិជន លើវិស័យជាច្រើន រួមមាន (តែមិនកំណត់ត្រឹម) វិស័យអចលនទ្រព្យ និងការសាងសង់ ធនាគារ និងហិរញ្ញវត្ថុ ធានារ៉ាប់រង ទូរគមនាគមន៍ ទេសចរណ៍ និងសណ្ឋាគារ ការងារ ទីផ្សារមូលធន (អាជីវកម្មមូលបត្រ និងឧបករណ៍និស្សន្ទ) កិច្ចសន្យាទិញ-លក់ ទំនិញ និងសេវាកម្ម ហិរញ្ញប្បទានគម្រោង ការអង្កេតផ្នែកច្បាប់ អាជីវកម្មកម្មន្តសាល និងការធ្វើជាតំណាងឱ្យកូនក្តី នៅក្នុងតុលាការ សម្រាប់រឿងក្តីរដ្ឋប្បវេណី និងពាណិជ្ជកម្ម។

ចាប់តាំងពីឆ្នាំ២០១៨មក ក្នុងនាមជាមជ្ឈត្តករជាន់ខ្ពស់ និងជំនាញមួយរូប លោកបានចូលរួមគ្រប់គ្រង សម្រេច និងដឹកនាំរឿងក្តីមជ្ឈត្តកម្ម និងសវនការមជ្ឈត្តកម្ម ដែលទាក់ទងនឹងសេចក្តីសម្រេចលើវិវាទពាណិជ្ជកម្ម ជាពិសេសទាក់ទងនឹងរឿងពាណិជ្ជកម្មអន្តរជាតិ កិច្ចសន្យាផ្គត់ផ្គង់ និងផ្តល់សេវាកម្ម និងបញ្ហា ទាក់ទងនឹងការសាងសង់។

ក្នុងឆ្នាំ២០២២ លោកទទួលបានគុណវុឌ្ឍិជា សន្ធានករ ដែលទទួលស្គាល់ដោយមជ្ឈមណ្ឌលដោះស្រាយវិវាទ (Centre for Effective Dispute Resolution (CEDR)) ដែលមានទីតាំង នៅចក្រភពអង់គ្លេស។

លោក ប៊ាង ជាសហភាគា នៃការិយាល័យមេធាវី ភីវ៉ាយធី និងសហការី (PYT & Associates) ដែលបានចុះបញ្ជី ជាមួយគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។ លោកមានតួនាទីដឹកនាំ លើវិស័យធនាគារ និងហិរញ្ញវត្ថុ ហិរញ្ញប្បទានគម្រោង ធានារ៉ាប់រង ទូរគមនាគមន៍ ទេសចរណ៍ និងសណ្ឋាគារ ការងារ ការដោះស្រាយវិវាទ ក្នុងយុត្តាធិការ នៃនិយ័តករមូលបត្រកម្ពុជា និងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម រួមទាំងរឿងក្តីរដ្ឋប្បវេណី និងពាណិជ្ជកម្មផងដែរ។ លោកក៏ចូលរួមដឹកនាំ លើវិស័យផ្សេងទៀត ដូចជាអចលនទ្រព្យ និងការសាងសង់ (ប្រតិបត្តិការ) ការបញ្ចូល និងការទិញភាគហ៊ុន និងទីផ្សារមូលបត្រ និងឧបករណ៍និស្សន្ទ រួមទាំងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជាសាធារណៈ លើកដំបូង (Initial Public Offering (IPO))។

## AHMAD SHAZLI BIN KAMARULZAMAN

**អភិបាលមិនឯករាជ្យមិនប្រតិបត្តិ**

- សញ្ជាតិម៉ាឡេស៊ី
- អាយុ ៥៨ ឆ្នាំ
- ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩*
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧ លើក ក្នុងឆ្នាំ២០២៤

*(*ចូលនិវត្តន៍ ពីធនាគារ នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥)*

លោក Ahmad Shazli Bin Kamarulzaman បានទទួលសញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រ (កិត្តិយស) ជំនាញសេដ្ឋកិច្ច និងគណនេយ្យ ពីសាកលវិទ្យាល័យ ប្រ៊ីស្តុល (University of Bristol) នៃចក្រភពអង់គ្លេស។

លោកគឺជា អភិបាលមិនឯករាជ្យមិនប្រតិបត្តិ នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចាប់ពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥។

លោក Ahmad Shazli គឺជា សហប្រធាននាយកប្រតិបត្តិ នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម និងប្រតិបត្តិការធនាគាររបស់ស៊ីអាយអិមប៊ី គ្រុប ចាប់តាំងពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣។ មុនកាន់តំណែងនេះ លោកគឺជា អនុប្រធាននាយកប្រតិបត្តិ នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មរបស់ស៊ីអាយអិមប៊ី គ្រុប។

ក្នុងនាមជា សហប្រធាននាយកប្រតិបត្តិ នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម និងប្រតិបត្តិការធនាគារ លោក Ahmad Shazli ទទួលបន្ទុកគ្រប់គ្រង លើអាជីវកម្មធនាគាររបស់ស៊ីអាយអិមប៊ី គ្រុប សម្រាប់ធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូនេស៊ី ថៃ និងកម្ពុជា។ ការទទួលខុសត្រូវរបស់លោក រួមមានលើផ្នែកយុទ្ធសាស្ត្រ ឥណទាន ការគ្រប់គ្រងអតិថិជន ផលិតផល និងសេវាកម្ម ទាំងក្នុងផ្នែកសេវាកម្ម / អាជីវកម្មធនាគារទូទៅ (Conventional Banking) និងផ្នែកសេវាកម្ម / អាជីវកម្មធនាគារឥស្លាម (Islamic Banking)។

លោក Ahmad Shazli បានដឹកនាំការផ្លាស់ប្តូរដ៏ជោគជ័យខ្លាំងមួយ លើនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម នៃធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសម៉ាឡេស៊ី ហើយក្រោមការដឹកនាំរបស់លោក អាជីវកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម បានចោះជំហានរីកចម្រើន គួរឱ្យកោតសរសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីពការងារ ជាមួយស៊ីអាយអិមប៊ី នៅខែមករា ឆ្នាំ២០០៦ លោកជាបុគ្គលឆ្នើមម្នាក់ នៅក្នុងប្រតិបត្តិការស្ថារ / ប្រមូលបំណុល របស់ស៊ីអាយអិមប៊ី គ្រុប ដោយលោកបានបង្កើត ផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិពិសេស ដើម្បីស្ថារឡើងវិញ នូវឥណទានមិនដំណើរការ របស់នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម / សហគ្រាស ធុនតូច និងមធ្យម និងនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល។ លោកជាប្រធានក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិ សាថន (Sathorn Asset Management Co Ltd) (ប្រទេសថៃ) និងជាប្រធាននាយកប្រតិបត្តិ នៃក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិពិសេស អាស៊ីអាគ្នេយ៍ ប៊ើហាដ (Southeast Asia Special Asset Management Berhad) ដែលជាក្រុមហ៊ុន Special Purpose Vehicle បង្កើតឡើងដើម្បីទិញទ្រព្យ / កម្ចី ដែលដាក់លក់ ដើម្បីជម្រះបំណុល (distressed loans/assets) ពីធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសម៉ាឡេស៊ី។

លោក Ahmad Shazli បានចាប់ផ្តើមអាជីពការងាររបស់លោក នៅក្នុងធនាគារពាណិជ្ជ (merchant bank) នាំមុខគេមួយ មុនពេលលោកប្តូរទៅបម្រើការ នៅក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិជាតិ របស់ម៉ាឡេស៊ី ឈ្មោះ ពេងហ្គូរសាន ដាណាហាតា ណាសិនណល ប៊ើហាដ (Pengurusan Danaharta Nasional Berhad (ហៅកាត់ថា ដាណាហាតា (Danaharta))។

បន្ថែមលើសពីនេះ លោក Shazli ក៏ជាស្ថាបនិកមួយរូប និងជារតនាគារិក នៃអង្គការ ក្រុមសកម្មមាតាបិតា ដើម្បីការអប់រំ (Parent Action Group for Education (ហៅកាត់ថា PAGE)) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ធ្វើកិច្ចការ ដើម្បីវិស័យអប់រំដំបូងគេបង្អស់របស់ប្រទេសម៉ាឡេស៊ី ដែលមានគោលបំណងផ្តល់ភាពឈានមុខគេ លើប្រព័ន្ធអប់រំរបស់ប្រទេសម៉ាឡេស៊ី។

## CHEONG WENG TEONG

**អភិបាលមិនឯករាជ្យមិនប្រតិបត្តិ**

- សញ្ជាតិម៉ាឡេស៊ី
- អាយុ ៥៦ ឆ្នាំ
- ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១*
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលទាំង ០៧ លើក ក្នុងឆ្នាំ ២០២៤

*(*ចូលនិវត្តន៍ ពីធនាគារ នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥)*

លោក Cheong Weng Teong បានទទួលសញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញទីផ្សារ ពីសាកលវិទ្យាល័យ អរអិមអាយធី (RMIT University)។ លោកគឺជា អភិបាលមិនឯករាជ្យមិនប្រតិបត្តិ របស់ធនាគារ ចាប់ពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥។

បច្ចុប្បន្ននេះ លោកជានាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល របស់ធនាគារ ស៊ីអាយអិមប៊ី ប៊ើហាដ ដែលលោកទទួលបន្ទុក លើការគ្រប់គ្រង់ និងប្រតិបត្តិការ របស់អាជីវកម្មសេវាកម្មហិរញ្ញវត្ថុបុគ្គល របស់ធនាគារនេះ។ មុនពេលកាន់តំណែងជា នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល លោកគឺជា នាយកសេវាកម្មចែកចាយ ផ្នែកសហគ្រាស និងលក់រាយ នៅធនាគារ ស៊ីអាយអិមប៊ី ប៊ើហាដ ព្រមទាំងជា នាយកសេវាកម្មចែកចាយសាខា របស់ធនាគារ សៅដឺន (Southern Bank)។ មុនចូលបម្រើការងារ នៅស៊ីអាយអិមប៊ី គ្រុប (ក្នុងឆ្នាំ២០០៤) លោកធ្លាប់ជា នាយកអភិវឌ្ឍន៍ផ្នែកលក់ នៅអេអាយជី ម៉ាខេតធីង គ្រុប (AIG Marketing Group) និងជានាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល នៃធនាគារ អេបីអេន អ៊ែមរ៉ូ (ABN AMRO Bank)។

លោកមានបទពិសោធន៍លើសពី ២៥ឆ្នាំ លើផ្នែកសេវាកម្មហិរញ្ញវត្ថុបុគ្គល រួមទាំងការគ្រប់គ្រងសាខា និងគ្រប់គ្រង ផ្នែកលក់ និងផលិតផល។ លោកជាបុគ្គលដ៏ឆ្នើមមួយរូប ក្នុងការបង្កើត និងអនុវត្តយុទ្ធសាស្ត្រលក់ និងចែកចាយ សម្រាប់សេវាកម្មហិរញ្ញវត្ថុបុគ្គល។ លោកបានផ្លាស់ប្តូរបណ្តាញសាខា និងមិនមែនសាខា ទៅជាស្ថាប័ន ផ្នែកលក់ដ៏ខ្លាំងពូកែមួយ។

## ប៊ុន យឺន

**ប្រធាននាយកប្រតិបត្តិ / អភិបាលមិនឯករាជ្យប្រតិបត្តិ**

- សញ្ជាតិខ្មែរ
- អាយុ ៦៩ ឆ្នាំ
- ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ចំនួន ០៦ លើក ក្នុងចំណោមកិច្ចប្រជុំទាំង ០៧ លើក ក្នុងឆ្នាំ២០២៤
- ជាសមាជិកគណៈកម្មាធិការហានិភ័យ

លោក ប៊ុន យឺន បានទទួលសញ្ញាបត្រឧត្តមសិក្សា ផ្នែកហិរញ្ញវត្ថុ គណនេយ្យ និងធនាគារ ពីក្រសួងហិរញ្ញវត្ថុ កម្ពុជា នៅឆ្នាំ១៩៨៧។ លោកក៏ទទួលបានគុណវុឌ្ឍិជា ធនាគារិកជំនាញ (Chartered Banker) ដែលបានផ្តល់ដោយវិទ្យាស្ថាន ជំនាញធនាគារ អាស៊ី (Asian Institute of Chartered Bankers ដែលហៅកាត់ថា AICB) ផងដែរ។

លោក ប៊ុន យឺន ត្រូវបានតែងតាំងជា ប្រធាននាយកប្រតិបត្តិ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីបានកាន់តំណែងជា អគ្គនាយករងរបស់ធនាគារ ចាប់តាំងពីពេលបង្កើតធនាគារដំបូង នៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មក លោកត្រូវបានតែងតាំងជា អភិបាលប្រតិបត្តិ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥។ លោកក៏ជាសមាជិក នៃគណៈកម្មាធិការហានិភ័យរបស់ធនាគារផងដែរ។

ក្នុងតំណែងជា អភិបាលប្រតិបត្តិ / ប្រធាននាយកប្រតិបត្តិ លោក ប៊ុន យឺន ទទួលខុសត្រូវរួមលើការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល រៀបចំអាជីវកម្មរបស់ធនាគារ និងដឹកនាំប្រតិបត្តិការ ស្របតាមគោលដៅយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្ម។ លោកធ្វើការដឹកនាំគណៈគ្រប់គ្រង ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្នុងឋានៈជាអភិបាលប្រតិបត្តិ / ប្រធាននាយកប្រតិបត្តិ លោកទទួលខុសត្រូវ ចំពោះមុខក្រុមប្រឹក្សាភិបាល លើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ។

លោក ប៊ុន យឺន បម្រើការងារ នៅក្នុងវិស័យធនាគារ អស់រយៈពេលជាង ៤០ឆ្នាំមកហើយ។ ជាមួយនឹងបទពិសោធន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងវិស័យធនាគារ លោកយល់ច្បាស់ អំពីទីផ្សារក្នុងស្រុក ហើយលោកដើរតួនាទីចម្បង ក្នុងការដឹកនាំអាជីវកម្មរបស់ធនាគារ។ លោកត្រូវបានទទួលស្គាល់ថា ជាបុគ្គលដ៏សំខាន់មួយរូប នៅក្នុងឧស្សាហកម្មធនាគារទាំងមូល។

## MOHD HANIZ BIN MOHD NAZLAN

**អភិបាលមិនឯករាជ្យមិនប្រតិបត្តិ**

- សញ្ជាតិម៉ាឡេស៊ី
- អាយុ ៤១ ឆ្នាំ
- ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥

លោក Haniz ជាប្រធាននាយកប្រតិបត្តិសេវាកម្មហិរញ្ញវត្ថុបុគ្គល នៃស៊ីអាយអិមប៊ី គ្រុប (CIMB Group) ដោយលោកទទួលបន្ទុកគ្រប់គ្រង លើសេវាកម្មហិរញ្ញវត្ថុបុគ្គល នៅតាមតំបន់របស់ស៊ីអាយអិមប៊ី គ្រុប។ បន្ទាប់ពីលោកត្រូវបានតែងតាំងឱ្យកាន់តួនាទីមួយនេះ នាថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៥ លោកទទួលបន្ទុកមើលការខុសត្រូវ លើគ្រប់ផ្នែកផ្សេងៗ នៃសេវាកម្មហិរញ្ញវត្ថុបុគ្គល ផលិតផល និងប្រព័ន្ធផ្តល់សេវារបស់ស៊ីអាយអិមប៊ី គ្រុប ក្នុងប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសសិង្ហបុរី ប្រទេសថៃ និងប្រទេសកម្ពុជា។

លោក Haniz បាននាំយកនូវបទពិសោធន៍ច្រើនជាង ១៨ឆ្នាំ លើយុទ្ធសាស្ត្រសាជីវកម្ម ហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការរួមបញ្ចូលគ្នា នៃធុរកិច្ច ការគ្រប់គ្រងគម្រោង គ្រប់គ្រងទ្រព្យសកម្ម មូលធនសាកល និងវិនិយោគអចលនទ្រព្យ។

លោកបានបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ម៉ាឡេស៊ី ចាប់តាំងពីខែមេសា ឆ្នាំ២០២១។ លោក Haniz ធ្លាប់ធ្វើជាធ្វើជា ប្រធាននាយកយុទ្ធសាស្ត្ររបស់ស៊ីអាយអិមប៊ី គ្រុប ដែលនៅក្នុងមុខងារនោះ លោកមានទំនួលខុសត្រូវ លើផតហ្វូលីយ៉ូចម្រុះ នៅស៊ីអាយអិមប៊ី គ្រុប ដែលរួមមាន នាយកដ្ឋានយុទ្ធសាស្ត្រ និងគ្រប់គ្រងសមិទ្ធផល នាយកដ្ឋានបទពិសោធន៍អតិថិជន នាយកដ្ឋាន ហិរញ្ញវត្ថុសាជីវកម្ម និងគ្រប់គ្រងការវិនិយោគ ក៏ដូចជាការិយាល័យប្រធាននាយកប្រតិបត្តិ។ លោកគឺជាបុគ្គលដ៏សំខាន់ ក្នុងការអនុវត្តកម្មវិធី CIMB's Forward23+ និងដឹកនាំ លើការកំណត់ផែនទីយុទ្ធសាស្ត្រ សម្រាប់ក្រោយឆ្នាំ២០២៤។ ក្នុងអំឡុងពេលនោះ លោកក៏មានតួនាទីដ៏សំខាន់មួយទៀត ក្នុងការពង្រឹងភាពរឹងមាំរបស់ប្រតិបត្តិការ ជំរុញការគ្រប់គ្រងសមិទ្ធផល និងអភិវឌ្ឍគំរូប្រតិបត្តិ ក្នុងតំបន់របស់ក្រុមហ៊ុនមេ។

បន្ថែមពីលើការត្រួសត្រាយផ្លូវ និងអនុម័ត លើបង្កើតគំនិតថ្មី លោក Haniz ក៏មានតួនាទីគ្រប់គ្រងយុទ្ធសាស្ត្រដៃគូជាច្រើនផងដែរ។ លោកបានដឹកនាំការរួមបញ្ចូលគ្នារបស់ ខេ អេ អេហ្វ អេគ្វីតធី (KAF Equities) និងការចុះបញ្ជីភាគហ៊ុនឡើងវិញ របស់ស៊ីអាយអិមប៊ី គ្រុប។

មុនពេលចូលបម្រើការងារ នៅស៊ីអាយអិមប៊ី គ្រុប លោក Haniz ជាប្រធាននាយកវិនិយោគ នៃលេមបាហ្គា តាបុង អង់កាតា ទេនតារ៉ា (Lembaga Tabung Angkatan Tentera - LTAT) ពីឆ្នាំ២០១៩ ដែលនៅទីនោះ លោកមានទំនួលខុសត្រូវ លើគ្រប់មុខងារវិនិយោគ និងសកម្មភាពគ្រប់គ្រង នៃការវិនិយោគរបស់ LTAT។ លោកគឺជាបុគ្គលសំខាន់មួយរូប ដែលបានបង្កើតផែនការបង្វែរទិសដៅរបស់ LTAT ឱ្យមានភាពប្រសើរឡើងវិញ រួមមានការអនុវត្តគម្រោងរៀបចំឡើងវិញ សម្រាប់ការវិនិយោគ រៀបចំឡើងវិញនូវក្រុមការងារវិនិយោគ ក៏ដូចជាពង្រឹងគោលនយោបាយនានា និងដំណើរការ នៃគន្លឹះវិនិយោគ ដែលនៅក្នុងចំណោមទាំងអស់នេះ បានរួមចំណែកបង្កើតក្របខណ្ឌបែងចែកទ្រព្យសកម្មយុទ្ធសាស្ត្រ (Strategic Asset Allocation (SAA) Framework) រយៈពេលវែងរបស់ LTAT។

មុនពេលចូលបម្រើការងា នៅ LTAT លោក Haniz បានចំណាយរយៈពេល នៃអាជីពការងារបស់លោកដ៏ច្រើន នៅភើម៉ូដាឡែន ណាស់សុនណល ប៊ើហាដ (Permodalan Nasional Berhad (PNB)) ជាមួយតួនាទីផ្សេងៗគ្នា រួមមានតួនាទីជាថ្នាក់ដឹកនាំ នៅក្នុងការិយាល័យរបស់ប្រធាននាយកប្រតិបត្តិ នាយកដ្ឋានអន្តរជាតិ នាយកដ្ឋានបែងចែកទ្រព្យសកម្មយុទ្ធសាស្ត្រ និងការវិនិយោគ។ លោកមានតួនាទីដ៏សំខាន់ ក្នុងការបង្កើតក្របខណ្ឌបែងចែកទ្រព្យសកម្មយុទ្ធសាស្ត្រ និងក្របខណ្ឌចំណូលមានកំណត់របស់ PNB បង្កើតគម្រោងគំរូប្រតិបត្តិការជាសាកល បង្កើតអង្គភាពមូលនិធិបរធនបាលកិច្ច ទៅក្នុងទីផ្សារសាកល ព្រមទាំងបានដឹកនាំប្រតិបត្តិការរួមបញ្ចូលគ្នា នៃធុរកិច្ចរបស់ PNB ទាំងក្នុងស្រុក និងក្រៅស្រុក។

តួនាទីជាអភិបាលរបស់លោក Haniz មាននៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី និង ធីអិនជី ឌីជីថល អេសឌីអិន ប៊ើហាដ (TNG Digital Sdn Bhd) បន្ថែមពីលើតួនាទីជាអភិបាលរបស់លោកនៅក្នុងស្ថាប័ន និងក្រុមហ៊ុនវិនិយោគផ្សេងៗ នៅក្នុងស៊ីអាយអិមប៊ី គ្រុប។ លោកក៏ជាប្រធានក្រុមប្រឹក្សាភិបាល នៃការត្រួតពិនិត្យរបស់ធនាគារ ស៊ីអាយអិមប៊ី វៀតណាមផងដែរ។

លោក Haniz បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រ (កិត្តិយស) លើផ្នែកវិទ្យាសាស្ត្រអនុគណិតវិទ្យា (Actuarial Science) ពីសាកលវិទ្យាល័យសេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយទីក្រុងឡុងដ៍ (London School of Economics and Political Science) និងបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញហិរញ្ញវត្ថុអនុវត្តន៍ និងការវិនិយោគ ពីវិទ្យាស្ថាន សេវាហិរញ្ញវត្ថុ នៃអូស្ត្រាលាស៊ី (Australasia)។ លោកគឺជាអ្នកជំនាញបច្ចេកទេសហិរញ្ញវត្ថុ (Certified Financial Technician) ហើយលោកក៏បានសិក្សាជំនាញអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ នៅសាលាពាណិជ្ជកម្មហាវើត (Harvard Business School) ផងដែរ។

## ANKUR SEHGAL

**អភិបាលមិនឯករាជ្យមិនប្រតិបត្តិ**

- សញ្ជាតិឥណ្ឌា
- អាយុ ៤២ ឆ្នាំ
- ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥

លោក Ankur Sehgal បានទទួលសញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ បច្ចេកវិទ្យា ជំនាញវិស្វកម្ម លោហវិទ្យា និងវត្ថុធាតុ (Metallurgical and Materials Engineering) ពីវិទ្យាស្ថាន បច្ចេកវិទ្យាឥណ្ឌារ៉ូគី (ហៅកាត់ថា IIT) នៃប្រទេសឥណ្ឌា។

បច្ចុប្បន្ន លោកជានាយកគ្រប់គ្រង ព្រមទាំងជាប្រធាននាយកអាជីវកម្ម និងយុទ្ធសាស្ត្ររបស់ធនាគារ ស៊ីអាយអិមប៊ី ហ្វីលីពីន (នៅប្រទេសហ្វីលីពីន) ដែលជាសាខាបរទេស របស់ធនាគារ ស៊ីអាយអិមប៊ី ប៊ើហាដ (ប្រទេសម៉ាឡេស៊ី) ដែលក្នុងតួនាទីនេះ លោកមានទំនួលខុសត្រូវ លើការដឹកនាំអាជីវកម្ម គោលដៅយុទ្ធសាស្ត្រ និងបង្កើតយុទ្ធនាការឌីជីថល នៅក្នុងប្រទេស។ លើសពីនេះ ស្របគ្នានឹងយុទ្ធសាស្ត្ររបស់ធនាគារ ស៊ីអាយអិមប៊ី ហ្វីលីពីន លើការពង្រីកវិសាលភាពឌីជីថល និងអាជីវកម្ម លោកក៏បានជួយណែនាំឱកាសអាជីវកម្ម និងភាពជាដៃគូថ្មីៗ ដើម្បីពង្រីកអាជីកម្មឌីជីថលបណ្តាញចែកចាយ / ផ្តល់សេវាកម្ម និងផលិតផល។

លោក Ankur Sehgal ត្រូវបានតែងតាំងជា អភិបាលមិនឯករាជ្យមិនប្រតិបត្តិ នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចាប់តាំងពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥។

លោកបាននាំយកនូវបទពិសោធន៍ច្រើនជាង ១៨ឆ្នាំ ក្នុងតួនាទីជាអ្នកដឹកនាំ លើវិស័យឌីជីថល និងហិរញ្ញវត្ថុបុគ្គល គ្រប់គ្រងផលិតផល ភាពជាដៃគូ យុទ្ធសាស្ត្រ និងហិរញ្ញវត្ថុអាជីវកម្ម ឥណទានប្រមូល / ទារបំណុល និងគ្រប់គ្រងហានិភ័យ ក្នុងប្រទេសសិង្ហបុរី សហរដ្ឋអាមេរិក ប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌា ។

មុនពេលចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ហ្វីលីពីន នៅក្នុងខែមករា ឆ្នាំ២០២០ លោកគឺជា នាយក ផ្នែកគ្រប់គ្រងឥណទានបុគ្គល និងប្រតិបត្តិការ នៃអេមបេង គ្រុប (AmBank Group) ក្នុងប្រទេសម៉ាឡេស៊ី ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៨។ មុនពេលបម្រើការងារនៅ អេមបេង គ្រុប លោកបានបម្រើការប្រមាណ ១២ឆ្នាំ នៅក្នុងតួនាទីផ្សេងៗគ្នា នៅក្នុងស្ថាប័នខុសគ្នាមួយចំនួន ដែលមានដូចជា ជេភីម័រហ្គេន ឆេស និង កូ. (JPMorgan Chase & Co.) យូណាយធីត អូវើរស៊ីបេង លីមីធីត (United Overseas Bank Ltd) និងធនាគារ ស៊ីអាយអិមប៊ី សិង្ហបុរី (សាខារបស់ធនាគារ ស៊ីអាយអិមប៊ី ប៊ើហាដ) ។

## DATIN ROSSAYA MOHD NASHIR

**លេខាធិការក្រុមហ៊ុនរួម**

- សញ្ជាតិម៉ាឡេស៊ី

Datin Rossaya Mohd Nashir ត្រូវបានតែងតាំងជា លេខាធិការក្រុមហ៊ុនរបស់ស៊ីអាយអិមប៊ី គ្រុប នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦។ ជាមួយតួនាទីជា លេខាធិការក្រុមហ៊ុន លោកស្រីទទួលខុសត្រូវ ក្នុងការដឹកនាំអភិបាលកិច្ចធនាគារ ព្រមទាំងផ្តល់ការប្រឹក្សា និងជំបូន្មាន ពាក់ព័ន្ធនឹងតួនាទី និងកាតព្វកិច្ចផ្សេងៗ របស់ប្រធាននាយកប្រតិបត្តិ និងក្រុមប្រឹក្សាភិបាល។ លោកស្រីដើរតួនាទីជាអ្នកទំនាក់ទំនង រវាងក្រុមប្រឹក្សាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗ ទាំងនៅក្នុងប្រទេសម៉ាឡេស៊ី និងនៅក្នុងប្រតិបត្តិការថ្នាក់តំបន់ របស់ស៊ីអាយអិមប៊ី គ្រុប ។

លោកស្រីមានចំណេះដឹង ផ្នែកវិស័យធនាគារយ៉ាងទូលំទូលាយ ជាមួយបទពិសោធន៍ ក្នុងការងារលេខាធិការក្រុមហ៊ុនជិត ៣០ឆ្នាំ។ Datin Rossaya គឺជា សមាជិករបស់គណៈកម្មាការក្រុមហ៊ុន នៃម៉ាឡេស៊ី (Companies Commission of Malaysia) ហើយក៏ជាអភិបាលមួយរូបនៃក្រុមហ៊ុនបុត្រសម្ព័ន្ធមួយចំនួន នៅក្នុងស៊ីអាយអិមប៊ី គ្រុប។ បន្ថែមលើសពីនេះ លោកស្រីជាអភិបាល នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ របស់ស៊ីអាយអិមប៊ី គ្រុប។

លោកស្រីមានចំណាប់អារម្មណ៍ និងមានបទពិសោធន៍ លើផ្នែកនិរន្តរភាព ក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុ ព្រមទាំងបានផ្តួចផ្តើមគម្រោងមួយចំនួន ដើម្បីជំរុញនិរន្តរភាព នៅក្នុងកន្លែងធ្វើការឱ្យ #teamCIMB។

លោកស្រីបានចាប់ផ្តើមអាជីពការងារដំបូង នៅក្រុមហ៊ុន ថាម អេនជីនៀរីង គ្រុប (Time Engineering Group)។ មុនចូលបម្រើការងារ នៅក្នុងស៊ីអាយអិមប៊ី គ្រុប លោកស្រីបម្រើការងារឱ្យក្រុមហ៊ុន តើម៉ូដាឡាន ណេសិនណល ប៊ើហាដ (Permodalan National Berhad) ក្នុងតំណែងជា លេខាធិការក្រុមហ៊ុនរួម នៃក្រុមហ៊ុនបុត្រសម្ព័ន្ធមួយចំនួន នៃក្រុមហ៊ុននេះ។

Datin Rossaya ទទួលបានសញ្ញាបត្រច្បាប់ ជំនាញច្បាប់ពាណិជ្ជកម្ម ពីសាកលវិទ្យាល័យខូវិនទ្រី (Coventry University) ចក្រភពអង់គ្លេស។ លោកស្រីគឺជា លេខាធិការមួយរូប ដែលទទួលបានវិញ្ញាបនបត្រ ពីគណៈកម្មការក្រុមហ៊ុន នៃម៉ាឡេស៊ី (Companies Commission of Malaysia) ហើយលោកស្រីក៏ជាសមាជិក (affiliate) មួយរូប នៃវិទ្យាស្ថានរដ្ឋបាល និងលេខាធិការជំនាញរបស់ម៉ាឡេស៊ីផងដែរ។ លោកស្រីបានបញ្ចប់ថ្នាក់ CIMB-CISL Sustainability Leadership Programme ពីវិទ្យាស្ថាននិរន្តរភាព នៃការដឹកនាំ (Institute for Sustainability Leadership) ពីសាកលវិទ្យាល័យ ខេមប្រ៊ីច (University of Cambridge)។

## លី សោភា

**លេខាធិការក្រុមហ៊ុនរួម**

- សញ្ជាតិខ្មែរ

លោកស្រី លី សោភា កាន់តួនាទីជា លេខាធិការក្រុមហ៊ុនរួម របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១០ មកម្ល៉េះ។ លោកស្រីគឺជា លេខាធិការក្រុមហ៊ុនរួមមួយរូប នៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្មរបស់ធនាគារ។ លោកស្រីក៏ជាលេខាធិការ នៃគណៈកម្មាធិការគ្រប់គ្រង និងគណៈកម្មាធិការត្រួតពិនិត្យលទ្ធផលអាជីវកម្មកម្ពុជា និងជាអ្នកចូលរួមអចិន្ត្រៃយ៍ ក្នុងគណៈកម្មាធិការផ្សេង៧ទៀតរបស់ធនាគារ រួមមានដូចជា គណៈកម្មាធិការហានិភ័យ និងគណៈកម្មាធិការឥណទានកម្ពុជា។

មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រីធ្លាប់បម្រើការងារជាជំនួយការនាយកប្រតិបត្តិជាន់ខ្ពស់នីតិកម្ម និងកិច្ចការក្រុមហ៊ុន នៅក្នុងធនាគារធំមួយ ក្នុងប្រទេសកម្ពុជា។ ក្នុងពេលតែមួយ ក្រៅពីការបន្តការសិក្សា លោកស្រីបានបម្រើការងារ ផ្នែកនីតិកម្ម និងលេខាធិការក្រុមហ៊ុន អស់រយៈពេល ០៦ឆ្នាំ នៅនាយកដ្ឋាននីតិកម្ម និងកិច្ចការក្រុមហ៊ុន នៅកន្លែងដែលធ្លាប់បម្រើការងារពីមុន។

លោកស្រី លី សោភា បានទទួលសញ្ញាបត្របរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៤ ហើយក្នុងឆ្នាំដដែលនេះ លោកស្រីក៏ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ជំនាញគណនេយ្យ ពីមហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម នៃវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង (បច្ចុប្បន្នជា សាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ) ផងដែរ។ ក្នុងឆ្នាំ២០០៧ លោកស្រីទទួលបានសញ្ញាបត្រ ថ្នាក់អនុបណ្ឌិត ជំនាញនីតិឯកជន ពីសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោកស្រីទទួលបានវិញ្ញាបនបត្រ ផ្នែកប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ពីវិទ្យាស្ថាន ជំនាញធនាគារ អាស៊ី (Asian Institute of Chartered Bankers ដែលហៅកាត់ថា AICB) នៅប្រទេសម៉ាឡេស៊ី ក្នុងឆ្នាំ២០១៧។ លោកស្រីក៏ទទួលបានគុណវុឌ្ឍិជាសន្ធានករ ដែលទទួលស្គាល់ដោយមជ្ឈមណ្ឌលដោះស្រាយវិវាទ (Centre for Effective Dispute Resolution ដែលហៅកាត់ថា CEDR) ដែលមានទីតាំង នៅចក្រភពអង់គ្លេស ក្នុងខែមករា ឆ្នាំ២០២២ ផងដែរ។ ក្នុងខែសីហា ឆ្នាំ២០២២ លោកស្រីបានចូលរួមវគ្គបណ្តុះបណ្តាលការប្រឡង និងទទួលបានវិញ្ញាបនបត្រ សម្រាប់បុគ្គល ដែលត្រូវទទួលស្គាល់គុណវុឌ្ឍិ ក្នុងវិស័យបរិធនបាលកិច្ចលើកទី១។ លើសពីនេះ លោកស្រីក៏ទទួលបានវិញ្ញាបនបត្រ សម្រាប់បុគ្គល ដែលត្រូវបានទទួលស្គាល់គុណវុឌ្ឍិ សម្រាប់ជំនាញមជ្ឈត្តការពាណិជ្ជកម្ម ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ ផងដែរ។

# គណៈកម្មាធិការគ្រប់គ្រង

## ប៊ុន យីន

**ប្រធាននាយកប្រតិបត្តិ**

**ចូលនិវត្តន៍ ពីតំណែងជា ប្រធាននាយកប្រតិបត្តិ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥*

សញ្ជាតិខ្មែរ

លោក ប៊ុន យីន បានទទួលសញ្ញាបត្រឧត្តមសិក្សា ផ្នែកហិរញ្ញវត្ថុ គណនេយ្យ និងធនាគារ ពីក្រសួងហិរញ្ញវត្ថុ កម្ពុជា នៅឆ្នាំ១៩៨៧។ លោកក៏ទទួលបានគុណវុឌ្ឍិជា ធនាគារិកជំនាញ (Chartered Banker) ដែលបានផ្តល់ដោយវិទ្យាស្ថាន ជំនាញធនាគារ អាស៊ី (Asian Institute of Chartered Bankers ដែលហៅកាត់ថា AICB) ផងដែរ។

លោក ប៊ុន យីន ត្រូវបានតែងតាំងជា ប្រធាននាយកប្រតិបត្តិ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីបានកាន់តំណែងជា អគ្គនាយករងរបស់ធនាគារ ចាប់តាំងពីពេលបង្កើតធនាគារដំបូង នៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មក លោកត្រូវបានតែងតាំងជា អភិបាលប្រតិបត្តិ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥។ លោកក៏ជាសមាជិក នៃគណៈកម្មាធិការហានិភ័យរបស់ធនាគារផងដែរ។

ក្នុងតំណែងជា អភិបាលប្រតិបត្តិ / ប្រធាននាយកប្រតិបត្តិ លោក ប៊ុន យីន ទទួលខុសត្រូវរួមលើការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល រៀបចំអាជីវកម្មរបស់ធនាគារ និងដឹកនាំប្រតិបត្តិការ ស្របតាមគោលដៅយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្ម។ លោកធ្វើការដឹកនាំគណៈគ្រប់គ្រង ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្នុងឋានៈជាអភិបាលប្រតិបត្តិ / ប្រធាននាយកប្រតិបត្តិ លោកទទួលខុសត្រូវ ចំពោះមុខក្រុមប្រឹក្សាភិបាល លើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ។

លោក ប៊ុន យីន បម្រើការងារ នៅក្នុងវិស័យធនាគារ អស់រយៈពេលជាង ៤០ឆ្នាំមកហើយ។ ជាមួយនឹងបទពិសោធន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងវិស័យធនាគារ លោកយល់ច្បាស់ អំពីទីផ្សារក្នុងស្រុក ហើយលោកដើរតួនាទីចម្បង ក្នុងការដឹកនាំអាជីវកម្មរបស់ធនាគារ។ លោកត្រូវបានទទួលស្គាល់ថា ជាបុគ្គលដ៏សំខាន់មួយរូប នៅក្នុងឧស្សាហកម្មធនាគារទាំងមូល។

## ហុង ជៀប

**នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម**

**តែងតាំងជា ប្រធាននាយកប្រតិបត្តិ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥*

សញ្ជាតិខ្មែរ

ជាមួយនឹងបទពិសោធន៍ការងារជាច្រើនឆ្នាំ នៅក្នុងវិស័យធនាគារពាណិជ្ជ លើផ្នែកបម្រើសេវាកម្មអតិថិជន ព្រមទាំងផ្នែកគ្រប់គ្រងហានិភ័យ លោក ហុង ជៀប មានចំណេះដឹងយ៉ាងស៊ីជម្រៅលើវិស័យធនាគារ និងទំនាក់ទំនងអតិថិជន ក្នុងការផ្តល់នូវយោបល់ ដល់ផ្នែកដែលពាក់ព័ន្ធ ក្នុងដំណើរការអាជីវកម្មរបស់ធនាគារ ព្រមទាំងការគ្រប់គ្រងហានិភ័យ។ លោក ហុង ជៀប ក៏ធ្លាប់បានបម្រើការងារជា នាយកគ្រប់គ្រងហានិភ័យ របស់ធនាគារបរទេសមួយ នៅក្នុងប្រទេសឡាវផងដែរ។

មុនពេលក្លាយជា នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ លោក ហុង ជៀប ធ្លាប់កាន់តំណែងជា នាយកគ្រប់គ្រងហានិភ័យ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី អស់រយៈពេល ៥ឆ្នាំ ដែលលោកត្រូវទទួលបន្ទុក ផ្នែកគ្រប់គ្រងហានិភ័យទូទៅ និងជាប្រធានគណៈកម្មការឥណទាន នៅក្នុងធនាគារ ដោយធ្វើការយ៉ាងជិតស្និទ្ធ ជាមួយអង្គភាព ដែលពាក់ព័ន្ធ ដើម្បីធានាការអនុវត្តដ៏ខ្ជាប់ខ្ជួន នូវវប្បធម៌គ្រប់គ្រងហានិភ័យ នៅក្នុងធនាគារទាំងមូល។

ក្នុងមុខតំណែងជា នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម លោក ហុង ជៀប ទទួលបន្ទុកយ៉ាងសំខាន់ ក្នុងការរៀបចំផែនការ និងអនុវត្តយុទ្ធសាស្ត្រសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មរបស់ធនាគារ។ លោកដឹកនាំក្រុមការងារ ដើម្បីសម្រេចបានកំណើនឥណទានយ៉ាងឆាប់រហ័ស ដោយរក្សាបាននូវគុណភាពទ្រព្យសកម្មល្អប្រសើរ បង្កើនទំហំប្រាក់បញ្ញើ លើកកម្ពស់សមត្ថភាព និងផលិតភាព នៃក្រុមការងារ រួមទាំងបង្កើនប្រាក់ចំណេញ សម្រាប់ធនាគារទាំងមូលផងដែរ។ ក្រៅពីនេះ លោក ហុង ជៀប បានពង្រឹងសហប្រតិបត្តិការ រវាងក្រុមការងារសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម និងក្រុមការងារដទៃទៀត នៅក្នុងធនាគារផងដែរ។

លោក ហុង ជៀប ទទួលបានសញ្ញាបត្របរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម ហើយបានបញ្ចប់ការសិក្សា លើកម្មវិធីភាពជាអ្នកដឹកនាំ CIMB-INSEAD ផងដែរ។

## ហេង តូរ៉ង់

**នាយករតនាភិបាល និងទីផ្សារ**

សញ្ជាតិខ្មែរ

លោក ហេង តូរ៉ង់ ជាសមាជិកម្នាក់ ក្នុងគណៈកម្មាធិការគ្រប់គ្រង របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលបានចូលរួមបំពេញការងារ នៅពេលធនាគារបើកដំណើរការដំបូង ក្នុងឆ្នាំ២០១០។ លោកក៏បានរួមចំណែក ក្នុងការបង្កើតក្រុមការងារគ្រប់គ្រងហានិភ័យ ព្រមទាំងបានបំពេញតួនាទីជាលេខាធិការ របស់គណៈកម្មាធិការហានិភ័យផងដែរ។ នៅពាក់កណ្តាលឆ្នាំ២០១៣ លោកត្រូវបានប្រគល់ភារកិច្ចបន្តឱ្យដឹកនាំនាយកដ្ឋានរតនាភិបាល និងទីផ្សារ ដែលលោកទទួលបន្ទុកគ្រប់គ្រងលើតារាងតុល្យការរបស់ធនាគារ ទីផ្សារមូលនិធិ ហានិភ័យសន្ទនីយភាព ហានិភ័យ និងប្រតិបត្តិការប្តូរប្រាក់បរទេស និងការលក់ផលិតផល ផ្នែករតនាភិបាលផ្សេងៗទៀត រួមទាំងការក្សានូវទំនាក់ទំនងដ៏រឹងមាំ ជាមួយនឹងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូនានា។

ក្នុងនាមជាសមាជិក នៃគណៈកម្មាធិការគ្រប់គ្រង លោកតូរ៉ង់ ក៏មានតួនាទីជាសមាជិកម្នាក់ ក្នុងគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម និងគណៈកម្មាធិការហានិភ័យរបស់ធនាគារផងដែរ ដោយមានការរួមចំណែក និងឥទ្ធិពលរបស់គាត់ ក្នុងដំណើរការសម្រេចចិត្តសំខាន់ៗ នៅក្នុងធនាគារ។

មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោក តូរ៉ង់ ទទួលបានបទពិសោធន៍យ៉ាងទូលំទូលាយ ក្នុងនាមជាប្រធាន ផ្នែកគ្រប់គ្រងហានិភ័យសាច់ប្រាក់ និងទីផ្សារ ដែលមានជំនាញប្រតិបត្តិការរតនាភិបាល និងហានិភ័យទីផ្សារ។ មិនតែប៉ុណ្ណោះ លោកក៏ទទួលបន្ទុក ក្នុងការប្រតិបត្តិការមូលនិធិរតនាភិបាល និងគ្រប់គ្រងលំហូរសាច់ប្រាក់ នៅធនាគារធំមួយក្នុងប្រទេសកម្ពុជា អស់រយៈពេលជាង ៦ឆ្នាំ។

លោក តូរ៉ង់ បានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ ពីវិទ្យាស្ថាន ជាតិគ្រប់គ្រងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ បញ្ញាសាស្ត្រកម្ពុជា និងវគ្គសិក្សាជាន់ខ្ពស់ ផ្នែក Accelerated Universal Bankers Programme ពីសាកលវិទ្យាល័យ បច្ចេកវិទ្យាណានយ៉ាង (Nayang Technological University) ក្នុងប្រទេសសិង្ហបុរី។ ជាមួយនឹងកម្រិតវប្បធម៌នៃការអប់រំ និងបទពិសោធន៍ការងារដ៏ចម្រុះបែបរបស់ខ្លួន លោក តូរ៉ង់ ទទួលបានជំនាញអនុវត្តន៍ការងារច្បាស់លាស់ ក្នុងការដោះស្រាយការងារសំខាន់ៗ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។

## គី សាណា

**នាយិកាសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ**

សញ្ជាតិខ្មែរ

លោកស្រី គី សាណា បានបម្រើការងារ ក្នុងវិស័យធនាគារជាង ២២ឆ្នាំ។ លោកស្រីបានចាប់ផ្តើមអាជីព ជាមួយនឹងធនាគារអន្តរជាតិមួយ ដោយបានកាន់មុខតំណែងផ្សេងៗគ្នា គិតចាប់ពីផ្នែកបម្រើសេវាកម្មអតិថិជន ដល់ផ្នែកគាំទ្រប្រតិបត្តិការធនាគារ ផ្នែកឥណទាន និងហិរញ្ញប្បទានពាណិជ្ជកម្ម រហូតក្លាយជា គណៈគ្រប់គ្រងជាន់ខ្ពស់មួយរូប។ លោកស្រីបានចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០១០ ក្នុងមុខតំណែងជា ប្រធានសាខា ដែលជាសាខាដំបូងគេបង្អស់របស់ធនាគារ។ លោកស្រីទទួលបន្ទុក លើសេវាកម្មធនាគារជាន់ខ្ពស់ (Preferred Banking) និងសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម មុនពេលត្រូវបានតែងតែជា នាយិកាសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។

នៅក្នុងមុខតំណែងនេះ លោកស្រី សាណា ទទួលខុសត្រូវ លើការគ្រប់គ្រងទំនាក់ទំនងសេវាកម្មធនាគារ ជាមួយនឹងអតិថិជនក្រុមហ៊ុនធំៗ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ព្រមទាំងគ្រប់គ្រងដំណើរការទាំងមូល របស់សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុ របស់ធនាគារ ស៊ីអាយអិមប៊ី នៅក្នុងប្រទេសកម្ពុជា។ លើសពីសេវាកម្មផ្តល់ឥណទានសាជីវកម្ម បែបប្រពៃណី លោកស្រីមានតួនាទីក្នុងការផ្តល់ដំណោះស្រាយ និងគុណតម្លៃបន្ថែម ស្របតាមតម្រូវការសេវាកម្មប្រតិបត្តិការធនាគារ រួមមានការគ្រប់គ្រងសាច់ប្រាក់ ហិរញ្ញប្បទានពាណិជ្ជកម្ម និងសេវាធនាគារ តាមប្រព័ន្ធអ៊ីនធើណេត។

ក្នុងអំឡុងពេលនៃការបំពេញការងាររបស់ខ្លួន លោកស្រី សាណា ទទួលបានពានរង្វាន់មួយចំនួន រួមមាន៖

១. ពានរង្វាន់សាខាឆ្នើម ប្រចាំឆ្នាំ២០១១ ពីធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា
២. ពានរង្វាន់បុគ្គលិកឆ្នើម ប្រចាំឆ្នាំ២០១១ ពីធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា
៣. ពានរង្វាន់អិមមើរ៉ល ឆ្នាំ២០១៣ (Emerald Award 2013) សម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាល ពីស៊ីអាយអិមប៊ី គ្រុប
៤. ពានរង្វាន់ស្ត្រីឆ្នើម ដែលមានឥទ្ធិពលបំផុត ឆ្នាំ២០២០ ពីធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា
៥. ពានរង្វាន់អង្គភាពអាជីវកម្មឆ្នើម ប្រចាំឆ្នាំ២០២៤ (ពានរង្វាន់ជាក្រុម)

លោកស្រី សាណា ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកគណនេយ្យ និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលពាណិជ្ជកម្ម។ លោកស្រីបានបញ្ចប់វគ្គសិក្សា ក្នុងកម្មវិធីបណ្តុះបណ្តាល លើជំនាញ Accelerated Universal Bankers Programme នៅសាកលវិទ្យាល័យ បច្ចេកវិទ្យាណានយ៉ាង (Nayang Technological University) ក្នុងប្រទេសសិង្ហបុរី។

## TEO HONG JOO

**សហនាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល**

▷ សញ្ជាតិម៉ាឡេស៊ី

លោក Teo Hong Joo បានចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី នៅខែកញ្ញា ឆ្នាំ២០២៤ ក្នុងមុខតំណែងជា អ្នកដឹកនាំការផ្លាស់ប្តូរយុទ្ធសាស្ត្រផ្នែកលក់ ហើយក្រោយមកមិនយូរប៉ុន្មាន ត្រូវបានដំឡើងតំណែងជា សហនាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល នៅខែតុលា ឆ្នាំ២០២៤។ ក្នុងមុខតំណែងនេះ លោកទទួលខុសត្រូវ លើការដំរុញយុទ្ធសាស្ត្រអាជីវកម្ម និងដឹកនាំក្រុមការងារ ដើម្បីសម្រេចបានផែនការលក់ផលិតផល ផ្នែកប្រាក់បញ្ញើ និងឥណទាន គ្រប់គ្រងកិច្ចសហការដៃគូ ព្រមទាំងពង្រីកអាជីវកម្មបែងកាសូរេនផងដែរ។

ជាមួយនឹងបទពិសោធន៍ការងារជាង ២៣ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ និងធនាគារ លោក Teo Hong Joo ធ្លាប់បានកាន់តួនាទីជា អ្នកដឹកនាំថ្នាក់តំបន់មួយចំនួន មុនពេលចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ មុខតំណែងទាំងអស់នោះ គឺរួមមាន នាយកអភិវឌ្ឍន៍អាជីវកម្ម នៅស៊ីអាយអិមប៊ី គ្រុប នាយកផ្នែកលក់ នៅក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ និងអគ្គនាយកអាជីវកម្ម នៅធនាគារ SHWE ក្នុងប្រទេសមីយ៉ាន់ម៉ា។

ក្នុងអំឡុងពេលបំពេញការងារ នៅស៊ីអាយអិមប៊ី គ្រុប លោក Teo Hong Joo ទទួលបានពានរង្វាន់លេចធ្លោមួយចំនួន រួមមាន៖

- ពានរង្វាន់អិមមើរ៉ែល សម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាល របស់ស៊ីអាយអិមប៊ី
- ពានរង្វាន់អិមមើរ៉ែល សម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាល ដែលមានប្រជាប្រិយភាពបំផុត របស់ស៊ីអាយអិមប៊ី
- ពានរង្វាន់គ្រូបង្វឹកល្អបំផុត របស់ CIMB RED
- ពានរង្វាន់ថ្នាក់តំបន់ CEO Challenge ដែលមាន STM ល្អបំផុត របស់ស៊ីអាយអិមប៊ី គ្រុប
- ពានរង្វាន់អ្នកស្តាបនាល្អបំផុត របស់ CIMB Sunlife (បែងកាសូរេន)
- ជ័យលាភី សម្រាប់ដំណើរកម្សាន្តប្រទេសជប៉ុន អេស្ប៉ាញ និងកោះបាលី របស់ CIMB Sunlife

លោក Teo Hong Joo ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកបច្ចេកវិទ្យាព័ត៌មាន លើមុខជំនាញប្រព័ន្ធពហុព័ត៌មាន ពីសាកលវិទ្យាល័យ Charles Sturt ក្នុងប្រទេសអូស្ត្រាលី និងបានបញ្ចប់វគ្គសិក្សាកម្មវិធីបណ្តុះបណ្តាល លើជំនាញ Accelerated Universal Bankers Programme ពីសាកលវិទ្យាល័យ បច្ចេកវិទ្យា ណានយ៉ាង (Nanyang Technological University) ក្នុងប្រទេសសិង្ហបុរី។

## ប៊ិច សុម៉ាលី

**សហនាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល**

▷ សញ្ជាតិខ្មែរ

លោកស្រី ប៊ិច សុម៉ាលី បានចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី នៅខែឧសភា ឆ្នាំ២០២១ ហើយត្រូវបានដំឡើងតំណែងជា នាយិកាសេវាកម្មហិរញ្ញវត្ថុបុគ្គល នៅខែឧសភា ឆ្នាំ២០២២។

ក្នុងមុខតំណែងនេះ លោកស្រី សុម៉ាលី ទទួលខុសត្រូវ លើការគ្រប់គ្រងទូទៅ និងសមិទ្ធផលហិរញ្ញវត្ថុ ព្រមទាំងយុទ្ធសាស្ត្រអាជីវកម្ម នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល របស់ធនាគារ ស៊ីអាយអិមប៊ី ដែលរួមមានបទពិសោធន៍សេវាកម្មអតិថិជន បណ្តាញសាខា ការគ្រប់គ្រងឥណទាន និងផ្នែកអាជីវកម្ម ដូចជាប្រាក់បញ្ញើបុគ្គល សេវាកម្មធនាគារជាន់ខ្ពស់ (Preferred Banking) ឥណទាន សម្រាប់អតិថិជនជាលក្ខណៈបុគ្គល (ឥណទានគេហដ្ឋាន ឥណទានរថយន្ត ឥណទានបុគ្គល រួមទាំងផលិតផល ផ្នែកសេវាកម្មហិរញ្ញវត្ថុបុគ្គលដទៃទៀត) និងប័ណ្ណឥណទាន។ លោកស្រីបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើតក្រុមការងារ ផ្នែកឌីជីថល និងសេវាកម្មធនាគារចល័ត តាមទូរសព្ទដៃ។

ជាមួយនឹងបទពិសោធន៍ការងារជាង ២០ឆ្នាំ ក្នុងវិស័យធនាគារ និងទូទាត់ប្រាក់ លោកស្រីធ្លាប់កាន់មុខតំណែងមួយចំនួន រួមមានផ្នែកប្រតិបត្តិការធនាគារ និងការទូទាត់ប្រាក់ចល័ត តាមទូរសព្ទដៃ ជាមួយនឹងបទពិសោធន៍ការងារកម្រិតអន្តរជាតិ ក្នុងប្រទេសមីយ៉ាន់ម៉ា សិង្ហបុរី និងអូស្ត្រាលី។

លោកស្រី សុម៉ាលី ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ ក្នុងរាជធានីភ្នំពេញ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ និងគ្រប់គ្រង ពីសាកលវិទ្យាល័យ Charles Sturt។

## ហេង វុទ្ធី
**នាយកហិរញ្ញវត្ថុ**

សញ្ជាតិខ្មែរ

លោក ហេង វុទ្ធី គឺជាបុគ្គលមួយរូប ក្នុងគណៈកម្មាធិការគ្រប់គ្រង របស់ធនាគារស៊ីអាយអិមប៊ី ភីអិលស៊ី ដែលបានចូលរួមបំពេញការងារ នៅពេលធនាគារបើកដំណើរការដំបូង ក្នុងឆ្នាំ២០១០។ ភារកិច្ចម្បងរបស់លោក គឺរួមមានការគ្រប់គ្រងមុខងារហិរញ្ញវត្ថុ រៀបចំផែនការ ដឹកនាំ និងគ្រប់គ្រងបុគ្គលិក ក្នុងការអភិវឌ្ឍ អនុវត្ត និងរៀបចំគោលនយោបាយ និងនីតិវិធី សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ចវិកា ពន្ធដារ គណនេយ្យ និងរបាយការណ៍បទប្បញ្ញត្តិ ព្រមទាំងយុទ្ធសាស្ត្រអាជីវកម្មរបស់ធនាគារទាំងមូល។

លោក វុទ្ធី ត្រូតពិនិត្យផងដែរ លើប្រព័ន្ធ និងរបាយការណ៍គណនេយ្យ ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំផែនការអាជីវកម្ម និងដើរតួនាទីជា អ្នកសម្របសម្រួល ជាមួយក្រុមហ៊ុនមេ នៅប្រទេសម៉ាឡេស៊ី។ មុនពេលចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកមានបទពិសោធន៍ ៨ឆ្នាំ ក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុ និងកាន់តួនាទីជា នាយករងហិរញ្ញវត្ថុ នៅធនាគារធំមួយ ក្នុងប្រទេសកម្ពុជា។

លោក វុទ្ធី ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ បញ្ញាសាស្ត្រកម្ពុជា ហើយបានបញ្ចប់ការសិក្សា ថ្នាក់គណនេយ្យការជាន់ខ្ពស់ (ACCA: Association of Chartered Certified Accountants) ពីសាលាពាណិជ្ជកម្ម CamEd ដែលជាស្ថាប័នទទួលបានសិទ្ធិជាផ្លូវការ ពីចក្រភពអង់គ្លេស ក្នុងការបណ្តុះបណ្តាល ACCA នៅប្រទេសកម្ពុជា។

## អ៊ុំ ចិន្តាភក្តី
**នាយិកាធនធានសាជីវកម្ម**

សញ្ជាតិខ្មែរ

ក្នុងនាមជាគណៈគ្រប់គ្រងមួយរូប របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលបានចូលរួមបំពេញការងារ នៅពេលធនាគារបើកដំណើរការដំបូង លោកស្រី អ៊ុំ ចិន្តាភក្តី គឺជាបុគ្គលសំខាន់ដែលបានជំរុញឱ្យមានភាពជោគជ័យ ក្នុងការគ្រប់គ្រងដឹកនាំ លើយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស ដែលរួមមានការជ្រើសរើសបុគ្គលិកសក្តានុពល / ការគ្រប់គ្រងអនុវត្តន៍ការងារ និងប្រាក់រង្វាន់លើកទឹកចិត្ត / កម្មវិធីភ្ជាប់ទំនាក់ទំនងនិយោជិត / ការកសាងវប្បធម៌ការងារ ព្រមទាំងការបណ្តុះបណ្តាល និងគ្រប់គ្រងធនធានមនុស្ស។ លោកស្រីធានាថា ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺជាស្ថាប័នការងារឈានមុខគេមួយ នៅលើទីផ្សារ។ ក្នុងឆ្នាំ២០២៤ លោកស្រីជួយជ្រោមជ្រែង ដល់ធនាគារដើម្បីឈ្នះពានរង្វាន់ «ទីកន្លែងការងារល្អបំផុត ក្នុងប្រទេសកម្ពុជា» និងពានរង្វាន់ «ភាពចម្រុះបែបសមភាព និងភាពរួមបញ្ចូលគ្នា» ដែលជាសមិទ្ធផលគួរជាទីមោទក របស់ស្ថាប័នទាំងមូល។

រហូតមកដល់បច្ចុប្បន្ន លោកស្រី ភក្តី រួមចំណែក ក្នុងការសម្រេចបានសមិទ្ធផលរបស់ធនាគារ តាមរយៈការកសាង ពង្រឹង និងបង្កើនសមត្ថភាពនិយោជិត ប្រកបដោយភាពប្រកួតប្រជែង និងជំរុញដល់ធនធានមនុស្ស ឱ្យអស់ពីលទ្ធភាពរបស់ពួកគេ។ ចំណុចផ្តោតចម្បងរបស់លោកស្រី គឺរួមមានការទាក់ទាញ និងការរក្សាទុក នូវនិយោជិតសក្តានុពល ដែលជួយពន្លឿនភាពរីកចម្រើន និងនិរន្តភាពរបស់អាជីវកម្ម សម្រាប់រយៈពេលខ្លី មធ្យម និងរយៈពេលវែងរបស់ធនាគារ។

លោកស្រី ភក្តី មានជំនាញទំនាក់ទំនងយ៉ាងល្អ ដែលអាចធ្វើការយ៉ាងជិតស្និទ្ធ បានដោយរលូន ជាមួយនឹងថ្នាក់ដឹកនាំ ក្នុងការបង្កើត និងអនុវត្តផែនការ នៃការសម្រេចជោគជ័យ ក្រោមការជួយគាំទ្រយ៉ាងពេញទំហឹង ពីកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីអភិវឌ្ឍន៍ នៅក្នុងប្រទេស និងថ្នាក់តំបន់។

ក្រៅពីជំនាញ ផ្នែកគ្រប់គ្រងធនធានមនុស្ស លោកស្រីទទួលបន្ទុក លើការដឹកនាំចាត់ចែង ផ្នែករដ្ឋបាល ការគ្រប់គ្រងគម្រោងទ្រព្យសម្បត្តិ និងមុខងារលទ្ធកម្មយុទ្ធសាស្ត្រ ដែលត្រូតពិនិត្យ ទាំងលើលទ្ធកម្ម ពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងមិនពាក់ព័ន្ធនឹងបច្ចេកវិទ្យា។ លោកស្រីធានានូវការគ្រប់គ្រងនាយកដ្ឋានទាំងពីរនេះ ដោយផ្តោតលើការសម្រេចបានគម្រោងនានា ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល នៃការចំណាយ។

មុនពេលចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី អ៊ុំ ចិន្តាភក្តី មានបទពិសោធន៍ជាង ១៥ឆ្នាំ ក្នុងមុខតំណែងជាអ្នកគ្រប់គ្រង ផ្នែកធនធានមនុស្ស ជាមួយបណ្តាស្ថាប័នជាច្រើនរួចមកហើយ។ លោកស្រីបានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលពាណិជ្ជកម្ម ពីវិទ្យាស្ថានជាតិគ្រប់គ្រង ក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០២២ លោកស្រីទទួលបានវិញ្ញាបនបត្រ ផ្នែកធនាគារអាជីព ដែលត្រូវបានទទួលស្គាល់ដោយស្ថាប័ន Asian Institution of Chartered Bankers និងវិទ្យាស្ថាន Chartered Banker ពីចក្រភពអង់គ្លេស។

## ហេង វិបុត្រ
**នាយកបច្ចេកវិទ្យា និងទិន្នន័យ**

- សញ្ជាតិខ្មែរ

លោក ហេង វិបុត្រ បានចូលបម្រើការងារ នៅក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងមុខតំណែងជា នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ នៅខែសីហា ឆ្នាំ២០១៨ ហើយបន្ទាប់មក លោកត្រូវបានតែងតាំងជា នាយកបច្ចេកវិទ្យា និងទិន្នន័យ នៅខែកញ្ញា ឆ្នាំ២០២២។ ក្នុងមុខតំណែងនេះ លោកទទួលខុសត្រូវ លើការរៀបចំ និងអនុវត្តផែនការជាយុទ្ធសាស្ត្រ ផ្នែកបច្ចេកវិទ្យារបស់ធនាគារ ដែលរួមមានការគ្រប់គ្រងធនធានមនុស្ស និងផលិតភាពបុគ្គលិក ការត្រួតពិនិត្យការវិវឌ្ឍទៅ នៃគម្រោង និងការវាយតម្លៃហានិភ័យ។ លោកដឹកនាំក្រុមការងារ ដើម្បីធានាថា គោលនយោបាយ និងនីតិវិធីគឺត្រូវបានអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងគាំទ្រអង្គភាពអាជីវកម្ម និងអង្គភាពគាំទ្រអាជីវកម្ម ឱ្យបានទាន់ពេលវេលា។

សម្រាប់ផ្នែកទិន្នន័យ លោក វិបុត្រ ក៏ទទួលខុសត្រូវ លើការគ្រប់គ្រងអភិបាលកិច្ចទិន្នន័យរបស់ធនាគារ រួមមានការគ្រប់គ្រងទិន្នន័យ ការប្រើប្រាស់ទិន្នន័យ ការរក្សាទុកទិន្នន័យ ដែលមិនប្រើប្រាស់ និងទៅតាមការកំណត់ ដែលត្រូវរក្សាទុក។ លោកក៏ធានាផងដែរថា គោលនយោបាយគ្រប់គ្រងទិន្នន័យរបស់ធនាគារ គឺត្រូវបានធ្វើបច្ចុប្បន្នភាពទៀងទាត់ និងអនុលោមតាមបទប្បញ្ញត្តិ និងដំណើរការផ្ទៃក្នុង។

លោក វិបុត្រ មានបទពិសោធន៍ការងារជាង ២២ឆ្នាំ ក្នុងវិស័យធនាគារ ហើយលោកបានចាប់ផ្តើមអាជីពការងារជា វិស្វករសរសេរកម្មវិធីកុំព្យូទ័រ ក្នុងឆ្នាំ២០០៣។ មុនពេលចូលបម្រើការងារនៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកធ្លាប់បំពេញការងារជា នាយកសេវាកម្មបច្ចេកវិទ្យាព័ត៌មាននៅធនាគារក្នុងស្រុកដ៏ធំមួយ ក្នុងប្រទេសកម្ពុជា។

លោក ហេង វិបុត្រ ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

## RACHEL NGUYEN
**នាយិកាបច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ**

- សញ្ជាតិវៀតណាម

លោកស្រី Rachel Nguyen បានចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា នៅខែមេសា ឆ្នាំ២០២៤ ក្នុងមុខតំណែងជា នាយិកាបច្ចេកវិទ្យា ឌីជីថល និងទិន្នន័យ។ លោកស្រីក៏កាន់មុខតំណែងជា នាយិកាបណ្តាញចែកចាយ ផ្នែកឌីជីថល និងគ្រប់គ្រងបច្ចេកវិទ្យាសម្រាប់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសវៀតណាម ហើយទទួលខុសត្រូវ លើការជំរុញមុខងារឌីជីថល សម្រាប់ប្រទេសទាំងពីរផងដែរ។

លោកស្រី Rachel ធ្លាប់បានកាន់តួនាទីជាថ្នាក់ដឹកនាំជាច្រើន ជាមួយនឹងបទពិសោធន៍ការងារជាង ១៨ឆ្នាំ ផ្នែកឌីជីថល ដែលលោកស្រីបានចូលរួមយ៉ាងពេញទំហឹង ក្នុងការងារលើកកម្ពស់ផ្នែកឌីជីថល លើវិស័យ និងភូមិសាស្ត្រផ្សេងៗគ្នា។ លោកស្រីបានចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសវៀតណាម នៅខែមករា ឆ្នាំ២០១៩ ហើយរួមចំណែកយ៉ាងសំខាន់ ក្នុងការជំរុញការផ្លាស់ប្តូរ ក្នុងស្ថាប័ន ពីធនាគារ បែបប្រពៃណី ទៅកាន់ធនាគារ បែបឌីជីថល។

មុនពេលចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសវៀតណាម និងក្នុងប្រទេសកម្ពុជា លោកស្រី Rachel មានបទពិសោធន៍ការងារដ៏លេចធ្លោ និងច្រើនក្រាស់ក្រែល ក្នុងក្រុមហ៊ុនប្រឹក្សា ផ្នែកបច្ចេកវិទ្យាមួយចំនួន ដូចជាក្រុមហ៊ុន Accenture ក្រុមហ៊ុន GMC Software Technology ក្រុមហ៊ុន AdNovum ក្រុមហ៊ុន Anacle Systems ។ល។ មិនតែប៉ុណ្ណោះ លោកស្រីធ្លាប់បានបំពេញការងារជា ទីប្រឹក្សាឯករាជ្យ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ ផងដែរ ដោយលោកស្រីផ្តល់សេវាកម្មប្រឹក្សាយោបល់ និងអនុវត្តន៍គម្រោង ដល់អតិថិជន នៅជុំវិញពិភពលោក។

លោកស្រី Rachel ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសាកលវិទ្យាល័យ Portsmouth ក្នុងចក្រភពអង់គ្លេស និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាលាពាណិជ្ជកម្ម ណានយ៉ាង (Nanyang Business School) ក្នុងប្រទេសសិង្ហបុរី។

## អ៊ុក ថានិន

**នាយកគ្រប់គ្រងផលិតផល និងចីរភាព**

សញ្ជាតិខ្មែរ

លោក អ៊ុក ថានិន បានចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០១៧ ដែលមានតួនាទីត្រួតពិនិត្យ លើនាយកដ្ឋានគ្រប់គ្រងផលិតផល។ ទំនួលខុសត្រូវការងាររបស់លោក គឺរួមមានការគ្រប់គ្រង ការសម្របសម្រួល និងការអនុវត្តគម្រោង បទប្បញ្ញត្តិ និងសេចក្តីណែនាំ ដែលពាក់ព័ន្ធនឹងផលិតផលថ្មីៗ និងមានស្រាប់ ដើម្បីបំពេញតាមតម្រូវការទីផ្សារ។ ក្នុងឆ្នាំកន្លងមកនេះ លោកបានចាត់ចែងនាយកដ្ឋានគ្រប់គ្រងផលិតផល និងបាននាំយកផលិតផលថ្មីៗ ដោយជោគជ័យ ដែលនាំឱ្យធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី កាន់តែមានភាពប្រកួតប្រជែងមួយកម្រិតទៀត នៅលើទីផ្សារ។ មិនតែប៉ុណ្ណោះ លោកបានដឹកនាំសម្របសម្រួល លើគម្រោងទូទាំងធនាគារជាច្រើន ដែលរួមមានកម្មវិធីចីរភាពផងដែរ។

មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកមានបទពិសោធន៍ ៩ឆ្នាំ នៅក្នុងឧស្សាហកម្មហិរញ្ញវត្ថុ ក្នុងផ្នែកផ្សេងៗគ្នា ដូចជាសេវាកម្មធានារ៉ាប់រងទូទៅ ការគ្រប់គ្រងឥណទាន និងសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម។

លោក ថានិន ធ្លាប់ទទួលអាហារូបករណ៍ ពីរដ្ឋាភិបាលសិង្ហបុរី និងអាហារូបករណ៍ Fulbright។ លោកបានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ពីសាកលវិទ្យាល័យជាតិ សិង្ហបុរី ក្នុងឆ្នាំ២០០៦ និងថ្នាក់អនុបណ្ឌិត ពីសាកលវិទ្យាល័យ Vanderbilt នៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០១២។ លោកបានក្លាយជាសមាជិក Beta Gamma Sigma ដែលជាស្ថាប័នអន្តរជាតិ សម្រាប់ថ្នាក់ឧត្តមសិក្សា ផ្នែកអាជីវកម្ម ក្នុងឆ្នាំ២០១២។

## ហេង ភួងរចនា

**នាយិកាប្រតិបត្តិការ**

សញ្ជាតិខ្មែរ

លោកស្រី ហេង ភួងរចនា បានចូលបម្រើការងារ នៅក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០១២ និងត្រូវបានតែងតាំងជា នាយិកា នៃនាយកដ្ឋានប្រតិបត្តិការ ក្នុងឆ្នាំ២០២២។

ក្នុងមុខតំណែងនេះ លោកស្រី រចនា ទទួលខុសត្រូវ លើការគ្រប់គ្រងមុខងារផ្សេងៗ ផ្នែកការិយាល័យគាំទ្រ រួមមានសេវាកម្មផ្ទេរប្រាក់ ក្នុងប្រទេស និងក្រៅប្រទេស ហិរញ្ញប្បទានពាណិជ្ជកម្ម ការទូទាត់មូលប្បទានបត្រ ការគ្រប់គ្រងម៉ាស៊ីនប្រតិបត្តិការស្វ័យប្រវត្តិ ការគ្រប់គ្រងសាច់ប្រាក់របស់ធនាគារទាំងមូល សេវាកម្មធនាគារ តាមប្រព័ន្ធអ៊ីនធើណេត ប្រតិបត្តិការតនាគារ សេវាកម្មបញ្ចេញឥណទាន និងសេវាកម្មទូទាត់ប្រាក់ដទៃទៀត។ ជាមួយគ្នានេះដែរ លោកស្រីដឹកនាំ និងអភិវឌ្ឍក្រុមការងារ ដើម្បីធានានូវភាពរីកចម្រើន នៃវិជ្ជាជីវៈការងាររបស់ពួកគេ ដោយរក្សាបាននូវការផ្តល់សេវាកម្ម និងការគាំទ្រដ៏ល្អប្រពៃ ប្រកបដោយគុណភាព។

លោកស្រី រចនា មានបទពិសោធន៍ការងារជាង ២០ឆ្នាំ ផ្នែកបម្រើសេវាកម្មធនាគារ និងមុខងារការិយាល័យគាំទ្រ។ មុនពេលចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រីធ្លាប់បំពេញការងារជា នាយិកាសេវាកម្មធនាគារ នៅធនាគារក្នុងស្រុកមួយ ក្នុងប្រទេសកម្ពុជា។

លោកស្រីទទួលបានសញ្ញាបត្របរិញ្ញាបត្រចំនួនពីរ គឺផ្នែកគណនេយ្យ ពីវិទ្យាស្ថានជាតិ គ្រប់គ្រង និងផ្នែកទំនាក់ទំនងភាសាអង់គ្លេស ពីសាកលវិទ្យាល័យ ន័រតុន។

## ខៀវ ឡានីន
**នាយកសវនកម្មផ្ទៃក្នុង**

សញ្ជាតិខ្មែរ

ក្នុងនាមជាអ្នកចូលរួមចំណែកមួយរូប ក្នុងគណៈកម្មាធិការគ្រប់គ្រង របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី នៅពេលបើកដំណើរការដំបូង ក្នុងឆ្នាំ២០១០ លោក ខៀវ ឡានីន ទទួលខុសត្រូវ លើការអភិវឌ្ឍ និងពិនិត្យមើលផែនការសវនកម្ម យុទ្ធសាស្ត្រ ស្តង់ដារ និងគោលនយោបាយ ព្រមទាំងការគ្រប់គ្រងទូទៅ ក្នុងនាយកដ្ឋានសវនកម្មផ្ទៃក្នុង របស់ធនាគារ។

លោក ឡានីន បានចូលបម្រើការងារ ក្នុងវិស័យធនាគារ ជាពិសេសមុខងារសវនកម្មផ្ទៃក្នុង ជាមួយនឹងបទពិសោធន៍ជាង ២២ឆ្នាំមកហើយ ដែលលោកមានសមត្ថភាព ក្នុងការបំពេញតួនាទីយ៉ាងមានប្រសិទ្ធភាព និងជាជំនួយ ទៅដល់គណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រង ក្នុងការបង្កើតការគ្រប់គ្រងចំណាយ ប្រកបដោយប្រសិទ្ធភាព ការកំណត់ និងវាយតម្លៃហានិភ័យ ការផ្តល់អនុសាសន៍ លើវិធានការកាត់បន្ថយហានិភ័យ ដោយធានាដំណើរការអភិបាលកិច្ចឱ្យបានល្អប្រសើរ និងការគ្រប់គ្រងការងារសវនកម្ម។ ទាំងអស់នេះ គឺដើម្បីស្របទៅតាមការផ្លាស់ប្តូរ នូវបច្ចេកវិទ្យាទិសដៅរបស់ក្រុមហ៊ុនមេ និងការអនុវត្តផែនការ ពីគណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ។

លោក ឡានីន ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងគណនេយ្យពីសាកលវិទ្យាល័យបៀលប្រាយ។ លោកក៏បានបញ្ចប់វគ្គសិក្សា ផ្នែកប្រតិបត្តិតាម និងកម្មវិធីបណ្តុះបណ្តាលអ្នកឯកទេសហានិភ័យ តាមប្រព័ន្ធអ៊ីនធើណេត ពីវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ។

## ឈុន ពុទ្ធកុម្ភៈវត្តី
**នាយិកាប្រតិបត្តិតាម**

សញ្ជាតិខ្មែរ

លោកស្រី ឈុន ពុទ្ធកុម្ភៈវត្តី បានចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងមុខតំណែងជា នាយិកាប្រតិបត្តិតាម នៅខែសីហា ឆ្នាំ២០១៧។ លោកស្រីទទួលខុសត្រូវ លើការងារគ្រប់គ្រងរួម លើមុខងារប្រតិបត្តិតាម និងរាយការណ៍ ទៅកាន់ក្រុមប្រឹក្សាភិបាល នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ ក្នុងមុខតំណែងជា នាយិកាប្រតិបត្តិតាម លោកស្រីវត្តី ត្រូតពិនិត្យ និងដឹកនាំការងារទាំងឡាយ ដែលទាក់ទងនឹងផ្នែកប្រតិបត្តិតាម នៅក្នុងធនាគារ និងជាអ្នកទំនាក់ទំនងចម្បង ជាមួយនឹងធនាគារជាតិ នៃកម្ពុជា និងនិយតករដទៃទៀត។

លោកស្រី វត្តី បានចាប់ផ្តើមអាជីពការងារជាសវនករ ក្នុងក្រុមហ៊ុនសវនកម្មអន្តរជាតិមួយ ហើយបន្ទាប់មក លោកស្រីបានចាប់យកតួនាទីការងារ ផ្នែកប្រតិបត្តិតាម ក្នុងវិស័យហិរញ្ញវត្ថុ។ លោកស្រីវត្តី មានបទពិសោធន៍ការងារជាង ១៨ឆ្នាំ ក្នុងវិស័យធនាគារ ជាមួយនឹងជំនាញ ផ្នែកប្រតិបត្តិតាម និងគ្រប់គ្រងហានិភ័យប្រតិបត្តិការ។ មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី វត្តី ធ្លាប់កាន់តួនាទីជា នាយិកាគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងគ្រប់គ្រងផ្ទៃក្នុង នៅធនាគារធំមួយ ក្នុងប្រទេសកម្ពុជា។

លោកស្រី វត្តី បានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យ បញ្ញាសាស្ត្រ កម្ពុជា។ លោកស្រី វត្តី ក៏បានបញ្ចប់ថ្នាក់វិញ្ញាបនបត្រ សម្រាប់មន្ត្រីប្រតិបត្តិតាម ពីវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ និងវិញ្ញាបនបត្រ កម្រិតអន្តរជាតិ ផ្នែកប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (International Advanced Certificate in Anti Money Laundering and International Diploma in Anti Money Laundering) ពីវិទ្យាស្ថាន International Compliance Association (ICA) ដែលមានទីស្នាក់ការកណ្តាល នៅចក្រភពអង់គ្លេស។

## គៀន វឌ្ឍនា
**នាយកគ្រប់គ្រងហានិភ័យ**

▷ សញ្ជាតិខ្មែរ

លោក គៀន វឌ្ឍនា គឺជានាយកគ្រប់គ្រងហានិភ័យ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលមានតួនាទីត្រួតពិនិត្យ លើការគ្រប់គ្រងហានិភ័យទាំងមូល និងធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនឹងអង្គភាពអាជីវកម្មផ្សេងទៀត ព្រមទាំងក្រុមការងារហានិភ័យ របស់ស៊ីអាយអិមប៊ី គ្រុប ដើម្បីបង្ហាប វប្បធម៌ និងការគ្រប់គ្រងហានិភ័យ នៅក្នុងធនាគារ។

លោក វឌ្ឍនា គឺជាអ្នកចូលរួមដំបូងមួយរូប ក្នុងការបង្កើតក្រុមការងារគ្រប់គ្រងឥណទាន នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០១០ ដែលត្រួតពិនិត្យមើលឥណទាន លើគ្រប់ផ្នែកអាជីវកម្ម (សេវាកម្មហិរញ្ញវត្ថុបុគ្គល សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ ព្រមទាំងរតនាគិបាល និងទីផ្សារ)។ លោកមានចំណេះដឹង និងបទពិសោធន៍ដ៏ទូលំទូលាយ លើផ្នែកគ្រប់គ្រងឥណទាន។ លោកបានពង្រឹងជំនាញរបស់ខ្លួនបន្ថែម ជាមួយនឹងការយល់ដឹង អំពីអតិថិជន និងវិស័យធនាគារ តាមរយៈការធ្វើការ ជាមួយនឹងក្រុមការងារគ្រប់គ្រងឥណទាន ក្នុងប្រទេសម៉ាឡេស៊ី និងសិង្ហបុរី ដែលទទួលបន្ទុកត្រួតពិនិត្យសំណើសុំឥណទានទាំងអស់ពីប្រទេសកម្ពុជា ថៃ និងម៉ាឡេស៊ី។

លោក គៀន វឌ្ឍនា ត្រូវបានតែងតាំងជា ប្រធានគណៈកម្មការឥណទាន និងគណៈកម្មាការគុណភាពទ្រព្យសកម្ម ដោយផ្អែកលើបទពិសោធន៍ដ៏ក្រាស់ក្រែល ផ្នែកគ្រប់គ្រងឥណទាន រយៈពេលជាង ១៥ឆ្នាំ ក្នុងវិស័យធនាគារ។ លោកផ្តល់នូវទិសដៅ និងការណែនាំ ផ្នែកឥណទាន ដើម្បីរក្សា និងទាក់ទាញអតិថិជនល្អ។ ព្រមទាំងធានាឱ្យបាននូវគុណភាពឥណទាន ដែលធនាគារមាន។ ក្រៅពីនេះ លោកពិនិត្យមើលការគ្រប់គ្រងហានិភ័យប្រភេទផ្សេងទៀត ដែលរួមមានហានិភ័យប្រតិបត្តិការ ហានិភ័យទីផ្សារ ហានិភ័យសន្ទនីយភាព និងប្រភពទុន ហានិភ័យតតិយភាព ហានិភ័យផ្លែងបន្លំ និងហានិភ័យបច្ចេកវិទ្យា។

លោក វឌ្ឍនា ទទួលបានសញ្ញាបត្របរិញ្ញាបត្រចំនួនពីរ រួមមានបរិញ្ញាបត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងបរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រគណិតវិទ្យា។ ជាមួយគ្នានេះ លោកបានបញ្ចប់វគ្គសិក្សាកម្មវិធីបណ្តុះបណ្តាល លើជំនាញវាយតម្លៃឥណទាន របស់ CIMB-Omega និង Accelerated Universal Bankers Programme ពីសាកលវិទ្យាល័យ បច្ចេកវិទ្យាណានយ៉ាង (Nanyang Technological University) ក្នុងប្រទេសសិង្ហបុរី។

## លី សោភា
**នាយិកានីតិកម្ម និងលេខាធិការក្រុមហ៊ុន**

▷ សញ្ជាតិខ្មែរ

លោកស្រី លី សោភា មានតួនាទីជានាយិកានីតិកម្ម និងលេខាធិការក្រុមហ៊ុន នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចាប់តាំងពីថ្ងៃចាប់ផ្តើមប្រតិបត្តិការដំបូងរបស់ធនាគារ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១០។ លោកស្រីទទួលខុសត្រូវ លើតួនាទីនីតិកម្ម និងលេខាធិការក្រុមហ៊ុន។ លោកស្រីគឺជាលេខាធិការក្រុមហ៊ុនរួមមួយរូប នៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្មរបស់ធនាគារ។ លោកស្រីក៏ជាលេខាធិការ នៃគណៈកម្មាធិការគ្រប់គ្រង និងគណៈកម្មាធិការត្រួតពិនិត្យលទ្ធផលអាជីវកម្មកម្ពុជា និងជាអ្នកចូលរួមអចិន្ត្រៃយ៍ ក្នុងគណៈកម្មាធិការផ្សេងៗទៀតរបស់ធនាគារ រួមមានដូចជាគណៈកម្មាធិការហានិភ័យ និងគណៈកម្មាធិការឥណទានកម្ពុជា។

មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រីធ្លាប់បម្រើការងារជាជំនួយការនាយកប្រតិបត្តិជាន់ខ្ពស់នីតិកម្ម និងកិច្ចការក្រុមហ៊ុន នៅក្នុងធនាគារធំមួយ ក្នុងប្រទេសកម្ពុជា។ ក្នុងពេលតែមួយ ក្រៅពីការបន្តការសិក្សា លោកស្រីបានបម្រើការងារ ផ្នែកនីតិកម្ម និងលេខាធិការក្រុមហ៊ុន អស់រយៈពេល ០៦ឆ្នាំ នៅនាយកដ្ឋាននីតិកម្ម និងកិច្ចការក្រុមហ៊ុន នៅកន្លែងដែលធ្លាប់បម្រើការងារពីមុន។

លោកស្រី លី សោភា បានទទួលសញ្ញាបត្របរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៤ ហើយក្នុងឆ្នាំដដែលនេះ លោកស្រីក៏ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ជំនាញគណនេយ្យ ពីមហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម នៃវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង (បច្ចុប្បន្នជា សាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ) ផងដែរ។ ក្នុងឆ្នាំ២០០៧ លោកស្រីទទួលបានសញ្ញាបត្រ ថ្នាក់អនុបណ្ឌិត ជំនាញនីតិឯកជន ពីសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោកស្រីទទួលបានវិញ្ញាបនបត្រ ផ្នែកប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ពីវិទ្យាស្ថានជំនាញធនាគារ អាស៊ី (Asian Institute of Chartered Bankers ដែលហៅកាត់ថា AICB) នៅប្រទេសម៉ាឡេស៊ី ក្នុងឆ្នាំ២០១៧។ លោកស្រីក៏ទទួលបានគុណវុឌ្ឍិជាសន្ធានករ ដែលទទួលស្គាល់ដោយមជ្ឈមណ្ឌលដោះស្រាយវិវាទ (Centre for Effective Dispute Resolution ដែលហៅកាត់ថា CEDR) ដែលមានទីតាំង នៅចក្រភពអង់គ្លេស ក្នុងខែមករា ឆ្នាំ២០២២ ផងដែរ។ ក្នុងខែសីហា ឆ្នាំ២០២២ លោកស្រីបានចូលរួមវគ្គបណ្តុះបណ្តាលការប្រឡង និងទទួលបានវិញ្ញាបនបត្រ សម្រាប់បុគ្គល ដែលត្រូវទទួលស្គាល់គុណវុឌ្ឍិ ក្នុងវិស័យបរធនបាលកិច្ចលើកទី១។ លើសពីនេះ លោកស្រីក៏ទទួលបានវិញ្ញាបនបត្រ សម្រាប់បុគ្គល ដែលត្រូវបានទទួលស្គាល់គុណវុឌ្ឍិ សម្រាប់ជំនាញមជ្ឈត្តការពាណិជ្ជកម្ម ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ ផងដែរ។



# ០៦

## របាយការណ៍ហិរញ្ញវត្ថុ


៩០ ..... របាយការណ៍ក្រុមប្រឹក្សាភិបាល

៩២ ..... របាយការណ៍សវនករឯករាជ្យ

៩៤ ..... របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

៩៥ ..... របាយការណ៍ចំណូលលម្អិត

៩៦ ..... របាយការណ៍បម្រែបម្រួលមូលធន

៩៧ ..... របាយការណ៍លំហូរសាច់ប្រាក់

៩៨ ..... កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

១៤២ ..... ព័ត៌មានហិរញ្ញវត្ថុបន្ថែម ទៅតាមតម្រូវការ
របស់ធនាគារជាតិ នៃកម្ពុជា

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល («ក្រុមប្រឹក្សាភិបាល») របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (ហៅកាត់ថា «ធនាគារ») សូមដាក់ជូននូវរបាយការណ៍របស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលបានធ្វើសវនកម្មរួច គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់។

## អំពីធនាគារ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានបង្កើតឡើងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ហើយធនាគារនេះ គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលកាន់កាប់ទាំងស្រុង ដោយ CIMB Bank Berhad ដែលជាធនាគារមានអាជ្ញាបណ្ណចុះបញ្ជីពាណិជ្ជកម្ម នៅប្រទេសម៉ាឡេស៊ី។ ក្រុមហ៊ុន CIMB Group Holdings Berhad ជាធនាគារចុះបញ្ជីលក់មូលបត្រ ដែលធ្វើប្រតិបត្តិការ នៅប្រទេសម៉ាឡេស៊ី គឺជាក្រុមហ៊ុនមេចុងក្រោយរបស់ធនាគារ។ អាសយដ្ឋានអាជីវកម្ម ដែលបានចុះបញ្ជីរបស់ធនាគារ មានទីតាំងស្ថិតនៅផ្ទះលេខ៦០ មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ រួមមានការធ្វើប្រតិបត្តិការ លើរាល់សកម្មភាពអាជីវកម្មធនាគារ និងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ពុំមានការផ្លាស់ប្តូរណាមួយ គួរឱ្យកត់សម្គាល់ ទៅលើលក្ខណៈ នៃសកម្មភាពអាជីវកម្មចម្បង ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះឡើយ។

## លទ្ធផល នៃប្រតិបត្តិការ និងភាគលាភ

លទ្ធផល នៃប្រតិបត្តិការរបស់ធនាគារ សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងស្ថានភាព នៃអាជីវកម្មរបស់ធនាគារ នាកាលបរិច្ឆេទនោះ គឺត្រូវបានបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ពុំបានផ្តល់អនុសាសន៍ ក្នុងការទូទាត់ភាគលាភណាមួយ សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ នេះឡើយ។

| ឈ្មោះ | មុខងារ | កាលបរិច្ឆេទតែងតាំង |
|---|---|---|
| Tan Sri Mohd Nasir Bin Ahmad | អភិបាលមិនឯករាជ្យមិនប្រតិបត្តិ / ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ |
| លោក ប៊ុន យ៉ីន | អភិបាលប្រតិបត្តិមិនឯករាជ្យ / ប្រធាននាយកប្រតិបត្តិ | ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ |
| លោកស្រី Aisyah Lam Binti Abdullah | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ | ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ |
| លោក ឡុង ប៊ាង | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ | ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ |
| លោក Mohd Haniz Bin Mohd Nazlan | អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ | ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥ |
| លោក Ankur Sehgal | អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ | ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥ |
| លោក Ahmad Shazli Kamarulzaman | អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ | ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ (ចូលនិវត្តន៍ នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥) |
| លោក Cheong Weng Teong | អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ | ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ (ចូលនិវត្តន៍ នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥) |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ត្រូវបានធ្វើសវនកម្ម ដោយក្រុមហ៊ុន ប្រ៊ូន សនចុន (ខេមបូឌា) លីមីធីត។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានអភិបាលរបស់ធនាគារបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យា ដែលធ្វើឡើងដោយធនាគារ ឬដោយសាជីវកម្មពាក់ព័ន្ធជាមួយនឹងធនាគារ ដែលមានអភិបាលនោះជាសមាជិក ឬជាមួយក្រុមហ៊ុន ដែលអភិបាលនោះ មានផលប្រយោជន៍ ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែមានការលាតត្រដាង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការសមស្រប ដើម្បីទ្រព្យសកម្មទាំងឡាយណា ដែលទំនងជាមិនអាចទទួលស្គាល់បាន ក្នុងប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារតាមតម្លៃ ដូចដែលបានបង្ហាញ ក្នុងកំណត់ត្រាគណនេយ្យរបស់ធនាគារ ត្រូវបានកាត់បន្ថយឱ្យស្មើនឹងសមតុល្យ ដែលត្រូវបានរំពឹងទុកថា អាចទទួលស្គាល់បាន។

នាកាលបរិច្ឆេទ នៃរបាយការណ៍នេះ និងផ្អែកលើការយល់ដឹងច្បាស់លាស់បំផុត ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីស្ថានការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិនត្រឹមត្រូវ ជាសារវន្តណាមួយឡើយ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

ក. ពុំមានបន្ទុកណាមួយ លើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើង ចាប់តាំងពីចុងការិយបរិច្ឆេទ ដែលដាក់បញ្ចាំ សម្រាប់ការធានា ចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ លើកលែងតែបានលាតត្រដាង ក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

ខ. ពុំមានបំណុលយថាហេតុណាមួយ ដែលកើតមានឡើង ចំពោះធនាគារចាប់តាំងពីចុងការិយបរិច្ឆេទមក ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញ ក្នុងអំឡុងពេល ១២ខែ បន្ទាប់ពីចុងបញ្ចប់ការិយបរិច្ឆេទ ដែលនឹងមាន ឬអាចនឹងមានផលប៉ះពាល់ជាសារវន្ត ដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

នាកាលបរិច្ឆេទ នៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីព្រឹត្តិការណ៍ណាមួយ ដែលមិនបានវែកញែក នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលនឹងបណ្តាលឱ្យសមតុល្យណាមួយ ដែលបានបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុថា មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផល នៃប្រតិបត្តិការរបស់ធនាគារ ក្នុងការិយបរិច្ឆេទនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្ត ពីសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។ តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេល រវាងចុងការិយបរិច្ឆេទនេះ និងកាលបរិច្ឆេទ នៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្ត ដល់លទ្ធផល នៃប្រតិបត្តិការរបស់ធនាគារ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបច្ចុប្បន្ន ដែលរបាយការណ៍នេះ បានរៀបចំឡើងនោះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង មានទំនួលខុសត្រូវ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលបង្ហាញនូវគ្រប់ទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្ត ពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដារគណនេយ្យនៃស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ដែលអនុម័តដោយនិយ័តករគណនេយ្យ និងសវនកម្ម នៃកម្ពុជា ដោយផ្អែកលើស្តង់ដារគណនេយ្យ នៃស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (IASB)។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ គណៈគ្រប់គ្រងតម្រូវឱ្យ៖

១. អនុម័តគោលនយោបាយគណនេយ្យ ដែលសមស្រប បានគាំទ្រដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្ត ប្រកបដោយសង្គតិភាព
២. អនុលោមតាមតម្រូវការស្តង់ដារគណនេយ្យ នៃស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយ ពីតម្រូវការទាំងនោះ ក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ត្រូវប្រាកដថា ការប្រាសចាកទាំងនោះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ
៣. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ប្រកបដោយប្រសិទ្ធភាព
៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋានបន្តនិរន្តរភាព នៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនអាច សន្មតថា ធនាគារនឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នាពេលអនាគតបន្តទៀតបាន និង
៥. ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព និងចូលរួមរាល់សេចក្តីសម្រេចសំខាន់ៗទាំងអស់ ដែលប៉ះពាល់ ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថា រាល់ការសម្រេចចិត្តនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវ ក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ធនាគារ ហើយក៏ត្រូវចាត់វិធានការឱ្យសមស្រប ដើម្បីទប់ស្កាត់ និងរកឱ្យឃើញនូវការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាល សូមបញ្ជាក់ថា ធនាគារបានអនុវត្ត តាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំ និងត្រួតពិនិត្យ លើរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការអនុម័ត លើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយ ព្រមទាំងកំណត់សម្គាល់នានា បានបង្ហាញនូវគ្រប់ទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្ត ពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដារគណនេយ្យនៃស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ចុះហត្ថលេខា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

**លោក ប៊ុន យីន**
អភិបាលប្រតិបត្តិ / ប្រធាននាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥

# របាយការណ៍សវនករឯករាជ្យ

ជូនចំពោះភាគហ៊ុនិករបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (ហៅកាត់ថា «ធនាគារ») ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងរបាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ព្រមជាមួយកំណត់សម្គាល់ លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងគោលនយោបាយគណនេយ្យជាសារវន្ត និងសេចក្តីពន្យល់ព័ត៌មានផ្សេងទៀត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ ដែលភ្ជាប់មកជាមួយ ផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្ត ពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យ CIFRS ដែលអនុម័តដោយនិយ័តករគណនេយ្យ និងសវនកម្ម នៃកម្ពុជា ដោយផ្អែកលើស្តង់ដាគណនេយ្យនៃ IFRS ដែលចេញដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (ស្តង់ដារគណនេយ្យ នៃ CIFRS)។

## មូលដ្ឋាន នៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិ នៃកម្ពុជា (CISAs)។ ទំនួលខុសត្រូវរបស់យើងខ្ញុំ ស្ថិតក្រោមស្តង់ដារទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែម នៅក្នុងកថាខណ្ឌ ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុ នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាព ពីក្រុមហ៊ុន ដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) (IESBA Code) និងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ ក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវ ទៅតាមតម្រូវការក្រមសីលធម៌ទាំងនេះ និង IESBA Code។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់មូលដ្ឋាន សម្រាប់មតិយោបល់របស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវ ចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរាប់បញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនកររបស់យើងខ្ញុំ ដែលយើងខ្ញុំបានទទួល មុនកាលបរិច្ឆេទ នៃរបាយការណ៍របស់សវនករនេះ ព្រមទាំងរបាយការណ៍ប្រចាំឆ្នាំ ដែលយើងខ្ញុំរំពឹងថា នឹងអាចទទួលបាន បន្ទាប់ពីកាលបរិច្ឆេទនោះ។

មតិយោបល់របស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ ទៅលើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំមិនផ្តល់សេចក្តីសន្និដ្ឋាន ក្នុងទម្រង់ នៃការធានាបែបណាមួយឡើយ។

ភ្ជាប់ជាមួយនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំមានទំនួលខុសត្រូវ ក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្ត ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបាន ពីការធ្វើសវនកម្មថាតើព័ត៌មានទាំងនោះ អាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើផ្អែកតាមការងារ ដែលយើងខ្ញុំបានអនុវត្ត យើងខ្ញុំសន្មតថា មានកំហុសឆ្គងជាសារវន្តកើតឡើង លើព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីត្រូវរាយការណ៍ នៅក្នុងករណីនេះឡើយ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងបុគ្គល មានអភិបាលកិច្ច ទៅលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងរបស់ធនាគារ ទទួលខុសត្រូវ ក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវ ដោយអនុលោមតាមស្តង់ដាគណនេយ្យ CIFRS និងទទួលខុសត្រូវ លើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រង កំណត់ថា វាមានភាពចាំបាច់ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការវាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រង មានទំនួលខុសត្រូវ ចំពោះការវាយតម្លៃ ទៅលើសមត្ថភាពធនាគារ ក្នុងការបន្តប្រតិបត្តិការ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាងប្រសិនជាមានបញ្ហា ទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាព ជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រង មានគោលបំណងរំសាយធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

បុគ្គលមានអភិបាលកិច្ច មានទំនួលខុសត្រូវ ក្នុងការត្រួតពិនិត្យ ទៅលើដំណើរការ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ត្រូវបានធ្វើសវនកម្ម ដោយសវនករផ្សេងទៀត ដែលបានបង្ហាញមតិយោបល់ត្រឹមត្រូវ លើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤។

## ការទទួលខុសត្រូវរបស់សវនករ ទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាន នូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្ម ដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាង ដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថា ការធ្វើសវនកម្ម ដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិ នៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្ត ដែលកើតមានឡើងនោះទេ។ ការរាយការណ៍ខុស អាចកើតមានឡើង ពីការក្លែងបន្លំ ឬកំហុសឆ្គង ដែលអាចចាត់ទុកថា ជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នា បានធ្វើឱ្យប៉ះពាល់ ដល់សេចក្តីសម្រេចចិត្ត ផ្អែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយ នៃការធ្វើសវនកម្ម ដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិ នៃកម្ពុជា យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈភាតុនិយម ប្រកបដោយវិជ្ជាជីវៈ ទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យ នៃការរាយការណ៍ខុសជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើតឡើង ដោយការក្លែងបន្លំ ឬកំហុសឆ្គង ដោយអចេតនា រៀបចំ និងអនុវត្តនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្ម ឱ្យបានគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋាន សម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យ ដែលមិនអាចរកឃើញ ដោយការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គង ដោយអចេតនា ដោយសារតែការក្លែងបន្លំ រួមបញ្ចូលទាំងការរួមគំនិតការក្លែងបន្លំ ដោយចេតនា ការលុបចោល ដោយចេតនា ការបង្ហាញខុស ឬការល្មើស ទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់ អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្ម ដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណង ក្នុងការបង្ហាញនូវមតិយោបល់ លើប្រសិទ្ធភាព នៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារនោះទេ។
- ធ្វើការវាយតម្លៃភាពសមស្រប លើគោលនយោបាយគណនេយ្យ ដែលបានប្រើប្រាស់ និងភាពសមហេតុផល នៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានា ដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- សន្និដ្ឋានដ៏សមស្របមួយ ទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រង លើមូលដ្ឋាននិរន្តរភាពគណនេយ្យ និងផ្អែកទៅលើភស្តុតាងសវនកម្ម ដែលទទួលបានថាតើភាពមិនប្រាកដប្រជា ជាសារវន្ត បានកើតឡើង ទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌ ដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំង ទៅលើលទ្ធភាព នៃការបន្តនិរន្តរភាពរបស់ធនាគារ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនច្បាស់លាស់ជាសារវន្ត នឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ ដើម្បីទាញការយកចិត្តទុកដាក់ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ទៅនឹងការលាតត្រដាង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវ នឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្ម ដែលទទួលបានគិតត្រឹមថ្ងៃ នៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយ ស្ថានភាព ឬក៏ព្រឹត្តិការណ៍ នាពេលអនាគត អាចបណ្តាលឱ្យធនាគារមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងនានា ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញប្រតិបត្តិការ និងព្រឹត្តិការណ៍នានា បានបង្ហាញនូវភាពសមស្របដែរឬទេ។

យើងខ្ញុំប្រាស្រ័យទាក់ទង ជាមួយនឹងក្រុមប្រឹក្សាភិបាល ទៅលើបញ្ហាផ្សេងៗ កំណត់វិសាលភាព និងពេលវេលា ក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមទាំងកង្វះខាតសំខាន់ៗ មួយចំនួន ទៅលើការត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញ អំឡុងពេលធ្វើសវនកម្ម។

Grant Thornton

**ហ្គ្រានេ សនថុន (ខេមបូឌា) លីមីធីត**
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

**Ronald C. Almera**
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ៣៩.៤៩៣.៤២១ | ១៥៨.៩៦១.០២០ | ៥១.០១៣.៥៤៥ | ២០៨.៣៩០.៣៣១ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល | ៥ | ១០៥.០៣១.៤៩៤ | ៤២២.៧៥១.៧៦៣ | ៨២.០៩៥.៥៥២ | ៣៣៥.៣៦០.៣៣០ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ | ៦ | ៣៤៥.៧៨៣.២២៣ | ១.៣៩១.៧៧៧.៤៧៣ | ២៥៧.២៧៧.៣២៥ | ១.០៥០.៩៧៧.៨៧៣ |
| ឥណទាន និងបុរេប្រទាន តាមថ្លៃដើមបានរំលស់-សុទ្ធ | ៧ | ៩៤១.៣៣៤.៩៦១ | ៣.៧៨៨.៨៧៣.២១៨ | ៩៨៤.៨៣៤.៦៧៤ | ៣.៨៥៩.៦៤៩.៦៤៣ |
| ប្រាក់តម្កល់ តាមបទប្បញ្ញត្តិ នៅធនាគារកណ្តាល | ៨ | ៩០.៩៣៥.៤៩១ | ៣៦៦.០១៥.៣៥១ | ១០៣.៨៩១.៥៤៧ | ៤២៤.៣៩៦.៩៦៩ |
| សិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម-សុទ្ធ | ៩ | ៤.៣១៧.២៨១ | ១៧.៣៧៧.០៥៦ | ៥.៥៣៨.០៨៦ | ២២.៦២៣.០៨១ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ-សុទ្ធ | ១០ | ៤.២៥២.៣៣០ | ១៧.១១៥.៦២៨ | ៦.០៩៥.៤១១ | ២៤.៨៩៩.៧៥៤ |
| ទ្រព្យសកម្មអរូបី-សុទ្ធ | ១១ | ១.១៤៦.៥៤៣ | ៤.៦១៤.៨៣៦ | ១.៥៣៥.៦៩៣ | ៦.២៧៣.៣០៦ |
| ទ្រព្យសកម្មពន្ធពន្យារ-សុទ្ធ | ១២ | ២.០៧៥.៩៧៥ | ៨.៣៥៥.៧៩៩ | ១.៦៦៤.៧៧៩ | ៦.៨០០.៦២២ |
| ទ្រព្យសកម្មផ្សេងៗ | ១៣ | ៦.៩៦០.១២២ | ២៨.០១៤.៤៩១ | ៦.៥៤៤.២០៧ | ២៦.៧៣៣.០៨៦ |
| **ទ្រព្យសកម្មសរុប** | | ១.៥៤១.៣៣០.៨៤១ | ៦.២០៣.៨៥៦.៦៣៥ | ១.៤៦០.៤៩០.៨១៩ | ៥.៩៦៦.១០៤.៩៩៥ |
| **ចំណុល និងមូលធន** | | | | | |
| **ចំណុល** | | | | | |
| ប្រាក់បញ្ញើ ពីធនាគារ | ១៤ | ១១៥.៦៥១.០៨៣ | ៤៦៥.៤៩៥.៦០៩ | ១៨៩.១០០.៤០៥ | ៧៧២.៤៧៥.១៥៤ |
| ប្រាក់បញ្ញើ ពីអតិថិជន | ១៥ | ១.១៤៤.៤០២.៧២៩ | ៤.៦០៦.២២០.៩៨៤ | ៩៩៤.៦១៥.៧២៨ | ៤.០៦៣.០០៥.២៤៩ |
| ប្រាក់កម្ចី | ១៦ | ៥១៧.៥៨០ | ២.០៨៣.២៦០ | ១.១៥២.០១៥ | ៤.៧០៥.៩៨១ |
| បំណុលបន្ទាប់បន្សំ | ១៧ | ៣២.៣១៨.៦៧៤ | ១៣០.០៨២.៦៦៣ | ៨៧.៤០៥.៥៩២ | ១៩៣.៦៥១.៨៤៣ |
| បំណុលភតិសន្យា | ៩ | ៤.៩០៦.១០៤ | ១៩.៧៤៧.០៦៩ | ៦.១៦៤.៩០០ | ២៥.១៨៣.៦១៧ |
| បំណុលពន្ធ លើប្រាក់ចំណូលប្រចាំឆ្នាំ | ៣០ក | ៤.០៩៣.៦៨០ | ១៦.៤៧៧.០៦២ | ៣.១៦២.០៦២ | ១២.៩១៧.០២៣ |
| អត្ថប្រយោជន៍និយោជិត | ១៨ | ៥.០៤៩.៤៥១ | ២០.៣២៤.០៤០ | ៤.១៥៥.៨១៨ | ១៦.៩៧៦.៥១៧ |
| បំណុលផ្សេងៗ | ១៩ | ១៣.៥៤៣.០៧៨ | ៥៤.៥១០.៨៨៩ | ១១.៦២០.១៤៩ | ៤៧.៤៦៨.៣០៨ |
| **ចំណុលសរុប** | | ១.៣២០.៤៨២.៣៧៩ | ៥.៣១៤.៩៤១.៥៧៦ | ១.២៥៧.៣៧៦.៦៦៩ | ៥.១៣៦.៣៨៣.៦៩២ |
| **មូលធន** | | | | | |
| ដើមទុន | ២០ | ៧៥.០០០.០០០ | ៣០១.៨៧៥.០០០ | ៧៥.០០០.០០០ | ៣០៦.៣៧៥.០០០ |
| ទុនបម្រុង សម្រាប់ការទូទាត់ ផ្អែកតាមភាគហ៊ុន | ២១ | ១.០៣៧.៥៣៨ | ៤.១៧៦.០៩០ | ៩១៩.២៥១ | ៣.៧៥៥.១៤០ |
| ប្រាក់ចំណេញរក្សាទុក | | ៦០.៨៤៤.៦៨៤ | ២៤៦.៨២៦.០៦២ | ៦៧.៣៩៩.០៣១ | ២៧៣.៥០៨.៨០៦ |
| ដើមទុនបម្រុង | ២២ | ៦៥.០០០.០០០ | ២៦១.៦២៥.០០០ | ៨២.០០០.០០០ | ១៧១.៥៧០.០០០ |
| ទុនបម្រុង តាមបទប្បញ្ញត្តិ | ២៣ | ១៨.៩៦៦.២៤០ | ៧៦.៣៣៩.១១៦ | ១៧.៧៩៥.៨៦៨ | ៧២.៦៩៦.១២១ |
| ទុនបម្រុងផ្សេងៗ | | - | (១.៩២៦.២០៩) | - | ១.៨១៦.២៣៦ |
| **មូលធនសរុប** | | ២២០.៨៤៨.៤៦២ | ៨៨៨.៩១៥.០៥៩ | ២០៣.១១៨.១៥០ | ៨២៩.៧២១.៣០៣ |
| **ចំណុល និងមូលធនសរុប** | | ១.៥៤១.៣៣០.៨៤១ | ៦.២០៣.៨៥៦.៦៣៥ | ១.៤៦០.៤៩០.៨១៩ | ៥.៩៦៦.១០៤.៩៩៥ |

កំណត់សម្គាល់ ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយ នៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍ចំណូលលម្អិត

សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| ចំណូលការប្រាក់ | ២៤ | **៨៩.៦០២.៣៣២** | **៣៦៤.៧៧១.០៩៤** | ៨១.៧៨០.២២៥ | ៣៣៦.១១៦.៧២៥ |
| ចំណាយការប្រាក់ | ២៤ | (៤៦.៦៥២.៣៨៧) | (១៨៩.៩២១.៨៦៧) | (៤៣.១២០.៩៩៣) | (១៧៧.២២៧.២៨១) |
| **ចំណូលការប្រាក់សុទ្ធ** | ២៤ | **៤២.៩៤៩.៩៤៥** | **១៧៤.៨៤៩.២២៧** | ៣៨.៦៥៩.២៣២ | ១៥៨.៨៨៩.៤៤៤ |
| ចំណូលកម្រៃ និងជើងសា | ២៥ | **៧.៥៩៦.៩១៣** | **៣០.៩២៧.០៣៣** | ៦.៩២៤.១៧២ | ២៨.៤៥៨.៣៤៧ |
| ចំណាយកម្រៃ និងជើងសា | ២៥ | (២.៥០០.២០១) | (១០.១៧៨.៣១៨) | (២.២៧៣.២៨២) | (៩.៣៤៣.១៨៩) |
| **ចំណូលកម្រៃ និងជើងសាសុទ្ធ** | ២៥ | **៥.០៩៦.៧១២** | **២០.៧៤៨.៧១៥** | ៤.៦៥០.៨៩០ | ១៩.១៩៥.១៥៨ |
| ចំណូលប្រតិបត្តិការផ្សេងៗ | | **២.២៣៣.៣៥៣** | **៩.០៩១.៩៨០** | ២.៤៧០.៨២៣ | ១០.១៥៥.០៨៣ |
| ខាតផ្សេងៗ - សុទ្ធ | | **២៨៥.៩៩៧** | **១.១៦៤.២៩៤** | (៨១.៤៣២) | (៣៣៤.៦៨៦) |
| **ចំណូលប្រតិបត្តិការសរុប** | | **២.៥១៩.៣៥០** | **១០.២៥៦.២៧៤** | ២.៣៨៩.៣៩១ | ៩.៨២០.៣៩៧ |
| ការខាតបង់ឥណទាន លើឱនភាពនៃតម្លៃ | ២៦ | (៤.០៨៩.០៤៣) | (១៦.៦៤៦.៤៩៤) | (៥០៨.៥៦៧) | (២.០៩០.២១០) |
| **(ខាត)/ចំណូលប្រតិបត្តិការសុទ្ធ** | | **(១.៥៦៩.៦៩៣)** | **(៦.៣៩០.២២០)** | ១.៨៨០.៨២៤ | ៧.៧៣០.១៨៧ |
| **ចំណាយ** | | | | | |
| ចំណាយបុគ្គលិក | ២៧ | (១៤.៣៦៦.២០២) | (៥៨.៤៨៤.៨០៨) | (១៣.៦៧៥.១០៥) | (៥៦.២០៤.៦៨២) |
| រំលស់ និងរំលស់ទ្រព្យសកម្មអរូបី | ២៨ | (៤.៦៣៦.២៥៣) | (១៨.៨៧៤.១៨៦) | (៤.៩៧២.៨៩៩) | (២០.៤៣៨.៦១៥) |
| ចំណាយប្រតិបត្តិការផ្សេងៗ | ២៩ | (៥.១៣៤.៣១៧) | (២០.៩០១.៨០៤) | (៥.៣៧៣.២៣៦) | (២២.០៨៤.០០០) |
| | | (២៤.១៣៦.៧៧២) | (៩៨.២៦០.៧៩៨) | (២៤.០២១.២៨០) | (៩៨.៧២៧.២៩៧) |
| **ចំណេញមុនបង់ពន្ធ លើប្រាក់ចំណូល** | | **២២.៣៤០.១៩២** | **៩០.៩៤៦.៩២៤** | ២១.១៦៥.៧០៦ | ៨៧.០០៧.៤៩២ |
| ចំណាយពន្ធ លើប្រាក់ចំណូល | ៣០ខ | (៤.៧២៤.១៦៧) | (១៩.២៣២.០៨៤) | (៤.៥៥៦.២៥៧) | (១៨.៧២៦.២១៦) |
| **ចំណេញ ក្នុងការិយបរិច្ឆេទ** | | **១៧.៦១៦.០២៥** | **៧១.៧១៤.៨៤០** | ១៦.៦១៣.៤៤៩ | ៦៨.២៨១.២៧៦ |
| **ខាតលម្អិតផ្សេងៗ៖** | | | | | |
| ខ្លង់ដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញ ក្នុងចំណេញ ឬខាត លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៣.៧៤២.៤៤៥) | - | (២.១៨៨.១១០) |
| **ចំណូលលម្អិតសរុប** | | **១៧.៦១៦.០២៥** | **៦៧.៩៧២.៣៩៥** | ១៦.៦១៣.៤៤៩ | ៦៦.០៩៣.១៦៦ |
| **ចំណេញបែងចែកទៅ៖** | | | | | |
| ម្ចាស់ធនាគារ | | **១៧.៦១៦.០២៥** | **៧១.៧១៤.៨៤០** | ១៦.៦១៣.៤៤៩ | ៦៨.២៨១.២៧៦ |
| **ចំណូលលម្អិតសរុបបែងចែកទៅ៖** | | | | | |
| ម្ចាស់ធនាគារ | | **១៧.៦១៦.០២៥** | **៦៧.៩៧២.៣៩៥** | ១៦.៦១៣.៤៤៩ | ៦៦.០៩៣.១៦៦ |

កំណត់សម្គាល់ ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយ នៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | ដើមទុន | | ទុនបម្រុង សម្រាប់ការទូទាត់ ផ្អែកតាមភាគហ៊ុន | | ប្រាក់ចំណេញរក្សាទុក | | ដើមទុនបម្រុង | | ទុនបម្រុង តាមបទប្បញ្ញត្តិ | | ទុនបម្រុងផ្សេងៗ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារ អាមេរិក | ពាន់ រៀល | ដុល្លារ អាមេរិក | ពាន់ រៀល | ដុល្លារ អាមេរិក | ពាន់ រៀល | ដុល្លារ អាមេរិក | ពាន់ រៀល | ដុល្លារ អាមេរិក | ពាន់ រៀល | ដុល្លារ អាមេរិក | ពាន់ រៀល | ដុល្លារ អាមេរិក | ពាន់ រៀល |
| | (កំណត់សម្គាល់ ២.៣) | | (កំណត់សម្គាល់ ២.៣) | | (កំណត់សម្គាល់ ២.៣) | | (កំណត់សម្គាល់ ២.៣) | | (កំណត់សម្គាល់ ២.៣) | | (កំណត់សម្គាល់ ២.៣) | | (កំណត់សម្គាល់ ២.៣) | |
| **សមតុល្យ គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៤** | ៧៥.០០០.០០០ | ៣០៦.៣៧៥.០០០ | ៩១៩.២៥១ | ៣.៧៥៥.១៤០ | ៦៧.៣៩៩.០៣១ | ២៧៣.៥០៨.៨០៦ | ៤២.០០០.០០០ | ១៧១.៥៧០.០០០ | ១៧.៧៩៥.៨៦៨ | ៧២.៦៩៦.១២១ | - | ១.៨១៦.២៣៦ | ២០៣.១១៤.១៥០ | ៨២៩.៧២១.៣០៣ |
| ចំណេញ ក្នុងការិយបរិច្ឆេទ | - | - | - | - | ១៧.៦១៦.០២៥ | ៧១.៧១៤.៨៤០ | - | - | - | - | - | - | ១៧.៦១៦.០២៥ | ៧១.៧១៤.៨៤០ |
| **ការទូទាត់ ផ្អែកតាមភាគហ៊ុន៖** | | | | | | | | | | | | | | |
| តម្លៃ នៃការបម្រើការងារ របស់និយោជិត | - | - | ១១៨.២៨៧ | ៤៨១.៥៤៦ | - | - | - | - | - | - | - | - | ១១៨.២៨៧ | ៤៨១.៥៤៦ |
| **ការផ្ទេរទៅដើមទុនបម្រុង (កំណត់សម្គាល់ ២២)** | - | - | - | - | (២៣.០០០.០០០) | (៩៣.៦៣៣.០០០) | ២៣.០០០.០០០ | ៩៣.៦៣៣.០០០ | - | - | - | - | - | - |
| **ការផ្ទេរ ទៅទុនបម្រុង តាមបទប្បញ្ញត្តិ (កំណត់សម្គាល់ ២៣)** | - | - | - | - | (១.៩៧០.៣៧២) | (៨.៧៦៤.៥៨៨) | - | - | ១.៩៧០.៣៧២ | ៨.៧៦៤.៥៨៨ | - | - | - | - |
| **លម្អៀងពីការប្តូរប្រាក់បរទេស** | - | (៤.៥០០.០០០) | - | (៦០.៥៩៦) | - | - | - | (៣.៥៧៨.០០០) | - | (១.៩២១.៥៩៩) | - | (៣.៧៤២.៤៨៥) | - | (១៣.០០២.៦៣០) |
| **សមតុល្យ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | ៧៥.០០០.០០០ | ៣០១.៨៧៥.០០០ | ១.០៣៧.៥៣៨ | ៤.១៧៦.០៩០ | ៦០.៨៨៤.៦៨៤ | ២៨៦.៨២៦.០៦២ | ៦៥.០០០.០០០ | ២៦១.៦២៤.០០០ | ១៨.៩៦៦.២៨០ | ៧៦.៣៣៩.១១៦ | - | (១.៩២៦.២០៩) | ២២០.៨៨៨.៤៦២ | ៨៨៩.៩១៥.០៩៩ |
| **សមតុល្យ គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ៧៥.០០០.០០០ | ៣០៨.៧៧៥.០០០ | ៥៧៦.០២២ | ២.៣៧១.៨៨៣ | ៧១.៨៧៦.៣៣៨ | ២៩១.៩១០.៥៣៧ | ២៥.៥០០.០០០ | ១០៨.៩៨៣.៥០០ | ១៣.២០៥.១១២ | ៥៨.៣៦៥.៨៨៦ | - | ៨.០០៤.៣៨៦ | ១៨៦.១៥៧.៨៧២ | ៧៦៦.៨១០.៣១២ |
| ចំណេញ ក្នុងការិយបរិច្ឆេទ | - | - | - | - | ១៦.៦១៣.៨៨៩ | ៦៨.២៨១.២៧៦ | - | - | - | - | - | - | ១៦.៦១៣.៨៨៩ | ៦៨.២៨១.២៧៦ |
| **ការទូទាត់ ផ្អែកតាមភាគហ៊ុន៖** | | | | | | | | | | | | | | |
| តម្លៃ នៃការបម្រើការងារ របស់និយោជិត | - | - | ៣៨៣.២២៩ | ១.៨១០.៦៧១ | - | - | - | - | - | - | - | - | ៣៨៣.២២៩ | ១.៨១០.៦៧១ |
| **ការផ្ទេរទៅដើមទុនបម្រុង (កំណត់សម្គាល់ ២២)** | - | - | - | - | (១៦.៥០០.០០០) | (៦៧.៨១៥.០០០) | ១៦.៥០០.០០០ | ៦៧.៨១៥.០០០ | - | - | - | - | - | - |
| **ការផ្ទេរ ទៅទុនបម្រុង តាមបទប្បញ្ញត្តិ (កំណត់សម្គាល់ ២៣)** | - | - | - | - | (៤.៥៩០.៧៥៦) | (១៨.៨៦៨.០០៧) | - | - | ៤.៥៩០.៧៥៦ | ១៨.៨៦៨.០០៧ | - | - | - | - |
| **លម្អៀងពីការប្តូរប្រាក់បរទេស** | - | (២.៨០០.០០០) | - | (២៧.០១៨) | - | - | - | (១.២២៨.៥០០) | - | (៥៣៧.៣៣២) | - | (២.១៨៨.១១០) | - | (៦.៣៨០.៥៥៦) |
| **សមតុល្យ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | ៧៥.០០០.០០០ | ៣០៦.៣៧៥.០០០ | ៩១៩.២៥១ | ៣.៧៥៥.១៤០ | ៦៧.៣៩៩.០៣១ | ២៧៣.៥០៨.៨០៦ | ៤២.០០០.០០០ | ១៧១.៥៧០.០០០ | ១៧.៧៩៥.៨៦៨ | ៧២.៦៩៦.១២១ | - | ១.៨១៦.២៣៦ | ២០៣.១១៤.១៥០ | ៨២៩.៧២១.៣០៣ |

កំណត់សម្គាល់ ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយ នៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| **លំហូរសាច់ប្រាក់ ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់ ពីប្រតិបត្តិការ | ៣២ក | **៥៧.៦៣៦.៤៣០** | **២៣៤.៦៣៧.៩០៩** | ១៣៦.៨៤២.៨១៤ | ៥៦២.៤២៣.៩៦៤ |
| ការប្រាក់បានទទួល | | **៨៧.៥៦០.១០៥** | **៣៥៦.៤៥៧.១៨៧** | ៨១.៤១៣.០៧០ | ៣៣៤.៦០៧.៧១៨ |
| ការប្រាក់បានបង់ | | **(១៨.៤៣៩.៦៥៥)** | **(៧៥.០៦៧.៨៣៦)** | (៣៤.៨១៧.៦៦៨) | (១៤៣.១០០.៦១៥) |
| ពន្ធលើប្រាក់ចំណូលបានបង់ | ៣០ | **(៤.២០៣.៧៤៥)** | **(១៧.១១៣.៤៤៦)** | (៦.៣៩៦.៧១៦) | (២៦.២៩០.៥០៣) |
| ប្រាក់សោធនរបស់បុគ្គលិកបានបង់ | ១៨ | **(១៣៥.២០៧)** | **(៥៥០.៤២៨)** | (២៥៩.៥៦២) | (១.០៦៦.៨០០) |
| ប្រាក់ចំណាត់អតីតភាពការងារបានបង់ | ១៨ | **(២៩.៩០៤)** | **(១២១.៧៣៩)** | (៣៩.៤០៧) | (១៦១.៩៦៣) |
| **សាច់ប្រាក់សុទ្ធ ពីសកម្មភាពប្រតិបត្តិការ** | | **១២២.៣៨៨.០២៤** | **៤៩៨.២៤១.៦៤៧** | ១៧៦.៧៤២.៥៣១ | ៧២៦.៤១១.៨០១ |
| **លំហូរសាច់ប្រាក់ ពីសកម្មភាពវិនិយោគ** | | | | | |
| មូលបត្រអាចជួញដូរបាន | | - | - | ៥.២៣០.០០០ | ២១.៤៩៥.៣០០ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ - មានកាលកំណត់លើសបីខែ | | - | - | - | - |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | | **(៧៩៥.៥១២)** | **(៣.២៣៨.៥២៩)** | (១.៤២៩.១៧៣) | (៥.៨៧៣.៩០១) |
| ការទិញទ្រព្យសកម្មអរូបី | | **(៩៨៧.៣៧៨)** | **(៣.៨៥៦.៧៧៦)** | (៦៨៤.៤៥២) | (២.៨១៣.០៩៨) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | - | - | ៤៤.៧២៤ | ១៨៣.៨១៦ |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុង/ពីសកម្មភាពវិនិយោគ** | | **(១.៧៤២.៨៩០)** | **(៧.០៩៥.៣០៥)** | ៣.១៦១.០៩៩ | ១២.៩៩២.១១៧ |
| **លំហូរសាច់ប្រាក់ ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | ១៦ | **(៦៣៤.៤៣៥)** | **(២.៥៨២.៧៨៥)** | (២០.២៧៩.០៧០) | (៨៣.៣៨៦.៩៧៨) |
| ការទូទាត់សងប្រាក់កម្ចី | ១៧ | **(១៥.០០០.០០០)** | **(៦១.០៦៥.០០០)** | - | - |
| ការទូទាត់ភតិសន្យាជាប្រាក់ដើម | ៩ | **(១.៧៦៩.៩៧៨)** | **(៧.២០៥.៥៨០)** | (១.៧២៧.២១១) | (៧.០៩៨.៨៣៧) |
| **សាច់ប្រាក់សុទ្ធបានប្រើ ក្នុងសកម្មភាពហិរញ្ញប្បទាន** | | **(១៧.៤០៤.៤១៣)** | **(៧០.៨៥៣.៣៦៥)** | (២២.០០៦.២៨១) | (៩០.៤៤៥.៨១៥) |
| **កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **១០៣.២៤០.៧២១** | **៤២០.២៩២.៩៧៧** | ១៥៧.៨៩៧.៣៨៩ | ៦៨៨.៩៥៨.១០៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ | | **៣៨២.៧៥៨.១៣៥** | **១.៥៦៣.៥៦៦.៩៨០** | ២២៤.៨៦០.៧៨៦ | ៩២៥.៧៥១.៨៥៧ |
| លម្អៀងពីការប្តូរប្រាក់ | | - | **(២៧.៧១៤.៥៦៥)** | - | (១១.១៤២.៩៨០) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | ៣១ | **៤៨៥.៩៩៨.៨៥៦** | **១.៩៥៦.១៨៥.៣៩២** | ៣៨២.៧៥៨.១៣៥ | ១.៥៦៣.៥៦៦.៩៨០ |

កំណត់សម្គាល់ ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយ នៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ការលាតត្រដាងសកម្មភាពវិនិយោគ និងហិរញ្ញប្បទានមិនមែនជាសាច់ប្រាក់ ក្នុងកំណត់សម្គាល់គឺ៖

- ការបន្ថែមសិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម និងបំណុលភតិសន្យា ក្នុងកំណត់សម្គាល់៩។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## ១. ព័ត៌មានទូទៅ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចុះបញ្ជី នៅក្នុងប្រទេសកម្ពុជា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ដោយមានវិញ្ញាបនបត្រ ចុះបញ្ជីលេខ ០០០១០៥២៤ ចេញដោយក្រសួងពាណិជ្ជកម្ម និងបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០។ ធនាគារ គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលកាន់កាប់ទាំងស្រុង ដោយ CIMB Bank Berhad ដែលជាធនាគារមានអាជ្ញាប័ណ្ណចុះបញ្ជីអាជីវកម្ម នៅប្រទេសម៉ាឡេស៊ី។ ក្រុមហ៊ុន CIMB Group Holdings Berhad ជាធនាគារចុះបញ្ជីលក់មូលបត្រ ដែលធ្វើប្រតិបត្តិការ នៅប្រទេសម៉ាឡេស៊ី គឺជាក្រុមហ៊ុនមេចុងក្រោយ។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺផ្តល់សេវាធនាគារគ្រប់ប្រភេទ និងផ្តល់សេវាផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។ ធនាគារបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មធនាគារ ដែលចេញដោយធនាគារជាតិ នៃកម្ពុជា (ហៅកាត់ថា NBC ឬធនាគារកណ្តាល) នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០។

ការិយាល័យចុះបញ្ជីរបស់ធនាគារ មានទីតាំងស្ថិតនៅផ្ទះលេខ៦០ មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## ២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត

កំណត់សម្គាល់នេះ ផ្តល់នូវបញ្ជី នៃព័ត៌មាន អំពីគោលនយោបាយគណនេយ្យជាសារវន្ត ដែលបានប្រើប្រាស់ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ គោលនយោបាយទាំងនេះ ត្រូវបានអនុវត្តយ៉ាងមានសង្គតិភាពគ្រប់ឆ្នាំ ដែលបានបង្ហាញទាំងអស់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ២.១ មូលដ្ឋាន នៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដារគណនេយ្យ នៃស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ដែលអនុម័តដោយនិយ័តករគណនេយ្យ និងសវនកម្មនៃកម្ពុជា ដោយផ្អែកលើស្តង់ដារគណនេយ្យ នៃស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយ ដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (IASB)។

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំ ក្រោមអនុសញ្ញាថ្លៃដើមប្រវត្តិសាស្ត្រ។

ធនាគារលាតត្រដាងសមតុល្យ សម្រាប់ទ្រព្យសកម្ម និងបំណុលនីមួយៗ ដែលរំពឹងថាត្រូវប្រមូលមកវិញ ឬត្រូវទូទាត់ ក្នុងរយៈពេលមិនលើស១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ជារយៈពេលខ្លី ហើយសមតុល្យ ដែលលើសពី១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ជារយៈពេលវែង។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលស្របទៅតាមស្តង់ដារគណនេយ្យ នៃស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់សំខាន់ៗ។ ហើយវាក៏តម្រូវឱ្យគណៈគ្រប់គ្រង ធ្វើការវិនិច្ឆ័យ នៅក្នុងដំណើរការ នៃការអនុវត្តគោលនយោបាយ គណនេយ្យនេះផងដែរ។ ផ្នែក ដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញកម្រិតខ្ពស់ ឬផ្នែក ដែលការសន្មត និងការប៉ាន់ស្មាន មានលក្ខណៈជាសារវន្ត ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាង នៅក្នុងកំណត់សម្គាល់ ៣។

របាយការណ៍ហិរញ្ញវត្ថុ ជាភាសាអង់គ្លេស ត្រូវបានរៀបចំឡើងចេញពីរបាយការណ៍ហិរញ្ញវត្ថុជាភាសាខ្មែរ។ ក្នុងករណីមិនមានសង្គតិភាព ឬមានភាពខុសគ្នា ក្នុងការបកស្រាយ រវាងភាសាទាំងពីរនោះត្រូវយករបាយការណ៍ហិរញ្ញវត្ថុ ជាភាសាខ្មែរជាគោល។

### ២.២ ស្តង់ដារគណនេយ្យថ្មី និងចំណេកស្រាយ

#### i) ស្តង់ដារថ្មី និងស្តង់ដារ ដែលបានធ្វើវិសោធនកម្ម ដែលអនុវត្តដោយធនាគារ

ធនាគារបានអនុវត្តស្តង់ដារ និងវិសោធនកម្ម ជាលើកដំបូង ចំពោះរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទ ដែលចាប់ផ្តើម នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៤៖

- ការធ្វើចំណាត់ថ្នាក់ លើបំណុលរយៈពេលខ្លី ឬរយៈពេលវែង (វិសោធនកម្ម ទៅលើ CIAS ១)
- បំណុលភតិសន្យា ក្នុងការលក់ និងការជួលត្រឡប់ (វិសោធនកម្ម ទៅលើ CIFRS ១៦)
- ការរៀបចំហិរញ្ញវត្ថុរបស់អ្នកផ្គត់ផ្គង់ (វិសោធនកម្ម ទៅលើ CIAS ៧ និង CIFRS ៧)
- កិច្ចព្រមព្រៀងបំណុលរយៈពេលវែង (វិសោធនកម្ម ទៅលើ CIAS ១)

វិសោធនកម្ម ដែលបានរៀបរាប់ខាងលើ ពុំមានផលប៉ះពាល់ណាមួយ ទៅលើសមតុល្យ ដែលបានទទួលស្គាល់ ក្នុងការិយបរិច្ឆេទមុន និងមិនរំពឹងថា មានផលប៉ះពាល់ខ្លាំង សម្រាប់ការិយបរិច្ឆេទនេះ និងការិយបរិច្ឆេទ នាពេលអនាគតនោះទេ។

#### ii) ស្តង់ដារថ្មី និងការបកស្រាយ ដែលមិនទាន់បានអនុវត្ត ដោយធនាគារ

នាកាលបរិច្ឆេទ នៃការអនុម័ត លើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ស្តង់ដារគណនេយ្យថ្មី និងស្តង់ដារគណនេយ្យ ដែលបានកែតម្រូវ ដែលត្រូវបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព ហើយមិនទាន់បានអនុវត្តជាមុន ដោយធនាគារ មានដូចខាងក្រោម៖

- កង្វះខាតលទ្ធភាព ក្នុងការផ្លាស់ប្តូរ (វិសោធនកម្មទៅលើ CIAS ២១)
- វិសោធនកម្ម លើចំណាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ (វិសោធនកម្ម ទៅលើ CIFRS ៩ និង ៧)
- IFRS ១៨ ការបង្ហាញ និងការលាតត្រដាង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- IFRS ១៩ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមិនមានគណនេយ្យភាពសាធារណៈ៖ ការលាតត្រដាង

ការធ្វើវិសោធនកម្មទាំងនេះ មិនត្រូវបានរំពឹងទុកថា នឹងបង្កឱ្យមានផលប៉ះពាល់សំខាន់ៗ ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្នុងការិយបរិច្ឆេទ នៃការអនុវត្តដំបូងទេ ដូច្នេះហើយការលាតត្រដាង មិនត្រូវបានធ្វើឡើងឡើយ។

### ២.៣ ការប្តូរូបិយប័ណ្ណ

#### i) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណ សម្រាប់បង្ហាញ

សមាសធាតុ ដែលបានរាប់បញ្ចូល ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិបទសេដ្ឋកិច្ចចម្បង ដែលធនាគារធ្វើប្រតិបត្តិការ (រូបិយប័ណ្ណមុខងារ)។ រូបិយប័ណ្ណមុខងារ គឺជាប្រាក់ដុល្លារអាមេរិក ឆ្លុះបញ្ចាំងសេដ្ឋកិច្ច នៃព្រឹត្តិការណ៍ និងស្ថានភាពរបស់ធនាគារ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណ សម្រាប់បង្ហាញរបស់ធនាគារ។

#### ii) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណ ក្រៅពីប្រាក់ដុល្លារអាមេរិក គឺត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់ នាកាលបរិច្ឆេទ នៃប្រតិបត្តិការនោះ។ ចំណេញ និងខាត ពីការប្តូររូបិយប័ណ្ណបរទេស ដែលជាលទ្ធផល ពីការទូទាត់ប្រតិបត្តិការ និងពីការប្តូរទ្រព្យសកម្ម និងបំណុលជារូបិយវត្ថុ ដែលកំណត់ដោយរូបិយប័ណ្ណ ក្រៅពីប្រាក់ដុល្លារអាមេរិក នាចុងការិយបរិច្ឆេទ នៃអត្រាប្តូរប្រាក់ ត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

#### iii) ការបង្ហាញជាប្រាក់រៀល

អនុលោមតាមច្បាប់ ស្តីពីគណនេយ្យ និងសវនកម្ម របាយការណ៍ហិរញ្ញវត្ថុ ត្រូវបង្ហាញជាប្រាក់រៀលខ្មែរ។ របាយការណ៍ចំណូលលទ្ធិត និងរបាយការណ៍លំហូរសាច់ប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀលខ្មែរ ដោយប្រើអត្រាប្តូរប្រាក់ជាមធ្យម សម្រាប់ការិយបរិច្ឆេទ។ ទ្រព្យសកម្ម និងបំណុល សម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ ដែលបានបង្ហាញ មូលធនរបស់ភាគទុនិក និងទុនបម្រុងត្រូវបានប្តូរ តាមអត្រាប្តូរប្រាក់ចុងគ្រា នាកាលបរិច្ឆេទ នៃរបាយការណ៍។ លម្អៀងពីការប្តូររូបិយប័ណ្ណទាំងអស់ ដែលកើតមកពីការប្តូរមូលធនរបស់ភាគទុនិក និងទុនបម្រុង ត្រូវបានទទួលស្គាល់ដោយផ្ទាល់ ក្នុងមូលធន ហើយលម្អៀង ពីការប្តូររូបិយប័ណ្ណទាំងអស់ផ្សេងៗទៀត ត្រូវបានទទួលស្គាល់ នៅក្នុងចំណូលលទ្ធិតផ្សេងៗ។

ធនាគារបានប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការ ដែលចេញផ្សាយដោយធនាគារជាតិ នៃកម្ពុជា។ គិតត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ គឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៧១រៀល (ឆ្នាំ២០២៣៖ ១ដុល្លារអាមេរិក ស្មើនឹង ៤.១១០រៀល) ហើយអត្រាប្តូរប្រាក់ចុងគ្រា គឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០២៥រៀល (ឆ្នាំ២០២៣៖ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៨៥រៀល)។

#### iv) ការបង្គត់តួលេខ

សមតុល្យប្រាក់រៀលខ្មែរទាំងអស់ ដែលបានបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់ ត្រូវបានបង្គត់ឱ្យកៀកបំផុត ទៅនឹងឯកតារូបិយប័ណ្ណជាពាន់រៀល លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

## ២.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់គោលបំណង នៃការបង្ហាញ នៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើ ដែលមិនមានការរឹតត្បិត និងប្រាក់តម្កល់ នៅធនាគារជាតិ នៃកម្ពុជា និងនៅធនាគារផ្សេងៗ ព្រមទាំងការវិនិយោគរយៈពេលខ្លី ដែលមានកាលកំណត់ ៣ខែ ឬតិចជាងនេះ ដែលធនាគារអាចមានលទ្ធភាពពេញលេញ ក្នុងការដកសាច់ប្រាក់ ក្នុងគោលបំណងទូទៅ នៅពេលដែលមានតម្រូវការ ហើយប្រឈមតិច ចំពោះហានិភ័យ នៃការផ្លាស់ប្តូរតម្លៃ។

ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល និងនៅធនាគារផ្សេងៗ ត្រូវបានយោងតាមថ្លៃដើមបានរំលស់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ឥណទានវិចារូបន៍ ត្រូវបានបង្ហាញជាប្រាក់កម្ចី ក្នុងបំណុលរយៈពេលខ្លី នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ២.៥ ទ្រព្យសកម្មហិរញ្ញវត្ថុ

### i) ការធ្វើចំណាត់ថ្នាក់

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ថ្នាក់ តាមការវាស់វែង៖ រំលស់ថ្លៃដើមតម្លៃ សមស្របតាមរយៈចំណូលលម្អិតផ្សេងៗ (FVOCI) ឬតម្លៃសមស្រប តាមរយៈគណនីចំណេញ ឬខាត (FVTPL)។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែង តាមរំលស់ថ្លៃដើម ប្រសិនបើវាបំពេញទៅនឹងលក្ខខណ្ឌដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្ម ដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកទ្រព្យសកម្ម ដើម្បីធ្វើការប្រមូលលំហូរសាច់ប្រាក់ តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យា របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ ចំពោះលំហូរសាច់ប្រាក់ សម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (SPPI)។

ឧបករណ៍បំណុល ត្រូវបានវាស់វែងតាម FVOCI លុះត្រាតែវាបានបំពេញ តាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្ម ដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុក ដើម្បីការប្រមូលសាច់ប្រាក់ តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យា របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ ចំពោះលំហូរសាច់ប្រាក់ ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ SPPI។

សម្រាប់ការទទួលស្គាល់ការវិនិយោគ លើមូលធនជាលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរធនាគារ អាចជ្រើសរើសការបង្ហាញការប្រែប្រួល នាពេលបន្ទាប់ ចំពោះតម្លៃសមស្របតាមរយៈលទ្ធផលលម្អិតផ្សេងៗ (OCI)។ ការជ្រើសរើសនេះធ្វើឡើង ដោយផ្អែកលើមូលដ្ឋាន នៃការវិនិយោគនីមួយៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀត ដែលត្រូវបានចាត់ថ្នាក់ តាមការវាស់វែងតាម FVTPL។

លើសពីនេះ សម្រាប់ការទទួលស្គាល់ជាលើកដំបូង ធនាគារអាចនឹងកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបំពេញតាមលក្ខខណ្ឌ ក្នុងការវាស់វែង តាមរំលស់ថ្លៃដើម ឬតាម FVOCI ប្រសិនបើវាស់វែង តាម FVTPL នឹងលុបបំបាត់ ឬកាត់បន្ថយជាសារវន្ត នូវភាពមិនស៊ីគ្នា នៃគណនេយ្យ ដែលនឹងកើតឡើង។

### ii) ការវាយតម្លៃម៉ូដែលអាជីវកម្ម

ធនាគារធ្វើការវាយតម្លៃ អំពីគោលបំណង នៃគំរូអាជីវកម្ម លើទ្រព្យសកម្ម ក្នុងកម្រិតសំណុំឥណទាននីមួយៗ ព្រោះគំរូនេះបង្ហាញយ៉ាងច្បាស់ ពីវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មាន ទៅគណៈគ្រប់គ្រង។ ព័ត៌មានទាំងនោះ រួមមាន៖

- គោលនយោបាយ និងគោលបំណង ដែលបានបញ្ជាក់ សម្រាប់សំណុំឥណទាន និងអនុវត្តប្រតិបត្តិការ នូវគោលនយោបាយទាំងនោះ។ ជាពិសេស ថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ផ្តោតលើការរំស្វែងរកចំណូលការប្រាក់ តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឱ្យស៊ីសង្វាក់គ្នា រវាងរយៈពេល នៃទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនឹងរយៈពេលនៃបំណុល ដែលជាមូលនិធិរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឱ្យមានលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម។
- វិធី ក្នុងការវាយតម្លៃលទ្ធផល នៃសំណុំឥណទាន និងវិធីរាយការណ៍ ទៅគណៈគ្រប់គ្រងរបស់ធនាគារ
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលនៃគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រ សម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀប ដែលគណៈគ្រប់គ្រងអាជីវកម្ម ទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់សំណង ផ្អែកលើតម្លៃសមស្រប នៃទ្រព្យសកម្ម ដែលបានគ្រប់គ្រង ឬលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងរយៈពេល នៃការលក់ ក្នុងគ្រាមុន មូលហេតុ នៃការលក់នោះ និងការរំពឹងទុក អំពីសកម្មភាពលក់ នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់ មិនត្រូវបានចាត់ទុកថា ដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយ នៃការវាយតម្លៃទូទៅ អំពីរបៀប ដែលធ្វើឱ្យសម្រេចបាននូវគោលបំណង ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ បានយ៉ាងត្រឹមត្រូវ។

ទ្រព្យសកម្មហិរញ្ញវត្ថុ សម្រាប់ការជួញដូរ ឬចាត់ចែង និងជាលទ្ធផល ត្រូវបានវាយតម្លៃ តាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះ មិនមែនសម្រាប់ប្រមូលលំហូរសាច់ប្រាក់ តាមកិច្ចសន្យា ឬមិនមែនសម្រាប់ទាំងការប្រមូលលំហូរសាច់ប្រាក់ តាមកិច្ចសន្យា និងសម្រាប់លក់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះឡើយ។

### iii) ការវាយតម្លៃថាតើលំហូរសាច់ប្រាក់ តាមកិច្ចសន្យា គឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់

ចំពោះគោលបំណង នៃការវាយតម្លៃនេះ «ប្រាក់ដើម» គឺជាតម្លៃសមស្រប នៃទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលទទួលស្គាល់ជាលើកដំបូង។ «ការប្រាក់» គឺជាតម្លៃតបស្នងមួយ សម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យឥណទាន ដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើម នៅជាប់ជំពាក់ ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ការចំណាយ រួមទាំងហានិភ័យ ក្នុងការផ្តល់កម្ចី ជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) រួមទាំងអត្រាប្រាក់ចំណេញ។

ធនាគារពិចារណា ទៅលើលក្ខខណ្ឌកិច្ចសន្យា របស់ឧបករណ៍ហិរញ្ញវត្ថុ ដើម្បីវាយតម្លៃថាតើសាច់ប្រាក់តាមកិច្ចសន្យា គឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ដែរឬទេ។ វារួមបញ្ចូលការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យា ដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលមិនអាចបំពេញ តាមលក្ខខណ្ឌ នៃការទូទាត់តែប្រាក់ដើម និងការប្រាក់។

ក្នុងការវាយតម្លៃ ធនាគារពិចារណា ទៅលើ៖

- ព្រឹត្តិការណ៍ជាយថាភាព ដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេល នៃលំហូរសាច់ប្រាក់
- លក្ខខណ្ឌពិសេសជាអានុភាព
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យារពេលសង
- លក្ខខណ្ឌ ដែលកម្រិតធនាគារ ក្នុងការទាមទារមកវិញ នូវលំហូរសាច់ប្រាក់ ពីទ្រព្យសកម្មជាក់លាក់ (ដូចជាឥណទាន ដែលមិនអាចប្រមូលមកវិញបាន) និង
- លក្ខណៈពិសេស ដែលកែប្រែតម្លៃតបស្នង សម្រាប់ពេលវេលា នៃការប្រើប្រាស់ទឹកប្រាក់ (ឧទាហរណ៍ការកំណត់អត្រាការប្រាក់ឡើងវិញ តាមកាលកំណត់)។

### iv) ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ នៅពេលដែលធនាគារក្លាយជាភាគីមួយ ក្នុងកិច្ចសន្យានៃឧបករណ៍ណាមួយ។ ការទិញ និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ តាមមធ្យោបាយធម្មតា ត្រូវបានទទួលស្គាល់ នាកាលបរិច្ឆេទជួញដូរ ជាកាលបរិច្ឆេទ ដែលធនាគារធ្វើការទិញ ឬលក់ទ្រព្យសកម្មនោះ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលសិទ្ធិ ក្នុងការទទួលលំហូរសាច់ប្រាក់ ពីទ្រព្យសកម្មនោះ បានហួសកាលកំណត់ ឬត្រូវបានផ្ទេរ ហើយធនាគារបានផ្ទេរនូវរាល់ហានិភ័យជាសារវន្ត និងផលកម្មសិទ្ធិទាំងអស់។ ចំណេញ ឬខាត ពីការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែង តាមថ្លៃដើមបានរំលស់ ត្រូវបានទទួលស្គាល់ នៅក្នុងចំណេញ ឬខាត នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានគេឈប់ទទួលស្គាល់។

**v) ការវាស់វែង**

នាពេលទទួលស្គាល់លើកដំបូង ធនាគារវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ តាមតម្លៃសមស្របបូកបន្ថែមជាមួយនឹងចំណាយប្រតិបត្តិការផ្សេងៗ ដែលបានចំណាយផ្ទាល់ ក្នុងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុ មិនត្រូវបានវាស់វែង តាមតម្លៃសមស្រប ក្នុងចំណេញ ឬខាត (FVPL)។ ចំណាយប្រតិបត្តិការ នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកត់ត្រា តាម FVPL ត្រូវបានកត់ត្រាជាចំណាយ ក្នុងចំណេញ ឬខាត។ បន្ទាប់ពីការទទួលស្គាល់លើកដំបូងភ្លាម សំវិធានធនសម្រាប់ឱនភាព នៃតម្លៃតំណាងនំរឹងទុក (ECL) ត្រូវបានទទួលស្គាល់ សម្រាប់ទ្រព្យសកម្ម ដែលត្រូវបានវាស់វែង តាមថ្លៃដើមបានរំលស់ ដែលនាំឱ្យមានការខាតបង់គណនេយ្យ ដែលត្រូវបានទទួលស្គាល់ ក្នុងចំណេញ ឬខាត នៅពេលទ្រព្យសកម្មមួយ ត្រូវបានបង្កើតឡើងថ្មី។

ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានដេរីវេទីវ ត្រូវបានគេគិតទៅលើចំនួនរបស់វាទាំងស្រុង នៅពេលធ្វើការកំណត់លំហូរសាច់ប្រាក់របស់វា សម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់។

**ឧបករណ៍ចំណុល**

ការវាស់វែងឧបករណ៍ចំណុល គឺអាស្រ័យទៅលើគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្ម និងលក្ខណៈ នៃលំហូរសាច់ប្រាក់ របស់ទ្រព្យសកម្មនោះ។ ធនាគារធ្វើចំណាត់ថ្នាក់ឧបករណ៍ចំណុលរបស់ខ្លួន ជាទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានវាស់វែង តាមថ្លៃដើមបានរំលស់។

ថ្លៃដើមបានរំលស់៖ ទ្រព្យសកម្ម ដែលត្រូវបានកាន់កាប់ សម្រាប់ការប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា ដែលលំហូរសាច់ប្រាក់នោះ គឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ (SPPI) ត្រូវបានវាស់វែង តាមថ្លៃដើមបានរំលស់។ តម្លៃយោង នៃទ្រព្យសកម្មទាំងនេះ ត្រូវបានកែតម្រូវទៅតាមសំវិធានធន សម្រាប់ការខាតបង់តំណាងនំរឹងទុក ដែលបានទទួលស្គាល់។ ចំណូលការប្រាក់ ដែលបានពីទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុងចំណូលការប្រាក់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

ចំពោះតំណាងផ្តល់ឱ្យបុគ្គលិក សម្រាប់ទិញផ្ទះ ដែលមានអត្រាការប្រាក់ទាបជាងអត្រាទីផ្សារ ត្រូវបានទទួលស្គាល់លើកដំបូង តាមតម្លៃបច្ចុប្បន្ន នៃការទូទាត់សាច់ប្រាក់ នាពេលអនាគត និងធ្វើអប្បហារ តាមអត្រាការប្រាក់ លើទីផ្សារ នៃតំណាងប្រហាក់ប្រហែលគ្នា។ ចំនួនលម្អៀង រវាងសាច់ប្រាក់បានបង់ និងតម្លៃបច្ចុប្បន្ន នៃសាច់ប្រាក់ត្រូវទទួល ក្នុងពេលអនាគត ត្រូវបានទទួលស្គាល់ជាបុរេប្រទានអត្ថប្រយោជន៍និយោជិត ក្នុងខ្នង់ទ្រព្យសកម្មផ្សេងៗ។

**vi) ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ**

ធនាគារធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ នៅពេលដែលគំរូអាជីវកម្ម សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មរបស់ខ្លួន មានការប្រែប្រួល។

**vii) ឱនភាព នៃតម្លៃទ្រព្យសម្បត្តិហិរញ្ញវត្ថុ**

ធនាគារវាយតម្លៃការខាតតំណាងនំរឹងទុក (ECL) តាមមូលដ្ឋាននំរឹងមើល ទៅថ្ងៃអនាគត ដែលទាក់ទងជាមួយនឹងឧបករណ៍ចំណុលរបស់ខ្លួន ដែលវាស់វែងតាមថ្លៃដើមបានរំលស់ ព្រមទាំងហានិភ័យ ដែលកើតពីកិច្ចសន្យាផ្តល់តំណាង (រួមទាំងតំណាងវិបារូបន៍មិនបានដក និងហ្វាស៊ីលីធី ដែលអាចប្រើប្រាស់ឡើងវិញ) និងកិច្ចសន្យាធានា ផ្នែកហិរញ្ញវត្ថុ។ ធនាគារទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ ចំពោះការខាតប្រភេទនេះ នាកាលបរិច្ឆេទរាយការណ៍។ ការវាស់វែង ECL ឆ្លុះបញ្ចាំងពី៖

- ចំនួនលម្អៀង និងចំនួន ដែលបានថ្លឹងប្រូបាប ដែលត្រូវបានកំណត់ ដោយធ្វើការវាយតម្លៃលើលទ្ធភាព ដែលអាចកើតឡើងមួយចំនួន
- ពេលវេលានៃតម្លៃទឹកប្រាក់ និង
- ព័ត៌មាន ដែលមានភាពសមហេតុផល និងមានការគាំទ្រ ដែលអាចរកបាន ដោយពុំចាំបាច់មានការចំណាយ និងការខំប្រឹងប្រែងលើសលប់ នាកាលបរិច្ឆេទរាយការណ៍ អំពីព្រឹត្តិការណ៍នាពេលអតីតកាល ពេលបច្ចុប្បន្ន និងការព្យាករ អំពីលក្ខខណ្ឌ នាពេលអនាគត។

ធនាគារបានអនុវត្តវិធីសាស្ត្រ បីដំណាក់កាល ចំពោះការវាស់វែងការខាតតំណាងនំរឹងទុក សម្រាប់ប្រភេទដូចខាងក្រោម៖

- ឧបករណ៍ចំណុលវាស់វែង តាមថ្លៃដើមបានរំលស់ និង
- កិច្ចសន្យាផ្តល់តំណាង (រួមទាំងតំណាងវិបារូបន៍ ដែលមិនទាន់បានដកប្រាក់ និងហ្វាស៊ីលធីអាចប្រើប្រាស់ឡើងវិញ) និងកិច្ចសន្យាធានា ផ្នែកហិរញ្ញវត្ថុ

អនុវត្តវិធីសាស្ត្របីដំណាក់កាល ផ្អែកទៅលើបម្រែបម្រួលហានិភ័យតំណាង ចាប់តាំងពីការទទួលស្គាល់លើកដំបូង៖

(ក) ដំណាក់កាលទី១៖ ECL ១២ខែ

ដំណាក់កាលទី១ រួមបញ្ចូលនូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានកំណើនហានិភ័យតំណាងគួរឱ្យកត់សម្គាល់ ចាប់តាំងពីការកត់ត្រាលើកដំបូង ឬមានហានិភ័យតំណាងទាបត្រឹមទាប នាកាលបរិច្ឆេទរាយការណ៍។ ECL ១២ខែ ត្រូវបានកត់ត្រា ហើយចំណូលការប្រាក់ ត្រូវបានគណនា តាមចំនួនសមតុល្យយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

(ខ) ដំណាក់កាលទី២៖ ECL ពេញមួយអាយុកាល – មិនមានឱនភាព នៃតម្លៃតំណាង

ដំណាក់កាលទី២ រួមមានទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានកំណើនហានិភ័យតំណាងជាសារវន្ត ចាប់តាំងពីការកត់ត្រាលើកដំបូង (លើកលែងតែវាមានហានិភ័យតំណាងទាប នាកាលបរិច្ឆេទរាយការណ៍) ប៉ុន្តែមិនមានភស្តុតាងជាក់ស្តែងបង្ហាញពីឱនភាព នៃតម្លៃ។ ECL ពេញមួយអាយុកាល ត្រូវបានកត់ត្រា ហើយចំណូលការប្រាក់ ត្រូវបានគណនា តាមចំនួនសមតុល្យយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

(គ) ដំណាក់កាលទី៣៖ ECL ពេញមួយអាយុកាល – មានឱនភាព នៃតម្លៃតំណាង

ដំណាក់កាលទី៣ រួមមានទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានភស្តុតាងជាក់ស្តែងបង្ហាញពីឱនភាព នៃតម្លៃ នាកាលបរិច្ឆេទរាយការណ៍។ ECL ពេញមួយអាយុកាលត្រូវបានកត់ត្រា ហើយចំណូលការប្រាក់ ត្រូវបានគណនា តាមចំនួនតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

## ២.៦ ចំណុលហិរញ្ញវត្ថុ

ចំណុលហិរញ្ញវត្ថុ ត្រូវបានកត់ត្រា នៅពេលដែលធនាគារក្លាយជាភាគីមួយ នៅក្នុងកិច្ចសន្យានៃឧបករណ៍ណាមួយ។ ចំណុលហិរញ្ញវត្ថុរបស់ធនាគារ រួមមានប្រាក់បញ្ញើរបស់ធនាគារ ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់កម្ចី ចំណុលបន្ទាប់បន្សំ ចំណុលភតិសន្យា និងចំណុលហិរញ្ញវត្ថុផ្សេងៗ។

ចំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់លើកដំបូង តាមតម្លៃសមស្របដកចំណាយប្រតិបត្តិការ ចំពោះចំណុលហិរញ្ញវត្ថុទាំងអស់ ដែលមិនវាស់វែង តាមតម្លៃសមស្រប ក្នុងចំណេញ ឬខាត។

ចំណុលហិរញ្ញវត្ថុ ដែលមិនត្រូវបានចាត់ថ្នាក់ តាមតម្លៃសមស្រប ក្នុងចំណេញ ឬខាត ត្រូវបានវាស់វែង តាមថ្លៃដើមបានរំលស់។ ចំណុលហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែង តាមថ្លៃដើមបានរំលស់ មានប្រាក់បញ្ញើ ពីធនាគារ ប្រាក់បញ្ញើ ពីអតិថិជន ប្រាក់កម្ចី ចំណុលបន្ទាប់បន្សំ ចំណុលភតិសន្យា និងចំណុលហិរញ្ញវត្ថុផ្សេងៗ។

ចំណុលហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលកាតព្វកិច្ច ក្រោមកិច្ចសន្យា ត្រូវបានរំលាយ ឬផុតអាណត្តិ។

## ២.៧ កិច្ចសន្យាផ្តល់តំណាង និងកិច្ចសន្យាធានា ផ្នែកហិរញ្ញវត្ថុ

កិច្ចសន្យាផ្តល់តំណាង (រួមមានតំណាងវិបារូបន៍ ដែលមិនទាន់បានដកប្រាក់ និងហ្វាស៊ីលីធីអាចប្រើប្រាស់ឡើងវិញ) ដែលធនាគារបានផ្តល់ ត្រូវបានវាស់វែង តាមចំនួនសំវិធានធន សម្រាប់ការខាតបង់។ ធនាគារមិនបានផ្តល់កិច្ចសន្យាផ្តល់តំណាងណាមួយ ដែលមានអត្រាការប្រាក់ទាបជាងអត្រាទីផ្សារទេ ឬកិច្ចសន្យា ដែលអាចត្រូវបានទូទាត់ ជាសាច់ប្រាក់សុទ្ធ ឬតាមរយៈការផ្តល់ ឬការចេញឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតទេ។

ចំពោះកិច្ចសន្យាផ្តល់តំណាង (រួមមានតំណាងវិបារូបន៍ ដែលមិនទាន់បានដកប្រាក់ និងហ្វាស៊ីលីធីដែលអាចប្រើប្រាស់ឡើងវិញ) ការខាតតំណាងនំរឹងទុក ត្រូវបានទទួលស្គាល់ជាសំវិធានធន (ដែលត្រូវបានដាក់បង្ហាញ ក្នុងបំណុលផ្សេងៗ)។ ទោះជាយ៉ាងណាក៏ដោយ ចំពោះកិច្ចសន្យា ដែលរួមបញ្ចូលទាំងតំណាង និងកិច្ចសន្យា ដែលមិនទាន់ដកប្រាក់ ហើយដែលធនាគារមិនអាចកំណត់ការខាតតំណាងនំរឹងទុក ដាច់ដោយឡែក ចំពោះកិច្ចសន្យាតំណាង ដែលមិនទាន់ដកប្រាក់ ត្រូវបានទទួលស្គាល់រួមគ្នា ក្នុងសំវិធានធន សម្រាប់តំណាងបាត់បង់។ ក្នុងករណីដែលការខាតតំណាងនំរឹងទុករួមបញ្ចូលគ្នា លើសពីចំនួនសមតុល្យយោងដុល របស់តំណាង នោះការខាតតំណាងនំរឹងទុក ត្រូវបានទទួលស្គាល់ជាសំវិធានធន។

កិច្ចសន្យាធានា ផ្នែកហិរញ្ញវត្ថុ គឺជាកិច្ចសន្យាទាំងឡាយណា ដែលតម្រូវឱ្យអ្នកចេញផ្សាយការធានា ធ្វើការទូទាត់ជាក់លាក់មួយ ដើម្បីផ្តល់សំណង ទៅអ្នកកាន់កាប់ ចំពោះការខាតបង់ ដែលកើតមានឡើង ដោយសារកូនបំណុលណាមួយ មិនបានសងបំណុល នៅពេលដល់ថ្ងៃកំណត់ ដោយអនុលោមទៅតាមលក្ខខណ្ឌ នៃឧបករណ៍បំណុលនោះ។ ការធានា ផ្នែកហិរញ្ញវត្ថុប្រភេទនេះ គឺត្រូវបានផ្តល់ឱ្យធនាគារគ្រឹះស្ថានហិរញ្ញវត្ថុ និងអង្គភាពផ្សេងៗជំនួសអតិថិជន ដើម្បីធានាលើឥណទាន ឥណទានវិបារូបន៍ និងហ្វាស៊ីលីធីធនាគារផ្សេងៗ។

ការធានាផ្នែកហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់លើកដំបូង ក្នុងរបាយការណ៍ហិរញ្ញវត្ថុ តាមតម្លៃសមស្រប នាកាលបរិច្ឆេទផ្តល់ការធានានោះ។ ការធានាត្រូវបានព្រមព្រៀង តាមលក្ខខណ្ឌជំហែងដៃ ហើយតម្លៃបុព្វលាភ ដែលបានព្រមព្រៀង មានចំនួនប្រហាក់ប្រហែលនឹងតម្លៃ នៃកាតព្វកិច្ច ក្នុងការធានា។ បុព្វលាភ ដែលនឹងត្រូវទទួលបាន នាពេលអនាគត មិនត្រូវបានទទួលស្គាល់ទេ។ កិច្ចសន្យាធានា ផ្នែកហិរញ្ញវត្ថុ ត្រូវបានវាស់វែងបន្តបន្ទាប់ តាមចំនួនណាមួយ ដែលខ្ពស់ជាងគេ រវាងចំនួនដែលត្រូវបានកំណត់ ដោយផ្អែកទៅតាមគំរូការខាតឥណទានរំពឹងទុក ក្រោម CIFRS ៩ ស្តីពី «ឧបករណ៍ហិរញ្ញវត្ថុ» និងចំនួន ដែលត្រូវបានទទួលស្គាល់លើកដំបូង ដកនឹងចំនួនប្រាក់ចំណូលបង្គរ ដែលត្រូវបានទទួលស្គាល់ ដោយផ្អែកទៅតាមគោលនយោបាយរបស់ CIFRS ១៥ ស្តីពី «ប្រាក់ចំណូល ពីកិច្ចសន្យា ជាមួយអតិថិជន ទៅតាមភាពសមស្រប»។

ការប៉ាន់ស្មាន ត្រូវបានកំណត់ដោយផ្អែកទៅតាមបទពិសោធន៍ នៃប្រតិបត្តិការប្រហាក់ប្រហែលគ្នា និងប្រវត្តិនៃការខាតបង់ ក្នុងគ្រាកន្លងមក និងបូកបន្ថែមជាមួយនឹងការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង។ ចំណូលកម្រៃសេវា ដែលរកបានត្រូវបានទទួលស្គាល់ តាមមូលដ្ឋានថេរអាស្រ័យ ទៅតាមអាយុកាលនៃការធានានោះ។

ការកើនឡើង នៃបំណុលដែលពាក់ព័ន្ធនឹងការធានា ត្រូវបានរាយការណ៍ នៅក្នុងចំណេញ ឬខាត ក្នុងខ្នង់ចំណាយប្រតិបត្តិការ។

## ២.៨ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានកាត់កង ហើយចំនួនទឹកប្រាក់សុទ្ធ បន្ទាប់ពីកាត់កង ត្រូវបានរាយការណ៍ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានសិទ្ធិតាមផ្លូវច្បាប់ ក្នុងការកាត់កងចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់ ហើយធនាគារមានចំណងនឹងទូទាត់ តាមមូលដ្ឋានចំនួនទឹកប្រាក់សុទ្ធ ឬមានចំណងកត់ត្រាទ្រព្យសកម្ម និងទូទាត់បំណុល ក្នុងពេលដំណាលគ្នា។

## ២.៩ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រា តាមថ្លៃដើមបានរំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃ។ ថ្លៃដើមប្រវត្តិសាស្ត្រ រួមមានចំណាយផ្ទាល់ផ្សេងៗ ដែលបានចំណាយ ក្នុងការទិញទ្រព្យសម្បត្តិនោះ។

ចំណាយបន្តបន្ទាប់ផ្សេងៗ ត្រូវបានកត់ត្រាបញ្ចូល ទៅក្នុងសមតុល្យយោង នៃទ្រព្យសមកម្មនោះ ឬត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ដាច់ដោយឡែក តាមការសមស្រប តែនៅពេលដែលមានភាពប្រាកដថា ផលប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគត នៃទ្រព្យនោះនឹងហូរចូលមក ក្នុងធនាគារ ហើយថ្លៃដើម នៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ។ រាល់ចំណាយ លើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុក នៅក្នុងចំណេញ ឬខាត ក្នុងឆ្នាំហិរញ្ញវត្ថុ ដែលប្រតិបត្តិការនោះកើតឡើង។

ការងារកំពុងដំណើរការ មិនត្រូវបានរំលស់ទេ។ រំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុក ក្នុងចំណេញ ឬខាត តាមមូលដ្ឋានថេរ អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មនីមួយៗ និងទៅតាមអត្រាប្រចាំឆ្នាំ ដូចខាងក្រោម៖

| | អត្រារំលស់ |
|---|---|
| ការកែលម្អលើទ្រព្យជួល | ២០% ឬរយៈពេលជួល មួយណាខ្លីជាង |
| បរិក្ខារការិយាល័យ | ១០% ទៅ ២០% |
| បរិក្ខារកុំព្យូទ័រ | ២០% |
| កម្មវិធីកុំព្យូទ័រ | ១០% ទៅ ៣៣,៣៣% |
| យានយន្ត | ២០% |

រំលស់ លើការងារកំពុងដំណើរការ ចាប់ផ្តើមឡើង នៅពេលដែលទ្រព្យសកម្ម មានភាពរួចរាល់សម្រាប់ការប្រើប្រាស់។ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យ និងកែតម្រូវតាមភាពសមស្រប នាចុងកាលបរិច្ឆេទរាយការណ៍នីមួយៗ។

ប្រសិនបើសមតុល្យយោង នៃទ្រព្យសកម្មណាមួយ លើសពីតម្លៃ ដែលអាចស្រង់មកវិញបាន វាត្រូវបានកត់ត្រាបន្ថយ ឱ្យនៅត្រឹមតម្លៃប៉ាន់ស្មាន ដែលអាចស្រង់មកវិញបាន។

ចំណេញ និងខាត ពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ ដោយធ្វើការប្រៀបធៀបសាច់ប្រាក់ បានពីការលក់ និងសមតុល្យយោង ហើយត្រូវបានទទួលស្គាល់ នៅក្នុងចំណេញ ឬខាត។

ទ្រព្យសម្បត្តិ និងបរិក្ខារ ដែលបានធ្វើរំលស់ពេញលេញ ត្រូវបានរក្សាទុក ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រហូតដល់វាត្រូវបានលក់ចេញ ឬលុបចោល។

## ២.១០ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ ដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍ តាមថ្លៃដើមបានរំលស់បង្គរ និងការខាត ដែលបណ្តាលមកពីឱនភាពនៃតម្លៃ។ អាជ្ញាបណ្ណកម្មវិធីកុំព្យូទ័រ ដែលបានទិញ ត្រូវបានធ្វើមូលធនកម្ម តាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើង ក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ ថ្លៃដើមត្រូវបានរំលស់ ក្នុងរយៈពេលបីឆ្នាំ តាមវិធីសាស្ត្ររំលស់ថេរ លើកលែងតែអាជ្ញាប័ណ្ណ សម្រាប់កម្មវិធីធនាគារ ដែលមានអាយុកាលប្រើប្រាស់ដប់ឆ្នាំ។

ការងារកំពុងដំណើរការ មិនត្រូវបានរំលស់ទេ។ ចំណាយនានា ពាក់ព័ន្ធនឹងការថែរក្សាទ្រព្យសកម្មអរូបី ត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

## ២.១១ ឱនភាព នៃតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណា ដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានរំលស់ទេ និងត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំឱនភាព នៃតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយ ចង្អុលបង្ហាញថា សមតុល្យយោងរបស់វា នឹងមិនអាចស្រង់មកវិញបាន។ ការខាតបង់ឱនភាព នៃតម្លៃ ត្រូវបានទទួលស្គាល់ តាមចំនួនលម្អៀង រវាងសមតុល្យយោង នៃទ្រព្យសកម្មនោះ ធៀបជាមួយតម្លៃ ដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃមួយណា ដែលខ្ពស់ជាងគេ រវាងតម្លៃសមស្រប នៃទ្រព្យនោះ ដកចំណាយ ក្នុងការលក់ចេញ និងតម្លៃនៅប្រើប្រាស់។ ក្នុងការប៉ាន់ស្មានរកឱនភាព នៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់ជាក្រុមតូចៗបំផុត ដែលគេអាចកំណត់លំហូរសាច់ប្រាក់របស់វា ដាច់ដោយឡែកពីគ្នា ដែលវាមានឯករាជ្យទាំងស្រុង ពីលំហូរសាច់ប្រាក់ចូលរបស់ទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មដទៃ (ក្រុមបង្កើតសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដែលមានឱនភាព នៃតម្លៃ ត្រូវបានត្រួតពិនិត្យរកមើលលទ្ធភាព ក្នុងការកត់ត្រាឱនភាព នៃតម្លៃត្រឡប់ទៅវិញ នាចុងកាលបរិច្ឆេទរាយការណ៍នីមួយៗ។

ការខាតបង់ លើឱនភាព នៃតម្លៃត្រូវបានកត់ត្រា ក្នុងចំណេញ ឬខាត ក្នុងកាលបរិច្ឆេទ ដែលកើតឡើងនោះ។ ការកត់ត្រាបញ្ច្រាស នៃការខាតបង់ឱនភាពតម្លៃ ត្រូវបានទទួលស្គាល់ ក្នុងចំណេញ ឬខាត ត្រឹមកម្រិតមួយ ដែលមិនធ្វើឱ្យសមតុល្យយោងរបស់ទ្រព្យសកម្មនេះ មិនលើសពីសមតុល្យយោង ដែលត្រូវកំណត់ដករំលស់ លើទ្រព្យសកម្មរូបី និងអរូបី ក្នុងករណីពុំមានការទទួលស្គាល់ការខាតបង់ លើឱនភាពនៃតម្លៃ។

## ២.១២ ភតិសន្យា

**ធនាគារជាភតិករ:**

នៅពេលចាប់ផ្តើមកិច្ចសន្យា ធនាគារវាយតម្លៃថាតើកិច្ចសន្យានោះ ឬខ្លឹមសាររបស់វា ជាភតិសន្យាដែរឬទេ។ កិច្ចសន្យាមួយ ឬខ្លឹមសារ នៃកិច្ចសន្យាមួយ ត្រូវបានចាត់ទុកថា ជាភតិសន្យា ប្រសិនបើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រង ការប្រើប្រាស់ទ្រព្យសកម្មជាកំលាក់មួយ ក្នុងរយៈពេលកំណត់មួយ ជាថ្នូរនឹងតម្លៃតបស្នង។

កិច្ចសន្យា អាចមានទាំងធាតុភតិសន្យា និងធាតុមិនមែនភតិសន្យា។ ធនាគារបានបែងចែកសាច់ប្រាក់ ក្នុងកិច្ចសន្យាជាធាតុភតិសន្យា និងធាតុមិនមែនភតិសន្យា អាស្រ័យលើថ្លៃឈ្នួល ដែលពាក់ព័ន្ធរបស់វា។

លក្ខខណ្ឌ ក្នុងភតិសន្យា ត្រូវបានចរចាឡើងវិញ តាមមូលដ្ឋានដាច់ដោយឡែក និងមានលក្ខខណ្ឌខុសៗពីគ្នា។ កិច្ចព្រមព្រៀងភតិសន្យា មិនបានបណ្តាលឱ្យមានកិច្ចសន្យាណាមួយ ក្រៅពីអត្ថប្រយោជន៍ដែលបានធានា នៅក្នុងទ្រព្យសកម្មភតិសន្យា ដែលត្រូវបានកាន់កាប់ ដោយភាគីម្ចាស់ជួលនោះទេ។ ទ្រព្យសកម្ម ដែលត្រូវបានជួល អាចនឹងមិនត្រូវបានប្រើប្រាស់ ជាទ្រព្យធានា ក្នុងការខ្ចីប្រាក់ទេ។

ភតិសន្យា ត្រូវបានទទួលស្គាល់ជាសិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម និងជាបំណុលពាក់ព័ន្ធ នាកាលបរិច្ឆេទ ដែលទ្រព្យសកម្ម ដែលបានជួល មានភាពរួចរាល់ សម្រាប់ប្រើប្រាស់។

ទ្រព្យសកម្ម និងបំណុល ដែលកើតពីភតិសន្យា ត្រូវបានវាស់វែងជាដំបូង តាមមូលដ្ឋានតម្លៃបច្ចុប្បន្ន។

**i) បំណុលភតិសន្យា**

បំណុលភតិសន្យា រួមបញ្ចូលនូវតម្លៃបច្ចុប្បន្នសុទ្ធ នៃការទូទាត់ភតិសន្យាថេរ (រួមទាំងការបង់ប្រាក់ថេរផ្សេងៗ) ដកនឹងការលើកទឹកចិត្តផ្សេងៗ សម្រាប់ការជួល ដែលត្រូវទទួលបាន។

ការទូទាត់ភតិសន្យា ដែលត្រូវធ្វើឡើង ក្រោមជម្រើស ដែលអាចពន្យារពេលបាន ប្រកបដោយភាពសមហេតុផល ត្រូវបានរួមបញ្ចូល នៅក្នុងការវាស់វែងបំណុល។

ការទូទាត់ភតិសន្យា ត្រូវបានធ្វើអប្បហារ ដោយប្រើអត្រាជាក់ស្តែង ក្នុងភតិសន្យា។ ប្រសិនបើអត្រាការប្រាក់មិនអាចកំណត់បាន ដោយភាពងាយស្រួលនោះ ដែលជាទូទៅចំពោះការណីភតិសន្យា នៅក្នុងធនាគារ អត្រាកំណើនប្រាក់កម្ចីរបស់ភាគីអ្នកជួល ត្រូវបានប្រើប្រាស់ ហើយវាគឺជាអត្រា ដែលភាគីអ្នកជួលនីមួយៗ ត្រូវចំណាយ ដើម្បីទទួលបានប្រាក់កម្ចី ដែលមានភាពចាំបាច់ ដើម្បីទទួលបានទ្រព្យសកម្ម ដែលមានតម្លៃប្រហាក់ប្រហែលនឹងទ្រព្យសកម្ម ដែលមានសិទ្ធិប្រើប្រាស់ នៅក្នុងបរិយាកាសសេដ្ឋកិច្ចស្រដៀងគ្នា ជាមួយនឹងលក្ខខណ្ឌ និងការធានាប្រហាក់ប្រហែលគ្នា។

ដើម្បីកំណត់អត្រាកំណើនប្រាក់កម្ចី ធនាគារអាចធ្វើទៅបាន ដោយប្រើហិរញ្ញប្បទានភាគីទីបី ដែលទទួលបាន ពីភាគីអ្នកជួលនីមួយៗ គឺជាចំណុចចាប់ផ្តើម ហើយកែតម្រូវលើការផ្លាស់ប្តូរលក្ខខណ្ឌហិរញ្ញប្បទាន ចាប់តាំងពីហិរញ្ញប្បទានភាគីទីបីទទួលបាន។

ការទូទាត់ភតិសន្យា ត្រូវបានបែងចែក រវាងប្រាក់ដើម និងចំណាយការប្រាក់។ ចំណាយការប្រាក់ ត្រូវបានកត់ត្រាជាបន្ទុក ក្នុងចំណេញ ឬខាត ក្នុងរយៈពេល នៃភតិសន្យានោះ ដើម្បីបង្កើតអត្រាការប្រាក់ថេរ តាមកាលកំណត់មួយ លើចំនួនសមតុល្យបំណុលភតិសន្យា ដែលនៅសល់ ក្នុងការិយបរិច្ឆេទនីមួយៗ។

**ii) សិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម**

សិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម ត្រូវបានវាស់វែងជាដំបូង តាមថ្លៃដើម ដែលរួមមាន៖

- សមតុល្យ នៃបំណុលភតិសន្យា ដែលបានវាស់វែងលើកដំបូង
- ការទូទាត់ភតិសន្យាណាមួយ ដែលបានធ្វើឡើង នៅកាលបរិច្ឆេទចាប់ផ្តើម ឬមុនកាលបរិច្ឆេទចាប់ផ្តើម ដកការលើកទឹកចិត្តផ្សេងៗ ដែលទទួលបាន ពីការជួល
- ចំណាយផ្លាស់លើកដំបូង និង
- ចំណាយ សម្រាប់ការជួសជុសឡើងវិញ ប្រសិនបើមាន

សិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម ជាទូទៅត្រូវបានដករំលស់ តាមមូលដ្ឋានរំលស់ថេរ លើរយៈពេលណាមួយ ដែលខ្លីជាងគេ រវាងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម និងរយៈពេលជួល។ ប្រសិនបើធនាគារមានបំណងជាក់លាក់ដ៏សមហេតុផល ក្នុងការទិញនោះ សិទ្ធិប្រើប្រាស់ លើទ្រព្យសកម្មនោះ ត្រូវបានដករំលស់ លើអាយុកាលប្រើប្រាស់មូលដ្ឋានរបស់ទ្រព្យសកម្មនោះ។

បន្ទាប់មកទៀត សិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម ត្រូវបានវាស់វែង តាមថ្លៃដើមបានរំលស់បង្គរ និងការខាត ដែលបណ្តាលមក ពីឱនភាព នៃតម្លៃបង្គរ ប្រសិនបើមាន និងធ្វើនិយ័តកម្ម នូវចំនួនបំណុលភតិសន្យា ដែលវាស់វែងឡើងវិញ។

**iii) ការលើកលែងការទទួលស្គាល់**

ការទូទាត់នានា ដែលពាក់ព័ន្ធនឹងភតិសន្យា ដែលមានរយៈពេលខ្លី ត្រូវបានកត់ត្រា ក្នុងចំណេញ ឬខាត តាមមូលដ្ឋានថេរ អាស្រ័យទៅតាមរយៈពេល នៃភតិសន្យា។ ភតិសន្យា ដែលមានរយៈពេលខ្លី រួមមានការជួលទីតាំង សម្រាប់ម៉ាស៊ីនអេធីអិម។

## ២.១៣ សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់ នៅពេលធនាគារមានកាតព្វកិច្ចស្របច្បាប់ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ដែលវាទំនងជាមានលំហូរចេញ នៃអត្ថប្រយោជន៍សេដ្ឋកិច្ច របស់ធនាគារ ដែលតម្រូវឱ្យមានការទូទាត់ តាមកាតព្វកិច្ច ហើយការប៉ាន់ស្មានអាចត្រូវបានធ្វើឡើង តាមសមតុល្យនៃកាតព្វកិច្ចទាំងនោះ។

សំវិធានធន ត្រូវបានទទួលស្គាល់ នៅពេលដែលមានកាតព្វកិច្ច តាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផល នៃព្រឹត្តិការណ៍ ពីអតីតកាល ហើយវាទំនងជាអាចតម្រូវឱ្យមានការចំណាយធនធាន ដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ ត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញ ដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ ដោយគិតទៅលើចំណាត់ថ្នាក់ នៃកាតព្វកិច្ចទាំងមូល។ សំវិធានធន ត្រូវបានទទួលស្គាល់ ទោះបីជាកម្រិត នៃលំហូរចេញ ដើម្បីទូទាត់កាតព្វកិច្ចនោះ មានចំនួនតូចក៏ដោយ។

សំវិធានធន ត្រូវបានគណនា តាមតម្លៃបច្ចុប្បន្ន នៃចំណាយ ដែលត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ន នៃតម្លៃសាច់ប្រាក់ គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗ នៃកាតព្វកិច្ចនោះ។ ការកើនឡើង នៃសំវិធានធន ដោយសារពេលវេលា ដែលបានកន្លងផុត ត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់។

## ២.១៤ ប្រាក់កម្ចី

ប្រាក់កម្ចី ត្រូវបានវាស់វែងលើកដំបូង តាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការកើនឡើង ហើយបន្ទាប់មក វាត្រូវបានវាស់វែង តាមថ្លៃដើមបានរំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

## ២.១៥ បំណុលបន្ទាប់បន្សំ

បំណុលបន្ទាប់បន្សំ ត្រូវបានវាស់វែងលើកដំបូង តាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការកើនឡើង ហើយបន្ទាប់មក វាត្រូវបានវាស់វែង តាមថ្លៃដើមបានរំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

## ២.១៦ អត្ថប្រយោជន៍និយោជិត

**i) អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី**

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ត្រូវបានកត់ត្រាបង្គរក្នុងឆ្នាំ ដែលបុគ្គលិកបានបម្រើការងារឱ្យធនាគារ។

**ii) ប្រាក់សោធននិវត្តន៍**

ធនាគារបង់ភាគទានប្រចាំខែ ជាប្រាក់សោធន តាមរបបភាគទានជាកាតព្វកិច្ច ទៅបេឡាជាតិរបបសន្តិសុខ សង្គម (ប.ស.ស) ដែលជាផ្នែកសាធារណៈរដ្ឋបាល នៃរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន ក្នុងប្រទេសកម្ពុជា។ ធនាគារមិនមានកាតព្វកិច្ចបង់ប្រាក់បន្ថែមទៀតទេ នៅពេលដែលបានបង់ភាគទាននេះរួច។ ភាគទាន ត្រូវបានកត់ត្រាជាចំណាយអត្ថប្រយោជន៍បុគ្គលិក នៅពេលដល់ថ្ងៃកំណត់។

**iii) អត្ថប្រយោជន៍បុគ្គលិករយៈពេលវែងផ្សេងៗ - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ**

នៅខែមិថុនា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើវិសោធនកម្ម លើច្បាប់ ស្តីពីការងារ ដែលណែនាំ ពីគម្រោងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។ បន្ទាប់មក នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ប្រកាសលេខ ៤៤៣ ក.ប/ ប្រ.ក.ខ.ល ត្រូវបានចេញផ្សាយ ដោយបានផ្តល់នូវគោលនយោបាយណែនាំ ស្តីពីការអនុវត្តច្បាប់នេះ។ អនុលោមទៅតាមច្បាប់/ប្រកាសនេះ អង្គភាពនីមួយៗ តម្រូវឱ្យទូទាត់ប្រាក់បំណាច់អតីតភាពការងារឱ្យបុគ្គលិក ដែលមានកិច្ចសន្យាការងារមិនមានចិរវេលាកំណត់ ដូចខាងក្រោម៖

- ប្រាក់បំណាច់ការងារប្រចាំឆ្នាំ - ចូលជាធរមាន ក្នុងខែមករា ឆ្នាំ២០១៩ - ស្មើនឹង ១៥ថ្ងៃ នៃប្រាក់បៀវត្សប្រចាំខែរបស់បុគ្គលិក និងអត្ថប្រយោជន៍ ក្នុងឆ្នាំនីមួយៗ គិតជាមធ្យម ដែលត្រូវទូទាត់រៀងរាល់ ៦ខែម្តង នៅថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣១ ខែធ្នូ (៧.៥ថ្ងៃ ក្នុងការទូទាត់ម្តងៗ)។
- ប្រាក់បំណាច់រំលឹកអតីតភាពការងារ - និយោជិតមានសិទ្ធិទទួលបានប្រាក់បំណាច់រំលឹកអតីតភាពការងារស្មើនឹង ១៥ថ្ងៃ នៃប្រាក់បៀវត្សរបស់ពួកគេ ក្នុងមួយឆ្នាំ គិតចាប់តាំងពីថ្ងៃចូលបម្រើការងារ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយនៅតែបន្តការងារ ជាមួយធនាគារ។ ការបើកប្រាក់បំណាច់រំលឹកអតីតភាពការងារ គឺអាស្រ័យទៅតាមចំនួនឆ្នាំអតីតភាពការងាររបស់បុគ្គលិកម្នាក់ៗ ហើយមិនត្រូវលើសពី ៦ខែ នៃប្រាក់បៀវត្សដុលជាមធ្យមទេ។ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីណែនាំលេខ ០៤២/១៩ ក.ប/ស.ណ.ន.ខ.ល ដើម្បីពន្យារពេលការបើកប្រាក់បំណាច់រំលឹកអតីតភាពការងារ ដែលនឹងត្រូវទូទាត់ឱ្យចំនួនបីថ្ងៃម្តង ក្នុងខែមិថុនា និងខែធ្នូ ដោយចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០២១។

ការទូទាត់ប្រាក់បំណាច់ការងារប្រចាំឆ្នាំត្រូវបានចាត់ទុកថាជាអត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ហើយវាត្រូវបានកត់ត្រាបង្ករក្នុងឆ្នាំ ដែលបុគ្គលិកបានបម្រើការងារឱ្យធនាគារ។

ការបើកប្រាក់បំណាច់រំលឹកអតីតភាពការងារ ត្រូវបានចាត់ថ្នាក់ ជាអត្ថប្រយោជន៍បុគ្គលិករយៈពេលវែង ក្រៅពីអត្ថប្រយោជន៍ ដែលត្រូវទូទាត់ ក្នុងរយៈពេល ១២ខែបន្ទាប់។ បំណុលប្រាក់បំណាច់អតីតភាពការងារវិឭក ត្រូវបានកត់ត្រា តាមតម្លៃបច្ចុប្បន្ន នៃកាតព្វកិច្ច ដែលបានកំណត់នាការិយបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្ត្រ projected unit credit ដើម្បីធ្វើការប៉ាន់ស្មានឱ្យបានកាន់តែល្អ នូវតម្លៃចុងក្រោយ ដែលធនាគារត្រូវបង់ឱ្យបុគ្គលិក ជាថ្នូរនឹងការបម្រើការងារឱ្យធនាគារ ក្នុងពេលបច្ចុប្បន្ន និងក្នុងឆ្នាំកន្លងមក។ តម្លៃបច្ចុប្បន្ន នៃការបើកប្រាក់បំណាច់រំលឹកអតីតភាពការងារ ត្រូវបានកំណត់ដោយធ្វើអប្បហារ លើចំនួនទឹកប្រាក់ប៉ាន់ស្មាន ដែលត្រូវទូទាត់ នាពេលអនាគត ដោយយោងទៅតាមសញ្ញាប័ណ្ណសាជីវកម្ម ដែលមានគុណភាពខ្ពស់ នៃរូបិយប័ណ្ណរបស់បំណុលនោះ។

**iv) អត្ថប្រយោជន៍និយោជិតផ្សេងៗ - ប្រាក់សោធនបុគ្គលិក**

ធនាគារបានកត់ត្រាប្រាក់សោធនបុគ្គលិក សម្រាប់ជាអត្ថប្រយោជន៍ ដល់បុគ្គលិកពេញសិទ្ធិទាំងអស់។ ទាំងនិយោជិត និងនិយោជក បង់វិភាគទាន ៥% នៃប្រាក់បៀវត្សប្រចាំខែរបស់បុគ្គលិកម្នាក់ៗ។ បុគ្គលិក ដែលបានបម្រើការងាររយៈពេលបីឆ្នាំ ឬតិចជាងនេះ នៅពេលលាឈប់ ពីការងារ ឬចូលនិវត្ត នឹងទទួលបានត្រឹមតែវិភាគទានបង្ករបស់ខ្លួនតែប៉ុណ្ណោះ។ ចំណែកបុគ្គលិក ដែលបានបម្រើការងារ លើសពីរយៈពេលបីឆ្នាំ នៅពេលលាឈប់ ពីការងារ ឬចូលនិវត្ត នឹងទទួលបានទាំងវិភាគទានរបស់ពួកគេផង និងរបស់ធនាគាផង។

មូលនិធិនេះ ត្រូវបានរក្សាទុក ក្នុងគណនីធនាគារដោយឡែក សម្រាប់បុគ្គលិកម្នាក់ៗ ប៉ុន្តែស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារ។ ធនាគារផ្តល់ការប្រាក់ ទាំងចំពោះវិភាគទានរបស់ធនាគារ និងវិភាគទានរបស់បុគ្គលិក តាមអត្រាការប្រាក់របស់ប្រាក់បញ្ញើមានកាលកំណត់ ១២ខែ។ ចំណាយវិភាគទាន (៥% ពីធនាគារ) ត្រូវបានកត់ត្រា ក្នុងចំណេញ ឬខាត តាមមូលដ្ឋានប្រចាំខែ។

**v) អត្ថប្រយោជន៍ សម្រាប់ការទូទាត់ ផ្អែកតាមភាគហ៊ុន**

CIMBGH បានបង្កើតផែនការលើកទឹកចិត្តរយៈពេលវែង (LTIP) ដែលចាប់ផ្តើម នៅខែមិថុនា ឆ្នាំ២០២១ ដែលរួមមាន ផែនការជម្រើសភាគហ៊ុនរបស់បុគ្គលិក (ESOS) និងផែនការអំណោយភាគហ៊ុន (SGP)។

ផែនការ LTIP ត្រូវបានផ្តល់ឱ្យបុគ្គលិក ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់ធនាគារ និងជាផែនការទូទាត់ ដោយភាគហ៊ុន។ ចំណាយប្រតិបត្តិការទូទាត់ តាមភាគហ៊ុន ត្រូវបានទទួលស្គាល់ ក្នុងកំណើនមូលធន អាស្រ័យទៅតាមលទ្ធផល និង/ឬ លក្ខខណ្ឌការងារ ដែលបានបំពេញ និងបញ្ចប់ទៅវិញ នៅពេលធនាគារបានប្រគល់ប្រាក់រង្វាន់ ឱ្យបុគ្គលិករួច។ តម្លៃសមស្រប នៃការបម្រើការងាររបស់បុគ្គលិក ដែលទទួលបាន ជាថ្នូរនឹងការផ្តល់ភាគហ៊ុន និង/ឬ ជម្រើសភាគហ៊ុន ត្រូវបានទទួលស្គាល់ជាចំណាយ ក្នុងចំណេញ ឬខាត ក្នុងរយៈពេលផ្តល់អត្ថប្រយោជន៍ ផ្អែកទៅតាមចំនួនភាគហ៊ុនប៉ាន់ស្មាន និង/ឬ ជម្រើសភាគហ៊ុនដ៏ល្អបំផុត ដែលរំពឹងថា ត្រូវប្រគល់ នាកាលបរិច្ឆេទផ្តល់អត្ថប្រយោជន៍។

ចំនួនសរុប ដែលត្រូវបានចំណាយ ក្នុងរយៈពេលផ្តល់អត្ថប្រយោជន៍ ត្រូវបានកំណត់ដោយយោងទៅតាមតម្លៃសមស្រប នាកាលបរិច្ឆេទបានផ្តល់ភាគហ៊ុន និង/ឬ ជម្រើសភាគហ៊ុន។ លក្ខខណ្ឌផ្តល់ភាគហ៊ុនមិនផ្អែកតាមទីផ្សារ ត្រូវបានរួមបញ្ចូល នៅក្នុងការសន្មត ចំពោះចំនួនភាគហ៊ុន និង/ឬ ជម្រើសភាគហ៊ុន ដែលរំពឹងថា ត្រូវប្រគល់។ នាដំណាច់កាឭយបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារបានកែប្រែការប៉ាន់ស្មានរបស់ខ្លួន ចំពោះការប៉ាន់ស្មានចំនួនភាគហ៊ុន និង/ឬ ជម្រើសភាគហ៊ុន ដែលរំពឹងថា ត្រូវប្រគល់ ដោយផ្អែកទៅតាមលក្ខខណ្ឌ ក្នុងការផ្តល់អត្ថប្រយោជន៍។ ផលប៉ះពាល់ណាមួយ នៃការកែប្រែនេះ ចំពោះការប៉ាន់ស្មាន ដែលត្រូវបានធ្វើឡើង ពីដំបូង ត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ចំណេញ ឬខាត នូវចំនួនស្មើគ្នានឹងចំនួននិយ័តកម្ម នៅក្នុងមូលធន។ នៅពេលដែលទឹកប្រាក់រង្វាន់ នៃការរៀបចំការទូទាត់ ផ្អែកតាមភាគហ៊ុន មានលក្ខខណ្ឌផ្តល់ ដែលមានចំណាត់ថ្នាក់ ចំណែកតូច១នីមួយៗ ត្រូវបានទទួលស្គាល់ជាចំនួនប្រាក់រង្វាន់ ដាច់ដោយឡែក ដូចនេះតម្លៃសមស្របរបស់ចំណែកតូច១នោះ ត្រូវបានទទួលស្គាល់ ក្នុងរយៈពេលផ្តល់ភាគហ៊ុននោះ។

ធនាគារប៉ាន់ស្មានតម្លៃសមស្រប នៃជម្រើស ដោយប្រើវិធីសាស្ត្រ Black-Scholes model។ វិធីសាស្ត្រនេះ តម្រូវឱ្យមានជាតុចូល ដូចជាតម្លៃកំណត់ តម្លៃភាគហ៊ុន នាពេលបច្ចុប្បន្ន ពេលវេលាហួសកំណត់ អត្រាការប្រាក់ ដែលគ្មានហានិភ័យ និងភាពប្រែប្រួលបង្កប់ នៃជម្រើសនោះ។

នៅពេលដែលមានការកែប្រែផែនការទូទាត់ ផ្អែកតាមភាគហ៊ុនកើតឡើង តម្លៃសមស្រប នៅកាលបរិច្ឆេទផ្តល់ភាគហ៊ុន នៅតែត្រូវបានទទួលស្គាល់ជាបន្ត រួមជាមួយនឹងតម្លៃបន្ថែមណាមួយ ដែលកើតឡើង នៅកាលបរិច្ឆេទ នៃការកែប្រែនោះ ប្រសិនបើលក្ខខណ្ឌមិនមែនទីផ្សារ ត្រូវបានបំពេញ។

## ២.១៧ ទុនបម្រុង តាមបទប្បញ្ញត្តិ

ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវបានតម្រូវឱ្យគណនាសំវិធានធន តាមច្បាប់ អនុលោមទៅតាមប្រកាសលេខធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ សារាចរណែនាំលេខ ធ៧-០១៨-០០១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ និងសារាចរណែនាំលេខ ធ៧-០២១-២៣១៤ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ (អនុវត្តពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤) ស្តីពីចំណាត់ថ្នាក់ហានិភ័យ តណទាន និងសំវិធានធន លើឥនភាព នៃតម្លៃ។ ប្រសិនបើសំវិធានធន តាមបទប្បញ្ញត្តិបង្ករ មានចំនួនខ្ពស់ជាងឥនភាព នៃតម្លៃបង្ករ ផ្អែកតាម CIFRS ៩ នោះ «ការបំពេញបន្ថែម - topping up» នឹងត្រូវបានកត់ត្រាជាទុនបម្រុង តាមបទប្បញ្ញត្តិ និងត្រូវបានដាក់បង្ហាញ នៅក្នុងមូលធន។ បន្ទាប់មកទុនបម្រុង ត្រូវបានកត់ត្រាបញ្ច្រាស (រហូតដល់សូន្យ) ប្រសិនបើសំវិធានធន តាមច្បាប់បង្ករ មានចំនួនស្មើគ្នា ឬទាបជាងឥនភាព នៃតម្លៃបង្ករ ដែលផ្អែកតាម CIFRS ៩។ ទុនបម្រុង តាមបទប្បញ្ញត្តិត្រូវបានតម្កល់ទុកមួយឡែក ជាទ្រនាប់ទុន ហើយមិនអាចបែងចែកបាន និងមិនត្រូវបានអនុញ្ញាតឱ្យរួមបញ្ចូល នៅក្នុងការគណនាមូលនិធិថ្នាល់សុទ្ធទេ។

## ២.១៨ ចំណូល និងចំណាយការប្រាក់

ចំណូល និងចំណាយការប្រាក់ ពីឧបករណ៍ហិរញ្ញវត្ថុ ដែលវាស់វែង តាមថ្លៃដើមបានរំលស់ ត្រូវបានទទួលស្គាល់ ក្នុងចំណូលការប្រាក់ និងចំណាយការប្រាក់ ក្នុងចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព គឺជាវិធីសាស្ត្រ ក្នុងការគណនាថ្លៃដើមដករំលស់ នៃទ្រព្យសកម្មហិរញ្ញវត្ថុមួយឬបំណុលហិរញ្ញវត្ថុមួយ និងជាវិធីសាស្ត្រក្នុងការបែងចែកចំណូលការប្រាក់ឬចំណាយការប្រាក់ លើរយៈពេល ដែលពាក់ព័ន្ធ។ អត្រាការប្រាក់មានប្រសិទ្ធភាព គឺជាអត្រា ដែលធ្វើអប្បហារជាក់ស្តែង ចំពោះការទូទាត់សាច់ប្រាក់ ឬបង្កាន់ដៃទទួលប្រាក់ប៉ាន់ស្មាន នាពេលអនាគត ក្នុងរយៈពេលនៃអាយុកាលប៉ាន់ស្មាន របស់ឧបករណ៍ហិរញ្ញវត្ថុ ឬក្នុងរយៈពេលណាមួយ ដែលខ្លីជាង ទៅតាមភាពសមស្រប ចំពោះសមតុល្យយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ នៅពេលគណនាអត្រាការប្រាក់មានប្រសិទ្ធភាព ធនាគារបានកត់ត្រារាល់លក្ខខណ្ឌ ក្នុងកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ និងបានរួមបញ្ចូលនូវកម្រៃ ឬកំណើនចំណាយនានា ដែលបានចំណាយដោយផ្ទាល់ ទៅលើឧបករណ៍នោះ នឹងវាជាផ្នែកមួយ នៃអត្រាការប្រាក់មានប្រសិទ្ធភាព ប៉ុន្តែមិនមែនជាការខាតឥណទាន នាពេលអនាគតទេ។

ចំណូលការប្រាក់ ត្រូវបានគណនា ដោយអនុវត្ត នូវអត្រាការប្រាក់មានប្រសិទ្ធភាព ចំពោះសមតុល្យយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ លើកលែងតែចំពោះ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានឱនភាព នៃតម្លៃ ដែលបានទិញ ឬ បានបង្កើតឡើង (Purchased or originated credit-impaired financial assets - POCI) ដែលអត្រាការប្រាក់ មានប្រសិទ្ធភាព សម្រាប់កែតម្រូវតណទានលើកដំបូង ត្រូវបានអនុវត្តចំពោះថ្លៃដើមដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។
- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមែនជា POCI ប៉ុន្តែបានក្លាយជាឥណទាន ដែលមានឱនភាពនៃតម្លៃមួយផ្នែកធំ (ឬ «ដំណាក់កាលទី៣») ដែលចំណូលការប្រាក់ ត្រូវបានគណនា ដោយប្រើអត្រាការប្រាក់មានប្រសិទ្ធភាព ចំពោះថ្លៃដើមដករំលស់របស់វា (ឧ. កាត់កង ជាមួយនឹងសំវិធានធន សម្រាប់ការខាតឥណទានរំពឹងទុក)។

### ២.១៩ ចំណូលកម្រៃ និងជើងសា

ចំណូលកម្រៃ និងជើងសា ត្រូវបានទទួលស្គាល់ជាចំណូល នៅពេលដែលវាបានបំពេញតាមគំរូលក្ខខណ្ឌទាំងអស់ (កាតព្វកិច្ច នៃដំណើរការ ត្រូវបានទទួលយក ហើយការគ្រប់គ្រង ត្រូវបានផ្ទេរក្នុងពេលវេលាណាមួយ ឬចំណុច នៃពេលវេលាណាមួយ)។

កម្រៃ ក្នុងដំណើរការផ្តល់ឥណទានបុរេប្រទាន និងហិរញ្ញប្បទាន ដែលទំនងជាអាចត្រូវបានផ្តល់ឱ្យ ត្រូវបានពន្យារ (ជាមួយនឹងចំណាយផ្ទាល់ពាក់ព័ន្ធ) ហើយចំណូល ដែលជាផ្នែក នៃអត្រាការប្រាក់ប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ដោយធ្វើនិយ័តកម្ម ទៅលើអត្រាការប្រាក់ប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុនោះ។

## ៣. ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ និងការវិនិច្ឆ័យ

ធនាគារធ្វើការប៉ាន់ស្មាន និងការសន្មត ដោយគិតទៅលើអនាគតកាល។ តាមនិយមន័យ លទ្ធផល នៃការប៉ាន់ស្មានគណនេយ្យ កម្រស្មើគ្នា ជាមួយនឹងលទ្ធផលជាក់ស្តែងណាស់។ ដើម្បីធ្វើឱ្យមានតិកាព័ត៌មាន នៃការប៉ាន់ស្មានកាន់តែមានភាពល្អប្រសើរឡើង អញ្ញត្តិជាក់លាក់សំខាន់ៗ ដែលជាធាតុធ្វើឱ្យមានការប៉ះពាល់ជាសារវន្ត ចំពោះលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានធ្វើតេស្តរកភាពងាយប្រែប្រួលរបស់វា ចំពោះបម្រែបម្រួលប៉ារ៉ាម៉ែត្រមូលដ្ឋាន។ ការប៉ាន់ស្មាន និងការសន្មត ដែលមានហានិភ័យខ្លាំង ដែលនាំឱ្យមានការកែសម្រួលជាសារវន្ត ទៅនឹងសមតុល្យ យោងទ្រព្យសកម្ម និងបំណុល នៅក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ត្រូវបានកត់សម្គាល់ ដូចខាងក្រោម៖

#### i) សំវិធានធន សម្រាប់ការខាតឥណទានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែង តាមថ្លៃដើមបានរំលស់

សំវិធានធន សម្រាប់ការខាតឥណទានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែង តាមថ្លៃដើមបានរំលស់ តម្រូវឱ្យប្រើប្រាស់គំរូស្មុគស្មាញ និងការសន្មតជាក់លាក់ ចំពោះលក្ខខណ្ឌសេដ្ឋកិច្ច នាពេលអនាគត និងលក្ខណៈរបស់ឥណទាន (ឧ. លទ្ធភាព ដែលអតិថិជនអាចមិនសងប្រាក់ និងបណ្តាលឱ្យមានការខាតបង់)។

ការវិនិច្ឆ័យជាក់លាក់មួយចំនួន ក៏ត្រូវបានតម្រូវ នៅក្នុងការអនុវត្តតម្រូវការគណនេយ្យ សម្រាប់ការវាស់វែង ECL ផងដែរ ដូចជា៖

- ការបង្កើតក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានលក្ខណៈស្រដៀងគ្នា ក្នុងគោលបំណង ដើម្បីវាស់វែង ECL
- ជ្រើសរើសគំរូ និងការសន្មតសមស្រប សម្រាប់ការវាស់វែង ECL
- ការកំណត់លក្ខណៈវិនិច្ឆ័យ ចំពោះកំណើនហានិភ័យឥណទានអតិថិជន ដែលមានកំណើនហានិភ័យជាសារវន្ត (SICR)
- អនុវត្តការសន្មត និងការវិភាគ លើលំហូរសាច់ប្រាក់ នាពេលអនាគតរំពឹងទុក និងព័ត៌មានដែលព្យាករ អំពីអនាគត
- អនុវត្តវិធីសាស្ត្របន្ថែមរបស់គណៈគ្រប់គ្រង ដើម្បីចាប់យកនូវវិវឌ្ឍថ្មីៗ ដែលមិនមាននៅក្នុងគំរូ ECL ដែលមានស្រាប់
- អនុវត្តវិធីសាស្ត្រមិនមែនបច្ចេកទេស ចំពោះ ECL ដោយពិចារណាបន្ថែមលក្ខណៈវិនិច្ឆ័យផ្នែកគុណភាពបន្ថែម សម្រាប់ SICR ចំពោះឥណទាន ដែលត្រូវបានរៀបចំឡើងវិញ ដែលមិនត្រូវបានរួមបញ្ចូល នៅក្នុងគំរូ ECL ដែលមានស្រាប់។

#### ii) អត្ថប្រយោជន៍បុគ្គលិករយៈពេលវែងផ្សេងៗ - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

តម្លៃបច្ចុប្បន្ន នៃកាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ អាស្រ័យទៅលើកត្តាមួយចំនួន ដែលត្រូវបានកំណត់ ដោយមូលដ្ឋានមួយ ដែលប្រើប្រាស់ការសន្មតមួយចំនួន។ ការសន្មតដែលត្រូវបានប្រើប្រាស់ ក្នុងការកំណត់ចំណាយចុងក្រោយ សម្រាប់ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ រួមមានអត្រាបម្រែបម្រួលបុគ្គលិក និងអត្រាអប្បហារ។ បម្រែបម្រួលណាមួយ ក្នុងការសន្មតទាំងនេះ នឹងធ្វើឱ្យមានផលប៉ះពាល់ លើសមតុល្យយោងរបស់កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។

#### iii) លក្ខខណ្ឌភតិសន្យា

ក្នុងការកំណត់លក្ខខណ្ឌភតិសន្យា គណៈគ្រប់គ្រងពិចារណា ទៅលើភាពជាក់ស្តែង និងលក្ខខណ្ឌទាំងអស់ ដែលបង្កើតឱ្យមានការលើកទឹកចិត្ត ផ្នែកសេដ្ឋកិច្ច ដើម្បីអនុវត្តជម្រើស ក្នុងការបន្តការជួល ឬជម្រើសមិនបន្តការជួល។ ជម្រើសក្នុងការបន្តការជួល (ឬរយៈពេល បន្ទាប់ពីជម្រើសបញ្ឈប់ការជួល) ត្រូវបានរួមបញ្ចូល នៅក្នុងលក្ខខណ្ឌភតិសន្យា ប្រសិនបើភតិសន្យានោះ មានភាពជាក់លាក់សមហេតុផល សម្រាប់ការបន្តការជួល (ឬមិនបញ្ឈប់តែប៉ុណ្ណោះ)។

#### iv) ការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសកម្ម

អាយុកាល នៃការប្រើប្រាស់ទ្រព្យសកម្មរបស់ធនាគារ ត្រូវបានប៉ាន់ស្មាន ផ្អែកលើការរំពឹងទុកទ្រព្យសកម្មអាចប្រើប្រាស់បាន។ ការប៉ាន់ស្មានអាយុកាលទ្រព្យសម្បត្តិ និងបរិក្ខារ និងសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មរបស់ធនាគារ ត្រូវបានត្រួតពិនិត្យជាប្រចាំ តាមកាលកំណត់ និងកែប្រែ ប្រសិនបើការរំពឹងទុក ខុសពីការប៉ាន់ស្មាន ដោយសាររូបរាង បច្ចេកទេស ឬសម័យកាល និងតាមច្បាប់ ឬការកំណត់ការប្រើប្រាស់ទ្រព្យសកម្មរបស់ធនាគារ។ បន្ថែមលើសពីនេះ ការប៉ាន់ស្មានអាយុកាល គឺផ្អែកទៅលើការវាយតម្លៃ តាមការអនុវត្ត នៅក្នុងវិស័យ ការវាយតម្លៃ តាមអ្នកបច្ចេកទេសខាងក្នុង និងបទពិសោធន៍លើទ្រព្យសកម្មដែលស្រដៀងគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលប្រតិបត្តិការ នៅពេលអនាគតអាចប៉ះពាល់ជាសារវន្ត ដោយការកែប្រែការប៉ាន់ស្មាន តាមកត្តា ដែលរៀបរាប់ខាងលើ។ ចំនួនទឹកប្រាក់ និងពេលវេលា នៃការកត់ត្រាចំណាយនៃរយៈពេលណាមួយ អាចមានផលប៉ះពាល់ ដោយសារការកែប្រែ នៃកត្តាទាំងនោះ។ ការថយចុះ នៃការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងសិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម នឹងកើនឡើងការទទួលស្គាល់ចំណាយប្រតិបត្តិការ និងថយចុះទ្រព្យសកម្មរយៈពេលវែង។

#### v) ការវាយតម្លៃគំរូអាជីវកម្ម

ការធ្វើចំណាត់ថ្នាក់ និងការវាស់វែង នៃទ្រព្យសកម្មហិរញ្ញវត្ថុ អាស្រ័យលើលទ្ធផល នៃការទូទាត់តែប្រាក់ដើម និងការប្រាក់ (SPPI) និងការធ្វើតេស្តគំរូអាជីវកម្ម។ ធនាគារកំណត់គំរូអាជីវកម្ម តាមកម្រិតមួយ ដែលឆ្លុះបញ្ចាំងពីរបៀប ដែលក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានគ្រប់គ្រងរួមគ្នា ដើម្បីសម្រេចបាននូវគោលបំណងអាជីវកម្មជាក់លាក់មួយ។ ការវាយតម្លៃនេះ រួមបញ្ចូលទាំងការវិនិច្ឆ័យ ដែលឆ្លុះបញ្ចាំង ពីភស្តុតាងពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងរបៀប ដែលការអនុវត្ត ទៅលើទ្រព្យសកម្ម ត្រូវបានវាយតម្លៃ និងការអនុវត្ត ត្រូវបានវាស់វែង និងហានិភ័យ ដែលប៉ះពាល់ដល់ការអនុវត្តទៅលើទ្រព្យសកម្ម និងរបៀប ដែលត្រូវបានគ្រប់គ្រង និងរបៀប ដែលអ្នកគ្រប់គ្រងទ្រព្យសកម្ម ត្រូវបានផ្តល់សំណង។

ធនាគារត្រួតពិនិត្យទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានវាស់វែង តាមថ្លៃដើមបានរំលស់ ឬតម្លៃសមស្រប តាមរយៈចំណូលលម្អិតផ្សេងៗ ដែលត្រូវបានឈប់ទទួលស្គាល់ មុនកាលកំណត់ ដើម្បីស្វែងយល់ពីហេតុផល សម្រាប់ការលក់ចេញ នូវទ្រព្យសកម្មហិរញ្ញវត្ថុនោះ និងថាតើហេតុផលស្របគ្នានឹងគោលបំណង នៃអាជីវកម្ម ដែលទ្រព្យសកម្ម ត្រូវបានកាន់កាប់ដែរឬទេ។ ការត្រួតពិនិត្យ គឺជាផ្នែកមួយ នៃការបន្តវាយតម្លៃរបស់ធនាគារ ថាតើគំរូអាជីវកម្ម ដែលទ្រព្យសកម្មហិរញ្ញវត្ថុនៅសល់ត្រូវបានគ្រប់គ្រងបន្ត មានលក្ខណៈសមស្របដែរឬទេ ហើយប្រសិនបើវាមិនសមស្រប ថាតើមានការផ្លាស់ប្តូរគំរូអាជីវកម្មដែរឬទេ ហើយដូច្នេះការផ្លាស់ប្តូរ នាពេលអនាគត ទៅលើការធ្វើចំណាត់ថ្នាក់នៃទ្រព្យសកម្មទាំងនោះ។

#### vi) ពន្ធ

ពន្ធ ត្រូវបានគណនា ដោយផ្អែកលើមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិពន្ធ និងការបកស្រាយបច្ចុប្បន្ន។ ទោះបីជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងនេះ មានការប្រែប្រួល តាមកាលកំណត់ និងការកំណត់ចុងក្រោយ នៃការចំណាយពន្ធ នឹងត្រូវធ្វើឡើង បន្ទាប់ពីការត្រួតពិនិត្យ ដោយអគ្គនាយកដ្ឋានពន្ធដារ (GDT)។ លិខិតប្រកាសពន្ធរបស់ធនាគារ គឺស្ថិតនៅក្រោមការត្រួតពិនិត្យ តាមកាលកំណត់ ដោយអគ្គនាយកដ្ឋានពន្ធដារ។ ដោយសារការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពន្ធ ចំពោះប្រតិបត្តិការជាច្រើនប្រភេទ គឺងាយនឹងមានការបកស្រាយផ្សេងៗគ្នា ហើយសមតុល្យ ដែលបានរាយការណ៍ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ អាចត្រូវបានផ្លាស់ប្តូរ នាពេលក្រោយ តាមការកំណត់ចុងក្រោយ ដោយអគ្គនាយកដ្ឋានពន្ធដារ។

ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់ សម្រាប់ការខាតបង់ពន្ធ ដែលមិនបានប្រើប្រាស់ទាំងអស់ ហើយភាពខុសគ្នាជាបណ្តោះអាសន្ន ទៅលើការពង្រីកវិសាលភាព ដែលវាទំនងជាថា ប្រាក់ចំណេញជាប់ពន្ធ នាពេលអនាគត នឹងអាចធ្វើការផ្ទៀបទៅនឹងការខាតបង់ ដែលអាចប្រើប្រាស់បាន។ ការវិនិច្ឆ័យការគ្រប់គ្រងសំខាន់ៗ តម្រូវឱ្យធ្វើការកំណត់នូវសមតុល្យ នៃទ្រព្យសកម្មពន្ធពន្យារ ដែលអាចត្រូវបានទទួលស្គាល់ ដោយផ្អែកលើពេលវេលា និងកម្រិត នៃប្រាក់ចំណូលជាប់ពន្ធ នាពេលអនាគត រួមជាមួយនឹងយុទ្ធសាស្ត្ររៀបចំផែនការពន្ធ នាពេលអនាគត។

**vii) ឱនភាពតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ**

ឱនភាពតម្លៃកើតឡើង នៅពេលតម្លៃយោងរបស់ទ្រព្យសកម្ម ឬឯកតា បង្កើតសាច់ប្រាក់លើសពីសមតុល្យអាចប្រមូលមកវិញបាន ដោយកំណត់យកតម្លៃណាមួយ ដែលខ្ពស់ជាង រវាងតម្លៃសមស្របដកថ្លៃដើម ក្នុងការលក់ និងតម្លៃប្រើប្រាស់។ ការគណនាតម្លៃសមស្របដកថ្លៃដើម ក្នុងការលក់ ត្រូវបានផ្អែកលើទិន្នន័យ ដែលមានស្រាប់ ពីប្រតិបត្តិការលក់ នៅក្នុងប្រតិបត្តិការជំហរាងដៃ នៃទ្រព្យសកម្ម ដែលមានភាពស្រដៀងគ្នា ឬតម្លៃទីផ្សារ ដែលអាចសង្កេតបាន ដកថ្លៃដើមបន្ថែម សម្រាប់ការលក់ចេញនូវទ្រព្យសកម្ម។ ការគណនាតម្លៃប្រើប្រាស់ ត្រូវបានផ្អែកលើលំហូរសាច់ប្រាក់ ដែលបានធ្វើអប្បហារ។ លំហូរសាច់ប្រាក់ បានមកពីថវិកា និងមិនរាប់បញ្ចូលសកម្មភាពរៀបចំរចនាសម្ព័ន្ធឡើងវិញ ដែលធនាគារមិនទាន់បានសន្យា ឬការវិនិយោគ នាពេលអនាគតសំខាន់ៗ ដែលនឹងលើកកម្ពស់ការអនុវត្តរបស់ទ្រព្យសកម្ម នៃឯកតាបង្កើតសាច់ប្រាក់ ដែលកំពុងត្រូវបានសាកល្បង។ សមតុល្យ ដែលអាចប្រមូលមកវិញ គឺមានផលប៉ះពាល់ខ្លាំងបំផុត ចំពោះអត្រាអប្បហារ ដែលបានប្រើ សម្រាប់គំរូលំហូរសាច់ប្រាក់ ដែលបានធ្វើអប្បហារ។

## ៤. សាច់ប្រាក់ក្នុងដៃ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| *រយៈពេលខ្លី* | | | | |
| ប្រាក់ដុល្លារអាមេរិក | ៣៤.៧៨៨.២៦៣ | ១៤០.០២២.៧៥៩ | ៤៣.៩៨១.៥៩០ | ១៧៩.៦៦៤.៧៩៥ |
| ប្រាក់រៀល | ៤.៧០៥.១៥៨ | ១៨.៩៣៨.២៦១ | ៧.០៣១.៩៥៥ | ២៨.៧២៥.៥៣៦ |
| | ៣៩.៤៩៣.៤២១ | ១៥៨.៩៦១.០២០ | ៥១.០១៣.៥៤៥ | ២០៨.៣៩០.៣៣១ |

## ៥. ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| *រយៈពេលខ្លី* | | | | |
| គណនីចរន្ត | ៨៦.៨៧៣.៣៨៤ | ៣៨៩.៦៦៥.៣៧១ | ៥៨.៧២៩.៩៩០ | ២៣៩.៩១២.០០៩ |
| គណនីទុទាត់ | ១៣.៦៥២.៩១៨ | ៥៤.៩៥២.៩៩៥ | ១៥.៥៦១.២២៨ | ៦៣.៥៦៧.៦១៦ |
| មូលបត្រអាច ជួញដូរបាន (i) | ៤.៥០៥.១៩២ | ១៨.១៣៣.៣៩៧ | ៧.៨០៤.៣៣៨ | ៣១.៨៨០.៧០៥ |
| | ១០៥.០៣១.៤៩៨ | ៤២២.៧៩១.៧៦៣ | ៨២.០៩៥.៥៥២ | ៣៣៥.៣៦០.៣៣០ |

(i) ធនាគារ បានតម្កល់ មូលបត្រអាចជួញដូរបាន (NCDs) ដែលមានសមតុល្យ ចំនួន ៤.៥០៥.១៩២ដុល្លារអាមេរិក (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣៖ ៧.៨០៤.៣៣៨ដុល្លារអាមេរិក) ជាមួយធនាគារកណ្តាល ជាទ្រព្យបញ្ចាំ លើហ្វាស៊ីលីធី សម្រាប់ទូទាត់។

អត្រាការប្រាក់ប្រចាំឆ្នាំ នៃប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល មានដូចខាងក្រោម៖

| | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ |
|---|---|---|
| គណនីចរន្ត | 0% | 0% |
| គណនីទុទាត់ | 0% | 0% |
| មូលបត្រអាចជួញដូរបាន | ០,០៨% - ៣,២៣% | 0,0៧% - ៣,២៣% |

## ៦. ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| *រយៈពេលខ្លី* | | | | |
| *ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារក្នុងប្រទេស៖* | | | | |
| ប្រាក់បញ្ញើមានកាលកំណត់ | ១២០.៦១៩.៥៥៨ | ៤៨៥.៤៩៣.៧២១ | ២៩.៧៨៣.៣៣៤ | ១២១.៦៦៤.៩១៩ |
| គណនីចរន្ត | ១.៨២៣.៣១០ | ៧.៣៣៨.៨២៣ | ១.៣៤៩.៣៨០ | ៥.៥១២.២១៧ |
| គណនីសន្សំ | ២.០១៨.៩៣៥ | ៨.១២៦.២១៣ | ២.០០៤.៦១៥ | ៨.១៨៨.៨៥២ |
| | ១២៤.៨៦១.៨០៣ | ៥០០.៩៥៨.៧៥៧ | ៣៣.១៣៧.៣២៩ | ១៣៥.៣៦៥.៩៨៨ |
| *ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារក្រៅប្រទេស៖* | | | | |
| ប្រាក់បញ្ញើមានកាលកំណត់ | ២១០.១២២.៥០៩ | ៨៤៥.៧៤៣.០៩៩ | ២១៥.៨៧៥.៦១២ | ៨៨០.២១៧.៨៧៥ |
| គណនីចរន្ត | ១១.៣៩៤.៨២០ | ៤៥.៨៦៤.១៥០ | ៨.៨៤០.៨៣១ | ៣៦.១១៣.១៦២ |
| | ២២១.៥១៧.៣២៩ | ៨៩១.៦០៧.២៤៩ | ២២៤.៣១៦.០៨៣ | ៩១៦.៣៣១.០៣៧ |
| ដក៖ សំវិធានធន សម្រាប់ការខាតបណ្តាទានរំពឹងទុក | (១៩៥.៩០៩) | (៧៨៨.៥៣៣) | (១៧៦.០៨៧) | (៧១៩.១៥២) |
| | ៣៤៥.៧៨៣.២២៣ | ១.៣៩១.៧៧៧.៨៧៣ | ២៥៧.២៧៧.៣២៥ | ១.០៥០.៩៧៧.៨៧៣ |

អត្រាការប្រាក់ប្រចាំឆ្នាំ នៃប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ មានដូចខាងក្រោម៖

| | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ |
|---|---|---|
| គណនីចរន្ត | 0,00% - 0,00% | 0,00% - 0,00% |
| គណនីសន្សំ | ១,២៥% | ១,២៥% |
| ប្រាក់បញ្ញើមានកាលកំណត់ | ២,៧៥% - ៥,៥0% | ៣,២0% - ៥,៦២% |

## ៧. តណទាន និងបុរេប្រទានវាស់វែង តាមថ្លៃដើមបានរំលស់

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| តណទានរយៈពេលវែង | ៤៨0.៦១៧.៧៤0 | ១.៩៣៤.៤៨៦.៤0៤ | ៤៨២.១១៣.៥៣៧ | ១.៩៦៩.៤៣៣.៧៩៩ |
| តណទានទិញតេហដ្ឋាន | ២២៦.២៩៣.0២៨ | ៩១0.៨២៩.៤៣៨ | ២៨៣.១៦២.៣២៥ | ៩៩៣.៣១៨.0៩៨ |
| តណទានវិបារូបន៍ | ១៨៧.៩៨៦.៨៣៥ | ៥៩៥.៦៤៧.0១១ | ១២៥.១៧២.៩៣៣ | ៥១១.៣៣១.៤៣១ |
| សក្ខីបត្រតណទាន ជំនឿទុកចិត្ត | ៤៩.៧៦២.២៥0 | ២00.២៩៣.0៤៦ | ៤៨.៥៣៥.0៥៧ | ១៩៨.២៦៥.៧0៨ |
| តណទាន ដែលអាច ប្រើឡើងវិញបាន | ២៨.៦៣៨.៥៥៤ | ១១៥.២៧0.១៨0 | ២៣.២៥៩.១៣៩ | ៩៥.0១៣.៥៨៣ |
| តណទានរយៈពេលខ្លី | - | - | ១៣.៦៧៤.៨៤១ | ៥៥.៨៦១.៧២៥ |
| តណទានយានយន្ត | ១៣.៨២៧.៤៣១ | ៥៥.៦៥៥.៤90 | 90.៣៥៧.៩៨៤ | ៤២.៣១២.៣៦៥ |
| ប័ណ្ណតណទាន | ២.១២៣.៨៥៦ | ៨.៥៤៨.៥២0 | ១.៩៥៤.៥៨១ | ៧.៩៨៤.៤៦៣ |
| តណទានបគ្គល | ៩0៥.៤២៩ | ៣.៦៤៤.៣៥២ | ១.៣៧៥.៦២0 | ៥.៦១៩.៤0៨ |
| តណទានដុលសរុប | ៩៥0.១៥៥.១២៣ | ៣.៨២៤.៣៧៤.៣៧១ | ៩៤៩.៦0៦.0១៧ | ៣.៨៧៩.១៤0.៥៧៩ |
| ដក៖ សំវិធានធន សម្រាប់ ការខាតតណទាន រំពឹងទុក (ក) | (៨.៨២0.១៦២) | (៣៥.៥0១.១៥៣) | (៨.៧៧១.៣៨៣) | (១៩.៤៩0.៩៣៦) |
| **តណទានសុទ្ធសរុប** | ៩៤១.៣៣៤.៩៦១ | ៣.៧៨៨.៨៧៣.២១៨ | ៩៤៤.៨៣៤.៦៧៨ | ៣.៨៥៩.៦៤៩.៦៤៣ |

### (ក) សំវិធានធន សម្រាប់ការខាតឥណទានរំពឹងទុក

សំវិធានធន សម្រាប់ការខាតឥណទានរំពឹងទុក តាមដំណាក់កាល មានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| ECL ១២ខែ (ដំណាក់កាលទី១) | **៣.៧៨៧.៩៦១** | **១៥.២៤៦.៥៤៣** | ២.៦១១.៧០៧ | ១០.៦៦៨.៨២៣ |
| ECL ពេញមួយអាយុកាល-មិនថយចុះតម្លៃឥណទាន (ដំណាក់កាលទី២) | **១.១៨០.៤៧៣** | **៤.៧៥១.៤០៤** | ៦០៨.១៩៤ | ២.៤៨៤.៤៧២ |
| ECL ពេញមួយអាយុកាល-ថយចុះតម្លៃឥណទាន (ដំណាក់កាលទី៣) | **៣.៨៥១.៧២៨** | **១៥.៥០៣.២០៦** | ១.៥៥១.៤៤២ | ៦.៣៣៧.៦៤១ |
| | **៨.៨២០.១៦២** | **៣៥.៥០១.១៥៣** | ៤.៧៧១.៣៤៣ | ១៩.៤៩០.៩៣៦ |

### (ខ) វិភាគ តាមប្រភេទអាជីវកម្ម

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| តំណាងទិញគេហដ្ឋាន | **២២៦.៣៧១.៣៨១** | **៩១១.១៤៤.៨០៩** | ២៨៣.២២៩.០៤១ | ៩៩៣.៥៩០.៦៣២ |
| លក់ដុំ និងលក់រាយ | **១៧៨.៩៩៦.៥១៧** | **៧២០.៤៦០.៩៨១** | ១៨៣.៨០៥.៨៣៥ | ៧៤០.៨៤៦.៨៣៦ |
| នាំចូល និងនាំចេញ | **១២៦.៩៨៦.៥១៨** | **៥១១.១២០.៧៣៥** | ១៣៦.៦៨៤.១៥៧ | ៥៥៨.៣៥៤.៧៨១ |
| ហិរញ្ញវត្ថុ ធានារ៉ាប់រង អចលនទ្រព្យ និងសេវាអាជីវកម្ម | **១០៨.១៥១.៧២៨** | **៤៣៥.៣១០.៧០៥** | ៧៩.៩៤១.៥៥៩ | ៣២៦.៥៦១.២៦៩ |
| សំណង់ | **៧៧.៨៨៤.៧១៨** | **៣១៣.៤៨៥.៩៩០** | ៥៧.៥៦៨.០២១ | ២៣៥.១៨៩.០២៦ |
| ផលិតកម្ម | **៦១.៧៦១.១៥២** | **២៨៩.៥៨៨.៦៣៧** | ៧៥.២៨៣.៩៦៨ | ៣០៧.៥៣៥.០០៩ |
| សេវាមិនមែនហិរញ្ញវត្ថុផ្សេងៗ | **៣៥.២៦៩.២៨៣** | **១៤១.៩៥៨.៨៦៤** | ៣៨.៦៨៧.៦៩៣ | ១៥៧.៨៧៥.៨២៦ |
| គ្រឹះស្ថានហិរញ្ញវត្ថុ | **៣៤.០៥៥.២៦០** | **១៣៧.០៧២.៤២២** | ៥៣.០៦១.៣៣៥ | ២១៦.៧៥៥.៥៥៣ |
| ការដឹកជញ្ជូន ឃ្លាំងទំនិញ និងទំនាក់ទំនង | **៣២.២១៩.១៩២** | **១២៩.៦៨២.២៤៨** | ២៦.០៦៦.៤៦៨ | ១០៦.៨៨១.៥២២ |
| អគ្គិសនី ហ្គាស និងទឹកស្អាត | **៨.៨៨៨.៥២៤** | **៣៥.៦១៥.៣០៩** | ៩.៩១១.៣៩៨ | ៤០.៨៨៨.០៦១ |
| កសិកម្ម | **៦.៦១៨.៥២២** | **២៦.៦៣៩.៥៥១** | ២.២៦០.៧៩៥ | ៩.២៣៥.៣៨៨ |
| ផ្សេងៗ | **៥២.៩៩២.៣២៨** | **២១៣.២៩៤.១២០** | ៤៣.១៤៩.៧៨៧ | ១៧៦.២៦៦.៧១៦ |
| តំណាងទាំងសរុប | **៩៥០.១៥៥.១២៣** | **៣.៨២៤.៣៧៤.៣៧១** | ៩៨៩.៦០៦.០១៧ | ៣.៨៧៩.១៤០.៥៧៩ |

### (គ) វិភាគ តាមចំណាត់ថ្នាក់ឥណទាន

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| *តំណាងដំណើរការ* | | | | |
| ចំនួនដុល | **៩០៣.២៦៩.៣៣៤** | **៣.៦៣៥.៦៥៩.០៧០** | ៩១៨.៨៣៨.៧២២ | ៣.៧៥៣.៤៥៦.១៧៩ |
| ចំនួនដែលមានហានិភ័យពេលមិនសង | **៩៦២.៦៣១.១៩៧** | **៣.៨៧៤.៥៩០.៥៦៨** | ៩៧៨.០៥៩.៨៨៥ | ៣.៩៩៥.៣៧៤.៦៣០ |
| សំវិធានធន សម្រាប់ការខាតឥណទានរំពឹងទុក | **៣.៧៨៧.៩៦១** | **១៥.២៤៦.៥៤៤** | ២.៦១១.៧០៧ | ១០.៦៦៨.៨២៣ |
| *តំណាងក្រោមដំណើរការ* | | | | |
| ចំនួនដុល | **២៤.១៦៥.០៦០** | **៩៧.២៦៤.៣៦៧** | ១៤.៦៨៥.២៥១ | ៥៩.៩៨៩.២៥០ |
| ចំនួនដែលមានហានិភ័យពេលមិនសង | **៣៦.១១១.៤០៦** | **១៤៥.៣៤៨.៤០៩** | ២២.២៩០.៤៩២ | ៩១.០៥៦.៦៦០ |
| សំវិធានធន សម្រាប់ការខាតឥណទានរំពឹងទុក | **១.១៨០.៤៧៣** | **៤.៧៥១.៤០៤** | ៦០៨.១៩៤ | ២.៤៨៤.៤៧២ |
| *តំណាងមិនដំណើរការ* | | | | |
| ចំនួនដុល | **២២.៧២០.៧២៩** | **៩១.៤៥០.៩៣៤** | ១៦.០៨២.០៤៤ | ៦៥.៦៩៥.១៥០ |
| ចំនួនដែលមានហានិភ័យពេលមិនសង | **២៣.៣១៤.៥៦៥** | **៩៣.៨៤១.១២៤** | ១៦.៣៥៥.៨៦៦ | ៦៦.៨១៣.៧១៣ |
| សំវិធានធន សម្រាប់ការខាតឥណទានរំពឹងទុក | **៣.៨៥១.៧២៨** | **១៥.៥០៣.២០៥** | ១.៥៥១.៤៤២ | ៦.៣៣៧.៦៤១ |
| សរុប | | | | |
| ចំនួនដុល | **៩៥០.១៥៥.១២៣** | **៣.៨២៤.៣៧៤.៣៧១** | ៩៨៩.៦០៦.០១៧ | ៣.៨៧៩.១៤០.៥៧៩ |
| ចំនួនដែលមានហានិភ័យពេលមិនសង | **១.០២២.០៥៧.១៦៨** | **៤.១១៣.៧៨០.១០១** | ១.០១៦.៧០៦.២៤៣ | ៤.១៥៣.២៤៥.០០៣ |
| សំវិធានធន សម្រាប់ការខាតឥណទានរំពឹងទុក | **៨.៨២០.១៦២** | **៣៥.៥០១.១៥៣** | ៤.៧៧១.៣៤៣ | ១៩.៤៩០.៩៣៦ |

### (ឃ) វិភាគ តាមកាលកំណត់ឥណទាន

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| មិនលើស ១ឆ្នាំ | **២៨៧.៧៤៣.៦៣៦** | **៩៩៧.១៦៨.១៣៥** | ២២៨.៩០០.៤៨៩ | ៩៣៥.០៥៨.៤៩៧ |
| លើស ១ឆ្នាំ និងមិនលើស ៣ឆ្នាំ | **៨៨.១០០.០២៧** | **៣៥៤.៦០២.៦០៩** | ៩៧.៨៤៧.៦៨៤ | ៣៩៩.៧០៧.៧៨៩ |
| លើស ៣ឆ្នាំ និងមិនលើស ៥ឆ្នាំ | **៦៥.៥៨៨.៥២៩** | **២៦៣.៩៩៣.៨២៩** | ១៨០.១៤៨.៨៦៩ | ៧៣៥.៩០៨.១៣០ |
| លើស ៥ឆ្នាំ | **៥៤៨.៧២២.៩៣១** | **២.២០៨.៦០៩.៧៩៨** | ៤៤២.៧០៨.៩៧៥ | ១.៨០៨.៨៦៦.១៦៣ |
| តំណាងទាំងសរុប | **៩៥០.១៥៥.១២៣** | **៣.៨២៤.៣៧៤.៣៧១** | ៩៨៩.៦០៦.០១៧ | ៣.៨៧៩.១៤០.៥៧៩ |

**(ង) វិភាគ តាមហានិភ័យឥណទាន**

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| ហានិភ័យធម្មតា | ៨៧៥.២៦០.៩៣៦ | ៣.៥២២.៩២៥.២៦៧ | ៨៥៦.៨៧៤.៣១៥ | ៣.៥០០.៣៣១.៥៧៦ |
| ហានិភ័យធំ (i) | ៧៤.៨៩៤.១៨៧ | ៣០១.៤៤៩.១០៤ | ៩២.៧៣១.៧០២ | ៣៧៨.៨០៩.០០៣ |
| តំណាងដុលសរុប | ៩៥០.១៥៥.១២៣ | ៣.៨២៤.៣៧៤.៣៧១ | ៩៤៩.៦០៦.០១៧ | ៣.៨៧៩.១៤០.៥៧៩ |

(i) ហានិភ័យធំ ត្រូវបានកំណត់និយមន័យ ដោយធនាគារកណ្តាលថា ជាហានិភ័យតំណាងទូទៅ ចំពោះអ្នកទទួលជាឯកត្តជនណាមួយ ដែលលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

**(ច) វិភាគ តាមទំនាក់ទំនង**

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| ភាគីពាក់ព័ន្ធ | ៣.៤០០.៧៦៩ | ១៣.៦៨៤.០៩៥ | ២.៨២១.៣២៣ | ១១.៥២៥.៩០៤ |
| ភាគីមិនពាក់ព័ន្ធ | ៩៤៦.៧៥៤.៣៥៤ | ៣.៨១០.៦៨៦.២៧៦ | ៩៤៦.៧៨៤.៦៩៤ | ៣.៨៦៧.៦១៥.៤៧៥ |
| តំណាងដុលសរុប | ៩៥០.១៥៥.១២៣ | ៣.៨២៤.៣៧៤.៣៧១ | ៩៤៩.៦០៦.០១៧ | ៣.៨៧៩.១៤០.៥៧៩ |

**(ឆ) វិភាគ តាមនិវាសនដ្ឋាន**

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| និវាសនជន | ៩៥០.១៥៥.១២៣ | ៣.៨២៤.៣៧៤.៣៧១ | ៩៤៩.៦០៦.០១៧ | ៣.៨៧៩.១៤០.៥៧៩ |
| តំណាងដុលសរុប | ៩៥០.១៥៥.១២៣ | ៣.៨២៤.៣៧៤.៣៧១ | ៩៤៩.៦០៦.០១៧ | ៣.៨៧៩.១៤០.៥៧៩ |

**(ជ) អត្រាការប្រាក់**

| | ២០២៤ | ២០២៣ |
|---|---|---|
| បំណុលតំណាងទាន | ១៨,០០% | ១៨,០០% |
| តំណាងបុគ្គល | ១២,០០%-២២,០០% | ៨,០០% - ២៤,០០% |
| តំណាងយានយន្ត | ៧,០០%-១៣,៥០% | ៦,៥០% - ១៥,០០% |
| តំណាងដែលអាចប្រើឡើងវិញបាន | ៧,០០%-១១,០០% | ៦,៨០% - ៨,២៥% |
| សប្តីបត្រតំណាងជំនឿទុកចិត្ត | ៦,៨០%-៩,០០% | ៦,៣០% - ៧,៨០% |
| តំណាងរយៈពេលខ្លី | ៥,៧៥%-៩,៥០% | ៥,៧៥% - ៨,៥០% |
| តំណាងវិបារូបន៍ | ៥,២៥%-១០,៥០% | ៦,៩០% - ១១,០០% |
| តំណាងទិញគេហដ្ឋាន | ៣,៥០%-១៣,៥០% | ៣,៥០% - ១២,០០% |
| តំណាងរយៈពេលវែង | ២,០០%-១៨,០០% | ២,០០% - ១៨,០០% |

## ៨. ប្រាក់តម្កល់ តាមបទប្បញ្ញត្តិ នៅធនាគារកណ្តាល

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| *រយៈពេលខ្លី* | | | | |
| ទុនបម្រុងកាតព្វកិច្ច (i) | ៨៣.៤៣៥.៤៩១ | ៣៣៥.៨២៧.៨៥១ | ៩៦.៣៩១.៥៤៧ | ៣៩៣.៧៥៩.៤៦៩ |
| *រយៈពេលវែង* | | | | |
| ប្រាក់តម្កល់ធានា លើដើមទុន (ii) | ៧.៥០០.០០០ | ៣០.១៨៧.៥០០ | ៧.៥០០.០០០ | ៣០.៦៣៧.៥០០ |
| | ៩០.៩៣៥.៤៩១ | ៣៦៦.០១៥.៣៥១ | ១០៣.៨៩១.៥៤៧ | ៤២៤.៣៩៦.៩៦៩ |

**(i) ទុនបម្រុងកាតព្វកិច្ច**

ទុនបម្រុងកាតព្វកិច្ច គឺជាទុនបម្រុងអប្បបរមា ដែលត្រូវបានគណនា តាមអត្រា ៧% (ឆ្នាំ២០២៣៖ ៧%) នៃប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់កម្ចី ជាប្រាក់រៀលប្រាក់រៀល និងគិតតាមអត្រា ១២,៥% (ឆ្នាំ២០២៣៖ ៩%) នៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់អតិថិជន សម្រាប់រូបិយប័ណ្ណផ្សេងទៀត។ ទុនបម្រុងកាតព្វកិច្ច ចំពោះប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់កម្ចីមិនមានការប្រាក់ទេ។

**(ii) ប្រាក់តម្កល់ធានា លើដើមទុន**

យោងតាមប្រកាសលេខ ធ៧-០១-១៣៦ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ចេញដោយធនាគារកណ្តាល ស្តីពីប្រាក់តម្កល់ធានា លើដើមទុន តម្រូវឱ្យធនាគារតម្កល់ប្រាក់ចំនួន ១០% នៃដើមទុនចុះបញ្ជីរបស់ធនាគារ ជាប្រាក់តម្កល់ធានា លើដើមទុន នៅធនាគារកណ្តាល។ ប្រាក់តម្កល់នេះ មិនសម្រាប់ប្រើប្រាស់ ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ ហើយត្រូវបង្វិលជូនធនាគារវិញ នៅពេលដែលធនាគារស្ម័គ្រចិត្តបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នៅក្នុងប្រទេសកម្ពុជា។

អត្រាការប្រាក់ប្រចាំឆ្នាំ នៃប្រាក់តម្កល់តាមច្បាប់ នៅធនាគារកណ្តាល មានដូចខាងក្រោម៖

| | ២០២៤ | ២០២៣ |
|---|---|---|
| ប្រាក់តម្កល់ធានា លើដើមទុន | ១,១៥% - ១,៣៣% | ១,១៥% - ១,៣៣% |
| ទុនបម្រុងកាតព្វកិច្ច | 0% | 0% |

## ៩. ភតិសន្យា

កំណត់សម្គាល់នេះ ផ្តល់នូវព័ត៌មាន អំពីភតិសន្យា ដែលធនាគារជាភតិក:។

ធនាគារជួលអគារមួយចំនួន សម្រាប់ធ្វើប្រតិបត្តិការជាការិយាល័យកណ្តាល និងការិយាល័យសាខា។ ជាទូទៅ កិច្ចសន្យាជួល ត្រូវបានធ្វើឡើង សម្រាប់រយៈពេលកំណត់ ចាប់ពី២ឆ្នាំ រហូតដល់ ១០ឆ្នាំ។ ភតិសន្យាទាំងនេះ មានរយៈពេលជួល ដែលបញ្ជាក់ពីការឡើងថ្លៃ និងសិទ្ធិបន្តកិច្ចសន្យាខុសៗគ្នា។ ចំពោះការបន្តកិច្ចសន្យាជាថ្មី លក្ខខណ្ឌ នៃភតិសន្យាទាំងនេះ ត្រូវបានចរចាឡើងវិញ។

**ក) សមតុល្យ ដែលត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៣) | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| *សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម (រយៈពេលវែង)* | | | | |
| អគារ | ៤.៣១៧.២៨១ | ១៧.៣៧៧.០៤៦ | ៥.៥៣៨.០៨៦ | ២២.៦២៣.០៨១ |
| | ៤.៣១៧.២៨១ | ១៧.៣៧៧.០៤៦ | ៥.៥៣៨.០៨៦ | ២២.៦២៣.០៨១ |
| *បំណុលភតិសន្យា* | | | | |
| រយៈពេលខ្លី | ១.៥៨៨.៦២៨ | ៦.២៣៣.២២៨ | ១.៥៨៩.២៣៧ | ៦.៣២៨.៦៣៣ |
| រយៈពេលវែង | ៣.៣៥៧.៨៧៦ | ១៣.៥១៣.៨៨១ | ៤.៦១៥.៦៦៣ | ១៨.៨៥៤.៩៨៤ |
| | ៤.៩០៦.១០៤ | ១៩.៧៨៧.០៦៩ | ៦.១៦៤.៩០០ | ២៥.១៨៣.៦១៧ |

ខាងក្រោម គឺជាសមតុល្យទ្រព្យសកម្ម និងបំណុលភតិសន្យា ដែលត្រូវបានទទួលស្គាល់ និងប្រែប្រួល ក្នុងអំឡុងការិយបរិច្ឆេទ៖

| | សិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម | | | |
|---|---|---|---|---|
| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| នាដើមការិយបរិច្ឆេទ | ៥.៥៣៨.០៨៦ | ២២.៦២៣.០៨១ | ៧.៣៣២.៣៥០ | ៣០.១៨៧.២៨៥ |
| បន្ថែម | ២៨៨.៩១៩ | ១.១៧៦.១៨៩ | ៥៩.០៣៩ | ២៤២.៦៥០ |
| បន្ទុកក្នុងការិយបរិច្ឆេទ | (១.៥០៩.៧២៤) | (៦.១៤៦.០៨៧) | (១.៧៥២.១០៤) | (៧.២០១.១៤៧) |
| ការកែតម្រូវ លើការកែប្រែ ចំពោះភតិសន្យា | - | - | (១០១.៩៩) | (៤១៥.៩២៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (២៧៦.១២៧) | - | (១៨៩.៧៧៩) |
| នាចុងការិយបរិច្ឆេទ | ៤.៣១៧.២៨១ | ១៧.៣៧៧.០៥៦ | ៥.៥៣៨.០៨៦ | ២២.៦២៣.០៨១ |

| | បំណុលភតិសន្យា | | | |
|---|---|---|---|---|
| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| នាដើមការិយបរិច្ឆេទ | ៦.១៦៤.៩០០ | ២៥.១៨៣.៦១៧ | ៧.៩៣៥.២៦១ | ៣២.៦៦៩.៤៧០ |
| បន្ថែម | ២៨៨.៩១៩ | ១.១៧៦.១៨៩ | ៥៩.០៣៩ | ២៤២.៦៥០ |
| ការបង្កើនការប្រាក់ | ២២២.២៦៣ | ៩០៤.៨៣៣ | ២៨៨.៥៤៤ | ១.១៨៥.៩១៦ |
| ការកែតម្រូវ លើការកែប្រែ ចំពោះភតិសន្យា | - | - | (៣៩០.៧៣៣) | (១.៦០៥.៩១៣) |
| ការទូទាត់ | (១.៧៦៩.៩៧៨) | (៧.២០៥.៥៨០) | (១.៧២៧.២១១) | (៧.០៩៨.៨៣៧) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៣១១.៩៩០) | - | (២០៩.៦៦៩) |
| នាចុងការិយបរិច្ឆេទ | ៤.៩០៦.១០៤ | ១៩.៧៤៧.០៦៩ | ៦.១៦៤.៩០០ | ២៥.១៨៣.៦១៧ |
| តិចជាង ១ ឆ្នាំ | ១.៧១២.៧៥១ | ៦.៨៩៣.៨២៣ | ១.៨៥១.៨២៥ | ៧.៥៦៤.៧០៥ |
| ចាប់ពី ១ ទៅ ៥ ឆ្នាំ | ៣.៣៣៤.៣៥៧ | ១៣.៤២០.៧៨៧ | ៤.៨៩០.៣០៧ | ១៩.៩៧៦.៩០៤ |
| ច្រើនជាង ៥ ឆ្នាំ | ៨៨.៨៨៩ | ៣៥៧.៧៧៨ | ៣២៨.៨៨៩ | ១.៣៤៣.៥១២ |
| | ៥.១៣៥.៩៩៧ | ២០.៦៧២.៣៨៨ | ៧.០៧១.០២១ | ២៨.៨៨៥.១២១ |

**ខ) សមតុល្យ ដែលត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ចំណូលលម្អិត**

| | សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| រំលស់សិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម (កំណត់សម្គាល់ ២៨) | | | | |
| អគារ | ១.៥០៩.៧២៤ | ៦.១៤៦.០៨៧ | ១.៧៥២.១០៤ | ៧.២០១.១៤៧ |
| ចំណាយការប្រាក់ លើបំណុលភតិសន្យា (កំណត់សម្គាល់ ២៨) | | | | |
| អគារ | ២២២.២៦៣ | ៩០៤.៨៣៣ | ២៨៨.៥៤៤ | ១.១៨៥.៩១៦ |
| ចំណាយ ពាក់ព័ន្ធនឹងភតិសន្យារយៈពេលខ្លី (រួមបញ្ចូលក្នុងចំណាយប្រតិបត្តិការផ្សេងៗ) (កំណត់សម្គាល់ ២៩) | ២២៥.១១៥ | ៩១៦.៤៤៣ | ១៥២.៤៧៦ | ៦២៦.៦៧៦ |
| ចំណាយពាក់ព័ន្ធនឹងភតិសន្យាសរុប | ១.៩៥៧.១០២ | ៧.៩៦៧.៣៦៣ | ២.១៩៣.១២៤ | ៩.០១៣.៧៣៩ |

## ១០. ទ្រព្យសម្បត្តិ និងបរិក្ខារ

| រយៈពេលវែង | ការកែលម្អទ្រព្យជួល | បរិក្ខារការិយាល័យ | បរិក្ខារកុំព្យូទ័រ | យានយន្ត | ការងារកំពុងដំណើរការ | សរុប |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៤** | | | | | | |
| ថ្លៃដើម | ៨.៤៨៤.៨២១ | ២.០៧៥.៤៨៣ | ៤.៦៣៨.៧៨៨ | ១.២០២.២៨៤ | ១.២២៩.៨៩៥ | ១៧.៦៣១.២៧១ |
| រំលស់បង្គរ | (៥.២២៤.៧៦២) | (១.៥២១.៩៧៥) | (៣.៨០៩.៨២៣) | (៩៧៩.៣០០) | - | (១១.៥៣៥.៨៦០) |
| តម្លៃចុះបញ្ជីសុទ្ធ | ៣.២៦០.០៥៩ | ៥៥៣.៥០៨ | ៨២៨.៩៦៥ | ២២២.៩៨៤ | ១.២២៩.៨៩៥ | ៦.០៩៥.៤១១ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | ១៣.៣១៧.៣៤១ | ២.២៦១.០៨០ | ៣.៣៨៦.៣២២ | ៩១០.៨៩០ | ៥.០២៤.១២១ | ២៤.៨៩៩.៧៥៤ |
| **សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៣.២៦០.០៥៩ | ៥៥៣.៥០៨ | ៨២៨.៩៦៥ | ២២២.៩៨៤ | ១.២២៩.៨៩៥ | ៦.០៩៥.៤១១ |
| បន្ថែម | - | ២០០.៨៨៩ | ៥០២.៦២៣ | ៩២.០០០ | - | ៧៩៥.៥១២ |
| ផ្ទេរ | ៦២១.០៧៨ | - | - | - | (៦២១.០៧៨) | - |
| និយ័តកម្ម | | (៥៧១) | | | (៣៦៦.៥០០) | (៣៦៧.០៧១) |
| ចំណាយរំលស់ | (១.១៨១.៦២៤) | (៣២២.១៨០) | (៧១៣.៩១៤) | (៩៣.៨០៤) | - | (២.២៧១.៥២២) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ២.៧៣៩.៥១៣ | ៤៣១.៦៤៦ | ៦១៧.៦៧៤ | ២២១.១៨០ | ២៤២.៣១៧ | ៤.២៥២.៣៣០ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | | | | |
| ថ្លៃដើម | ៩.១០៥.៨៩៩ | ២.២៧៥.៨០១ | ៥.១៨១.៤១១ | ១.២៩៤.២៨៤ | ២៤២.៣១៧ | ១៨.០៥៩.៧១២ |
| រំលស់បង្គរ | (៦.៣៦៦.៣៨៦) | (១.៨៨៤.១៥៥) | (៤.៥២៣.៧៣៧) | (១.០៧៣.១០៤) | - | (១៣.៨០៧.៣៨២) |
| **តម្លៃចុះបញ្ជីសុទ្ធ** | **២.៧៣៩.៥១៣** | **៤៣១.៦៤៦** | **៦១៧.៦៧៤** | **២២១.១៨០** | **២៤២.៣១៧** | **៤.២៥២.៣៣០** |
| **សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣)** | **១១.០២៦.៥៤០** | **១.៧៣៧.៣៧៥** | **២.៤៨៦.១៣៨** | **៨៩០.២៤៨** | **៩៧៥.៣២៧** | **១៧.១១៥.៦២៨** |
| គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | | | | | | |
| ថ្លៃដើម | ៨.៧៤៨.០៤៤ | ២.០៦១.៨៩១ | ៤.០៩១.២៧៦ | ១.២៣៨.៣៩៤ | ១.៦៤៥.៣១២ | ១៧.៧៨៨.៩១៧ |
| រំលស់បង្គរ | (៥.៧៦៩.៨៦៥) | (១.៤០៧.៥៦៣) | (២.៩៦៣.៥៨៩) | (១.០៤៦.៣៤៩) | - | (១១.១៨៧.៣៦៦) |
| តម្លៃចុះបញ្ជីសុទ្ធ | ២.៩៧៨.១៧៩ | ៦៥៤.៣២៨ | ១.១២៧.៦៨៧ | ១៩២.០៤៥ | ១.៦៤៥.៣១២ | ៦.៦០១.៥៥១ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | ១២.២៦១.១៦៣ | ២.៦៩៣.៨៦៨ | ៤.៦៤២.៦៨៧ | ៧៩០.៦៤៩ | ៦.៧៩០.២១៨ | ២៧.១៧៨.៥៨៥ |
| សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ២.៩៧៨.១៧៩ | ៦៥៤.៣២៨ | ១.១២៧.៦៨៧ | ១៩២.០៤៥ | ១.៦៤៥.៣១២ | ៦.៦០១.៥៥១ |
| បន្ថែម | - | ១០៤.៥៩០ | ៤៤៣.២៤៩ | ១៤៤.២០០ | ៩៥២.១០៣ | ១.៦៤៤.១៤២ |
| ផ្ទេរ | ១.២០៥.២៦៤ | ៣០.៥៥៩ | ១៥៩.១២៤ | - | (១.៣៩៤.៩៤៧) | - |
| ចាត់ថ្នាក់ឡើងវិញ | - | (១.០៥៦) | ១.០៥៦ | - | ២៣.៤២៧ | ២៣.៤២៧ |
| ចំណាយរំលស់ | (៩២៣.៣៨៤) | (២៣៤.៩១៣) | (៩០២.១៥១) | (១១៣.២៦១) | - | (២.១៧៣.៧០៩) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៣.២៦០.០៥៩ | ៥៥៣.៥០៨ | ៨២៨.៩៦៥ | ២២២.៩៨៤ | ១.២២៩.៨៩៥ | ៦.០៩៥.៤១១ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | | | | | |
| ថ្លៃដើម | ៨.៤៨៤.៨២១ | ២.០៧៥.៤៨៣ | ៤.៦៣៨.៧៨៨ | ១.២០២.២៨៤ | ១.២២៩.៨៩៥ | ១៧.៦៣១.២៧១ |
| រំលស់បង្គរ | (៥.២២៤.៧៦២) | (១.៥២១.៩៧៥) | (៣.៨០៩.៨២៣) | (៩៧៩.៣០០) | - | (១១.៥៣៥.៨៦០) |
| តម្លៃចុះបញ្ជីសុទ្ធ | ៣.២៦០.០៥៩ | ៥៥៣.៥០៨ | ៨២៨.៩៦៥ | ២២២.៩៨៤ | ១.២២៩.៨៩៥ | ៦.០៩៥.៤១១ |
(*) ផលប៉ះពាល់ នៃការវាស់វែង ECL ដោយសារការប្រែប្រួល EAD និង PD ក្នុងអំឡុងឆ្នាំ គឺកើតឡើងពីការដាក់បញ្ចូលព័ត៌មាន ទៅក្នុងគំរូថ្មីៗជាប្រចាំ។

| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ | |
|---|---|---|---|---|
| | ECL ១២ ខែ | ECL ពេញមួយអាយុកាល-មិនថយចុះតម្លៃឥណទាន | ECL ពេញមួយអាយុកាល-ថយចុះតម្លៃឥណទាន | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ចំនួនមានហានិភ័យ** | | | | |
| ចំនួនមានហានិភ័យ គិតត្រឹម | | | | |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ៣៥៩.០៦១.៧៣៦ | - | - | ៣៥៩.០៦១.៧៣៦ |
| *បម្រែបម្រួល ដោយសារហានិភ័យ* | | | | |
| *នៅថ្ងៃទី១ ខែមករា៖* | | | | |
| ផ្ទេរទៅដំណាក់កាលទី១ | - | - | - | - |
| ផ្ទេរទៅដំណាក់កាលទី២ | - | - | - | - |
| ផ្ទេរទៅដំណាក់កាលទី៣ | - | - | - | - |
| ហានិភ័យថ្មី | ៤៤.៩៩៤.៩៩៥ | ៥៤.១៦៥ | - | ៤៥.០៤៩.១២០ |
| ហានិភ័យ ដែលត្រូវបាន | | | | |
| ឈប់ទទួលស្គាល់ | | | | |
| ឬហួសកាលកំណត់ | (៣០.៧៧៥.៤៦៣) | - | - | (៣០.៧៧៥.៤៦៣) |
| ចំនួនមានហានិភ័យ គិតត្រឹម | | | | |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៣៧៣.២៨១.២២៨ | ៥៤.១៦៥ | - | ៣៧៣.៣៣៥.៣៩៣ |
| **សមមូលពាន់រៀល** | | | | |
| (**កំណត់សម្គាល់ ២.៣**) | ១.៥២៤.៨៥៣.៨១៦ | ២២១.២៦៨ | - | ១.៥២៥.០៧៥.០៨០ |

**(ឆ) បណ្តុំទ្រព្យសកម្មហិរញ្ញវត្ថុ ធៀបនឹងហានិភ័យឥណទាន**

**(i) វិភាគ តាមតំបន់ភូមិសាស្ត្រ**

តារាងខាងក្រោមនេះ លម្អិតអំពីហានិភ័យឥណទានសំខាន់ៗរបស់ធនាគារ តាមសមតុល្យយោងដុលរបស់វា ដោយចាត់ថ្នាក់តាមតំបន់ភូមិសាស្ត្រ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ ក្នុងតារាងនេះ ធនាគារបានបែងចែកហានិភ័យ ទៅតាមប្រទេសនីមួយៗ ដោយផ្អែកតាមប្រទេស នៃភាគីដៃគូរបស់ខ្លួន។

| | ប្រទេសកម្ពុជា | ប្រទេសម៉ាឡេស៊ី | ប្រទេសថៃ | សហរដ្ឋអាមេរិក | ប្រទេសសិង្ហបុរី | ប្រទេសឥណ្ឌូនេស៊ី | ប្រទេសផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | | | | | | |
| *ទ្រព្យសកម្មក្នុងតារាងតុល្យការ៖* | | | | | | | | |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ | ១២៤.៤៦១.៨០៣ | ១២១.៥២១ | ២.៥៣១.៧៥៥ | ២១២.៥១៧.៧៨២ | ២០៤.៩៩៧ | ៧.១៥៨ | ៥.៩៣៨.២០៧ | ៣៤៥.៧៨៣.២២៣ |
| ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមបានរំលស់ | ៩៤១.៣៣៤.៩៦១ | - | - | - | - | - | - | ៩៤១.៣៣៤.៩៦១ |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ | ៩៩២.៦៦២ | - | - | - | - | - | - | ៩៩២.៦៦២ |
| | ១.០៦៦.៧៨៩.៤២៦ | ១២១.៥២១ | ២.៥៣១.៧៥៥ | ២១២.៥១៧.៧៨២ | ២០៤.៩៩៧ | ៧.១៥៨ | ៥.៩៣៨.២០៧ | ១.២៨៨.១១០.៨៤៦ |
| *ទ្រព្យសកម្មក្រៅតារាងតុល្យការ៖* | | | | | | | | |
| ធានាធនាគារ និងលិខិតឥណទាន | ១៨៣.៣២៧.៣៩៨ | - | - | - | - | - | - | ១៨៣.៣២៧.៣៩៨ |
| ចំណែកដែលមិនទាន់បានប្រើប្រាស់នៃឥណទានវិចារូបន៍ | ៩០.៩៨៥.១៣២ | - | - | - | - | - | - | ៩០.៩៨៥.១៣២ |
| ចំណែកដែលមិនទាន់បានប្រើប្រាស់នៃប័ណ្ណឥណទាន | ១៤.០៨៦.១៥១ | - | - | - | - | - | - | ១៤.០៨៦.១៥១ |
| កិច្ចសន្យាឥណទានមានកាលកំណត់ | ១.៥៩៤.៥៨៤ | - | - | - | - | - | - | ១.៥៩៤.៥៨៤ |
| | ២៨៩.៩៩៣.២៦៥ | - | - | - | - | - | - | ២៨៩.៩៩៣.២៦៥ |
| **សមតុល្យយោងដុល** | | | | | | | | |
| **ដក៖ សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក** | (៨.៩៦៧.៤៥០) | (២៣.២៧០) | (២.០២០) | (២.៨៣៦) | (១១៥.៦៤៩) | (៦) | - | (៩.១១១.២៣១) |
| **សមតុល្យយោងសុទ្ធ** | **១.៣៨៧.៨១៥.២៤១** | **៩៨.២៥១** | **២.៥២៩.៧៣៥** | **២១២.៥១៤.៩៤៦** | **៨៩.៣៤៨** | **៧.១៥២** | **៥.៩៣៨.២០៧** | **១.៥៦៨.៩៩២.៨៨០** |
| **សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣)** | **៥.៤២៤.៩៥៦.៣៤៥** | **៣៩៥.៨៦០** | **១០.១៨២.១៨៣** | **៨៥៥.៣៧២.៦៥៨** | **៣៥៩.៦២៦** | **២៨.៧៨៧** | **២៣.៩០១.២៨៣** | **៦.៣១៥.១៩៦.៣៤២** |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | | | |
| *ទ្រព្យសកម្មក្នុងតារាងតុល្យការ៖* | | | | | | | | |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | ២៨៧.៨៩៥.៥០០ | ៦.០៨៨.៥២៥ | ១.៨៥៥.៥៩៦ | ១.៦៥០.២២៧ | ៣៨៧.៧០៣ | ៧.៦៨៤ | ៨.១៣៧ | ២៥៧.៨៥៣.៣៧២ |
| ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមបានរំលស់ | ៩៨៩.៦០៦.០១៧ | - | - | - | - | - | - | ៩៨៩.៦០៦.០១៧ |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ | ១.៨១២.៨៦៦ | ១១៨.៨៨១ | ៦.១៣៨ | - | ២២.០៥៣ | ១.៣៩៨ | ១១៣ | ១.៥៦១.០០១ |
| | ១.១៩៨.៥១៣.៩៨៣ | ៦.១៦៧.៣៦៦ | ១.៨៦១.៧៣០ | ១.៦៥០.២២៧ | ៤០៩.៧៥៦ | ៩.០៧៨ | ៨.២៥០ | ១.២០៨.៦២០.៣៩០ |
| *ទ្រព្យសកម្មក្រៅតារាងតុល្យការ៖* | | | | | | | | |
| ធានាធនាគារ និងលិខិតឥណទាន | ២៧៧.២៨៣.៣២៣ | - | - | - | - | - | - | ២៧៧.២៨៣.៣២៣ |
| ចំណែកដែលមិនទាន់បានប្រើប្រាស់នៃឥណទានវិចារូបន៍ | ៦៥.៧៩៥.៩៨៨ | - | - | - | - | - | - | ៦៥.៧៩៥.៩៨៨ |
| ចំណែកដែលមិនទាន់បានប្រើប្រាស់នៃប័ណ្ណឥណទាន | ១២.៣៦៦.១៩៦ | - | - | - | - | - | - | ១២.៣៦៦.១៩៦ |
| កិច្ចសន្យាឥណទានមានកាលកំណត់ | ១៧.៨៨៩.៨៨៦ | - | - | - | - | - | - | ១៧.៨៨៩.៨៨៦ |
| | ៣៧៣.៣៣៥.៣៩៣ | - | - | - | - | - | - | ៣៧៣.៣៣៥.៣៩៣ |
| សមតុល្យយោងដុល | ១.៥៧១.៨៨៩.៣៧៦ | ៦.១៦៧.៣៦៦ | ១.៨៦១.៧៣០ | ១.៦៥០.២២៧ | ៤០៩.៧៥៦ | ៩.០៧៨ | ៨.២៥០ | ១.៥៨១.៩៥៥.៧៨៣ |
| ដក៖ សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក | (៥.០០៨.៧៩៨) | (៤.១៣៧) | (១.២៦៩) | (១.១២៩) | (២៦៥) | (៥) | (៥) | (៥.០១៥.៦០៨) |
| សមតុល្យយោងសុទ្ធ | ១.៥៦៦.៨៨០.៥៧៨ | ៦.១៦៣.២២៩ | ១.៨៦០.៨៦១ | ១.៦៨៩.០៩៨ | ៤០៩.៨៩១ | ៩.០៧៣ | ៨.២៨៥ | ១.៥៧៦.៩៨០.១៧៥ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | ៦.៨០០.៥៨៣.៧៦២ | ២៥.១៧៦.៧៩០ | ៧.៥៩៩.៩៨៣ | ៦.៧៣៦.៥៦៥ | ១.៦៧២.៧៧១ | ៣៧.០៦៣ | ៣៣.៦៨១ | ៦.៨៩១.៨០០.៦១៥ |

**(ii) វិភាគ តាមប្រភេទអាជីវកម្ម**

តារាងខាងក្រោមនេះ លម្អិតអំពីហានិភ័យឥណទានសំខាន់ៗរបស់ធនាគារ តាមសមតុល្យយោងដុលរបស់វា ដកឱនភាពនៃតម្លៃ ប្រសិនបើមាន ដោយចាត់ថ្នាក់ តាមវិស័យអាជីវកម្មរបស់ភាគីដៃគូ។

| | ឆ្នាំ២០២៤ | | | | | ឆ្នាំ២០២៣ | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ | គណនាទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដកសល់ | ទ្រព្យសកម្មផ្សេងៗ | ខ្ចង់ក្រៅតារាងតុល្យការ | សរុប | ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ | គណនាទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដកសល់ | ទ្រព្យសកម្មផ្សេងៗ | ខ្ចង់ក្រៅតារាងតុល្យការ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| គ្រឹះស្ថានហិរញ្ញវត្ថុ | ៣៨៥.៩៧៩.១៣២ | ៣៤.០៥៥.២៦០ | - | ២.០០០.០០០ | ៣៨២.០៣៤.៣៩២ | ២៥៧.៨៥៣.៣៧២ | ៥៣.០៦១.៣៣៥ | ៥៤០.២៨៧ | ១.៦០៧.៨២២ | ៣១២.៦៦២.៣៧៦ |
| បញ្ចាំ | - | ២២៦.៣៧១.៣៨១ | - | ៨៨៧.៦០៧ | ២២៧.២៥៨.៩៨៨ | - | ២៨៣.២២៩.០៨១ | ៧៣៩.៨២៣ | ១.១៨៩.៦៧១ | ២៨៥.១៥៨.១៣៥ |
| លក់ដុំ និងលក់រាយ | - | ១៧៨.៩៩៦.៥១៧ | - | ៤២.១៧២.៦៨៣ | ២២១.១៦៩.១៦០ | - | ១៨៣.៨០៥.៨៣៥ | - | ៨៦.១១១.៧៣០ | ២៦៩.៩១៧.៥៦៥ |
| នាំចូល និងនាំចេញ | - | ១២៦.៩៨៦.៥១៨ | - | ៩១.៥៨១.៧១២ | ២១៨.៥៦៨.២៣០ | - | ១៣៦.៦៨៤.១៥៧ | - | ១៨៨.៣២៩.៧៥៤ | ៣២៥.០១៣.៩១១ |
| ផលិតកម្ម | - | ៦១.៧៦១.១៥២ | - | ២៤.៩២៧.៧៨៨ | ៨៦.៦៨៨.៩៤០ | - | ៧៥.២៨៣.៩៦៨ | - | ២៦.៨២១.១៩២ | ១០២.១០៥.១៦០ |
| សេវាហិរញ្ញវត្ថុ ធានារ៉ាប់រង | | | | | | | | | | |
| អចលនទ្រព្យ និងអាជីវកម្ម | - | ១០៨.១៥១.៧២៨ | - | ៩៧៣.២៩៨ | ១០៩.១២៥.០២៦ | - | ៧៩.៩៤១.៥៥៩ | - | ២.០៣៥.៣៦២ | ៨១.៩៧៦.៩២១ |
| សេវាមិនមែនហិរញ្ញវត្ថុផ្សេងៗ | - | ៣៥.២៦៩.២៨៣ | - | ២.២៨៧.២៩៤ | ៣៧.៥៩៦.៥៧៧ | - | ៣៨.៦៨៧.៦៩៣ | - | ៤.៨៤៤.២៤៥ | ៤៣.០៩១.៩៣៨ |
| សំណង់ | - | ៧៧.៨៨៤.៧១៨ | - | ៣៦.០៩១.៤២០ | ១១៣.៩៧៦.១៣៨ | - | ៥៧.៥៦៨.០២១ | - | ៤០.៧៩៧.៥៣៦ | ៩៨.៣៦១.៥៥៧ |
| ការដឹកជញ្ជូន ឃ្លាំងទំនិញ | | | | | | | | | | |
| និងទំនាក់ទំនង | - | ៣២.២១៩.១៩២ | - | ៦.៧៣៥.៨៦៨ | ៣៨.៩៥៥.០៦០ | - | ២៦.០៦៦.៨៦៨ | - | ១៥.៨៥៨.៤២៤ | ៤១.៩២៤.៨៩២ |
| អគ្គិសនី ហ្គាស និងទឹកស្អាត | - | ៨.៨៤៨.៥២៤ | - | ២.១៦៧.៣៣៣ | ១១.០១៥.៨៥៧ | - | ៩.៩១១.៣៩៨ | ៩.០៧៨ | ១.០៩៥.៥៣៤ | ១១.០១៥.០១០ |
| កសិកម្ម | - | ៦.៦១៨.៥២២ | - | - | ៦.៦១៨.៥២២ | - | ២.២៦០.៧៩៥ | - | ២៧៣.៧៦៧ | ២.៥៣៤.៥៦២ |
| ផ្សេងៗ | - | ៥២.៩៩២.៣២៨ | ៩៩២.៦៦៣ | ៨០.១៦៨.៣០២ | ១៣៤.១៥៣.២៩៣ | - | ៤៣.១៨៩.៧៤៧ | ២៧២.២៥៣ | ៤.៧៧១.៧៥៦ | ៤៨.១៩៣.៧៥៦ |
| **សមតុល្យយោងដុល** | **៣៨៥.៩៧៩.១៣២** | **៥៥០.១៥៥.១២៣** | **៩៩២.៦៦៣** | **២៨៩.៩៩៣.២៦៩** | **១.៥៨៧.១២០.១៨៣** | ២៥៧.៨៥៣.៣៧២ | ៩៨៩.៦០៦.០១៧ | ១.៥៦១.០០១ | ៣៧៣.៣៣៥.៣៩៣ | ១.៥៨១.៩៥៥.៧៨៣ |
| **ដក៖ សំវិធានធន សម្រាប់** | | | | | | | | | | |
| **ការខាតឥណទានរំពឹងទុក** | (១៩៥.៩០៩) | (៨.៨២០.១៦២) | - | (៩៥.១៦០) | (៩.១១១.២៣១) | (១៧៦.០៨៧) | (៨.៧៧១.៣៨៣) | - | (៦៨.២១៨) | (៥.០១៥.៦០៨) |
| **សមតុល្យយោងសុទ្ធ** | **៣៨៥.៧៨៣.២២៣** | **៩៨១.៣៣៨.៩៦១** | **៩៩២.៦៦៣** | **២៨៩.៨៩៩.១០៥** | **១.៥៧៨.០០៨.៩៩២** | ២៥៧.២៧៧.៣២៥ | ៩៨៨.៨៣៨.៦៧៨ | ១.៥៦១.០០១ | ៣៧៣.២៦៧.១៧៥ | ១.៥៧៦.៩៨០.១៧៥ |
| **សមមូលពាន់រៀល** | | | | | | | | | | |
| (កំណត់សម្គាល់ ២.៣) | ១.៣៩១.៧៧៧.៨៧៣ | ៣.៧៨៨.៨៧៣.២១៨ | ៣.៩៩៥.៨៦៩ | ១.១៦៦.៨៣៩.៨៧៣ | ៦.៣៥១.៨៨៦.០៣៣ | ១.០៥០.៩៧៧.៨៧២ | ៣.៨៥៩.៦៨៩.៦៨៣ | ៦.៣៧៦.៦៨៩ | ១.៥២៨.៧៩៦.៨១០ | ៦.៨៨១.៨០០.៦១៨ |

### (ជ) ការរឹបអូសទ្រព្យបញ្ចាំ

ទ្រព្យសម្បត្តិ ដែលបានរឹបអូស ត្រូវលក់ចេញឱ្យបានឆាប់ តាមដែលអាចធ្វើបាន។ ធនាគារមិនប្រើប្រាស់ទ្រព្យបញ្ចាំ ដែលបានរឹបអូស សម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួនទេ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ធនាគារមិនបានរឹបអូសទ្រព្យសម្បត្តិ ដែលបានដាក់ជាវត្ថុបញ្ចាំនោះទេ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣៖ មិនមាន)។

### (i) ការវិភាគភាពប្រែប្រួល

ធនាគារបានធ្វើការប៉ាន់ស្មានភាពប្រែប្រួល ECL លើឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន ដោយផ្អែកទៅតាមបម្រែប្រួល នៃអញ្ញត្រសេដ្ឋកិច្ចសំខាន់ៗ។ កត្តានៃការប្រែប្រួល ដែលបានប្រើ គឺជាការសន្មតនានា ដែលផ្អែកទៅតាមការផ្លាស់ប្តូរស្របគ្នា នៃអញ្ញត្រសំខាន់ៗ ដើម្បីព្យាករ ពីផលប៉ះពាល់ ចំពោះ ECL របស់ធនាគារ។

អញ្ញត្រសំខាន់ៗ គឺជាអញ្ញត្រ ផ្នែកសេដ្ឋកិច្ច (MEVs) ដែលមានទំនាក់ទំនង ជាមួយនឹងអត្រាមិនសងប្រាក់ ដែលបានសង្កេត។ ក្នុងឆ្នាំ២០២៤ ការធ្វើតេស្ត ផ្នែកស្ថិតិបង្ហាញនូវទំនាក់ទំនង ជាមួយនឹងសន្ទស្សន៍តម្លៃទំនិញ (ឆ្នាំ២០២៣៖ ផលិតផលក្នុងស្រុកសរុប)។

តារាងខាងក្រោមនេះ បង្ហាញពីផលប៉ះពាល់ នៃ ECL ចំពោះការប្រែប្រួលអញ្ញត្រសំខាន់ៗ ដែលបានប្រើប្រាស់ ទន្ទឹមនឹងអញ្ញត្រផ្សេងៗ ដែលមិនមានការប្រែប្រួលៈ

| | ការប្រែប្រួល |
|---|---|
| សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ | +/-9% |

| | ឆ្នាំ២០២៤ | |
|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| ការថយចុះសរុប នៅក្នុង ECL លើការផ្លាស់ប្តូរវិជ្ជមាន នៅក្នុងអញ្ញត្រសំខាន់ៗ | (៧៥.៧៥៨) | (៣០៤.៩១០) |
| ការកើនឡើងសរុប នៅក្នុង ECL លើការផ្លាស់ប្តូរអវិជ្ជមាន នៅក្នុងអញ្ញត្រសំខាន់ៗ | ៧៥.៧៥៨ | ៣០៤.៩១០ |

| | ការប្រែប្រួល |
|---|---|
| សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ | +/-9% |

| | ឆ្នាំ២០២៣ | |
|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| ការថយចុះសរុប នៅក្នុង ECL លើការផ្លាស់ប្តូរវិជ្ជមាន នៅក្នុងអញ្ញត្រសំខាន់ៗ | (១៤.៨៦៩) | (៦០.៧៤០) |
| ការកើនឡើងសរុប នៅក្នុង ECL លើការផ្លាស់ប្តូរអវិជ្ជមាន នៅក្នុងអញ្ញត្រសំខាន់ៗ | ១៤.៨៦៩ | ៦០.៧៤០ |

## ៣៥.២ ហានិភ័យទីផ្សារ

ធនាគារប្រឈមមុខនឹងហានិភ័យទីផ្សារ ជាហានិភ័យ ដែលធ្វើឱ្យមានការប្រែប្រួលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់ នាពេលអនាគត នៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការផ្លាស់ប្តូរតម្លៃទីផ្សារ។ ហានិភ័យទីផ្សារ កើតឡើងដោយស្ថានភាពបើកចំហ នៃអត្រាការប្រាក់ រូបិយប័ណ្ណ និងផលិតផលមូលធន ដែលទាំងអស់នេះប្រឈមមុខនឹងបម្រែបម្រួលទីផ្សារជាក់លាក់ និងទូទៅ ព្រមទាំងបម្រែបម្រួលអត្រាទីផ្សារ ឬតម្លៃទីផ្សារ ដូចជាអត្រាការប្រាក់ គម្លាតឥណទាន អត្រាប្តូររូបិយប័ណ្ណ និងតម្លៃមូលធនជាដើម។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ធនាគារមិនមានប្រើឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ និងការផ្លាស់ប្តូរអត្រាការប្រាក់ ដើម្បីគ្រប់គ្រងហានិភ័យរបស់ខ្លួននោះទេ។

### (ក) ហានិភ័យការប្តូររូបិយប័ណ្ណ

ធនាគារធ្វើប្រតិបត្តិការអាជីវកម្ម នៅក្នុងប្រទេសកម្ពុជា ដោយប្រើរូបិយវត្ថុច្រើនប្រភេទ ដែលបណ្តាលឱ្យមានហានិភ័យរូបិយប័ណ្ណផ្សេងៗ ដែលភាគច្រើន គឺទាក់ទងនឹងប្រាក់រៀល និងប្រាក់ដុល្លារអូស្ត្រាលី។

ហានិភ័យការប្តូររូបិយប័ណ្ណ កើតពីប្រតិបត្តិការពាណិជ្ជកម្ម ក្នុងពេលអនាគត ទ្រព្យសកម្ម និងបំណុល ដែលបានកត់ត្រាជារូបិយប័ណ្ណមួយ ដែលមិនមែនជារូបិយប័ណ្ណមុខងាររបស់ធនាគារ។

គណៈគ្រប់គ្រង តាមដានហានិភ័យការប្តូររូបិយប័ណ្ណ ដោយធៀបនឹងរូបិយប័ណ្ណគោលរបស់ធនាគារ។ ប៉ុន្តែធនាគារមិនបានការពារហានិភ័យការប្តូររូបិយប័ណ្ណ ដែលកើតពីប្រតិបត្តិការពាណិជ្ជកម្ម ក្នុងពេលអនាគត ទ្រព្យសកម្ម និងបំណុល ដែលបានកត់ត្រា ដោយប្រើកិច្ចសន្យា នាពេលអនាគតទេ។

គោលនយោបាយរបស់ធនាគារ គឺរក្សាហានិភ័យការប្តូររូបិយប័ណ្ណ ឱ្យស្ថិតក្នុងកម្រិតដែលអាចទទួលយកបាន និងស្ថិតក្រោមគោលនយោបាយណែនាំ ដែលមានស្រាប់។

តារាងខាងក្រោមនេះ សង្ខេបអំពីហានិភ័យការប្តូររូបិយប័ណ្ណរបស់ធនាគារ។ ក្នុងតារាងខាងក្រោមនេះ គឺជាឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ តាមសមតុល្យយោងសុទ្ធរបស់វា ដោយវិភាគតាមរូបិយប័ណ្ណ និងមានតម្លៃសមមូលនឹងប្រាក់ដុល្លារអាមេរិក។

| | សមមូលជាប្រាក់ដុល្លារអាមេរិក | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | រៀល | អឺរ៉ូ | បាត | ដុល្លារអូស្ត្រាលី | ដុល្លារសិង្ហបុរី | ផោន | រីងហ្គីត | ផ្សេងៗ | សរុប |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៣៤.៧៨៨.២៦៣ | ៤.៧០៥.១៥៨ | - | - | - | - | - | - | - | ៣៩.៤៩៣.៤២១ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល | ៩៤.២២២.០៨៦ | ១០.៨០៩.៤០៨ | - | - | - | - | - | - | - | ១០៥.០៣១.៤៩៤ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ | ៣២៣.៣៨៣.៩៩០ | ១៣.៦៣៥.៥៩៥ | ២.២០៥.៩៥៣ | ២.៥៣១.៧៥៥ | ១.២៨១.៦២៩ | ២០៤.៩៩៧ | ៣១១.៧៨២ | ១២១.៥២១ | ២.១៨៦.០៨១ | ៣៨៥.៧៨៣.២២៣ |
| ឥណទាន និងបុរេប្រទានវាស់វែង តាមថ្លៃដើមដកវិលស់ | ៨៨២.១៣៧.៥២០ | ៩៩.១៩៧.៨៨១ | - | - | - | - | - | - | - | ៩៨១.៣៣៨.៩៦១ |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ | ៨៣៣.៥០៨ | ១៥៩.១៨៦ | ៩ | - | - | - | - | - | - | ៩៩២.៦៦៣ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ១.២៩៥.៣២៥.៣៦៧ | ១២៨.៥០៦.៧៨៨ | ២.២០៥.៩៦១ | ២.៥៣១.៧៥៥ | ១.២៨១.៦២៩ | ២០៤.៩៩៧ | ៣១១.៧៨២ | ១២១.៥២១ | ២.១៨៦.០៨១ | ១.៤៣២.៦៣៥.៧៦១ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ | ៩៧.៧៥២.៣៩៩ | ១៧.៨៩៨.៦៨៨ | | | | | | | | ១១៥.៦៥១.០៨៣ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១.១១៥.៩៦៨.២២៧ | ២១.៩០២.៥៥៩ | ១.៧៨០.៦៧៥ | ១.១០៣.៨០៨ | ១.៣២៨.២៥៨ | ៨៨.១០២ | ៣១១.៨៨០ | | ១.៩៦៣.២២៨ | ១.១៨៤.៨០២.៧២៩ |
| ប្រាក់កម្ចី | ៥១៧.៥៨០ | - | - | - | - | - | - | - | - | ៥១៧.៥៨០ |
| បំណុលបន្ទាប់បន្សំ | ៣២.៣១៨.៦៧៨ | - | - | - | - | - | - | - | - | ៣២.៣១៨.៦៧៨ |
| បំណុលភតិសន្យា | ៨.៩០៦.១០៨ | - | - | - | - | - | - | - | - | ៨.៩០៦.១០៨ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | ៧.៥៨២.២៨៧ | ៧៦.៥៨៨ | | | (៣១.៩៧១) | ១៣.៦៣៨ | | ១៩៦.៧៧១ | ៣៧៨ | ៧.៧៩៧.៦៨៧ |
| **បំណុលហិរញ្ញវត្ថុសរុប** | ១.២៥៩.០០៥.២៣១ | ៣៩.៨៧៨.២៣១ | ១.៧៨០.៦៧៥ | ១.១០៣.៨០៨ | ១.២៩២.២៨៣ | ១០១.៧៨០ | ៣១១.៨៨០ | ១៩៦.៧៧១ | ១.៩៦៣.៦០២ | ១.៣០៥.៥៩៣.៩១៧ |

| | សមមូលជាប្រាក់ដុល្លារអាមេរិក | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | រៀល | អឺរ៉ូ | បាត | ដុល្លារអូស្ត្រាលី | ដុល្លារសិង្ហបុរី | ផោន | រីងហ្គីត | ផ្សេងៗ | សរុប |
| ស្ថានភាពតារាងតុល្យការសុទ្ធ | ៣៦.៣២០.១៣៦ | ៨៨.៦២៨.៥១៧ | ៤៦៥.២៨៦ | ១.៤២៧.៩៥១ | (៥០.៦៥៤) | ១០៣.២៥៧ | ២៦២ | (៧៥.២៥០) | ២២២.៤៣៩ | ១២៧.០៤១.៩៤៤ |
| សមមូលពាន់រៀល | | | | | | | | | | |
| (កំណត់សម្គាល់ ២.៣) | ១៤៦.១៨៨.៥៤៧ | ៣៥៦.៧២៩.៧៨១ | ១.៨៧២.៧៧៦ | ៥.៧៤៧.៥០៣ | (២០៣.៨៨២) | ៤១៥.៦១១ | ១.០៥៣ | (៣០២.៨៨១) | ៨៩៥.៣១៧ | ៥១១.៣៤៣.៨២៥ |
| **ខ្ទង់ក្រៅតារាងតុល្យការ** | | | | | | | | | | |
| ធានាធនាគារ និងលិខិតឥណទាន | ១៨៣.៣២៧.៣៩៨ | - | - | - | - | - | - | - | - | ១៨៣.៣២៧.៣៩៨ |
| ចំណែក ដែលមិនទាន់បាន | | | | | | | | | | |
| ប្រើប្រាស់ នៃឥណទានវិបារូបន៍ | ៩០.៩៨៥.១៣២ | - | - | - | - | - | - | - | - | ៩០.៩៨៥.១៣២ |
| ចំណែក ដែលមិនទាន់បាន | | | | | | | | | | |
| ប្រើប្រាស់ នៃប័ណ្ណឥណទាន | ១៤.០៨៦.១៥១ | - | - | - | - | - | - | - | - | ១៤.០៨៦.១៥១ |
| កិច្ចសន្យាឥណទាន | | | | | | | | | | |
| មានកាលកំណត់ | ១.៥៩៤.៥៨៤ | - | - | - | - | - | - | - | - | ១.៥៩៤.៥៨៤ |
| | ២៨៩.៩៩៣.២៦៥ | - | - | - | - | - | - | - | - | ២៨៩.៩៩៣.២៦៥ |
| សមមូលពាន់រៀល | | | | | | | | | | |
| (កំណត់សម្គាល់ ២.៣) | ១.១៦៧.២២២.៨៩២ | - | - | - | - | - | - | - | - | ១.១៦៧.២២២.៨៩២ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤៣.៩៨១.៥៩០ | ៧.០៣១.៩៥៥ | - | - | - | - | - | - | - | ៥១.០១៣.៥៤៥ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ | | | | | | | | | | |
| នៅធនាគារកណ្តាល | ៦៦.៣៤៥.៦០៨ | ១៥.៧៤៩.៩៤៤ | - | - | - | - | - | - | - | ៨២.០៩៥.៥៥២ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ | | | | | | | | | | |
| នៅធនាគារផ្សេងៗ | ២៣៤.២២៦.៤៩១ | ១៥.៨៩៤.២២៨ | ១.៨៤៧.៤៩២ | ១.៨៥៤.៣២៧ | ៦២៦.៧១១ | ៣៨៧.៤៣៨ | ១៥៨.២៧២ | ១៣០.៦៦១ | ២.១៥១.៧០៥ | ២៥៧.២៧៧.៣២៥ |
| ឥណទាន និងបុរេប្រទានវាស់វែង | | | | | | | | | | |
| តាមថ្លៃដើមដកវំលស់ | ៨៤៦.៤៧៦.៧៣១ | ៩៨.៣៥៧.៩៤៣ | - | - | - | - | - | - | - | ៩៤៤.៨៣៤.៦៧៤ |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ | ១.០៦៩.៩៥៩ | ៤៥៤.០៧៨ | ២៨ | ៥.៦០២ | ៨ | ២០.៤៣០ | ៨.៤១១ | ២.៣៧៩ | ១០៦ | ១.៥៦១.០០១ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ១.១៩២.១០០.៣៧៩ | ១៣៧.៤៨៨.១៤៨ | ១.៨៤៧.៥២០ | ១.៨៥៩.៩២៩ | ៦២៦.៧១៩ | ៤០៧.៨៦៨ | ១៦៦.៦៨៣ | ១៣៣.០៤០ | ២.១៥១.៨១១ | ១.៣៣៦.៧៨២.០៩៧ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ | ១៧១.៧៥៨.៣៥២ | ១៧.៣៤២.០៥៣ | - | - | - | - | - | - | - | ១៨៩.១០០.៤០៥ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៩៥៦.២៨៣.០៣១ | ៣២.១២៩.១៨៨ | ៩៤៨.២៤៥ | ២.២២២.៥៣៨ | ៧០១.៨៤៣ | ១៩៩.៤៩៧ | ១១៨.៨១៩ | - | ២.០១២.៥៦៧ | ៩៩៤.៦១៥.៧២៨ |
| ប្រាក់កម្ចី | ១.១៥២.០១៥ | - | - | - | - | - | - | - | - | ១.១៥២.០១៥ |
| បំណុលបន្ទាប់បន្សំ | ៤៧.៤០៥.៥៩២ | - | - | - | - | - | - | - | - | ៤៧.៤០៥.៥៩២ |
| បំណុលភតិសន្យា | ៦.១៦៤.៩០០ | - | - | - | - | - | - | - | - | ៦.១៦៤.៩០០ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | ៧.៥៥៤.៤២៤ | ១១៩.០១៥ | ៣០៦.១២៣ | ២០០.៧១២ | ៨២.៧១៧ | ១៣២.២៣៥ | ៤២.៣៣៩ | ៣២៤.៦៨៨ | ១.២០២ | ៨.៧៦៣.៤៥៥ |
| បំណុលហិរញ្ញវត្ថុសរុប | ១.១៩០.៣១៨.៣១៤ | ៤៩.៥៩០.២៥៦ | ១.២៥៤.៣៦៨ | ២.៤២៣.២៥០ | ៧៨៤.៥៦០ | ៣៣១.៧៣២ | ១៦១.១៥៨ | ៣២៤.៦៨៨ | ២.០១៣.៧៦៩ | ១.២៤៧.២០២.០៩៥ |
| ស្ថានភាពតារាងតុល្យការសុទ្ធ | ១.៧៨២.០៦៥ | ៨៧.៨៩៧.៨៩២ | ៥៩៣.១៥២ | (៥៦៣.៣២១) | (១៥៧.៨៤១) | ៧៦.១៣៦ | ៥.៥២៥ | (១៩១.៦៤៨) | ១៣៨.០៤២ | ៨៩.៥៨០.០០២ |
| សមមូលពាន់រៀល | | | | | | | | | | |
| (កំណត់សម្គាល់ ២.៣) | ៧.២៧៩.៧៣៤ | ៣៥៩.០៦២.៨៨៩ | ២.៤២៣.០២៦ | (២.៣០១.១៦៦) | (៦៤៤.៧៨០) | ៣១១.០១៦ | ២២.៥៧០ | (៧៨២.៨៨២) | ៥៦៣.៩០២ | ៣៦៥.៩៣៤.៣០៩ |
| **ខ្ទង់ក្រៅតារាងតុល្យការ** | | | | | | | | | | |
| ធានាធនាគារ និងលិខិតឥណទាន | ២៧៧.២២១.៩៨៥ | - | - | - | - | - | - | - | - | ២៧៧.២២១.៩៨៥ |
| ចំណែក ដែលមិនទាន់បាន | | | | | | | | | | |
| ប្រើប្រាស់នៃឥណទានវិបារូបន៍ | ៦៥.០២០.១៦៨ | ៧៧៥.៨២០ | - | - | - | - | - | - | - | ៦៥.៧៩៥.៩៨៨ |
| ចំណែក ដែលមិនទាន់បាន | | | | | | | | | | |
| ប្រើប្រាស់ នៃប័ណ្ណឥណទាន | ១២.៣៦៦.១៩៦ | - | - | - | - | - | - | - | - | ១២.៣៦៦.១៩៦ |
| កិច្ចសន្យាឥណទានមានកាលកំណត់ | ១៧.៦៦៥.១៤៧ | ២១៧.៨៥៩ | - | - | - | - | - | - | - | ១៧.៨៨៣.០០៦ |
| | ៣៧២.២៧៣.៤៩៦ | ៩៩៣.៦៧៩ | - | - | - | - | - | - | - | ៣៧៣.២៦៧.១៧៥ |
| សមមូលពាន់រៀល | | | | | | | | | | |
| (កំណត់សម្គាល់ ២.៣) | ១.៥២០.៧៣៧.២៣០ | ៤.០៥៩.១៧៩ | - | - | - | - | - | - | - | ១.៥២៤.៧៩៦.៤០៩ |

**ការវិភាគផលប៉ះពាល់ ពីការប្រែប្រួល**

ធនាគារប្រឈមមុខនឹងហានិភ័យ ចំពោះផលប៉ះពាល់ នៃការផ្លាស់ប្តូរអត្រាប្តូរប្រាក់ ចំពោះរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ។ តារាងខាងក្រោម បង្ហាញពីរចនាសម្ព័ន្ធសំខាន់ នៃហានិភ័យការប្តូររូបិយប័ណ្ណរបស់ធនាគារ៖

| | ឆ្នាំ២០២៤ | | ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| **ទ្រព្យសកម្ម/(បំណុល)** | | | | |
| រៀល | **៨៨.៦២៨.៥១៧** | **៣៥៦.៧២៩.៧៨១** | ៨៧.៨៩៧.៨៩២ | ៣៥៩.០៦២.៨៨៩ |
| អឺរ៉ូ | **៤៦៥.២៨៦** | **១.៨៧២.៧៧៦** | ៥៩៣.១៥២ | ២.៤២៣.០២៦ |
| បាត | **១.៤២៧.៩៥១** | **៥.៧៤៧.៥០៣** | (៥៦៣.៣២១) | (២.៣០១.១៦៦) |
| ដុល្លារអូស្ត្រាលី | **(៥០.៦៥៤)** | **(២០៣.៨៨២)** | (១៥៧.៨៤១) | (៦៤៤.៧៨០) |
| ដុល្លារសិង្ហបុរី | **១០៣.២៥៧** | **៤១៥.៦១១** | ៧៦.១៣៦ | ៣១១.០១៦ |
| ផោន | **២៦២** | **១.០៥៣** | ៥.៥២៥ | ២២.៥៧០ |
| ហ្វ្រាំង | **(៧៥.២៥០)** | **(៣០២.៨៨១)** | (១៩១.៦៤៨) | (៧៨២.៨៨២) |
| ផ្សេងៗ | **២២២.៤៣៩** | **៨៩៥.៣១៧** | ១៣៨.០៤២ | ៥៦៣.៩០២ |
| | **៩០.៧២១.៨០៨** | **៣៦៥.១៥៥.២៧៨** | ៨៧.៧៩៧.៩៣៧ | ៣៥៨.៦៥៤.៥៧៥ |

ដូចបានបង្ហាញ ក្នុងតារាងខាងលើ ធនាគារប្រឈមមុខនឹងហានិភ័យ ចំពោះការផ្លាស់ប្តូរអត្រាប្តូរប្រាក់ដុល្លារអាមេរិក ធៀបនឹងប្រាក់រៀល។ ភាពប្រែប្រួល នៃចំណេញ ឬខាត ចំពោះការផ្លាស់ប្តូរអត្រា ការប្រាក់ ភាគច្រើនកើតមកពីឧបករណ៍ហិរញ្ញវត្ថុជាប្រាក់រៀល។

ការវិភាគខាងក្រោម ផ្អែកទៅតាមការសន្មតថា អត្រាប្តូរប្រាក់រៀលបានកើនឡើង ឬថយចុះ ១% ដែលផ្អែកទៅតាមបម្រែបម្រួលជាមធ្យម ក្នុងរយៈពេលបីឆ្នាំចុងក្រោយ នៃអត្រាប្តូរប្រាក់ គិតជាមធ្យម ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ និងប្រើអត្រា ១% ជាមូលដ្ឋាន ដើម្បីវាយតម្លៃ ក្នុងការវិភាគភាពប្រែប្រួល សម្រាប់រូបិយប័ណ្ណផ្សេងៗ។

ការវិភាគពីហានិភ័យ ដើម្បីវាយតម្លៃ អំពីផលប៉ះពាល់ ១% នៃការផ្លាស់ប្តូរអត្រាប្តូរប្រាក់ ចំពោះចំណេញ ឬខាត មានដូចខាងក្រោម៖

| | ឆ្នាំ២០២៤ | | ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| **កើនឡើង/(ថយចុះ)** | | | | |
| - ១% | | | | |
| រៀល | **៧១៦.១៩០** | **២.៨៨២.៦៦៥** | ៧១០.២៨៥ | ២.៩០១.៥១៤ |
| ដុល្លារអូស្ត្រាលី | **(៤០៩)** | **(១.៦៤៨)** | (១.២៧៥) | (៥.២០៨) |
| ផ្សេងៗ | **១៧.៣២៥** | **៦៩.៧៣៤** | ៤៦៨ | ១.៩១១ |
| | **៧៣៣.១០៦** | **២.៩៥០.៧៥១** | ៧០៩.៤៧៨ | ២.៨៩៨.២១៧ |
| **កើនឡើង/(ថយចុះ)** | | | | |
| - ១% | | | | |
| រៀល | **(៧០២.០០៨)** | **(២.៨២៥.៥៨២)** | (៦៩៦.២២០) | (២.៨៤៤.០៥៩) |
| ដុល្លារអូស្ត្រាលី | **៤០១** | **១.៦១៥** | ១.២៥០ | ៥.១០៦ |
| ផ្សេងៗ | **(១៦.៩៨២)** | **(៦៨.៣៥៣)** | (៤៥៩) | (១.៨៧៥) |
| | **(៧១៨.៥៨៩)** | **(២.៨៩២.៣២០)** | (៦៩៥.៤២៩) | (២.៨៤០.៨២៨) |

**(ខ) ហានិភ័យតម្លៃ**

ធនាគារមិនប្រឈមមុខនឹងហានិភ័យតម្លៃមូលបត្រទេ ដោយសារធនាគារមិនមានការវិនិយោគ ឬកាន់កាប់ការវិនិយោគ ដែលត្រូវបានចាត់ថ្នាក់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ តាមតម្លៃសមស្របទេ។

**(គ) ហានិភ័យអត្រាការប្រាក់**

ហានិភ័យអត្រាការប្រាក់ នៃលំហូរសាច់ប្រាក់ គឺជាហានិភ័យ ដែលធ្វើឱ្យមានការប្រែប្រួលលំហូរសាច់ប្រាក់ នាពេលអនាគត នៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការប្រែប្រួលអត្រាការប្រាក់ លើទីផ្សារ។ ហានិភ័យអត្រាការប្រាក់ នៃតម្លៃសមស្រប គឺជាហានិភ័យ ដែលធ្វើឱ្យមានការប្រែប្រួលតម្លៃ នៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការប្រែប្រួលអត្រាការប្រាក់ លើទីផ្សារ។ កម្រិត នៃការប្រាក់ អាចកើនឡើងដោយសារលទ្ធផល នៃការប្រែប្រួល ប៉ុន្តែអាចកាត់បន្ថយការខាតបង់ នៅក្នុងករណី ដែលបម្រែបម្រួលឥតរំពឹងទុកកើតឡើង។

ហានិភ័យអត្រាការប្រាក់សំខាន់ជាងគេរបស់ធនាគារ កើតមកពីប្រាក់កម្ចី ដែលមានអត្រាអថេរ ដែលធ្វើឱ្យធនាគារមានហានិភ័យអត្រាការប្រាក់ នៃលំហូរសាច់ប្រាក់។ ធនាគារមិនមានហានិភ័យអត្រាការប្រាក់ នៃតម្លៃសមស្របទេ ដោយសារអត្រាការប្រាក់ នៃឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាមតម្លៃដើមដករំលស់ គឺប្រហាក់ប្រហែលនឹងអត្រាទីផ្សារ។

នៅដំណាក់កាលនេះ គណៈគ្រប់គ្រង មិនមានគោលនយោបាយ ដើម្បីកំណត់កម្រិត នៃភាពមិនស៊ីគ្នា នៃអត្រាការប្រាក់ទេ ប៉ុន្តែគណៈគ្រប់គ្រង ធ្វើការត្រួតពិនិត្យយ៉ាងទៀងទាត់ ទៅលើភាពមិនស៊ីគ្នានេះ។ ជាងនេះទៅទៀត គណៈគ្រប់គ្រង ធ្វើការវិភាគ និងព្យាករយ៉ាងទៀងទាត់ ចំពោះបម្រែបម្រួលរំពឹងទុក នៃអត្រាការប្រាក់ និងរៀបចំហានិភ័យអត្រាការប្រាក់ នៃលំហូរសាច់ប្រាក់ ដោយវាយតម្លៃ ទៅលើផលប៉ះពាល់របស់វា និងចាត់វិធានការផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងហានិភ័យអត្រាការប្រាក់។

តារាងខាងក្រោមនេះ សង្ខេបពីហានិភ័យអត្រាការប្រាក់របស់ធនាគារ។ នៅក្នុងតារាងនេះ ក៏រួមបញ្ចូលនូវឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ តាមសមតុល្យយោងសុទ្ធ ដោយបានចាត់ថ្នាក់ តាមតម្លៃក្នុងកិច្ចសន្យាដើមគ្រា ឬតាមកាលបរិច្ឆេទផុតកំណត់សង ដោយផ្អែកលើមូលដ្ឋានមួយណា ដែលកើតឡើងមុន។

| | ១ខែ | ១ខែ ទៅ ៣ខែ | ៣ខែ ទៅ ១២ខែ | ១ឆ្នាំ ទៅ ៥ឆ្នាំ | លើស៥ឆ្នាំ | មិនមានការប្រាក់ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | ៣៩.៤៩៣.៤២១ | ៣៩.៤៩៣.៤២១ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល | - | - | ៤.៥០៥.១៩២ | - | - | ១០០.៥២៦.៣០២ | ១០៥,០៣១,៤៩៤ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ | ២.០១៨.៩៣៥ | ៣៣០.៥៤៦.១៥ | - | - | - | ១៣.២១៨.១៣០ | ៣៤៥.៧៨៣.២២៣ |
| តណាទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ | - | - | ២៣៨.៩២៣.៤៧៤ | ១៥៣.៦៨៨.៥៥៦ | ៥៤៨.៧២២.៩៣១ | - | ៩៤១.៣៣៤.៩៦១ |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | ៩៩២.៦៦២ | ៩៩២.៦៦២ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ២.០១៨.៩៣៥ | ៣៣០.៥៤៦.១៥៨ | ២៤៣.៤២៨.៦៦៦ | ១៥៣.៦៨៨.៥៥៦ | ៥៤៨.៧២២.៩៣១ | ១៥៤.២៣០.៥១៥ | ១.៤៣២.៦៣៥.៧៦១ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ | ១.៨៨៣.១៣៦ | - | ១១៣.៧៦៧.៩៤៧ | - | - | - | ១១៥.៦៥១.០៨៣ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៨៦.៣០១.៦៨៤ | - | ៦៥៥.៤៦០.៦៦៣ | - | - | ៤០២.៦៤០.៣៨២ | ១.១៤៤.៤០២.៧២៩ |
| ប្រាក់កម្ចី | - | - | ៣១០.៦៧២ | ២០៦.៩០៨ | | - | ៥១៧.៥៨០ |
| បំណុលបន្ទាប់បន្សំ | - | - | ៣១៨.៦៧៤ | | ៣២.០០០.០០០ | - | ៣២.៣១៨.៦៧៤ |
| បំណុលភតិសន្យា | - | - | ១.៥៤៨.៦២៨ | ២.០១២.០៦២ | ១.៣៤៥.៤១៤ | - | ៤.៩០៦.១០៤ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | - | - | - | | | ៧.៧៩៧.៦៤៧ | ៧.៧៩៧.៦៤៧ |
| | ៨៨.១៨៤.៨២០ | - | ៧៧១.៤០៦.៥៨៤ | ២.២១៨.៩៧០ | ៣៣.៣៤៥.៤១៤ | ៤១០.៤៣៨.០២៩ | ១.៣០៥.៥៩៣.៨១៧ |
| គម្លាតតម្លៃអត្រាការប្រាក់សរុប | (៨៦.១៦៥.៨៨៥) | ៣៣០.៥៤៦.១៥៨ | (៥២៧.៩៧៧.៩១៨) | ១៥១.៤៦៩.៥៨៦ | ៥១៥.៣៧៧.៥១៧ | (២៥៦.២០៧.៥១៤) | ១២៧.០៤១.៩៤៤ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | (៣៤៦.៨១៧.៦៨៧) | ១.៣៣០.៤៤៨.២៨៦ | (២.១២៥.១១១.១២២) | ៦០៩.៦៦៥.០៨៦ | ២.០៧៤.៣៩៤.៥០៦ | (១.០៣១.២៣៥.២៤៤) | ៥១១.៣៤៣.៨២៥ |
| **ខ្នង់ក្រៅតារាងតុល្យការ** | | | | | | | |
| ធានាធនាគារ និងលិខិតតណាទាន | ១៨៣.៣២៧.៣៩៨ | - | - | - | - | - | ១៨៣.៣២៧.៣៩៨ |
| ចំណែកតណាទានវិបារូបន៍មិនទាន់បានប្រើ | ៩០.៩៨៥.១៣២ | - | - | - | - | - | ៩០.៩៨៥.១៣២ |
| ចំណែកប័ណ្ណតណាទានមិនទាន់បានប្រើ | ១៨.០៨៦.១៥១ | - | - | - | - | - | ១៨.០៨៦.១៥១ |
| កិច្ចសន្យាតណាទានមានកាលកំណត់ | ១.៥៩៤.៥៨៤ | - | - | - | - | - | ១.៥៩៤.៥៨៤ |
| | ២៨៩.៩៩៣.២៦៥ | - | - | - | - | - | ២៨៩.៩៩៣.២៦៥ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | ១.១៦៧.២២២.៨៩២ | - | - | - | - | - | ១.១៦៧.២២២.៨៩២ |

| | ១ខែ | ១ខែ ទៅ ៣ខែ | ៣ខែ ទៅ ១២ខែ | ១ឆ្នាំ ទៅ ៥ឆ្នាំ | លើស៥ឆ្នាំ | មិនមានការប្រាក់ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | ៥១.០១៣.៥៨៥ | ៥១.០១៣.៥៨៥ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល | - | - | ៧.៨០៤.៣៣៨ | - | - | ៧៨.២៩១.២១៨ | ៨២.០៩៥.៥៥២ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ | ២២២.០២១.៥៥៩ | ២៥.០៩០.២២៦ | - | - | - | ១០.១៦៥.៥៨០ | ២៥៧.២៧៧.៣២៥ |
| តណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដកអំលស់ | ១៩.៥២៩.៨៦៨ | ៧០.៥៥៧.៦០៦ | ១៣៨.៥៨០.២៧៩ | ២៨០.១១៩.២២៩ | ៨៨០.០៨៧.៦៩២ | - | ៩៨៤.៨៣៤.៦៧៨ |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | ១.៥៦១.០០១ | ១.៥៦១.០០១ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ២៨១.៥៥១.៨២៧ | ៩៥.៦៨៧.៨៣២ | ១៨២.៣៨៤.៦១៣ | ២៨០.១១៩.២២៩ | ៨៨០.០៨៧.៦៩២ | ១៣៧.០៣១.៣០៨ | ១.៣៣៦.៧៨២.០៩៧ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ | ៦៥.៨៧១.៩៥៨ | ៨៩.០៨៩.៨៨៥ | ៧៣.៩២៩.៨៨៨ | - | - | ៦០៩.១៥៨ | ១៨៩.១០០.៨០៥ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៣៦១.៦៦៩.៦៨៨ | ៨៩.១៧៨.០៨៩ | ៨៦៨.៥៨៧.៥៥១ | - | - | ៧៥.២២០.៨៨០ | ៩៩៤.៦១៥.៧២៨ |
| ប្រាក់កម្ចី | ៩.២៩៨ | ៥៧.៣៨០ | ២៧៦.៧០៨ | ៧៨៨.៨៨៨ | ២៣.៧៩៣ | - | ១.១៥២.០១៥ |
| បំណុលបន្ទាប់បន្សំ | - | ៣១៨.៦៧៨ | ៨៦.៩១៨ | - | ៨៧.០០០.០០០ | - | ៨៧.៨០៥.៥៩២ |
| បំណុលភតិសន្យា | ១២៩.១៣៩ | ២៥៩.៥៩៣ | ១.១៨៤.៣១២ | ៣.៩៧១.៩៧៨ | ៦១៩.៨៧៨ | - | ៦.១៦៤.៩០០ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | - | - | - | - | - | ៨.៧៦៣.៤៥៥ | ៨.៧៦៣.៤៥៥ |
| | ៤២៧.២៨០.០៣៩ | ១៣៨.៩០៣.៥៨១ | ៥៨៤.០២៤.៩២៩ | ៤.៧៥៦.៨២២ | ៨៧.៦៨៣.៦៧១ | ៨៤.៥៩៣.០៩៣ | ១.២៨៧.២០២.០៩៥ |
| គម្លាតតម្លៃអត្រាការប្រាក់សរុប | (១៨៥.៧២៨.៦១២) | (៨៣.២៥៥.៧០៩) | (៨០១.៦៨០.៣១៦) | ២៧៥.៣៦២.៨០៧ | ៣៩២.៨០៤.០២១ | ៥២.៨៣៨.២១១ | ៨៩.៥៨០.០០២ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | (៧៥៨.៧០១.៣៨០) | (១៧៦.៦៩៩.៥៧១) | (១.៦៨០.៧០០.៦៩១) | ១.១២៨.៨៥៥.៨៣៣ | ១.៦០២.៩៧០.៨២៦ | ២១៨.២១០.០៩២ | ៣៦៥.៩៣៨.៣០៩ |
| **ខ្ទង់ក្រៅតារាងតុល្យការ** | | | | | | | |
| ធានាធនាគារ និងលិខិតតណទាន | ២.០៥៣.៨៧៨ | ៣.៦៩២.៩០២ | ២៧១.៨៧៥.២០៥ | - | - | - | ២៧៧.២២១.៩៨៥ |
| ចំណែកតណទានវិចារូបន៍មិនទាន់បានប្រើ | ៦៥.៧៩៥.៩៨៨ | - | - | - | - | - | ៦៥.៧៩៥.៩៨៨ |
| ចំណែកប័ណ្ណតណទានមិនទាន់បានប្រើ | ១២.៣៦៦.១៩៦ | - | - | - | - | - | ១២.៣៦៦.១៩៦ |
| កិច្ចសន្យាតណទានមានកាលកំណត់ | - | - | ១៨.០៧៥.៣០២ | - | ៣.៨០៧.៧០៨ | - | ១៧.៨៨៣.០០៦ |
| | ៨០.២១៦.០៦២ | ៣.៦៩២.៩០២ | ២៨៥.៥៥០.៥០៧ | - | ៣.៨០៧.៧០៨ | - | ៣៧៣.២៦៧.១៧៥ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | ៣២៧.៦៨២.៦១៣ | ១៥.០៨៥.៥០៥ | ១.១៦៦.៨៧៣.៨២១ | - | ១៥.៥៥៨.៨៧១ | - | ១.៥២៨.៧៩៦.៨១០ |

## ៣៥.៣ ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យ ដែលធនាគារមិនមានលទ្ធភាពបំពេញកាតព្វកិច្ចសងប្រាក់ តាមកាលកំណត់សង ចំពោះបំណុលហិរញ្ញវត្ថុរបស់ខ្លួន ក៏ដូចជាមិនមានលទ្ធភាពបំពេញមូលនិធិវិញបាន នៅពេលដែលបានដកមកប្រើប្រាស់រួចហើយ។ ផលវិបាកនេះ អាចបណ្តាលឱ្យធនាគារមិនអាចបំពេញកាតព្វកិច្ចសងប្រាក់ ទៅអ្នកធ្វើប្រាក់ និងកង្វះសាច់ប្រាក់ ដើម្បីឱ្យអតិថិជនខ្វី។

### (ក) ដំណើរការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល

គណៈគ្រប់គ្រង តាមដានសាច់ប្រាក់ងាយស្រួល ក្នុងតារាងតុល្យការ និងគ្រប់គ្រងការប្រមូលផ្តុំ និងទិន្នន័យបំណុល ដែលមានកាលកំណត់។ ការត្រួតពិនិត្យ និងការធ្វើរបាយការណ៍ ត្រូវបានធ្វើឡើងក្នុងទម្រង់ជាការត្រួតពិនិត្យ លើស្ថានភាពសាច់ប្រាក់ប្រចាំថ្ងៃ ហើយនិងរៀបចំគម្រោង សម្រាប់ថ្ងៃបន្ទាប់ប្រចាំសប្តាហ៍ និងប្រចាំខែជាលំដាប់ ដោយសារវាជារយៈពេលគន្លឹះ ក្នុងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល។ គណៈគ្រប់គ្រង តាមដានអំពីបម្រែបម្រួល នៃអ្នកធ្វើប្រាក់សំខាន់ៗ និងគម្រោង នៃការដកសាច់ប្រាក់របស់ពួកគេ។

### (ខ) ដំណើរការរកប្រភពទុន

ប្រភពសាច់ប្រាក់ងាយស្រួលចម្បងរបស់ធនាគារ បានមកពីដើមទុនបានបង់របស់ភាគទុនិក ប្រាក់កម្ចី បំណុលបន្ទាប់បន្សំ និងប្រាក់បញ្ញើរបស់ធនាគារ និងអតិថិជន។ គណៈគ្រប់គ្រង ត្រួតពិនិត្យប្រភពសាច់ប្រាក់ងាយស្រួលប្រចាំថ្ងៃយ៉ាងទៀងទាត់ តាមរយៈការត្រួតពិនិត្យ លើកាលកំណត់ នៃប្រាក់បញ្ញើមានកាលកំណត់ និងអ្នកធ្វើប្រាក់សំខាន់ៗ។

### (គ) លំហូរសាច់ប្រាក់អនិស្សន្ទ

តារាងខាងក្រោមនេះ បង្ហាញពីលំហូរសាច់ប្រាក់ត្រូវបង់ ក្រោមបំណុលហិរញ្ញវត្ថុមិននិស្សន្ទ ដោយផ្អែកតាមកាលកំណត់ លើកិច្ចសន្យា ដែលនៅសល់ នាកាលបរិច្ឆេទតារាងតុល្យការ។ ចំនួនទឹកប្រាក់ដែលបានលាតត្រដាង នៅក្នុងតារាងនេះ គឺជាលំហូរសាច់ប្រាក់ ក្នុងកិច្ចសន្យា ដែលមិនធ្វើអប្បហារ ដោយឡែកធនាគារគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ដោយផ្អែកតាមលំហូរសាច់ប្រាក់រំពឹងទុកដែលមិនធ្វើអប្បហារ។

| | ១ខែ | ១ខែ ទៅ ៣ខែ | ៣ខែ ទៅ ១២ខែ | ១ឆ្នាំ ទៅ ៥ឆ្នាំ | លើស៥ឆ្នាំ | សរុប |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៣៩.៤៩៣.៨២១ | - | - | - | - | ៣៩.៤៩៣.៨២១ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល | ១០០.៥២៦.៣០២ | - | ៤.៥០៥.១៩២ | - | - | ១០៥.០៣១.៤៩៤ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ | ២.០១៨.៩៣៥ | ១៣.២១៨.១៣០ | ៣៣០.៥៨៦.១៥៨ | - | - | ៣៨៥.៧៨៣.២២៣ |
| ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ | - | - | ២៣៨.៩២៣.៨៧៨ | ១៥៣.៦៨៨.៥៥៦ | ៥៨៨.៧២២.៩៣១ | ៩៤១.៣៣៨.៩៦១ |
| ទ្រព្យសកម្មផ្សេងៗ | ៩៩២.៦៦២ | - | - | - | - | ៩៩២.៦៦២ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ១៨៣.០៣១.៣២០ | ១៣.២១៨.១៣០ | ៥៧៣.៩៧៨.៨២៨ | ១៥៣.៦៨៨.៥៥៦ | ៥៨៨.៧២២.៩៣១ | ១.៨៣២.៦៣៥.៧៦១ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ | ១.៨៨៣.១៣៦ | - | ១១៣.៧៦៧.៩៤៧ | - | - | ១១៥.៦៥១.០៨៣ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៤៨៨.៩៤២.០៦៦ | - | ៦៥៥.៤៦០.៦៦៣ | - | - | ១.១៤៤.៤០២.៧២៩ |
| ប្រាក់កម្ចី | - | - | ៣១០.៦៧២ | ២០៦.៩០៨ | - | ៥១៧.៥៨០ |
| បំណុលបន្ទាប់បន្សំ | - | - | ៣១៨.៦៧៨ | | ៣២.០០០.០០០ | ៣២.៣១៨.៦៧៨ |
| បំណុលភតិសន្យា | - | - | ១.៥៤៨.៦២៨ | ២.០១២.០៦២ | ១.៣៤៥.៤១៩ | ៤.៩០៦.១០៤ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | ៧.៧៩៧.៦៤៧ | - | - | - | - | ៧.៧៩៧.៦៤៧ |
| បំណុលហិរញ្ញវត្ថុសរុប | ៤៩៨.៦២២.៨៤៩ | | ៧៧១.៤០៦.៥៨៤ | ២.២១៨.៩៧០ | ៣៣.៣៤៥.៤១៩ | ១.៣០៥.៥៩៣.៨១៧ |
| (បំណុល)/ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | (៣៥៥.៥៩១.៥២៩) | ១៣.២១៨.១៣០ | (១៩៧.៤៣១.៧៦០) | ១៥១.៤៦៩.៥៨៦ | ៥១៥.៣៧៧.៥១៧ | ១២៧.០៤១.៩៤៤ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | (១.៤៥២.៥៩១.៣៩៦) | ៥៣.៩៩៦.០៦១ | (៨០៦.៥០៨.៧៤២) | ៦១៨.៧៥៣.២៦១ | ២.១០៥.៣១៧.១៥៧ | ៥១៨.៩៦៦.៣៤១ |
| **ខ្នង់ក្រៅតារាងតុល្យការ** | | | | | | |
| លិខិតធានាធនាគារ និងលិខិតឥណទាន | ១៨៣.៣២៧.៣៩៨ | - | - | - | - | ១៨៣.៣២៧.៣៩៨ |
| ចំណែកឥណទានវិបារូបន៍មិនទាន់បានប្រើ | ៩០.៩៨៥.១៣២ | - | - | - | - | ៩០.៩៨៥.១៣២ |
| ចំណែកប័ណ្ណឥណទានមិនទាន់បានប្រើ | ១៤.០៨៦.១៥១ | - | - | - | - | ១៤.០៨៦.១៥១ |
| កិច្ចសន្យាឥណទានមានកាលកំណត់ | ១.៥៩៤.៥៨៤ | - | - | - | - | ១.៥៩៤.៥៨៤ |
| | ២៨៩.៩៩៣.២៦៥ | - | - | - | - | ២៨៩.៩៩៣.២៦៥ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | ១.១៦៧.២២២.៨៩២ | - | - | - | - | ១.១៦៧.២២២.៨៩២ |

| | ១ខែ | ១ខែ ទៅ ៣ខែ | ៣ខែ ទៅ ១២ខែ | ១ឆ្នាំ ទៅ ៥ឆ្នាំ | លើស៥ឆ្នាំ | សរុប |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥១.០១៣.៥៤៥ | - | - | - | - | ៥១.០១៣.៥៤៥ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល | ៧៨.២៩១.២១៨ | - | ៧.៨៥០.៧៨៨ | - | - | ៨២.១៨២.០០២ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារផ្សេងៗ | ២៣២.៤៨៦.៨១០ | ២៥.២៨៥.១៣៧ | - | - | - | ២៥៧.៧៣១.៩៤៧ |
| តណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ | ៥៩.១៣៤.១៧៨ | ១០១.៨៩៦.៦៨៩ | ២៩៦.៧៩២.៧២៩ | ៤៨២.៣៩៨.៧៤២ | ២៩៣.៦៣៣.៧៥៩ | ១.២៣៣.៨៥៦.០៩៧ |
| ទ្រព្យសកម្មផ្សេងៗ | ៨២៨.៦៧៣ | - | ១១២.២៧៧ | ១.០២០.០៥១ | - | ១.៥៦១.០០១ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ៨១៧.៣១៤.៨២៤ | ១២៧.១៨១.៨២៦ | ៣០៤.៧៥៥.៧៩០ | ៤៨៣.៨១៨.៧៩៣ | ២៩៣.៦៣៣.៧៥៩ | ១.៦២៦.៣០៤.៥៩២ |
| **ចំណុលហិរញ្ញវត្ថុ** | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ | ៦៦.១៥៤.១១៨ | ៤៩.៥២០.៨៧៣ | ៧៧.៨០៣.០៥៥ | - | - | ១៩៣.៨៧៧.៦៨៦ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៨៣៦.៩៧៩.៨០៣ | ៨៩.៩៣២.៣៣៨ | ៨៨៧.៦៥៦.០៦៣ | - | - | ១.០១៤.៥៦៨.២០០ |
| ប្រាក់កម្ចី | ៩.៥០៨ | ៦២.១៩៩ | ២៩៦.៦០៣ | ៨២០.៨២៩ | ២៣.៩៧៩ | ១.២១៣.១១៨ |
| បំណុលបន្ទាប់បន្សំ | - | ៥៦៩.៩៥៧ | ១.២៥១.៧៧១ | ៥.៨៣៦.០២៨ | ៥០.៨៨២.៣៨៤ | ៥៨.១០០.១០០ |
| បំណុលភតិសន្យា | ១៥០.០១៣ | ៣០០.០២៦ | ១.៣៨៤.២៨៦ | ៨.១៨៨.៨១៧ | ៧៨៦.៦៦៦ | ៦.៧២៩.៨០៨ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | ៧.០១០.៩៧៣ | ៨៩.៣៧៨ | ១.៧០៣.១០៨ | - | - | ៨.៧៦៣.៨៥៥ |
| បំណុលហិរញ្ញវត្ថុសរុប | ៥១០.៣០៨.៨១៥ | ១៨០.៨៣៨.៣៦៣ | ៥៧០.០៥៨.៨៨៦ | ១០.៨៨៥.២៧៨ | ៥១.២១២.៩៨៩ | ១.២៨២.៨៥១.៩២៧ |
| (បំណុល)/ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | (៩២.៩៨៩.៩៩១) | (១៣.២៥២.៥៣៧) | (២៦៥.២៩៩.០៩៦) | ៨៧២.៥៧៣.៥១៩ | ២៨២.៨២០.៧៧០ | ៣៨៣.៨៥២.៦៦៥ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | (៣៧៩.៨៦៨.១១៣) | (៥៨.១៣៦.៦១៨) | (១.០៨៣.៧៨៦.៨០៧) | ១.៩៣០.៨៦២.៨២៥ | ៩៩០.២៨៨.៨៨៥ | ១.៨០៣.០០៨.១៣៦ |
| **ខ្ទង់ក្រៅតារាងតុល្យការ** | | | | | | |
| លិខិតធានាធនាគារ និងលិខិតតណទាន | ២៧៧.២៨៣.៣២៣ | - | - | - | - | ២៧៧.២៨៣.៣២៣ |
| ចំណែកតណទានវិចារូបន៍មិនទាន់បានប្រើ | ៦៥.៧៩៥.៩៨៨ | - | - | - | - | ៦៥.៧៩៥.៩៨៨ |
| ចំណែកប័ណ្ណតណទានមិនទាន់បានប្រើ | ១២.៣៦៦.១៩៦ | - | - | - | - | ១២.៣៦៦.១៩៦ |
| កិច្ចសន្យាតណទានមានកាលកំណត់ | ១៧.៨៨៩.៨៨៦ | - | - | - | - | ១៧.៨៨៩.៨៨៦ |
| | ៣៧៣.៣៣៥.៣៩៣ | - | - | - | - | ៣៧៣.៣៣៥.៣៩៣ |
| សមមូលពាន់រៀល (កំណត់សម្គាល់ ២.៣) | ១.៥២៥.០៧៥.០៨០ | - | - | - | - | ១.៥២៥.០៧៥.០៨០ |

## ៣៥.៤ តម្លៃសមស្រប នៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

**(ក) ឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្រប**

ធនាគារមិនមានឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របទេ។

**(ខ) ឧបករណ៍ហិរញ្ញវត្ថុមិនវាស់វែងតាមតម្លៃសមស្រប**

គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានតម្លៃប្រហាក់ប្រហែលនឹងសមតុល្យយោងរបស់វា។

ការប៉ាន់ស្មានតម្លៃសមស្រប ផ្អែកទៅតាមវិធីសាស្ត្រ និងការសន្មតដូចខាងក្រោម៖

**(i) ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល និងធនាគារផ្សេងៗ**

សមតុល្យយោង នៃប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារកណ្តាល និងធនាគារផ្សេងៗ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា ដោយសារគណនីទាំងនេះភាគច្រើន គឺជាគណនីចរន្ត គណនីសន្សំ និងប្រាក់បញ្ញើរយៈពេលខ្លី។

**(ii) តណទាន និងបុរេប្រទានអតិថិជន**

ចំពោះតណទាន ដែលមានអត្រាថេរ ដែលមានកាលកំណត់ នៅសល់តិចជាង១ឆ្នាំ ជាទូទៅសមតុល្យយោងរបស់វា គឺជាតម្លៃសមស្របប៉ាន់ស្មានរបស់វា។

ចំពោះតណទាន ដែលមានអត្រាថេរ និងមានកាលកំណត់នៅសល់ ១ឆ្នាំ ឬលើសពី ១ឆ្នាំ តម្លៃសមស្របត្រូវបានប៉ាន់ស្មាន ដោយធ្វើអប្បហារលំហូរសាច់ប្រាក់ប៉ាន់ស្មាន នាពេលអនាគត និងប្រើអត្រាការប្រាក់របស់តណទាន នាពេលបច្ចុប្បន្ន ដោយសារអត្រាការប្រាក់តាមទីផ្សាររបស់តណទាន មានហានិភ័យតណទាន និងកាលកំណត់ប្រហាក់ប្រហែលគ្នា ហើយត្រូវបានវាយតម្លៃថា មានភាពខុសគ្នាតិចតួច ជាមួយនឹងអត្រាការប្រាក់របស់តណទាន តាមកិច្ចសន្យា។ ជាលទ្ធផល តម្លៃសមស្រប នៃតណទាន និងបុរេប្រទានអតិថិជនរយៈពេលវែង អាចមានតម្លៃប្រហាក់ប្រហែលនឹងសមតុល្យយោង នាកាលបរិច្ឆេទរាយការណ៍។

**(iii) ប្រាក់បញ្ញើរបស់ធនាគារ និងអតិថិជន**

តម្លៃសមស្រប នៃប្រាក់បញ្ញើរបស់ធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងអតិថិជន ដែលមានកាលកំណត់តិចជាង ១ឆ្នាំ មានតម្លៃប្រហាក់ប្រហែលនឹងសមតុល្យយោងរបស់វា ដោយសារប្រាក់បញ្ញើទាំងនេះមានរយៈពេលខ្លី។ តម្លៃសមស្រប នៃប្រាក់បញ្ញើរបស់ធនាគារ និងអតិថិជន ដែលមានកាលកំណត់លើសពី ១ឆ្នាំ ត្រូវបានគេរំពឹងថា មានតម្លៃប្រហាក់ប្រហែលនឹងសមតុល្យយោង ដោយសារធនាគារបានផ្តល់អត្រាការប្រាក់ប្រហាក់ប្រហែលគ្នា ទៅនឹងឧបករណ៍ ដែលមានកាលកំណត់ និងលក្ខខណ្ឌឥណទានស្រដៀងគ្នាដែរ។

តម្លៃសមស្របប៉ាន់ស្មាន នៃប្រាក់បញ្ញើ ដែលមិនមានកាលកំណត់ រួមទាំងប្រាក់បញ្ញើ ដែលគ្មានការប្រាក់ ប្រាក់បញ្ញើ ដែលអាចដកបាន តាមតម្រូវការ គឺជាចំនួនទឹកប្រាក់ ដែលត្រូវសង នាកាលបរិច្ឆេទរាយការណ៍។

**(iv) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុផ្សេងៗ**

សមតុល្យយោង នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានសន្មតថា មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារគណនីទាំងនេះមិនមានតម្លៃប្រែប្រួលជាសារវន្ត ទៅតាមអត្រាទីផ្សារទេ។

**(v) ប្រាក់កម្ចី និងបំណុលបន្ទាប់បន្សំ**

ប្រាក់កម្ចី និងបំណុលបន្ទាប់បន្សំ មិនត្រូវបានសម្រង់តម្លៃ លើទីផ្សារសកម្មទេ ហើយតម្លៃសមស្របរបស់វា មានតម្លៃប្រហាក់ប្រហែលនឹងសមតុល្យយោងរបស់វា ដោយសារអត្រាការប្រាក់ មានតម្លៃប្រហាក់ប្រហែលនឹងអត្រាទីផ្សារ។

គោលដៅរបស់ធនាគារ ក្នុងការគ្រប់គ្រងដើមទុន មានន័យទូលំទូលាយជាង «មូលធន» ដែលបានបង្ហាញ នៅលើតារាងតុល្យការ។ ការគ្រប់គ្រងដើមទុន មានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុន ដែលកំណត់ដោយធនាគារកណ្តាល
- ការពារលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ដើម្បីឱ្យធនាគារអាចបន្តផ្តល់ផលប្រយោជន៍ ដល់ភាគទុនិក និងដល់ភាគីផ្សេងៗ ដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម

ធនាគារកណ្តាល តម្រូវឱ្យធនាគារពាណិជ្ជទាំងអស់ ត្រូវ៖ (i) រក្សាដើមទុនអប្បបរមា (ii) រក្សាមូលនិធិថ្នាល់សុទ្ធរបស់ធនាគារយ៉ាងហោចណាស់ ឱ្យស្មើនឹងដើមទុនអប្បបរមា និង (iii) អនុលោមតាមអនុបាតសាធនភាពអនុបាតសាច់ប្រាក់ងាយស្រួល។

តារាងខាងក្រោមនេះ សង្ខេបអំពីសមាសធាតុដើមទុនតាមច្បាប់៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៣) |
| **ដើមទុនថ្នាក់ទី១** | | | | |
| ដើមទុន | ៧៥.០០០.០០០ | ៣០១.៨៧៥.០០០ | ៧៥.០០០.០០០ | ៣០៦.៣៧៥.០០០ |
| ទុនបម្រុង | ៦៥.០០០.០០០ | ២៦១.៦២៥.០០០ | ៤២.០០០.០០០ | ១៧១.៥៧០.០០០ |
| ចំណេញរក្សាទុក | ៥៤.៣៩៣.៥៤២ | ១៧៨.៥៥៣.៦៦៧ | ៤៤.២៧៨.៣៨៩ | ១៨០.៨៧៧.២១៩ |
| ដក៖ ទ្រព្យសកម្មអរូបី | (១.០៥២.៦៨២) | (៤.២៣៧.០៤៦) | (១.១៧៣.៥០១) | (៤.៧៩៣.៧៥២) |
| ដក៖ ឥណទានផ្តល់ឱ្យភាគីពាក់ព័ន្ធ | (៣.៤០០.៧៦៩) | (១៣.៦៨៨.០៩៥) | (២.៧៩៨.៤៩៨) | (១១.៤៣១.៨៦៤) |
| | ១៨៩.៩៤០.០៩២ | ៧២៤.៤២៨.៥២៦ | ១៥៧.៣០៦.៣៩០ | ៦៤២.៥៩៦.៦០៣ |
| **ដើមទុនថ្នាក់ទី២-ដើមទុនបន្ថែម** | | | | |
| សំវិធានធនទូទៅ | ១២.៥៩៧.០២០ | ៥០.៧០៣.០០៤ | ១២.៩១៩.៣៦៦ | ៥២.៧៧៥.៦១០ |
| បំណុលបន្ទាប់បន្សំ | ២៩.០០០.០០០ | ១៣០.០៨២.៦៦៣ | ៨៧.០០០.០០០ | ១៩១.៩៩៥.០០០ |
| | ៤១.៥៩៧.០២០ | ១៨០.៧៨៥.៦៦៧ | ៥៩.៩១៩.៣៦៦ | ២៤៤.៧៧០.៦១០ |
| | ២៣១.៥៣៧.៩១១ | ៩០៥.២១៤.១៩៣ | ២១៧.២២៥.៧៥៦ | ៨៨៧.៣៦៧.២១៣ |

## ៣៦. ព្រឹត្តិការណ៍ ក្រោយកាលបរិច្ឆេទ នៃរបាយការណ៍

ពុំមានការកែតម្រូវ ឬព្រឹត្តិការណ៍សំខាន់ៗ ដែលមិនបានកែតម្រូវ បានកើតឡើង នៅចន្លោះកាលបរិច្ឆេទ នៃរបាយការណ៍ និងកាលបរិច្ឆេទ នៃការអនុម័ត ទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដែលតម្រូវឱ្យមានការកែតម្រូវ ឬការលាតត្រដាងព័ត៌មាន ដែលត្រូវបានធ្វើឡើង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើយ។

## ៣៧. ការអនុម័ត លើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ត្រូវបានអនុម័តឱ្យចេញផ្សាយ ដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥។

# ព័ត៌មានហិរញ្ញវត្ថុបន្ថែម ទៅតាមតម្រូវការរបស់ ធនាគារជាតិ នៃកម្ពុជា

សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ខ្ញុំបាទជា អភិបាលប្រតិបត្តិ / ប្រធាននាយកប្រតិបត្តិ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី និងជាហត្ថលេខី សូមអះអាងថា តាមមតិយោបល់របស់ខ្ញុំបាទ ព័ត៌មានហិរញ្ញវត្ថុបន្ថែម ដែលបានភ្ជាប់មកជាមួយនេះ រួមមានការលាតត្រដាងព័ត៌មាន ទៅតាមតម្រូវការ នៃប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ត្រូវបានរៀបចំឡើង និងឆ្លុះបញ្ចាំងត្រឹមត្រូវ អំពីព័ត៌មានហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ ព័ត៌មានហិរញ្ញវត្ថុ និងទិន្នន័យទាំងនេះ គឺជាការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងធនាគារ។ ព័ត៌មានហិរញ្ញវត្ថុបន្ថែមនេះ មានសង្គតិភាព ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ហើយព័ត៌មានហិរញ្ញវត្ថុនេះដែរ មិនមានការរាយការណ៍ខុសជាសារវន្តទេ។

ចុះហត្ថលេខា ដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

**លោក ប៊ុន យីន**
អភិបាលប្រតិបត្តិ / ប្រធាននាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥

ព័ត៌មានហិរញ្ញវត្ថុនេះ មិនមែនជាផ្នែក នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មទេ។

## ១. អនុបាតក្របខណ្ឌសន្ទនីយភាព ប្រកាសលេខ ធ៧-០១៥-៣៤៩ ប្រ.ក. និងសារាចរណែនាំលេខ ធ៧-០២០-០០៣ ស.រ.ណ.ន

ធនាគារត្រូវអនុវត្តការគណនាអនុបាតក្របខណ្ឌសន្ទនីយភាព (LCR) ស្របតាមគំរូរបាយការណ៍ថ្មី ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ ជាដំណាក់កាលរហូតបំពេញបានទាំងស្រុង នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២០។ ធនាគារត្រូវរក្សាជាប្រចាំ នូវបរិមាណទ្រព្យសកម្មសន្ទនីយ ដែលអាចទទួលយកបានគ្រប់គ្រាន់ (eligible liquid assets) ដើម្បីឱ្យកម្រិតអនុបាត ដែលបានកំណត់ ស្របទៅតាមពេលវេលា ដូចខាងក្រោម៖

| ចាប់អនុវត្ត | ០១ កញ្ញា ២០១៦ | ០១ កញ្ញា ២០១៧ | ០១ កញ្ញា ២០១៨ | ០១ មិថុនា ២០១៩ | ០១ មករា ២០២០ |
|---|---|---|---|---|---|
| អនុបាតអប្បបរមា | ៦០% | ៧០% | ៨០% | ៩០% | ១០០% |

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ធនាគារមានអនុបាតក្របខណ្ឌសន្ទនីយ ១៨៦,៥៦%។

ការគណនាអនុបាតក្របខណ្ឌសន្ទនីយ ត្រូវបានលម្អិត នៅក្នុងតារាង១។

## ២. កាតព្វកិច្ចដើមទុនអប្បបរមា ប្រកាសលេខ ធ-០១៦-១១៧ ប្រ.ក.

ប្រកាសរបស់ធនាគារកណ្តាលលេខ ធ៧-០១៦-១១៧ ប្រ.ក. ស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តម្រូវឱ្យធនាគារពាណិជ្ជបង្កើតឡើង ក្រោមរូបភាពជាសាខាធនាគារបរទេស ដែលមានធនាគារមេ មានចំណាត់ថ្នាក់វិនិយោគ ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ២០០ពាន់លានរៀល (ឬ ៥០លានដុល្លារអាមេរិក) ហើយធនាគារពាណិជ្ជ ដែលបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ឬជាបុត្រសម្ព័ន្ធរបស់ធនាគារបរទេស ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៣០០ពាន់លានរៀល (ឬ ៧៥លានដុល្លារអាមេរិក) ក្នុងរយៈពេលពីរឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខា ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ នេះតទៅ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ធនាគារមានដើមទុនបានបង់ចំនួន ៧៥.០០០.០០០ដុល្លារអាមេរិក ដែលបានបំពេញតាមកាតព្វកិច្ច ដើមទុនអប្បបរមារួចហើយ។

## ៣. មូលនិធិថ្នាល់សុទ្ធ ប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក.

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ មូលនិធិថ្នាល់សុទ្ធរបស់ធនាគារមានចំនួន ២៣១.៥៣៧.១១១ ដុល្លារអាមេរិក ដូចគណនា ក្នុងតារាង២។

ធនាគារទាំងឡាយ ត្រូវរក្សាមូលនិធិថ្នាល់សុទ្ធរបស់ខ្លួន យ៉ាងហោចណាស់ស្មើនឹងដើមទុនអប្បបរមា។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ មូលនិធិថ្នាល់របស់ធនាគារ ដែលមានចំនួន ២៣១.៥៣៧.១១១ ដុល្លារអាមេរិក គឺខ្ពស់ជាងចំនួន ១៥៦.៥៣៧.១១១ដុល្លារអាមេរិក បើធៀបទៅនឹងដើមទុនអប្បបរមាចំនួន ៧៥.០០០.០០០ដុល្លារអាមេរិក។

ការគណនាមូលនិធិថ្នាល់សុទ្ធ ត្រូវបានលម្អិត នៅក្នុងតារាង២។

## ៤. អនុបាតសាធនភាព ប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក. និងប្រកាសលេខ ធ៧-០៧-១៣៥ ប្រ.ក.

ធនាគារត្រូវបានតម្រូវឱ្យរក្សាអនុបាតសាធនភាពយ៉ាងហោចណាស់ ១៥%។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ អនុបាតសាធនភាពរបស់ធនាគារមានចំនួន ១៨,៧៧% ដែលគណនា ដោយយកមូលនិធិថ្នាល់សុទ្ធរបស់ធនាគារ ជាភាគរយ នៃទ្រព្យសកម្ម ដែលថ្លឹងហានិភ័យ និងខ្នង់ក្រៅតារាងតុល្យការ។

ការគណនាអនុបាតសាធនភាព ត្រូវបានលម្អិត នៅក្នុងតារាង៣។

## ៥. ប្រតិបត្តិការរូបិយប័ណ្ណបរទេស ប្រកាសលេខ ធ៧-០០-៥០ ប្រ.ក.

ធនាគារធ្វើប្រតិបត្តិការអាជីវកម្ម និងរក្សាបញ្ជីគណនេយ្យរបស់ខ្លួន ជាប្រាក់ដុល្លារអាមេរិក។ ហេតុនេះរូបិយប័ណ្ណទាំងអស់ ក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានចាត់ទុកជារូបិយប័ណ្ណបរទេស។

**ខ្នង់តារាងតុល្យការ**

អនុលោមតាមប្រកាសលេខ ធ៧-០០-៥០ ប្រ.ក. គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ រាល់ទ្រព្យសកម្ម និងបំណុលរបស់ធនាគារទាំងអស់ ជារូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រាប្តូរ ដោយប្រើអត្រាប្តូរប្រាក់ នាដំណាច់ការិយបរិច្ឆេទ។

**ខ្នង់ក្រៅតារាងតុល្យការ**

ធនាគារត្រូវបានតម្រូវឱ្យកត់ត្រា ក្នុងខ្នង់ក្រៅតារាងតុល្យការ នូវកិច្ចសន្យា ទាក់ទងនឹងទ្រព្យសម្បត្តិ និងបរិក្ខារ ដែលកើតពីការទិញ និងលក់រូបិយប័ណ្ណបរទេស ទាក់ទងនឹងប្រតិបត្តិការដល់ដៃ (ដែលមានរយៈពេល ២ថ្ងៃ) និងប្រតិបត្តិការប្តូររូបិយប័ណ្ណមានកាលកំណត់។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ធនាគារមិនមានកិច្ចសន្យាប្រភេទនេះ សម្រាប់ប្រតិបត្តិការប្តូររូបិយប័ណ្ណ នាពេលអនាគត ហើយធនាគារបានអនុវត្ត ស្របតាមប្រកាសនេះ។

## ៦. ស្ថានភាពចំហសុទ្ធ នៃរូបិយប័ណ្ណបរទេស ប្រកាសលេខ ធ៧-០៧-១៣៤ ប្រ.ក. និងលិខិតលេខ ធ៧-០២០-៨៦៨ ធ.ត

អនុលោមតាមលក្ខខណ្ឌ នៃប្រកាសនេះ ធនាគារត្រូវបានតម្រូវឱ្យរក្សាស្ថានភាពចំហសុទ្ធ នៃរូបិយប័ណ្ណបរទេសមួយណាក៏ដោយ ឬស្ថានភាពចំហសុទ្ធ នៃរូបិយប័ណ្ណបរទេសទាំងអស់ ទោះក្នុងស្ថានភាពវែង ឬខ្លីក៏ដោយ មិនត្រូវឱ្យលើស ២០% នៃមូលនិធិថ្នាល់សុទ្ធ របស់ធនាគារឡើយ លើកលែងតែប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ធនាគារមិនមានស្ថានភាពចំហសុទ្ធ នៃរូបិយប័ណ្ណបរទេស ដែលលើស ២០% នៃមូលនិធិថ្នាល់សុទ្ធ របស់ធនាគារទេ ដូចបានលម្អិត ក្នុងតារាង៥។

## ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនហ្វាស៊ីលីធីហិរញ្ញវត្ថុបាត់បង់ ប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ណ.ន សារាចរណែនាំលេខ ធ៧-០២១-២៣១៤ ធ.ត និងសារាចរណែនាំលេខ ធ៧-០២១-០០១ ស.រ.ណ.ន និងសារាចរលេខ ធ៣០-០២៥-១៧០ ស.រ.ណ.ន

សារាចរណែនាំ របស់ធនាគារកណ្តាលលេខ ធ៧-០២១-២៣១៤ធ.ត ស្តីពីកាតព្វកិច្ចធ្វើចំណាត់ថ្នាក់ និងសំវិធានធន ចំពោះតំណាទានរៀបចំឡើងវិញ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ (ចាប់អនុវត្ត ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២) តម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ ធ្វើចំណាត់ថ្នាក់ និងសំវិធានធន ចំពោះតំណាទានរៀបចំឡើងវិញជាបីក្រុម គឺក្រុមតំណាទានរៀបចំឡើងវិញ ដែលមានស្ថានភាពល្អ ក្រុមតំណាទានរៀបចំឡើងវិញ ដែលមានស្ថានភាព ត្រូវការការរៀបចំឡើងវិញបន្ថែម និងក្រុមតំណាទានរៀបចំឡើងវិញ ដែលមានស្ថានភាពមិនល្អ។ ក្រុមនីមួយៗ ត្រូវបានបែងចែកជា ៥ថ្នាក់ និងទៅតាមកម្រិតសំវិធានធនអប្បបរមា។

សារាចរណែនាំ របស់ធនាគារកណ្តាលលេខ ធ៧-០២៣-០០១ សារាចរ ស្តីពីការរៀបចំតំណាទានឡើងវិញ ចំពោះវិស័យទេសចរណ៍ នៅខេត្តសៀមរាប ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤ អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ រៀបចំតំណាទានឡើងវិញ ចំពោះតំណាទាន ដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ នៅខេត្តសៀមរាប។ គ្រឹះស្ថានហិរញ្ញវត្ថុ អាចរៀបចំតំណាទានឡើងវិញបានចំនួន ២ដង គិតចាប់ពីថ្ងៃប្រសិទ្ធភាព នៃសារាចរណែនាំនេះ រហូតដល់ដំណាច់ខែធ្នូ ឆ្នាំ២០២៤។ គ្រឹះស្ថានហិរញ្ញវត្ថុ អាចរក្សាចំណាត់ថ្នាក់តំណាទានល្អបំផុត ត្រឹមចំណាត់ថ្នាក់ មុនពេលរៀបចំតំណាទានឡើងវិញ និងមិនចាំបាច់ធ្វើសំវិធានធនបន្ថែមឡើយ។

បន្ទាប់ពីរៀបចំតណាទានឡើងវិញ ប្រសិនបើគ្រឹះស្ថានវាយតម្លៃឃើញថា ស្ថានភាពលំបាក ផ្អែកហិរញ្ញវត្ថុ និងការខកខានទូទាត់សងរបស់អតិថិជន មិនមែនជាស្ថានភាពបណ្តោះអាសន្ន គ្រឹះស្ថានត្រូវទម្លាក់ចំណាត់ថ្នាក់តណាទាន និងត្រូវធ្វើសំវិធានធនបន្ថែម ចំពោះតណាទានរៀបចំឡើងវិញនោះភ្លាម។

គ្រឹះស្ថានអាចអនុវត្តការដំឡើងចំណាត់ថ្នាក់តណាទាន ដោយផ្អែកលើការវាយតម្លៃលទ្ធភាពទូទាត់សងរបស់អតិថិជនរយៈពេល ៦ខែ សម្រាប់តណាទានរយៈពេលវែង (៣ខែ សម្រាប់តណាទានរយៈពេលខ្លី) បន្ទាប់ពីរយៈពេលអនុគ្រោះចុងក្រោយ (ដំណាច់ខែធ្នូ ឆ្នាំ២០២៤) ស្របតាមប្រកាសលេខ ធ៧-០១៧-៣៤៤ ស្តីពីចំណាត់ថ្នាក់ហានិភ័យតណាទាន និងសំវិធានធន លើអ៊ីមែរមិន។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ មានតណាទានរៀបចំឡើងវិញចំនួន ៣ ចំពោះវិស័យទេសចរណ៍ នៅខេត្តសៀមរាប មានចំនួន ៥៨៤,៤២០ដុល្លារអាមេរិក។

ចំនួនទឹកប្រាក់ នៃសំវិធានធន លើអ៊ីមែរមិនខាតបង់របស់ហិរញ្ញវត្ថុ ដែលបានកំណត់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ គឺអនុលោមតាមតម្រូវការ នៃប្រកាស និងសារាចរណាទាំងនេះ។

នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥ ធនាគារជាតិ នៃកម្ពុជា បានចេញសារាចរលេខធ៣០-០២៥-១៧០ ដែលតម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បង្ហាញសំវិធានធនសរុប និងសំវិធានធន សម្រាប់ការប្រាក់បង្គរបានទទួល នៅគ្រប់ចំណាត់ថ្នាក់តណាទាន នៅក្នុងព័ត៌មានហិរញ្ញវត្ថុបន្ថែម សម្រាប់ឆ្នាំ២០២៤។

សេចក្តីលម្អិត អំពីការគណនាសំវិធានធនហ្វាស៊ីលីធីតណាទាន ដើម្បីអនុលោមតាមតម្រូវការរបស់ធនាគារកណ្តាល ត្រូវបានបង្ហាញ នៅក្នុងតារាង៤។

## ៨. ហានិភ័យតណាទានធំៗ ប្រកាសលេខ ធ៧-០៦-២២៦ ប្រ.ក.

តាមលក្ខខណ្ឌ នៃប្រកាសនេះ ធនាគារត្រូវបានតម្រូវឱ្យរក្សាគ្រប់ពេលវេលា នូវអនុបាតអតិបរមា ២០% រវាងហានិភ័យសរុប ដែលចេញពីប្រតិបត្តិការ ជាមួយនឹងអ្នកទទួលផលឯកត្តជននីមួយៗ និងមូលនិធិផ្ទាល់សុទ្ធ ហើយត្រូវរក្សាហានិភ័យតណាទានធំៗ មិនត្រូវឱ្យលើស ពី៣០០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារឡើយ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ធនាគារមិនមានហានិភ័យ ជាមួយនឹងអ្នកទទួលផលឯកត្តជន និងហានិភ័យតណាទានធំៗ ដែលលើសពី២០% និង ៣០០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ដូចបានគណនា ក្នុងតារាង២។

ចំពោះហានិភ័យតណាទានធំៗ ធៀបនឹងមូលនិធិផ្ទាល់សុទ្ធ សូមយោងទៅតារាង៧ អនុបាតទី២០ នៃការគណនាអនុបាតផ្សេងៗ។

## ៩. តណាទានភាគីពាក់ព័ន្ធ ប្រកាសលេខ ធ៧-០២-១៤៦ ប្រ.ក.

ធនាគារមិនត្រូវបានអនុញ្ញាតឱ្យផ្តល់តណាទាន ដល់ភាគីពាក់ព័ន្ធ លើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារទេ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ហានិភ័យតណាទានភាគីពាក់ព័ន្ធ មិនលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធទេ ដូចបានគណនា ក្នុងតារាង២។

ចំពោះតណាទានភាគីពាក់ព័ន្ធ ធៀបនឹងមូលនិធិផ្ទាល់សុទ្ធ សូមយោងទៅតារាង៧ អនុបាតទី១៩ នៃការគណនាអនុបាតផ្សេងៗ។

## ១០. អចលនទ្រព្យ ប្រកាសលេខ ធ៧-០១-១៨៦ ប្រ.ក.

